ទស្សនាវដ្ដីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- ពន្លឺបំភ្លឺការសម្លឹងមើលទៅអនាគត គួរតែក្រឡេកមើលទៅអតីតកាលផង
- សហគមន៍ចាមអ៊ីមាំសាន់ ៖ ជីវភាពបែបបុរាណ

[illegible]

លេខ ៦០ ខែធ្នូ ឆ្នាំ២០០៤

# ស្វែងរកការពិត

ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ៦០ ខែធ្នូ ឆ្នាំ២០០៤


## មាតិកា


◆ សំបុត្រៈ ទន្ទឹមនឹងការសម្លឹងមើលទៅអនាគត.......................... ១

**ផ្នែកឯកសារ**

◆ ផែនការ៥ឆ្នាំរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា......................... ២

◆ ពូល ទឿនៈ គ្រូបង្រៀនខេត្តបាត់ដំបង.................................. ៤

◆ ទស្សនៈរបស់កម្ពុជាប្រជាធិបតេយ្យ.................................... ៧

◆ បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរស-២១ .........១៤

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ សហគមន៍ចាម អ៊ីម៉ាំសាន់.............................................. ១៦

◆ ពេជ្រ កល្យាណៈ អតីតអ្នកទោសគុកសង់.............................១៩

◆ អ្នកទោសគុកក្រាំងតាចាន់..............................................២២

**ផ្នែកច្បាប់**

◆ តុលាការអន្តរជាតិលាតត្រដាងអំពីការកាត់ទោស...................២៥

**វេទិកាពិភាក្សាសាធារណៈ**

◆ សង្គមស៊ីវិលកម្ពុជាអំពាវនាវឲ្យសហគមន៍អន្តរជាតិ.................៣៩

◆ ពៀរអាចរំងាប់ដោយការមិនចងពៀរ.................................៤០

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ ពីប្រទេសកាណាដាៈ រឿងរ៉ាវជនរងគ្រោះនៃរបបខ្មែរក្រហម.....៤២

◆ គ្រួសារខ្ញុំ...............................................................៥២

◆ ការសន្ដោសនាំដល់ការគោរពសិទ្ធិមនុស្ស............................៥៩




ខកញ៉ា ឃួ កែទាំ នៅភូមិស្រែព្រៃ ឃុំអូរបុស្សី ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង




**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា



អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ ០២៩១ពម/៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្មេរលេខនេះ** យិន នាន, ញាណ សុជាតិ, ស៊ិរ សារីណា, សួន សីលា, អ៊ីសាក់ ថេប័រ, ស៊ូហ្សាណា លីនតុន, ប្រាយអាន់ តេ, ហ៊ីវ ឃីវ **អ្នកនិពន្ធនិងស្រាវជ្រាវៈ** លី សុផល, សូហ្វារីណា **អ្នកបកប្រែៈ** ដាត រចនា, ជី ទេវិទ្ធិ **និពន្ធនាយករងៈ** សាន់ កល្យាណ **និពន្ធនាយកទូទៅៈ** ឆាំង យុ **ក្រាហ្វិកកុំព្យូទ័រៈ** ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយៈ** មាស ប៊ុនថាន



Email: dccam@online.com.kh, Homepage: www.dccam.org

# សំបុត្រៈ ទន្ទឹមនឹងការសម្លឹងមើលទៅអនាគត គួរក្រឡេកមើលទៅអតីតកាលផង

មកទល់នឹងពេលនេះ សាលាជំនុំជម្រះក្ដីមេដឹកនាំខ្មែរក្រហម ស្ទើរតែលេចចេញជារូបរាងពិតប្រាកដហើយ ប៉ុន្ដែមានអ្នកជំនាញការជាច្រើនរូបកំពុងតែលើកសំណួរថា តើការដាក់ឲ្យមេដឹកនាំខ្មែរក្រហមទទួលខុសត្រូវចំពោះមុខច្បាប់នោះនឹងអាចជួយកាត់បន្ថយភាពក្រីក្ររបស់ប្រជាជននិងភាពអយុត្ដិធម៌ជាច្រើនដែលកំពុងតែប៉ះពាល់ដល់សង្គមកម្ពុជាបានដែរឬទេ? ចម្លើយថា "បាន" ដែលមិនទាន់មានការអះអាងគ្រប់គ្រាន់សម្រាប់បញ្ជាក់នោះ ហាក់ដូចជាដាក់ក្ដីសង្ឃឹមទៅលើសាលាជំនុំជម្រះក្ដីនេះខ្ពស់ពេក ។ សារសំខាន់របស់សាលាជំនុំជម្រះក្ដីនេះ មិនត្រឹមតែដោះស្រាយកំហុសពីអតីតកាលតែប៉ុណ្ណោះទេ ប៉ុន្ដែសូម្បីតែប្រព័ន្ធច្បាប់និងសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាក៏នឹងទទួលបានផលប្រយោជន៍ពីសាលាជំនុំជម្រះក្ដីនេះដែរ ។

ដូចគ្នានឹងប្រជាជនដែរ សេដ្ឋកិច្ចមានភាពស្មុគស្មាញនិងប្រែប្រួលជានិច្ចកាល ។ សេដ្ឋកិច្ចទទួលផលប៉ះពាល់តាមរយៈព្រឹត្ដការណ៍ផ្សេងៗដែលជួនកាលយើងមិនអាចគ្រប់គ្រងវាបាន ។ តាមរយៈបទពិសោធន៍ជាច្រើននៅក្នុងពិភពលោកដែលបានបង្ហាញរួចមកហើយ សេដ្ឋកិច្ចអាចរីកលូតលាស់ទៅបានដោយសារគោលគំនិតរបស់ប្រជាជន ។ ប្រជាជននឹងផ្ដល់ការឆ្លើយតបយ៉ាងវិជ្ជមានចំពោះសេដ្ឋកិច្ចរបស់ជាតិ នៅពេលដែលប្រជាជនមានទំនុកចិត្ដថាប្រទេសរបស់ខ្លួនរុងរឿង នៅពេលដែលប្រជាជនជឿជាក់ថាខ្លួនមានសិទ្ធិចូលរួមក្នុងការផ្ដល់យោបល់ផ្សេងៗសម្រាប់អនាគតរបស់ប្រទេសនិងជឿជាក់ទៅលើប្រព័ន្ធនយោបាយដែលគ្រប់គ្រងលើការរស់នៅរបស់ខ្លួន ។ ពាណិជ្ជករនឹងចូលមកធ្វើវិនិយោគនៅក្នុងប្រទេសមួយដរាបណាដឹងថាប្រទេសនោះមានប្រព័ន្ធច្បាប់ត្រឹមត្រូវដែលផ្ដល់ឲ្យមនុស្សគ្រប់នូវសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ ។

អ្នកជំនួញនឹងបង្កើតការងារនៅក្នុងប្រទេសជាជាងបង្ហិលប្រាក់ពីកន្លែងមួយទៅកន្លែងមួយទៀតដោយសារតែរំពឹងថាប្រព័ន្ធច្បាប់របស់ប្រទេសដែលខ្លួនកំពុងធ្វើវិនិយោគប្រព្រឹត្ដចំពោះពាណិជ្ជករប្រកបដោយសមធម៌ ។ សាលាជំនុំជម្រះក្ដីមួយនេះក៏នឹងអាចផ្ដល់ឲ្យប្រជាជនកម្ពុជានូវឱកាសមួយក្នុងការគិតថា នៅទីបំផុតប្រទេសកម្ពុជាអាចកំណត់ជោគវាសនាសម្រាប់ខ្លួនឯងនិងគិតទៀតថារាជរដ្ឋាភិបាលកម្ពុជានឹងឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាជននិងកំពុងស្វែងរកយុត្ដិធម៌ជូនប្រជាជនរបស់ខ្លួន ។ នៅពេលដែលប្រជាជនមានទំនុកចិត្ដឡើងវិញចំពោះរាជរដ្ឋាភិបាលកម្ពុជា ប្រព័ន្ធសេដ្ឋកិច្ចក៏នឹងអាចអភិវឌ្ឍដែរ ។ សាលាជំនុំជម្រះក្ដីនេះនឹងផ្ដល់ផលប្រយោជន៍ច្រើននិងឆាប់រហ័ស ហើយលទ្ធផលនេះនឹងស្ថិតស្ថេរយូរអង្វែងសម្រាប់ប្រទេសកម្ពុជាដែលមានប្រជាពលរដ្ឋជិត៤០ភាគរយអាយុក្រោម១៨ឆ្នាំ ។

បន្ទាប់ពីមានសាលាជំនុំជម្រះក្ដី យុត្ដិធម៌ក៏នឹងទទួលបាននៅក្នុងទម្រង់អភិវឌ្ឍថ្មី ។ ប្រជាជនកម្ពុជាបានសាកល្បងរកមធ្យោបាយជាច្រើនដើម្បីរកទីបញ្ចប់ឲ្យរបបខ្មែរក្រហម ។ នៅក្នុងឆ្នាំ១៩៧៩ តុលាការកំបាំងមុខមួយបានលេចជារូបរាងឡើងដែលនៅពេលនោះយុត្ដិធម៌ត្រូវបានផ្ដល់ជូនប្រជាជនកម្ពុជាគ្រប់លំដាប់ថ្នាក់តាមរយៈការកាត់ទោសដែលមើលទៅហាក់ដូចជាមិនសូវសមរម្យតាមផ្លូវច្បាប់អន្ដរជាតិ ។ រាជរដ្ឋាភិបាលកម្ពុជាបានផ្ដល់ការលើកលែងទោសនិងបានធ្វើសមាហរណកម្មខ្មែរក្រហមចូលក្នុងសង្គមកម្ពុជាវិញក្នុងគោលបំណងផ្ដល់សន្ដិភាពដល់ប្រទេស ។ កម្ពុជាបានបង្កើតឲ្យមានបូជនីយដ្ឋានសម្រាប់រំឭកវិញ្ញាណក្ខន្ធជនរងគ្រោះដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហមនិងប្រកាសទិវា"ចងកំហឹង"ថែមទៀត ប៉ុន្ដែកម្ពុជានៅមិនទាន់រកទីបញ្ចប់នៃរបបនេះនៅឡើយទេ ។ ដូច្នេះសាលាជំនុំជម្រះក្ដីនេះនឹងផ្ដល់ជាមធ្យោបាយចុងក្រោយមួយច្បាស់លាស់ឲ្យប្រជាជនកម្ពុជាអាចមើលឃើញការស្វែងរកយុត្ដិធម៌និងតាមដានដំណើរការសាលាជំនុំជម្រះក្ដី ។ សាលាជំនុំជម្រះក្ដីនេះនឹងផ្ដល់ឱកាសឲ្យកម្ពុជាធ្វើជាគំរូនៅលើឆាកជាតិនិងអន្ដរជាតិ ។ ការទទួលបានឱកាសទាំងនេះរួមបញ្ចូលជាមួយលទ្ធភាពក្នុងការអប់រំប្រជាជនអំពីដំណើរការនិងសិទ្ធិរបស់ខ្លួនក្នុងសាលាជំនុំជម្រះក្ដី ជួយផ្ដល់សំឡេងកាន់តែច្រើនសម្រាប់ប្រជាជននៅក្នុងជួររាជរដ្ឋាភិបាល និងជូនប្រជាជនកម្ពុជានូវអ្វីដែលគាត់រង់ចាំអស់រយៈពេលយូរមកហើយ នោះគឺជាយុត្ដិធម៌និងប្រព័ន្ធច្បាប់ដែលបម្រើសេចក្ដីត្រូវការរបស់ប្រជាជនមិនមែនប្រឆាំងនឹងប្រជាជនទេ ។

**ឆាំង យុ**

# ផែនការ៥ឆ្នាំរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា

## បរិបទ

បន្ទាប់ពីរដ្ឋសភាផ្តល់សច្ចាប័នបង្កើតតុលាការខ្មែរក្រហម និងច្បាប់សម្រាប់អង្គជំនុំជម្រះវិសាមញ្ញ កាលពីថ្ងៃទី៤និងទី៥ ខែតុលា ឆ្នាំ២០០៤កន្លងទៅនេះ លទ្ធភាពក្នុងការបង្កើតសាលាជំនុំជម្រះក្តីកាត់ទោសមេដឹកនាំខ្មែរក្រហមកំពូលកាន់តែមានភាពច្បាស់លាស់ជាងមុនមួយកម្រិតទៀត ។ ជាការពិត ការជំរុញរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាកន្លងមកនេះ បានរួមចំណែកជួយធ្វើឲ្យមានដំណើរការលើការផ្តល់សច្ចាប័ននេះឡើង ។ លើសពីនេះទៅទៀត ថ្មីៗនេះរដ្ឋាភិបាលកម្ពុជាបានប្រកាសឲ្យមានថ្ងៃបុណ្យជាតិមួយដែលស្នើសុំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលនឹងប្រព្រឹត្តឡើងនៅថ្ងៃដំបូងនៃដំណើរការតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ហើយថ្ងៃនេះមានឈ្មោះថា «ទិវាបុណ្យយុត្តិធម៌និងផ្សះផ្សាជាតិ» ។ ដើម្បីត្រៀមខ្លួនជួយដល់ដំណើរការសាលាជំនុំជម្រះក្តីនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាបានបន្តប្រមូលឯកសារប្រវត្តិសាស្ត្រ កំណត់ទីតាំង និងធ្វើផែនទីរណ្តៅសាកសពរួមចំនួនពីរម៉ឺនកន្លែង និងគុកជាច្រើនទៀតដែលបង្កើតឡើងនៅក្នុងរបបខ្មែរក្រហម និងអភិវឌ្ឍវិធីសាស្ត្ររបស់ខ្លួនក្នុងការសិក្សាលើឯកសារក៏ដូចជារក្សាឯកសារទាំងនេះដែរ ។ បច្ចុប្បន្ននេះ មជ្ឈមណ្ឌលឯកសារកម្ពុជា គឺជាកន្លែងផ្ទុកឯកសារខ្មែរក្រហមច្រើនបំផុតក្នុងចំណោមមជ្ឈមណ្ឌលឯកសារដទៃទៀតលើសកលលោក ។ ម្យ៉ាងវិញទៀត មជ្ឈមណ្ឌលឯកសារកម្ពុជាក៏បានដើរតួយ៉ាងសកម្មក្នុងការផ្តល់ព័ត៌មាននិងការអប់រំផ្នែកប្រវត្តិសាស្ត្រខ្មែរក្រហមដល់សាធារណជន ដែលក្នុងនោះមជ្ឈមណ្ឌលបានចែកទស្សនាវដ្តីប្រចាំខែជាងប្រាំសែនច្បាប់សម្រាប់ប្រជាជនទូទាំងប្រទេសកម្ពុជាដោយឥតគិតថ្លៃ បោះពុម្ពផ្សាយសៀវភៅប្រវត្តិសាស្ត្រចំនួន៦ ផលិតខ្សែភាពយន្តឯកសារខ្នាតខ្លីចំនួនពីរ បង្កើតឲ្យមានការតាំងពិព័រណ៍ចំនួនបីលើកនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង និងបង្កើតកម្មវិធីវិទ្យុផ្សាយប្រចាំថ្ងៃនៅក្នុងខេត្តចំនួន៦ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាក៏ទើបតែបានបង្កើតបន្ទប់ព័ត៌មានសាធារណៈដើម្បីបើកចំហឲ្យកាន់តែទូលាយជូនសាធារណជនក្នុងការប្រើប្រាស់ឯកសាររបស់មជ្ឈមណ្ឌល ។ ជាងនេះទៅទៀតមជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកវគ្គហ្វឹកហ្វឺនច្បាប់ដែលមានរយៈពេលពីរសប្តាហ៍ដល់និស្សិតសាលាច្បាប់មួយក្រុមមុននឹងដំណើរការតុលាការខ្មែរក្រហមចាប់ផ្តើមនិងកំពុងបង្កើតកម្មវិធីថ្មីៗមួយចំនួនទៀតសម្រាប់ធ្វើឲ្យការចងចាំអំពីប្រវត្តិសាស្ត្ររបស់ប្រជាជនកម្ពុជានៅតែមានជីវិតរស់ជានិច្ច ។ បន្ថែមលើកិច្ចការខាងលើ មជ្ឈមណ្ឌលឯកសារកម្ពុជាក៏មានសកម្មភាពមួយចំនួនទៀតសម្រាប់ជួយស្វែងរកសមាជិកគ្រួសារដែលបានបាត់ខ្លួននៅក្នុងរបបខ្មែរក្រហម ផ្តល់ការពិភាក្សាដល់ជនរងគ្រោះនិងជនដៃដល់នៃរបបខ្មែរក្រហមលើការព្យាបាលជំងឺផ្លូវចិត្ត ផ្តល់សំឡេងដល់ក្រុមជនជាតិភាគតិចនិងបង្កើនការចូលរួមរបស់សង្គមស៊ីវិល ។

## ផែនការសម្រាប់រយៈពេល៥ឆ្នាំខាងមុខ

គោលបំណងសំខាន់របស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលបាននិងកំពុងធ្វើគឺការប្រមូលនិងថែរក្សាឯកសារប្រវត្តិសាស្ត្រ ។ ក្នុងអំឡុងពេល៣ឆ្នាំសម្រាប់ដំណើរការតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមដែលរំពឹងថានឹងចាប់ផ្តើមពីឆ្នាំ២០០៥ដល់ឆ្នាំ២០០៧ ការយកចិត្តទុកដាក់ខ្ពស់បំផុតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាគឺផ្តល់ឯកសារដែលអាចប្រើប្រាស់ជាភស្តុតាងសម្រាប់មេធាវីចុងចោទនិងដើមចោទ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាក៏នឹងជួយក្នុងការបកប្រែក៏ដូចជាវិភាគឯកសារសម្រាប់បុគ្គលិកតុលាការខ្មែរក្រហមនិងអ្នកស្រាវជ្រាវដទៃទៀត ។ ម្យ៉ាងវិញទៀត ទោះបីជា មជ្ឈមណ្ឌលឯកសារកម្ពុជាបន្តប្រមូលឯកសារសម្រាប់ការប្រើប្រាស់ក្នុងដំណើរការតុលាការខ្មែរក្រហមយ៉ាងណាក្តី (ភាគច្រើននៃឯកសារនេះមានរក្សាទុកនៅក្រៅប្រទេស និងមួយចំនួនទៀតស្ថិតនៅនឹងប្រជាជនកម្ពុជាដែលពុំបានដឹងអំពីតម្លៃនៃរឿងរ៉ាវរបស់ខ្លួន) ក៏យើងនឹងសិក្សាលើព្រឹត្តិការណ៍ប្រវត្តិសាស្ត្រសំខាន់ៗដទៃទៀតតាមរយៈការប្រមូលសាច់រឿង ការ

បរិយាយផ្ទាល់ពីជនរងគ្រោះរបបខ្មែរក្រហមនិងធ្វើការផ្សព្វផ្សាយប្រវត្តិសាស្ត្រចេញពីជនរងគ្រោះនោះនៅក្នុងអត្ថបទទស្សនាវដ្តី សៀវភៅ កម្មវិធីវិទ្យុ ពិពណ៌រូបថត និងផលិតជាខ្សែភាពយន្តជាដើម ។

ការផ្តល់ជូននូវព័ត៌មាននិងការអប់រំដល់សាធារណជន នៅតែជាគោលដៅចម្បងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ យើងបានរៀបចំកម្មវិធីជាច្រើនរួចជាស្រេចសម្រាប់សម្រេចគោលដៅទាំងពីររបស់យើង ។ "កម្មវិធីឯកសាររស់" របស់មជ្ឈមណ្ឌលនឹងអញ្ជើញជនរងគ្រោះនៃរបបខ្មែរក្រហមនិងអ្នកដឹកនាំតាមភូមិឃុំចំនួនមួយពាន់ពីររយនាក់ឲ្យមកចូលរួមស្តាប់សវនាការជំនុំជម្រះក្តីអតីតមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់ ។ អ្នកទាំងនោះនឹងផ្លាស់ប្តូរវេនគ្នាមកម្នាក់ម្តងក្នុងរយៈពេលមួយសប្តាហ៍ ។ នៅពេលអ្នកចូលរួមទាំងនោះត្រឡប់ទៅវិញ យើងនឹងរៀបចំអង្គប្រជុំសរុបប្រហែលប្រាំមួយពាន់នាក់នៅតាមបណ្តាភូមិឃុំ ដើម្បីឲ្យអ្នកភូមិដទៃទៀតបានយល់អំពីដំណើរការច្បាប់របស់កម្ពុជាក៏ដូចជាពិភាក្សាពីបទពិសោធន៍ផ្ទាល់ខ្លួនក្នុងរបបខ្មែរក្រហមដែរ ។ ការប្រជុំទាំងនោះនឹងមានថតទុកជាខ្សែភាពយន្តសម្រាប់ជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនិងការអប់រំក្នុងពេលអនាគតទៀត ។ ចំពោះគោលបំណងបង្កើនការអប់រំ យើងគ្រោងនឹងបង្កើនចំនួនអ្នកស្រាវជ្រាវប្រវត្តិសាស្ត្រកម្ពុជាតាមរយៈបង្កើតឲ្យមានការសិក្សាស្រាវជ្រាវកាន់តែច្រើនពីសំណាក់បុគ្គលិករបស់មជ្ឈមណ្ឌលកម្ពុជានិងពង្រីកទំនាក់ទំនងជាមួយវិទ្យាស្ថានអប់រំក្រៅប្រទេស ។ ឧទាហរណ៍តាមរយៈការស្រាវជ្រាវ ការផ្តល់អាហាររូបករណ៍ ការផ្តល់កម្មសិក្សាដល់សិស្សទាំងក្នុងស្រុក និងសិស្សដែលមកពីបរទេស និងបង្កើតវគ្គសិក្សាផ្នែកប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យដែលនឹងបញ្ចូលទៅក្នុងកម្មវិធីសិក្សាសាកលវិទ្យាល័យក្នុងស្រុកទាំងអស់ ។ ម្យ៉ាងវិញទៀត យើងក៏មានគម្រោងបង្កើតឲ្យមានសៀវភៅនិងកម្មវិធីសិក្សាពីអំពើប្រល័យពូជសាសន៍សម្រាប់សិស្សនៅថ្នាក់វិទ្យាល័យ ។

**ឆាំង យុ**

## វេទិកាថែរក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

មជ្ឈមណ្ឌលឯកសារកម្ពុជានិងសមាគមអ្នកនិពន្ធខ្មែរនឹងរៀបចំកម្មវិធី"វេទិកាថែរក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ" លើកទី២ ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៤ ដល់ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៥ ។ កម្មវិធីនេះសូមអំពាវនាវដល់សិស្ស និស្សិត ប្រជាជនកម្ពុជា និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលកំពុងរស់នៅទាំងក្នុងនិងក្រៅប្រទេសឲ្យសរសេរអត្ថបទស្តីអំពីរឿងរ៉ាវរបស់ខ្លួននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ព័ត៌មានទាំងឡាយស្តីអំពីរបបកម្ពុជាប្រជាធិបតេយ្យដែលលោកអ្នកបានដឹងឮ និងទស្សនៈផ្ទាល់ខ្លួនចំពោះរបបកម្ពុជាប្រជាធិបតេយ្យដើម្បីរួមចំណែកចងក្រងប្រវត្តិសាស្ត្រនៃរបបនេះឲ្យកាន់តែពិស្តារ ។

វេទិកានេះមានគោលបំណងសំខាន់ៗដូចតទៅ ÷

◆ រួមជាចំណែកថែរក្សាប្រវត្តិសាស្ត្រទុកសម្រាប់កូនចៅជំនាន់ក្រោយឲ្យបានដឹងនិងសិក្សារៀនសូត្រ ។

◆ ជាវិធីមួយដើម្បីរំងាប់អារម្មណ៍ដោយយកហេតុការណ៍ សេចក្តីទុក្ខ ការខឹងគុំគួនមកតម្កល់ជាឯកសារប្រវត្តិសាស្ត្រដើម្បីបម្រើដល់ការស្រាវជ្រាវតទៅអនាគត ។

◆ ការចងចាំគឺជាសន្តិវិធីមួយក្នុងការទប់ស្កាត់មិនឲ្យអំពើប្រល័យពូជសាសន៍កើតឡើងជាថ្មីម្តងទៀតនៅក្នុងសង្គមមនុស្ស ។

◆ ជួយដល់ការស្វែងរកយុត្តិធម៌ជូនដល់ប្រជាជនកម្ពុជាដែលបានស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម និងជួយលើកកម្ពស់ការគោរពសិទ្ធិមនុស្សនៅកម្ពុជា ។

ប្រធានបទខាងលើនេះតម្រូវឲ្យលោកអ្នកសរសេរបែបប្រវត្តិ-សាស្ត្រចាប់ពី១០ទំព័រឡើងទៅ ។ មជ្ឈមណ្ឌលឯកសារកម្ពុជានិងសមាគមអ្នកនិពន្ធខ្មែរនឹងមានកិត្តិយសចុះផ្សាយស្នាដៃរបស់លោកអ្នកនៅលើទំព័រទស្សនាវដ្តី ស្វែងការរកការពិត ព្រមទាំងផ្តល់ថវិកាដល់ម្ចាស់អត្ថបទដែលនឹងត្រូវសរសេរបន្ថែមទៀតដើម្បីបោះពុម្ពជាសៀវភៅ ។ លោកអ្នកអាចផ្ញើអត្ថបទមកសមាគមអ្នកនិពន្ធខ្មែរដែលមានទីស្នាក់ការនៅវត្តបទុមវតី ឬមជ្ឈមណ្ឌលឯកសារកម្ពុជា ប្រអប់សំបុត្រលេខ១១១០ភ្នំពេញ ឬតាមរយៈអ៊ីមែលៈ dccam@online.com.kh ។

សូមទាក់ទងព័ត៌មានបន្ថែមតាមរយៈទូរស័ព្ទលេខៈ ០២៣ ២១១ ៨៧៥ ឬ ០១២ ៨៨៣ ០៧២ ។ សូមអរគុណ ។

*(អត្ថបទសង្ខេបចេញពីឯកសារចម្លើយសារភាព)*

# ពូល ទឿន: គ្រូបង្រៀននៅខេត្តបាត់ដំបង

ពូល ទឿន ហៅ ចាំង អាយុ៤០ឆ្នាំ គឺជាគ្រូបង្រៀនម្នាក់នៅក្នុងខេត្តបាត់ដំបង ក្នុងសម័យសង្គមរាស្ត្រនិយម ។ ទឿន មានស្រុកកំណើតនៅភូមិតាំងចឹក ឃុំញាយ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ។ ឪពុករបស់គាត់ឈ្មោះ ពូល ធុច ម្តាយ ដៃ វិត ជាកសិករ ។ នៅពេលដែលខ្មែរក្រហមឡើងកាន់អំណាច ទឿន គឺជាប្រជាជនថ្មីនៅក្នុងសហករណ៍ក្តុល ឃុំ៤ ស្រុកដូនទាវ តំបន់៤ ភាគពាយ័ព្យ ។ ទឿន ត្រូវអង្គការចាប់ខ្លួននៅថ្ងៃទី១១ ខែ៤ ឆ្នាំ១៩៧៧ និងបញ្ជូនមកដាក់នៅមន្ទីរឃុំឃាំងស-២១(គុកទួលស្លែង) ។

## ប្រវត្តិការសិក្សា

ទឿន បានធំដឹងក្តីនិងសិក្សានៅក្នុងខេត្តកំពង់ស្ពឺ ។ នៅឆ្នាំ១៩៤៩ ទឿន បានមកសិក្សានៅសាលាបឋមសិក្សាវត្តត្រពាំងឈូក ខេត្តកំពង់ស្ពឺ ។ ក្រោយពីប្រលងជាប់សញ្ញាបត្របឋមសិក្សានៅឆ្នាំ១៩៥៤-៥៥ ទឿនបានចូលរៀនថ្នាក់ទី៦នៅវិទ្យាល័យឯកជនកម្ពុជាបុត្រភ្នំពេញ ។ នៅឆ្នាំ១៩៥៨ ទឿន រៀននៅសាលាឯកជនចម្រើនវិជ្ជាថ្នាក់ទី៣និងបានប្រឡងជាប់ជានិស្សិតគ្រូបង្រៀននៅវិទ្យាស្ថានជាតិគរុកោសល្យភ្នំពេញ ។ ទឿន សិក្សាផងនិងបង្រៀននៅសាលាបឋមសិក្សាវត្តត្រពាំងឈូកផង ហើយនៅឆ្នាំ១៩៦៣ បានប្រឡងចូលសិក្សានៅមហាវិទ្យាល័យគរុកោសល្យភ្នំពេញ ។

## ការសិក្សានិងនយោបាយ

ក្នុងពេលកំពុងសិក្សានៅមហាវិទ្យាល័យគរុកោសល្យ ទឿន ត្រូវមិត្តរួមថ្នាក់ឈ្មោះ ជៀន គឹមយាន អប់រំបញ្ចុះបញ្ចូលឲ្យអស់ជំនឿលើបដិវត្តន៍ ។ ទឿន បាននិយាយថា គឹមយាន បានពន្យល់គាត់ពីហេតុផលលំបាកៗ តាំងពីកង្វះខាតសិទ្ធិសេរីភាព ការហូបចុក ស្លៀកពាក់ និងការដើរហើរ ដោយមានលើកឧទាហរណ៍ពីបណ្តាប្រទេសសេរីមួយចំនួន ។ ទឿន ពេញចិត្តនៅពេលនិយាយពីរបបសេរី ហេតុដូច្នេះគាត់បានសម្រេចចិត្តចូលជាសមាជិកសេ.អ៊ី.អា តាំងពីពេលនោះមក ។ ទឿន ទទួលភារកិច្ចទៅបង្កប់ខ្លួននៅក្នុងជួរបដិវត្តន៍ ។

នៅក្នុងឆ្នាំដដែល គឹមយាន បានអូសទាញកម្លាំងនិស្សិតសាស្ត្រាចារ្យបានចំនួន១០នាក់ ចំណែក ទឿន បានអូសទាញកម្លាំងបានបីនាក់ឈ្មោះ អ៊ុយ ទីម៉ន, មុិញ ជន និង កាំង កូវិន ។

ឆ្នាំ១៩៦៥ដល់ឆ្នាំ១៩៦៧ ទឿន ត្រូវក្រសួងអប់រំចាត់តាំងឲ្យទៅបង្រៀននៅវិទ្យាល័យសូរិយោវង្ស ខេត្តស្វាយរៀង ។ ពេលនោះ គាត់អូសទាញបានសិស្សជំនិតពីរនាក់និងសាស្ត្រាចារ្យពីរនាក់ឈ្មោះ ចាន់ អៀន និង ជុំ បាន ។ អ្នកទាំងពីរនេះមានធាតុចម្រើនកណ្តាលដែលជាហេតុធ្វើឲ្យ ទឿន ងាយស្រួលអូសទាញ ។

ឆ្នាំ១៩៦៦ ទឿន បានទៅបញ្ចុះបញ្ចូលប្អូនថ្លៃជីដូនមួយម្នាក់ទៀតឈ្មោះ ឯក ស៊ីណា ។ ស៊ីណា ជាមនុស្សដែលមានទស្សនៈចង់ឲ្យប្រទេសកម្ពុជាក្លាយជាប្រទេសអ្នកមានដូចសហរដ្ឋអាមេរិកដោយផ្អែកលើធនធានធម្មជាតិរបស់ប្រទេស ។

ក្នុងឆ្នាំ១៩៦៧ ទឿន បានប្រមូលកម្លាំងដែលគាត់កសាងបានទាំងអស់ចំនួន១០នាក់ មកជួប ជៀម គឹមយាន ដើម្បីខ្ទេសនាមជាសមាជិកពេញសិទ្ធិ ។ បន្ទាប់ពីបានខ្ទេសនាម អ្នកទាំង១០នាក់បានទទួលផែនការយកទៅអនុវត្ត ។

ឆ្នាំ១៩៦៨ ទឿន បានទទួលបញ្ជាឲ្យទៅរៀបចំមូលដ្ឋានមួយនៅព្រៃសណ្តាន់ក្នុងខេត្តកំពង់ធំ ។ ចំណែក ជៀម គឹមយាន ដឹកនាំកម្លាំងទាំង១០នាក់ទៅតាមក្រោយ ក៏ប៉ុន្តែត្រូវទ័ពព្រៃបាញ់សម្លាប់ចោលទាំងអស់ ។ ទឿន បានភៀសខ្លួនមកស្នាក់អាស្រ័យផ្ទះបងប្រុសនៅភ្នំពេញមួយរយៈ ។ ទឿន ត្រូវបងប្រុសរបស់គាត់នាំទៅសារភាពអំពីកំហុសរបស់ខ្លួនដើម្បីកុំឲ្យលំបាកក្នុងការរស់នៅដោយលាក់បំពួន ។ ក្រោយពីសារភាពរួច ទឿន ត្រូវបានបញ្ជូនទៅពន្ធនាគារអស់រយៈពេល៩ខែ ។ ពេលនោះ ទឿន បានបន្តសកម្មភាពរបស់គាត់ជាមួយ ឈ្មោះ ជិន និង ប្រឹក ដែលជាអ្នកជាប់គុកជាមួយគ្នា ។ ជិន និង ប្រឹក ធ្លាប់ធ្វើទាហានពាក់ដោយបីជាន់ ។ នៅក្នុងគុកព្រៃស ឈ្មោះទាំងពីរនេះបានត្រូវ

ប្រធានគុកព្រៃសចាត់តាំងឲ្យមើលការខុសត្រូវអ្នកទោសចំនួន ៣០នាក់ ដែលក្នុងចំណោមនោះមាន ទៀន ម្នាក់ដែរ ។ ឆ្នាំ១៩៦៩ ទៀន បានត្រូវដោះលែងពីគុក ។

មុនឆ្នាំ១៩៧០ ទៀន និងប៉ូលិសស័ក្តិ៤ម្នាក់ឈ្មោះ ណេ បានចាប់ផ្តើមធ្វើសកម្មភាពប្រឆាំងបដិវត្តន៍ដោយចូលរួមអូសទាញអ្នកបម្រើឲ្យមកបម្រើការក្នុងរបបសាធារណរដ្ឋខ្មែរ ។ ទៀន អូសទាញបានអ្នកបម្រើពីរនាក់ឈ្មោះ ដៃ ឆុន និង វ៉ាន់ សារិត ។ ទៀន បានភ្ជាប់សេ.អ៊ី.អារបស់គាត់ជាមួយខ្មែរម្នាក់ទៀត ឈ្មោះ ឃុយ សៀន អតីតសាស្ត្រាចារ្យនៅសាលាឯកជនភ្នំពេញ ។

ឆ្នាំ១៩៧១ ទៀន ទៅបង្រៀនសិស្សនៅខេត្តបាត់ដំបង ។ ចំណែក ឃុយ សៀន ដឹកនាំកម្លាំងដែលប្រមូលបានធ្វើដំណើរទៅតាមក្រោយ ។ នៅខេត្តបាត់ដំបង ទៀន បានស្នាក់នៅផ្ទះបងជីដូនមួយគាត់ឈ្មោះ ស៊ិន លំ ជាគយនិងធ្វើគិញពាក់ស័ក្តិមួយការពារខ្សែក្រវ៉ាត់ក្រុងបាត់ដំបង ។ ទៀន និង ស៊ិន លំ បានសហការគ្នាដើរអូសទាញប្រជាជនតាមខ្សែក្រវ៉ាត់ក្រុងបាត់ដំបងប៉ែកខាងជើងដែលជាតំបន់ ស៊ិន លំ ត្រួតត្រា ។ ទៀន អូសទាញបានប្រជាជនម្នាក់ឈ្មោះ កុល សឿត ឲ្យភ្ញាក់រឭកឡើងនិងសុំឲ្យគាត់ចូលធ្វើជាគិញសម្ងាត់ភ្ជាប់ជាមួយខ្សែ ស៊ិន លំ ។ នៅពាក់កណ្តាលឆ្នាំ១៩៧១ ទៀន បានបញ្ចុះបញ្ចូលគ្រូបង្រៀនពីរនាក់ឈ្មោះ ដាន់ នួន និង លី ប៊ិន ។

ឆ្នាំ១៩៧២ ទៀន អូសទាញបានគ្រូបង្រៀនបីនាក់ ។ ការបញ្ចុះបញ្ចូលអ្នកទាំងបីនេះក៏មិនខុសពីអ្នកមុនៗដែរ ។ ទៀន បានបញ្ជូនគ្រូទាំងបីនាក់នោះឲ្យទៅ ឃុយ សៀន ដើម្បីណែនាំបន្ថែមទៀត ។

ឆ្នាំ១៩៧៣ ទៀន បានភ្ជាប់ខ្លួនរបស់គាត់ទៅនឹងខ្សែគិញបីនាក់ឈ្មោះ លួត, ង៉ុយ និង វ៉ាន់ វឿត តាមរយៈគិញម្នាក់ឈ្មោះ អោក ។ ទៀន ទៅបង្រៀនសិស្សផងនិងឆ្លៀតពេលដើរអូសទាញកម្លាំងផង ។ គ្រូម្នាក់ឈ្មោះ វ៉ាន ចំរ៉ាត់ នៅស្រុកមង្គលបុរី តំបន់៣ ក៏ត្រូវ ទៀន អូសទាញបានដែរ ។

ឆ្នាំ១៩៧៤ ទៀន បានឡើងមកភ្នំពេញរាយការណ៍ឲ្យ ឃុយ សៀន អំពីកម្លាំងដែលគាត់កសាងបានក្នុងរយៈពេលជាងមួយឆ្នាំនៅខេត្តបាត់ដំបង និងទទួលផែនការបន្ថែមសម្រាប់យកទៅអប់រំកម្លាំងឲ្យមានប្រសិទ្ធភាព ។ ក្រៅពីការណែនាំ ឃុយ សៀន បានប្រាប់អំពីផែនការថ្មីនិងផែនការត្រៀមចាញ់ដើម្បីឲ្យ ទៀន យកផែនការទាំងនេះទៅរាយការណ៍ជូនសមាជិកនៅខេត្តបាត់ដំបង ។ ផែនការនេះគឺ “ទី១ សេ.អ៊ី.អាថ្នាក់លើបានបង្កប់កម្លាំងក្នុងជួរបដិវត្ត ។ ក្រៅជួរបដិវត្តក៏មានរៀបចំជាកម្លាំងសម្ងាត់ច្រើននាក់ទៀត ។ ផែនការទី១នេះ ទាក់ទងទៅនឹងគោលនយោបាយពួករំដោះ ។ បើពួកនេះសប្បាយក្លេចខ្លួននឹងជ័យជម្នះបែបសន្តិភាពនិយម យើងយកកម្លាំងត្រៀមសម្ងាត់ទាំងអស់រួមផ្សំនឹងទាហានគិញនិងបញ្ញាជនដែលចាត់តាំងបានឲ្យងើបឡើងស្រុះគ្នាវាយបដិវត្តន៍មិនឲ្យដឹងខ្លួនមុន ។ បើមិនបានសម្រេច យើងអនុវត្តផែនការទី២ ទោះបីខាងបដិវត្តន៍មិនសប្បាយក្លេចខ្លួន យើងត្រៀមកម្លាំងវាយបដិវត្តន៍នៅតាមតំបន់ផ្សេងៗ ។ ផែនការម្យ៉ាងទៀត បើសម្តេចដឹកនាំប្រទេសកម្ពុជា យើងអាចរស់នៅបានស្រួល ហើយមានឱកាសផ្តួលគោលដៅហរអ្នកដឹកនាំសំខាន់ៗរបស់បដិវត្តន៍” ។ ទៀន បានយកផែនការទាំងអស់នេះទៅពន្យល់ដល់សមាជិកទាំងអស់របស់គាត់នៅក្នុងខេត្តបាត់ដំបង ។

ចំណែកផែនការត្រៀមចាញ់របស់ ទៀន នៅខេត្តបាត់ដំបង គឺ “ពេលចប់សង្គ្រាមភ្លាម កម្លាំងទាំងអស់ចាំទទួលការណែនាំពី ដាំ ឈួប (ជាទាហានស័ក្តិពីរ) ដើម្បីវាយបដិវត្តន៍ពីក្រោយខ្នងក្នុងពេលដែលកងទ័ពរំដោះសប្បាយក្លេចខ្លួន ។ ទាំងអស់គ្នាត្រូវចាំអនុវត្តតាម ដាំ ឈួប ។ បើផែនការនេះមិនបានសម្រេច ត្រូវចូលរួមជាមួយកម្លាំងសេ.អ៊ី.អាទូទៅក្នុងប្រទេសទាំងមូល ។ ផែនការទី២ គឺត្រៀមកម្លាំងសម្ងាត់ឲ្យកាន់តែច្រើននិងកសាងកម្លាំងថ្មីបន្ថែម រួមជាមួយនឹងផែនការទី១ រង់ចាំវាយនៅតាមតំបន់ផ្សេងៗនៅពេលបដិវត្តន៍ក្លេចខ្លួន ។ បើផែនការទាំងពីរនេះមិនបានសម្រេចចាំដោះស្រាយរកមូលហេតុក្រោយ” ។

ចុងឆ្នាំ១៩៧៤ សភាពការណ៍នៅទីក្រុងភ្នំពេញកាន់តែច្របូកច្របល់ ខ្មែរក្រហមផ្លោងចូលព្រលានយន្តហោះពោធិ៍ចិនតុងស្ទើរតែរៀងរាល់ថ្ងៃ ។ សៀន បានធ្វើដំណើរទៅខេត្តបាត់ដំបងដើម្បីឧទ្ទេសនាមកម្លាំងរបស់ ទៀន ដែលមិនទាន់បានចូលជាសមាជិកពេញសិទ្ធិយ៉ាងប្រញាប់ប្រញាល់និងសង្ខេបបំផុត ។

លុះដល់ថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ទៀន បានទៅជួប

គណៈតំបន់៤ឈ្មោះ ខែក បុិន ហៅ ស៊ូ អតីតជាគ្រូបង្រៀន នៅខេត្តកំពង់ស្ពឺ ។ ខែក បុិន បាននាំគាត់ឲ្យស្គាល់កន្លែងផ្សេងៗ ដូចជាឃ្លាំង អំបិល ទឹកត្រី អង្ករ ។ល ។ និងបន្ទាប់មកបាន បញ្ចូលគាត់ទៅក្នុងខ្សែបញ្ជាជនតំបន់៤ ដើម្បីធ្វើការជាមួយគ្នា ។ ទឿន បានត្រូវចាត់តាំងឲ្យធ្វើការនៅភូមិទួលអំពិល ។ មួយខែ ក្រោយមក ខែក បុិន បានហៅគាត់ឲ្យទៅរៀបចំពិធីបុណ្យមហា សន្និបាតទទួលជ័យជម្នះ ។ នៅឱកាសនោះ សោម សំអុិន អតីត សាស្ត្រាចារ្យខាងប្រវត្តិសាស្ត្រ បានបញ្ចុះបញ្ចូលជាថ្មីឲ្យគាត់នឹក ឃើញអំពីការបាត់បង់ទឹកដីភាគខាងលិចដែលថៃបានឈ្លានពាន និងកំពុងតែមានបំណងពង្រីកបន្ថែមទៀត ។ ទឿន បានត្រូវខទ្ទុស នាមជាសមាជិកម្តងទៀតក្រោយពេលពិធីមហាសន្និបាតចប់ សព្វគ្រប់ ។

ទឿន និង អុឹង ឡៃហៀង (អតីតសាស្ត្រាចារ្យ) បានដើរ បំផុសប្រជាជននៅស្រុក៤១តំបន់៤ ឲ្យលែងស្តាប់បញ្ជាកម្មា-ភិបាលឃុំ ។ មិនយូរប៉ុន្មាន ដំណឹងនេះបានលេចឮដល់គណៈ សហករណ៍ឃុំ៣០ស្រុកមោង អុឹង ឡៃហៀង ត្រូវអង្គការដកឲ្យ ទៅធ្វើការនៅឃុំអូរមុនី ។ ចំណែក ទឿន ដឹកនាំ សុិន លំ ដើរ បំផ្លិចបំផ្លាញភ្លឺស្រែ លួចបើកទឹកដាក់ទ្រូ លប និងបំផ្លិចបំផ្លាញ ដំណាំផ្សេងទៀត ។

ក្រោយមក ទឿន បានត្រូវអង្គការដកចេញពីភូមិរាំងក្រោល ដោយសារគាត់មានទំនាស់ជាមួយកម្មាភិបាលភូមិរាំងក្រោលអំពី បញ្ហាហៅប្រជាជនមកប្រជុំដោយពុំមានសុំការអនុញ្ញាត ។ ទន្ទឹម នឹងសកម្មភាពខាងលើនេះ ទឿន និង យ៉ូវ ឆុំ បានបន្តអប់រំ ប្រជាជនតទៅទៀត ដោយអ្នកទាំងពីរលើកយកគំនិតរបស់ សោម សំអុិន ទៅពន្យល់ណែនាំនិងលើកយកចំណុចខ្វះខាត មួយចំនួនរបស់បដិវត្តន៍មកបង្ហាញ ។ ការលើកយកហេតុផល ទាំងនេះបានធ្វើឲ្យការអប់រំរបស់ ទឿន មានប្រសិទ្ធភាព ។ នៅចុង ឆ្នាំ១៩៧៥ ក្រុមបញ្ជាជនដែលដើរឃោសនានៅតំបន់៤ត្រូវ រំលាយចោលទាំងស្រុង ដោយសារអង្គការបដិវត្តន៍សង្ស័យថា ក្រុមនេះបានធ្វើសកម្មភាពប្រឆាំងបដិវត្តន៍ ។ បញ្ជាជនមួយចំនួន ត្រូវអង្គការបំបែកឲ្យទៅនៅជាមួយប្រជាជនតាមសហករណ៍ មិនតែប៉ុណ្ណោះថែមទាំងត្រូវអង្គការតាមដានជាប់ជានិច្ចទៀត ។

មកដល់ចុងឆ្នាំ១៩៧៦ ក្រោយពីឮដំណឹងថា បញ្ជាជន មួយចំនួនត្រូវអង្គការចាប់ខ្លួន សោម សំអុិន បាននាំ ទឿន ទៅ ធ្វើការនៅស្រុក៤៣ (ស្រុកដូនទាវ) ។ ទឿន ធ្វើការនៅភូមិត្រាង មានតួនាទីជំនួយការកម្មាភិបាល ។ ធ្វើការបានតែមួយសប្តាហ៍ ទឿន បានបង្កមានទំនាស់ជាមួយកម្មាភិបាលភូមិ ។ សំអុិន ក៏បាន ដកគាត់ឲ្យមកចិញ្ចឹមជ្រូកនៅភូមិក្តុល ។ ទឿន បានព្យាយាម ទាក់ទងជាមួយខ្សែគិញចាស់ៗ និងអូសទាញបានគិញចាស់ៗ ប្រាំនាក់ឲ្យចូលរួមធ្វើសកម្មភាពបំផ្លិចបំផ្លាញអង្ករស្រូវ ជ្រូក មាន់ទា អស់ជាច្រើន ។

នៅក្នុងឆ្នាំ១៩៧៧ ទឿន បានជួបពិភាក្សាជាសម្ងាត់ ជាមួយ សោម សំអុិន និង ស៊ូ អំពីផែនការមួយចំនួនដែលត្រូវបន្ត ធ្វើ ។ ក្រោយពីនោះមក ទឿន ត្រូវអង្គការដកចេញពីកន្លែង ចិញ្ចឹមជ្រូក ហើយដាក់ទិសឲ្យទៅច្រូតស្រូវរយៈពេលមួយខែ និងផ្លាស់ទៅលើកទំនប់ធ្វើអាងទឹករយៈពេលមួយខែកន្លះទៀត ។ បួនថ្ងៃបន្ទាប់ពី ទឿន ត្រឡប់មកដល់ផ្ទះវិញ គឺនៅថ្ងៃទី១៩ ខែ៤ ឆ្នាំ១៩៧៧ អង្គការក៏មកចាប់ខ្លួនគាត់ ។ ទឿន ត្រូវបានសួរ ចម្លើយដោយឈ្មោះ ខន នៅមន្ទីរស-២១ ។

នៅក្នុងចម្លើយសារភាព ទឿន បានរាយឈ្មោះមនុស្សចំនួន ៦១នាក់ ដែលមានជាប់ពាក់ព័ន្ធជាមួយនឹងសកម្មភាពរបស់ខ្លួន ។

**លី សុផល**


## រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជា គ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាននិងកំពុងសរសេរ អត្ថបទឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមក មជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោមៈ

ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

Email: dccam@online.com.kh

Home page: www.dccam.org

(ឯកសារខ្មែរក្រហម)

# ទស្សនៈមួយចំនួនអំពីបញ្ហាសេដ្ឋកិច្ចរបស់កម្ពុជាប្រជាធិបតេយ្យ

**សំណូមពរៈ**

១) សំណូមពរសំខាន់គឺបំពាក់នូវលក្ខការណ៍មួយចំនួនអំពីបញ្ហាសេដ្ឋកិច្ចដើម្បីធ្វើជាមូលដ្ឋាន ពិនិត្យ ពិចារណា និងណែនាំការងារសេដ្ឋកិច្ចរបស់យើង ។

២) សំណូមពរទី២គឺបំពាក់ទិសការងារសេដ្ឋកិច្ចរបស់យើងបច្ចុប្បន្ននិងទៅអនាគត ។

## I.លក្ខការណ៍មួយចំនួនអំពីសេដ្ឋកិច្ច

និយាយអំពីសេដ្ឋកិច្ចជាមូលដ្ឋានគឺនិយាយអំពីរបៀបផលិតកម្ម ។ អ្វីៗវាចេញពីនេះ ។ នេះជាមូលដ្ឋាននៃលទ្ធិម៉ាក្សលេនីនដែលចែងក្នុងសម្ភារនិយមប្រវត្តិសាស្ត្រ ។

បើរបៀបផលិតកម្មវាល្អ សេដ្ឋកិច្ចសង្គមវាដើរលឿន ។ បើរបៀបផលិតកម្មវាអាក្រក់ អន់ថយ ប្រតិកិរិយា សេដ្ឋកិច្ចសង្គមវាអន់ថយ ។

### ក) ការទាក់ទងផលិតកម្ម

ការទាក់ទងផលិតកម្មគឺការទាក់ទងរវាងមនុស្សដែលមានមធ្យោបាយផលិតកម្មនិងអ្នកធ្វើផលិតកម្មផ្ទាល់ ។ ជាក់ស្តែងការទាក់ទងរវាងម្ចាស់ដីនិងកសិករ ការទាក់ទងរវាងនាយទុននិងកម្មករ ។ ការទាក់ទងផលិតកម្មមានបីប្រភេទគឺ ទីមួយការទាក់ទងផលិតកម្មជិះជាន់ ទីពីរការទាក់ទងផលិតកម្មចម្រុះ និងទីបី ការទាក់ទងផលិតកម្មឯករាជ្យ ស្មើភាព សមូហភាព ។

◆ការទាក់ទងផលិតកម្មជិះជាន់ (ម្ចាស់ដីនិងកសិករ នាយទុននិងកម្មករ)

បើការទាក់ទងផលិតកម្មជាការទាក់ទងជិះជាន់ ការប្រាស្រ័យក្នុងសង្គមគឺមានទំនាស់ ។ ផលបានតែទៅលើវណ្ណៈជិះជាន់ ។ ត្រូវឃើញការទាក់ទងផលិតកម្មជិះជាន់ ដើម្បីវាយរំលំវា ។ បើនៅតែអីចឹងទេ សង្គមមិនដើរលឿនទៅមុខទេ ។

សារជាតិនៃរបបនីមួយៗគឺការទាក់ទងផលិតកម្មមិនមែនផលិតកម្ម ។ នេះជាលក្ខការណ៍សម្ភារនិយមប្រវត្តិសាស្ត្រ ។ ឧទាហរណ៍ការកែទម្រង់សេដ្ឋកិច្ចនៅឆ្នាំ១៩៦៣មិនបានផ្លាស់ប្តូររបបនៃសង្គមទេ វាមិនបានកម្ចាត់ការទាក់ទងផលិតកម្មជិះជាន់ទេ ។ ឧទាហរណ៍ នៅប្រទេសចក្រពត្តិនិងនាយទុនផ្សេងៗ ។

◆ ការទាក់ទងផលិតកម្មចម្រុះ ជាការទាក់ទងផលិតកម្មក្នុងរយៈកាលឆ្លងកាត់ពីការទាក់ទងជិះជាន់ទៅការទាក់ទងស្មើភាពឬសមូហភាព (គឺមកសង្គមនិយម) ។

រូបភាពចម្រុះនិងឯកជនៈ ជារយៈឆ្លងកាត់ជារូបភាពដំណើរការ ដើម្បីឆ្លងកាត់ក្នុងពេលដែល កម្មករ កសិករ មិនទាន់មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ខ្វះទុនជាដើម ។ មុនដំបូង រដ្ឋ កម្មករ កសិករ ត្រូវការប្រើទុនឯកជនខ្វះតាមរូបភាពចម្រុះរដ្ឋ(កម្មករ កសិករ) នាយទុន ។

◆ការទាក់ទងផលិតកម្មឯករាជ្យ ស្មើភាព សមូហភាព

យើងចង់បានការទាក់ទងផលិតកម្មនេះ ។ យើងត្រូវការវាយរបបជិះជាន់កែប្រែសង្គមនិយម ដើម្បីកសាងសង្គមនិយមដែលមធ្យោបាយផលិតកម្មទាំងអស់ជារបស់រដ្ឋកម្មករ-កសិករ ។

សេដ្ឋកិច្ចយើងសព្វថ្ងៃនៅជារបបសក្តិភូមិ នាយទុន ជាមូលដ្ឋាន ។ លក្ខណៈសម្ភារ លក្ខណៈជាក់ស្តែង វាតម្រូវឲ្យយើងដំណើរការតាមទិសវាយរបបជិះជាន់ ឆ្លងតាមរបបចម្រុះ កែប្រែសង្គមនិយម កសាងសង្គមនិយម ។ យើងត្រូវដឹងលំដាប់ដំណើរការដើម្បីមានទិសដៅដឹកនាំ ជាវិទ្យាសាស្ត្រ ជាវិចារណញ្ញាណ មិនមែនតាមតែមនោសញ្ចេតនាទេ ។

ក្នុងការប្រៀបធៀបរបបសេដ្ឋកិច្ចថ្មីនិងចាស់ ត្រូវប្រៀបធៀបក្នុងក្របខ័ណ្ឌប្រទេសនីមួយៗ ត្រូវប្រៀបធៀបរបបពីពេលមុនមកនិងរបបថ្មី ទើបមើលឃើញការចម្រើនឬមិនចម្រើន ។

### ខ) កម្លាំងផលិតកម្ម

កម្លាំងផលិតកម្មមានបីផ្នែកសំខាន់ គឺកម្លាំងមនុស្ស កម្លាំងមធ្យោបាយនិងឧបករណ៍ផលិតកម្ម និងកម្លាំងបច្ចេកទេសនិងពិសោធន៍ក្នុងការបង្កបង្កើនផល ។

១) កម្លាំងមនុស្សៈ មនុស្សដែលមានការភ្ញាក់រឭក នយោបាយ សតិអារម្មណ៍ ជាកម្លាំងផលិតកម្ម ជឿនលឿន ។ មនុស្សដែលមិនភ្ញាក់រឭកជាកម្លាំងផលិតកម្មអន់ថយ គឺធ្វើឲ្យតែរួចពីដៃ មិនមានគំនិតផ្តើមច្នៃប្រឌិត មិនគិតគូរ ។

◆ក្នុងក្របខ័ណ្ឌរបបជិះជាន់ ត្រូវជំរុញឲ្យប្រជាជនភ្ញាក់រឭក វាយកម្ទេចរបបនេះ យករបបថ្មី ទើបគេភ្ញាក់រឭកបង្កបង្កើនផល ក្នុងរបបថ្មី ។

◆ការយល់ជ្រួតជ្រាប ដើម្បីដំណើរការវាយកម្ទេចរបបជិះជាន់ជាការលំបាកត្រូវធ្វើស៊ិតស៊ាញ ។ ត្រូវបំពាក់គោលជំហរឲ្យរឹងប៉ឹង ។

២) កម្លាំងមធ្យោបាយផលិតកម្ម ឧបករណ៍ផលិតកម្ម

មធ្យោបាយសំខាន់ទី១គឺលុយ ។ វណ្ណៈនីមួយៗដណ្តើមសិទ្ធិកាន់កាប់មធ្យោបាយផលិតកម្មនេះ ។ យើងត្រូវក្តាប់មធ្យោបាយផលិតកម្មនេះដោយវាយរំលំវណ្ណៈជិះជាន់ ។

មធ្យោបាយសំខាន់ទី២គឺដីធ្លី ទន្លេ សមុទ្រ បឹងបួ ។ ពីមុនគឺម្ចាស់ដី នាយទុន វាកាន់កាប់ផលិតកម្មទាំងនេះ តាមរយៈនេះវាចាត់ចែងវាសនាសេដ្ឋកិច្ចកម្ពុជាទាំងអស់ ។ យើងត្រូវដណ្តើមកម្មសិទ្ធិលើមធ្យោបាយផលិតកម្មទាំងនេះ ដើម្បីយើងធ្វើម្ចាស់លើវាសនាសេដ្ឋកិច្ចកម្ពុជា ។

មធ្យោបាយផលិតកម្មសំខាន់ទី៣គឺខាងរោងចក្រធំៗ ។ រដ្ឋ កម្មករ កសិករ ត្រូវកាន់កាប់រោងចក្រធំៗ ។

មធ្យោបាយផលិតកម្មសំខាន់ទី៤គឺពាណិជ្ជកម្មក្រៅប្រទេសសំខាន់ៗត្រូវយើងកាន់កាប់ ។ បើមិនដូច្នោះទេ ចក្រពត្តិនិងនាយទុនវាចាត់ចែង ។

មធ្យោបាយទាក់ទងគមនាគមន៍ ជារទេះភ្លើង កប៉ាល់ យន្តហោះ ។ល ។ ក៏ត្រូវយើងក្តាប់បើមិនដូចនោះទេ យើងមិនម្ចាស់ការក្នុងការដឹកជញ្ជូនទេ ។

ក្រៅពីនេះឧបករណ៍បង្កបង្កើនផលជារទេះគោនង្គ័លរនាស់ ក៏ជាមធ្យោបាយផលិតកម្មដែរ ។ នរណាកាន់កាប់មធ្យោបាយផលិតកម្ម អ្នកនោះបត់បែនផលិតកម្ម ក្តាប់សេដ្ឋកិច្ច ។ ដូចនេះ បានជាយើងត្រូវវាយរំលំវណ្ណៈជិះជាន់ ដើម្បីកាន់កាប់មធ្យោបាយផលិតកម្ម ។

៣) កម្លាំងបច្ចេកទេសនិងពិសោធន៍ផលិតកម្ម

ទាល់តែមានបច្ចេកទេសនិងពិសោធន៍ផលិតកម្មទើបបង្កបង្កើនផលបានចម្រើន ។

បច្ចេកទេសគឺដូចជាមធ្យោបាយទឹក វិធីធ្វើការងារផ្សេងៗ លើកភ្លឺស្រែ ធ្វើទំនប់ រើសពូជ រហូតដល់ប្រើនង្គ័លបូរាណ សម័យម៉ាស៊ីន ពាក់កណ្តាលម៉ាស៊ីន ។ល ។ ត្រូវមានពិសោធន៍កាន់តែខ្ពស់ឡើង ដើម្បីបង្កបង្កើនផលឲ្យបានកាន់តែច្រើនៈ ពិសោធន៍ផ្ទាល់ខ្លួន ពិសោធន៍ពីកន្លែងផ្សេងៗ ពីទូទាំងប្រទេសនិងពីបរទេស ឧទាហរណ៍ ដីប្រទេសកម្ពុជាដែលល្អ មួយហិកតាបានផលស្រូវមួយតោន២០០គីឡូជាមធ្យម ដីប្រទេសវៀតណាម ចិន មិនដែលល្អមួយហិកតាបាន៥តោន-៧តោនទេ ។ បច្ចេកទេសនិងពិសោធន៍នៅទាប ផលិតផលក៏បានតិច បច្ចេកទេសនិងពិសោធន៍កាន់តែខ្ពស់ ផលិតផលក៏បានកាន់តែច្រើន ។

បច្ចេកទេសនិងពិសោធន៍ផលិតកម្មវានៅក្រោមការដឹកនាំនយោបាយ ។

**ក) លក្ខណៈសេដ្ឋកិច្ចនិងរបបមួយចំនួន**

យើងពិនិត្យលក្ខណៈសេដ្ឋកិច្ចក្នុងរបបមួយចំនួនដើម្បីម្ចាស់ការក្នុងការវិភាគវិនិច្ឆ័យនិងលើកគោលការណ៍ដឹកនាំតស៊ូ ។

១) របបសក្តិភូមិៈ ក្នុងរបបនេះតួនាទីសំខាន់គឺម្ចាស់ដីដែលមានមធ្យោបាយផលិតកម្ម ខាងដីធ្លី ហើយប្រើប្រាស់មធ្យោបាយនេះដើម្បីជិះជាន់កសិករ ។ ទំនាស់រវាងកសិករនិងម្ចាស់ដីជាទំនាស់បដិបក្ខប្រចាំ ។ រូបភាពជិះជាន់គឺ ឈ្នួលដី ប្រវាស់ដី បញ្ចាំ បណ្តាក់បុល ។ល ។

នៅទូទាំងប្រទេសយើង រូបភាពជិះជាន់នេះនៅមាននៅឡើយ ។ យើងត្រូវឃើញដើម្បីម្ចាស់ការក្នុងការកម្ទេចវា ។

២) របបនាយទុនៈ គឺជាពួកជនដែលមានទុនជាមធ្យោបាយផលិតកម្មដើម្បីជិះជាន់ប្រជាជនពិសេសកម្មករ ។ នាយទុនជាពាណិជ្ជករ ជាឧស្សាហករ នាយទុនកសិកម្ម មានលុយ មានដីចម្ការ(ធំៗ) មានរោងចក្រ ។ នាយទុនពាណិជ្ជករជិះជាន់អ្នកទិញរបស់របរប្រើប្រាស់ ។ នាយទុនឧស្សាហករជិះជាន់កម្មករ នាយទុនកសិកម្មជិះជាន់កម្មករកសិកម្ម ។

នៅប្រទេសកម្ពុជាជំនាន់ក្រោយសង្គ្រាមលោកទី២ ពិសេស

ពីឆ្នាំ១៩៥៥មក របបនាយទុនបានរីករាលដាល ទុនវាបានរីកមួយកម្រិតសំខាន់ ។

នៅតំបន់ខ្មាំងក៏ដូចជាក្នុងតំបន់រំដោះ សព្វថ្ងៃរបបនាយទុននៅមាននៅឡើយ ។ យើងត្រូវរំលស់វាបណ្ដើរៗ ។

៣) របបកម្ពុជាប្រជាធិបតេយ្យប្រជាជន

មានលក្ខណៈបួនយ៉ាងៈ រដ្ឋ សហករណ៍ ចម្រុះ ឯកជន (ទីក្រុង ជនបទ) ។

របបប្រជាធិបតេយ្យប្រជាជនជារបបសេដ្ឋកិច្ចឆ្លងកាត់ពីរបបសក្ដិភូមិទៅសង្គមនិយម ។ បើគ្មានរបបនេះគឺឆ្លងកាត់មិនបានទេ ចំពោះប្រទេសកសិកម្មអន់ថយ ។

សេដ្ឋកិច្ចរដ្ឋៈ

សេដ្ឋកិច្ចរដ្ឋកាន់កាប់មធ្យោបាយផលិតកម្មសំខាន់ៗ ។ ធាតុវាគឺធាតុសង្គមនិយមរដ្ឋ នៅក្នុងរបបប្រជាជាតិប្រជាធិប-តេយ្យប្រជាជន ។

សហករណ៍ៈ ជារបស់ប្រជាជនរួមគ្នា ជាសមូហភាពពីតូចទៅធំ ជាសង្គមនិយមរបស់ប្រជាជន ។

ក្នុងកិច្ចដំណើរការសមូហភាវូបនីយកម្មទាមទារកត្តាដឹកនាំរបស់បក្សត្រឹមត្រូវ ឲ្យប្រជាជនមានការភ្ញាក់រឭកនយោបាយសតិអារម្មណ៍ និងមានការចាត់តាំងត្រឹមត្រូវ មានកម្មាភិបាលដឹកនាំស៊ិតស្វាញ វាដើរតួ ។ ដូចនេះត្រូវដំណើរការពីទាបទៅខ្ពស់ដោយប្រជាជនកសិករ(តាមមាគ៌ាវណ្ណៈ) ធ្វើក្រោមការដឹកនាំរបស់បក្សដោយដកពិសោធខុសត្រូវជាបណ្ដើរៗ ។

សេដ្ឋកិច្ចនិងសហករណ៍ជាផ្នែកសង្គមនិយមដើម្បីសង្កត់នាយទុនកុំឲ្យងើបក្បាលវិញរួច ។ ការដែលរដ្ឋក្ដាប់សេដ្ឋកិច្ចនិងដំណើរការកសាងសហករណ៍ជាការតស៊ូវណ្ណៈតឹងតែងស្មុគស្មាញដែលត្រូវតស៊ូស៊ិតស្វាញណាស់ ។

ចម្រុះរដ្ឋនិងឯកជនៈ ខាងឧស្សាហកម្ម ខាងពាណិជ្ជកម្មគមនាគមន៍ និងខាងកសិកម្ម ។ សេដ្ឋកិច្ចទាំងអស់នេះត្រូវនៅក្រោមច្បាប់រដ្ឋ ។

ឯកជនៈ ក្នុងរបបប្រជាធិបតេយ្យ ប្រជាជនយើងមិនទាន់វាយផ្ដាច់នាយទុនទេ យើងវាយផ្ដាច់តែរបបសក្ដិភូមិ ។ ដូចនេះបាននៅមានសេដ្ឋកិច្ចឯកជន ។ នៅជនបទ ក្រោយបដិរូបដីស្រែនៅមានសេដ្ឋកិច្ច កសិករជាកសិករកណ្ដាលនិងកសិករមានជាដើម ។ នៅទីក្រុងមានសេដ្ឋកិច្ចអ្នកលក់ដូរ ដឹកជញ្ជូន សិប្បកម្មឧស្សាហកម្មតូចតាច ។ល ។ ទាំងនេះជាផ្នែកឯកជន ។

ដើម្បីឈានទៅសង្គមនិយម រដ្ឋនិងសហករណ៍ត្រូវដើរតួៈ ទាល់តែរដ្ឋនិងសហករណ៍ក្ដាប់មធ្យោបាយផលិតកម្មសំខាន់ៗ ទើបដើរតួកែប្រែសេដ្ឋកិច្ចឯកជនជាជំហានៗ ដើម្បីកែប្រែសង្គមនិយមបាន ។

នេះជាទិសដៅជាយុទ្ធសាស្ត្ររបស់យើង ។ តែក្នុងកិច្ចដំណើរការតាមយុទ្ធវិធី យើងឈានទៅទិសនេះតាមការប្រៀបធៀបកម្លាំងវណ្ណៈនីមួយៗក្នុងសង្គមយើង ។ យើងមើលយ៉ាងនេះដើម្បីឃើញទិសជាយុទ្ធសាស្ត្ររបស់យើងខាងផ្នែកសេដ្ឋកិច្ច ដើម្បីកុំឲ្យច្របូកច្របល់បណ្ដោយឲ្យរបបសក្ដិភូមិនិងនាយទុនវានៅដដែលឬរីករាលដាលថែមទៀត ។ ម្យ៉ាងទៀតដើម្បីកុំឲ្យវាឈានហួសយុទ្ធសាស្ត្រទៅទៀត ដោយវាយផ្ដាច់របបនាយទុនតែម្ដង ។ ត្រូវឈានទៅមុខជាជំហានៗតាមលំដាប់ដំណើរវិវត្តនៃការប្រៀបធៀបកម្លាំងនៃវណ្ណៈក្នុងសង្គម ។

៤) របបសង្គមនិយមៈ យើងវាយផ្ដាច់នាយទុន គ្មាននាយទុនទៀតទេ ។ នៅសល់តែរដ្ឋនិងសហករណ៍ ។ ឯកជននាយទុននិងឯកជនជនបទ ត្រូវចូលសហករណ៍ ។ ទាំងអស់នេះតាមដំណើរការកសាងសង្គមនិយម ។

### ឃ) កត្តាផ្សេងៗដើម្បីដំណើរការកសាងសេដ្ឋកិច្ចតាមមាគ៌ារបស់បក្ស

១) កត្តានយោបាយដឹកនាំៈ នេះជាកត្តាទី១ ជាកត្តាមូលដ្ឋានដើរតួ ។ កសាងសង្គមនិយមឬរបបប្រជាធិបតេយ្យ ប្រជាជនក្នុងរបបនាយទុនមិនអាចធ្វើទៅបានទេ ។ ក្នុងកត្តានយោបាយដឹកនាំនេះមានៈ បក្សដឹកនាំ រដ្ឋអំណាច(សម្រាប់អនុវត្តផ្ដាច់ការបដិវត្ត) និងកម្មាភិបាល ។

បក្សដឹកនាំៈ បក្សដឹកនាំបដិវត្តន៍ទាំងមូល បក្សដឹកនាំដំណើរការសេដ្ឋកិច្ចតាមមាគ៌ាមួយត្រឹមត្រូវ ។ បក្សយើងមានមាគ៌ារួមជាយុទ្ធសាស្ត្រហើយ តែបក្សយើងត្រូវមានមាគ៌ាដំណើរការសេដ្ឋកិច្ចឲ្យសមស្រប ដើម្បីចៀសវាងនូវអត្តនោម័តិរបស់យើងម្នាក់ៗ ។ ក្នុងន័យអនុវត្ត បក្សយើងត្រូវឯកភាពគ្នាតាំងពីលើដល់ក្រោម

តាមមាគ៌ារួមរបស់បក្ស ។ ដូចនេះ បក្សយើងចាំបាច់ត្រូវធ្វើមាគ៌ា តាមដានមាគ៌ា និងតម្រែតម្រង់ការអនុវត្តមាគ៌ាតាមពិសោធខុសត្រូវជាក់ស្តែង ។ ឧទាហរណ៍ សព្វថ្ងៃគោលជំហរបក្សដឹកនាំបង្កបង្កើនផលនៅខ្វះខាតច្រើនណាស់ ពេលធម្មតាក៏ដូចពេលរាំងស្ងួត ។ នេះមកពីគោលជំហរមាគ៌ារបស់បក្សមិនទាន់ជ្រួតជ្រាបរឹងប៉ឹង ។

ចាំបាច់ត្រូវបក្សជនយើងទាំងអស់ជ្រួតជ្រាបមាគ៌ាសេដ្ឋកិច្ច បើពុំដូចនេះទេ នាំឲ្យមានការខុសឆ្គង ហើយនាំឲ្យប៉ះពាល់ដល់កម្លាំងប្រជាជន ។

រដ្ឋអំណាចៈ ត្រូវមានអំណាចជាឧបករណ៍ផ្តាច់ការបដិវត្តន៍ជាឧបករណ៍ផ្តាច់ការរបស់បក្ស ។

ត្រូវមានរដ្ឋអំណាចរឹងប៉ឹងដើម្បីអនុវត្តមាគ៌ាវណ្ណៈនិយមរបស់បក្ស ត្រឹមត្រូវ មិន"ឆ្វេង" មិន"ស្តាំ" ។ បើឆ្វេងនាំឲ្យបែកកម្លាំង ។ បើធូររលុងរដ្ឋអំណាច វាមិនអនុវត្តផ្តាច់ការបដិវត្តតាមមាគ៌ារបស់បក្ស វាស៊ុមគ្រលុំជាមួយវណ្ណៈជិះជាន់ ។ ការដឹកនាំសេដ្ឋកិច្ច វាស្មុគស្មាញ ការប្រយុទ្ធវណ្ណៈក្នុងវិស័យសេដ្ឋកិច្ច វាតឹងតែងតទៅទៀត ។ ដើម្បីឈ្នះត្រូវមានរដ្ឋអំណាចរឹងប៉ឹង ។

មានរដ្ឋអំណាចទើបមានសិទ្ធិខាងនយោបាយ ។ មានរដ្ឋអំណាចទើបចាត់ចែងមធ្យោបាយផលិតកម្មបាន ។

កម្មាភិបាលៈ ត្រូវមានកម្មាភិបាលគ្រប់ផ្នែកៈ កម្មាភិបាលនយោបាយសេដ្ឋកិច្ច និងកម្មាភិបាលបច្ចេកទេសសេដ្ឋកិច្ច ។ កសាងពីទាបទៅខ្ពស់ដោយខ្លួនយើងជាសំខាន់ ។ ដំណើរការបណ្តើរកសាងបណ្តើរ ដោយឈរលើគោលជំហរឯករាជ្យម្ចាស់ការ ។ បើពីងផ្អែកលើបរទេសគឺខុសជាមូលដ្ឋាន ។

មានទស្សនៈយ៉ាងនេះទើបយើងឃើញថា ត្រូវខិតខំកសាងកម្មាភិបាលបណ្តើរៗ ពិសេសកសាងខាងគោលជំហរនយោបាយ ។

២) កត្តាមហាជនៈ ទាល់តែមហាជនយល់និងភ្ញាក់រឭកសតិអារម្មណ៍នយោបាយបណ្តើរៗ ទើបចាត់តាំងបានជាកម្លាំង ។ បើប្រជាជនមិនទាន់យល់ទេ ចាត់តាំងមិនបានទេ ។ ដូចនេះមានផែនការសេដ្ឋកិច្ចអ្វីក៏ដោយ ក៏ត្រូវគិតគូរអប់រំសតិអារម្មណ៍នយោបាយ



ឲ្យប្រជាជនទើបចាត់តាំងគេបាន ។ ចាប់ច្រកមិនបានទេ ។ ជួនណាយើងដែនការខ្ពស់ តែប្រជាជនមិនទាន់យល់ផែនការមុខតែបរាជ័យ ។

ដូចនេះត្រូវបង្កបង្កើតលក្ខណៈសម្បត្តិខាងសតិអារម្មណ៍នយោបាយនិងចាត់តាំងជាបណ្តើរៗ ពីទាបទៅខ្ពស់ ។ នេះជាគោលការណ៍ដឹកនាំតាមមាគ៌ាមហាជនរបស់បក្ស ។ បញ្ហានេះជាសម្ភារនិយម ជាវិទ្យាសាស្ត្រ ជារូបិយ ។ ធ្វើការផ្សារសតិអារម្មណ៍នយោបាយ ចាត់តាំងតាមបែបបទថ្មី មានការលំបាក ។ យើងត្រូវស៊ិតស្វាញ អំណត់ព្យុះពារ ដោយស្មារតីទទួលខុសត្រូវខ្ពស់ ។

ឧទាហរណ៍ៈ គោលការណ៍នៃសហករណ៍គឺចូលជាសមាជិកដោយភ្ញាក់រឭក ។ បង្ខំមិនបានទេ ។ បើប្រជាជនមិនទាន់ភ្ញាក់រឭកយើងបង្ខំឲ្យគេចូល គេចូលតែគេទោមនស្ស គេប្រឆាំងគ្នាឬគេចេញវិញ ។

៣) កត្តាមធ្យោបាយផលិតកម្ម

ទាល់តែយើងមានមធ្យោបាយផលិតកម្មនៅលើដៃយើងទើបយើងចាត់ចែងបាន ។ យើងត្រូវបង្កលក្ខណៈសម្បត្តិដើម្បីកាន់កាប់និងមានមធ្យោបាយផលិតកម្មជាបណ្តើរៗ ហើយដំណើរការជាបណ្តើរៗ ។ សរុបមកយើងត្រូវបង្កបង្កើតលក្ខណៈសម្បត្តិកសាងសេដ្ឋកិច្ចបណ្តើរដោយស៊ិតស្វាញ ។

២) សេដ្ឋកិច្ចកម្ពុជាបច្ចុប្បន្ន

ជាមូលដ្ឋានគឺសេដ្ឋកិច្ចសក្តិភូមិ(ម្ចាស់ដី) នាយទុនវាដើរតួគ្របដណ្តប់ ។ នាយទុនមាននាយទុនបរទេសនិងក្នុងស្រុក ។ លក្ខណៈសេដ្ឋកិច្ចនេះវាស្តែងចេញពីសង្គមអាណានិគម (ពាក់កណ្តាលអាណានិគមពេលមុន) និងពាក់កណ្តាលសក្តិភូមិ ។

នៅក្នុងតំបន់រំដោះក៏ដោយ ក៏សេដ្ឋកិច្ចសក្តិភូមិម្ចាស់ដីនិងនាយទុនវានៅតែគ្របដណ្តប់នៅឡើយដែរ ទោះជាវាថមថយផ្នែកណាខ្លះក៏ដោយ ។

យើងសន្និដ្ឋានយ៉ាងនេះដោយឈរលើការពិនិត្យទាក់ទងផលិតកម្មនឹងកម្លាំងផលិតកម្ម ។

ក) ទិដ្ឋភាពនៃការទាក់ទងផលិតកម្មក្នុងសេដ្ឋកិច្ចកម្ពុជា

នៅជនបទ ការទាក់ទងផលិតកម្មជាការទាក់ទងជិះជាន់ជាមូលដ្ឋាន ដោយម្ចាស់ដីជិះជាន់កសិករជាមូលដ្ឋាន ។ (នៅកន្លែងខ្លះខាងចុងកាត់មាត់ញកនៃតំបន់រំដោះយើង មានការកម្ចាត់ការទាក់ទងផលិតកម្មចាស់ខ្លះហើយ) ។

នៅទីក្រុងក៏នៅតែជាការទាក់ទងផលិតកម្មជិះជាន់ ដោយនាយទុន ជិះជាន់កម្មករ និងប្រជាជន ។

ខ) ទិដ្ឋភាពនៃកម្លាំងផលិតកម្មក្នុងសេដ្ឋកិច្ចកម្ពុជា

នៅក្នុងតំបន់រំដោះ យើងកាន់កាប់មធ្យោបាយផលិតកម្មមួយចំនួនដែរ តែភាគច្រើនឋិតក្នុងកណ្តាប់ដៃម្ចាស់ដីនាយទុន ។ ឧទាហរណ៍ៈ បឹងទន្លេសាប(បឹងទន្លេសាប) ជារូបភាពបឹងទន្លេសាបជារបស់រដ្ឋ តែជាក់ស្តែងនាយទុនកាន់កាប់បឹងទាំងនេះយកចំណេញច្រើនជាងរដ្ឋ ។ ទុន ដីធ្លី រោងចក្រ ពាណិជ្ជកម្ម គមនាគមន៍ ។ល ។ ក៏នៅលើដៃវណ្ណៈជិះជាន់កាន់កាប់ច្រើននៅឡើយ ។ ដូចនេះមានការប្រែប្រួលជាបរិមាណខ្លះ តែមិនទាន់មានការប្រែប្រួលខាងគុណភាពទេ ។ តាមការទាក់ទងផលិតកម្មយ៉ាងនេះ វណ្ណៈជិះជាន់ប្រើប្រាស់កម្មករកសិករតាមផលប្រយោជន៍របស់វា ។

៣) បច្ច័យនៃសេដ្ឋកិច្ចកម្ពុជាបច្ចុប្បន្នចំពោះជីវភាពប្រជាជន

ជីវភាពប្រជាជនលំបាក ។ នៅទីក្រុង វណ្ណៈជិះជាន់ ជិះជាន់ប្រជាជនទូទៅ ។

នៅជនបទប្រជាជនក៏យ៉ាប់យ៉ឺន ហើយឋិតនៅក្រោមការជិះជាន់របស់ម្ចាស់ដីនិងនាយទុន ។ នៅក្នុងតំបន់រំដោះ យើងរំដោះបានដែនដីហើយ យើងកាន់កាប់អំណាចហើយ តែមូលដ្ឋានយើងមិនទាន់រំដោះកម្លាំងពលកម្មរបស់កម្មករកសិករបានទេ ។

## III. ទិសដោះស្រាយនិងទិសកសាងសេដ្ឋកិច្ចរបស់បក្ស

១) ទិសយូរអង្វែងៈ របបសង្គមនិយម

២) ទិសយុទ្ធសាស្ត្រៈ របបសេដ្ឋកិច្ចប្រជាធិបតេយ្យប្រជាជន

៣) ទិសចំពោះមុខៈ អនុវត្តក្របខ័ណ្ឌនិងកម្រិតយុទ្ធវិធីនៃបដិវត្តប្រជាជាតិប្រជាធិបតេយ្យតាមគោលការណ៍ដំណើរការជំហានៗ ។

៤) ន័យអនុវត្តជាក់ស្តែងក្នុងយុទ្ធវិធីនាបច្ចុប្បន្នៈ

◆ កែប្រែជីវភាពប្រជាជនមួយកម្រិត(ក្នុងក្របខ័ណ្ឌសង្គ្រាមបដិវត្តសព្វថ្ងៃ)

◆ បម្រើសមរភូមិខាងមុខ(បម្រើសង្គ្រាមប្រជាជន)

◆ វាយសេដ្ឋកិច្ចខ្មាំង (បម្រើសង្គ្រាមប្រជាជន

◆ វាយរំលស់របបសក្តិភូមិ នាយទុនកុំប្រាដ័រជាបណ្តើរៗ តាមជំហានៗ ។

◆ រៀបចំលក្ខណៈសម្បត្តិនិងទីតាំងសេដ្ឋកិច្ចយើងថ្មី ជាបណ្តើរតាមជំហានលើគ្រប់ផ្នែកសេដ្ឋកិច្ច ។

◆គោលជំហររបស់យើងក្នុងកិច្ចដំណើរការដោះស្រាយនិងកសាងសេដ្ឋកិច្ចគឺអនុវត្តក្របខ័ណ្ឌនិងកម្រិតយុទ្ធវិធី ។ ចៀសវាងឆ្វេងដោយដំណើរការហួសពីក្របខ័ណ្ឌនិងកម្រិតយុទ្ធវិធីនាំឲ្យបែកកម្លាំង ប្រមូលកម្លាំងវាយខ្មាំង (ចក្រពត្តិអាមេរិកនិងបរិវារ) មិនបាន សម្រេចបដិវត្តប្រជាជាតិមិនបាន តាមរយៈនោះក៏រាំងរាដល់បដិវត្តប្រជាធិបតេយ្យ ។ ម្យ៉ាងទៀតក៏ត្រូវតស៊ូចៀសវាងស្តាំដោយមិនហ៊ានវាយរំលស់របបសក្តិភូមិនាយទុនកុំប្រាដ័រជាបណ្តើរៗ(ក្នុងក្របខ័ណ្ឌយុទ្ធវិធី) ដោយមិនយកចិត្តទុកដាក់កែប្រែជីវភាពប្រជាជនមូលដ្ឋាន ហើយដោយមិនដំណើរការរៀបចំលក្ខណៈសម្បត្តិនិងទីតាំងសេដ្ឋកិច្ចយើងថ្មីជាបណ្តើរតាមជំហានៗលើគ្រប់ផ្នែកសេដ្ឋកិច្ច ។

◆ ក្នុងទិសខាងលើនេះមានធាតុពីរ ធាតុប្រជាជាតិនិងធាតុប្រជាធិបតេយ្យក្នុងក្របខ័ណ្ឌយុទ្ធវិធី ។

◆ការកែប្រែជីវភាពប្រជាជន ពិសេសប្រជាជនមូលដ្ឋានមានតួនាទីសំខាន់ ហើយទាក់ទងដល់សង្គ្រាមបដិវត្ត ។ ប្រជាជនមូលដ្ឋាននៅខ្វះខាត ជីវភាពនៅយ៉ាប់យ៉ឺន ។ យើងមិនទាន់បានបំប៉នគេនៅឡើយ ។ ដូចនេះ យូរអង្វែងកម្លាំងនេះអាចហួតហេវ ។ ដូចនេះផ្នែកបម្រើប្រជាជាតិនិងប្រជាធិបតេយ្យត្រូវដំណើរទៅឲ្យសមស្របគ្នា ។

កែប្រែជីវភាពប្រជាជនក្នុងក្របខ័ណ្ឌសង្គ្រាមបដិវត្តសព្វថ្ងៃត្រូវចៀសវាង"កសាននិយម" ។ កែប្រែជីវភាពប្រជាជនដោយដឹកនាំប្រជាជនបង្កបង្កើនផលជាសំខាន់ ទន្ទឹមនេះដោយការផ្លាស់ប្តូរសេដ្ឋកិច្ចដែលចាំបាច់ ។

ត្រូវបង្កបង្កើនផលតាមគ្រប់រូបភាពៈ ឯកជនប្រវាស់ដៃរួម(ជាស្រែរួម ចម្ការរួម) ។ល ។ បច្ចុប្បន្ននេះឯកជននៅដើរតួ ។ ដូចនេះក្នុងការរៀបចំលក្ខណៈសម្បត្តិនិងទីតាំងសេដ្ឋកិច្ចយើងថ្មីត្រូវឈានតាមជំហានៗដោយប្រយ័ត្នប្រយែង កុំឲ្យប៉ះពាល់ដល់ការបង្កបង្កើនផល ដែលជាការនាំឲ្យប៉ះពាល់ដល់ការបំប៉នកម្លាំងប្រជាជនដល់កម្លាំងសង្គមអន្តរាយដល់ភារកិច្ចវាយខ្មាំង ។

◆ បម្រើសមរភូមិខាងមុខៈ ដោយប្រជាជនខបត្តម្ភបដិវត្តដោយភ្នាក់ពុកផង ដោយយើងទិញពីប្រជាជនផង ។

◆ វាយសេដ្ឋកិច្ចខ្មាំង ដោយហ៊ុមព័ទ្ធសេដ្ឋកិច្ចខ្មាំងនិងផ្តាច់គមនាគមន៍តទៅទៀត ។

◆ វាយរំលស់របបសក្តិភូមិនាយទុនកុំប្រាដ័រជាបណ្តើរៗតាមជំហានៗក្នុងក្របខ័ណ្ឌនិងកម្រិតយុទ្ធវិធី ។ វាយរំលស់រូបភាពជិះជាន់របស់សក្តិភូមិនាយទុនកុំប្រាដ័រដោយរឹបអូសយកដីពួកក្បត់ចែកជូនប្រជាជនមូលដ្ឋានដោយមានវិធានការបន្ថយឈ្នួលដី ឈ្នួលគោក្របី ការប្រាក់ កំណត់តម្លៃទំនិញ ។ល ។ តែសំខាន់ត្រូវវាយរំលស់ដោយស៊ីជម្រៅខាងខ្លឹមសារ ដោយអប់រំសតិអារម្មណ៍នយោបាយ និងបំពាក់គោលជំហរវណ្ណៈ តស៊ូវណ្ណៈឲ្យប្រជាជន ពិសេសប្រជាជនមូលដាន ។ ជាគុណសម្បត្តិរបស់យើង យើងមានចែកដីជូនប្រជាជនក្រីក្រច្រើន ហើយព្រមទាំងមានវិធានការច្រើន ដើម្បីបន្ថយឈ្នួលដី ឈ្នួលគោក្របី ការប្រាក់តម្លៃទំនិញ ។ល ។ តែជាការខ្វះខាត យើងមិនទាន់ស៊ីជម្រៅទៅក្នុងខ្លឹមសារ ដោយមិនទាន់បានអប់រំសតិអារម្មណ៍នយោបាយ ប្រជាជនឲ្យបានរឹងប៉ឹង ពិសេសមិនទាន់បានបំពាក់គោលជំហរវណ្ណៈ តស៊ូវណ្ណៈឲ្យប្រជាជន ដើម្បីឲ្យគេទៅជាកម្លាំងបដិវត្តន៍រឹងប៉ឹងនៅឡើយ ។ ព្រមជាមួយនោះក៏ពុំទាន់ណែនាំអនុវត្តនយោបាយដីធ្លីរបស់យើងឲ្យបានត្រឹមត្រូវ ដើម្បីបម្រើប្រជាជនមូលដ្ឋាន ។ ដូចនេះ ពង្រឹងប្រជាពលករទាំងស្មារតី ទាំងចាត់តាំង និងកែប្រែជីវភាពប្រជាជន ជាភារៈសំខាន់ដែលត្រូវដំណើរការតទៅទៀត ដើម្បីឲ្យខ្លឹមសារបដិវត្តវាជ្រួតជ្រាបទៅក្នុងប្រជាជន ។

◆ រៀបចំលក្ខណៈសម្បត្តិនិងទីតាំងសេដ្ឋកិច្ចយើងថ្មីៈ រៀបចំខាងនយោបាយសតិអារម្មណ៍ឲ្យរឹងប៉ឹងខាងជំហរវណ្ណៈ តស៊ូវណ្ណៈ ខាងសេដ្ឋកិច្ចរៀបចំទីតាំងសេដ្ឋកិច្ចថ្មី សេដ្ឋកិច្ចរដ្ឋ សេដ្ឋកិច្ចសហករណ៍ ពីទាបទៅខ្ពស់តាមលក្ខណៈសម្បត្តិផ្សេងៗក្នុងកន្លែងនីមួយៗ ។ កន្លែងខ្លះលឿន កន្លែងខ្លះយឺតតាមលក្ខណៈសម្បត្តិផ្សេងៗតែទាំងអស់គ្នាគឺនៅក្នុងក្របខ័ណ្ឌយុទ្ធវិធី ។

**(ឯកសារ D១៣៦៣៤)**



ក្រុមអ្នកដឹកនាំសហគមន៍អ៊ីស្លាម





# បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរ ស-២១ (គុកទួលស្លែង)

**រៀបចំនិងចងក្រងដោយៈ យិន នាន**

**(តពីលេខមុន)**

| ល.រ | ឈ្មោះ | តួនាទី | កន្លែងយក | ថ្ងៃចូល | ថ្ងៃកម្ទេច |
|---|---|---|---|---|---|
| ១៧២៤ | ពៅ ដាត ហៅ គឿន | យុទ្ធជន | កងពល៣១០ | ២៦-២-៧៧ | ១៧-៣-៧៧ |
| ១៧២៥ | សួស ពេជ | យុទ្ធជន | កងពល៣១០ | ២៥-២-៧៧ | ១៧-៣-៧៧ |
| ១៧២៦ | ព្រុំ ភី | យុទ្ធជន | កងពល៣១០ | ២៨-២-៧៧ | ១៧-៣-៧៧ |
| ១៧២៧ | ទេស យន ហៅ យឿន | ប្រធានក្រុម | កងពល៣១០ | ២៨-២-៧៧ | ១៧-៣-៧៧ |
| ១៧២៨ | អី យី | សមាជិកក្រុម | កងពល៣១០ | ២៥-២-៧៧ | ១៧-៣-៧៧ |
| ១៧២៩ | ផ្លូន យ៉ន ហៅ ញឹម | យុទ្ធជន | កងពល៣១០ | ២៥-២-៧៧ | ១៧-៣-៧៧ |
| ១៧៣០ | នុត រ៉ាំ | យុទ្ធជន | កងពល៣១០ | ២៥-២-៧៧ | ១៧-៣-៧៧ |
| ១៧៣១ | ម៉ម សួង ហៅ បុល | យុទ្ធជន | កងពល៣១០ | ២៤-២-៧៧ | ១៧-៣-៧៧ |
| ១៧៣២ | ខួត ស្រ៊ី | មេក្រុមនីរសារ | កងពល៣១០ | ២៨-២-៧៧ | ១៧-៣-៧៧ |
| ១៧៣៣ | ចន អឿន | យុទ្ធជន | កងពល៣១០ | ២៥-២-៧៧ | ១៧-៣-៧៧ |
| ១៧៣៤ | សំ ម៉ុន ហៅ ចាន់ | យុទ្ធជន | កងពល៣១០ | ២-៣-៧៧ | ១៧-៣-៧៧ |
| ១៧៣៥ | វ៉ាន់ ទឹម ហៅ យឿន | យុទ្ធជន | កងពល៣១០ | ៧-៣-៧៧ | ១៧-៣-៧៧ |
| ១៧៣៦ | គួយ គ្រី | យុទ្ធជន | ស-២១យ | ១១-២-៧៧ | ១៧-៣-៧៧ |
| ១៧៣៧ | ស្វាយ សឿន | មេក្រុម | កងពល៧០៣ | ១២-២-៧៧ | ១៧-៣-៧៧ |
| ១៧៣៨ | ទឹម គុច ហៅ ស៊ី | យុទ្ធជនមន្ទីរ | កងពល៧០៣ | ១៤-២-៧៧ | ១៧-៣-៧៧ |
| ១៧៣៩ | សុក គូ ហៅ គុន | មេក្រុម | កងពល៤៥០ | ១៨-២-៧៧ | ១៧-៣-៧៧ |
| ១៧៤០ | ឆេង ថៃ ហៅ ឆាត | មេក្រុម | កងពល៤៥០ | ១៨-២-៧៧ | ១៧-៣-៧៧ |
| ១៧៤១ | គុយ លាង ហៅ ណាត (ស្រី) | ប្រពន្ធ កែ ណាង | កងពល៣១០ | ៣១-១២-៧៦ | ១៧-៣-៧៧ |
| ១៧៤២ | ហម រី ហៅ រ៉ុម (ស្រី) | ប្រពន្ធ ទុំ ប៉ុម | កងពល៣១០ | ៣១-១២-៧៦ | ១៧-៣-៧៧ |
| ១៧៤៣ | ចាន់ គឿន ហៅ គីន (ស្រី) | ប្រពន្ធ ឯម ដាត | កងពល៣១០ | ៣១-១២-៧៦ | ១៧-៣-៧៧ |
| ១៧៤៤ | មៀច យ៉ុម ហៅ យឿន (ស្រី) | យុទ្ធនារី | មន្ទីរពេទ្យ៩៨ | ១២-១២-៧៦ | ១៧-៣-៧៧ |
| ១៧៤៥ | ទន ហៀង (ស្រី) | មេពួក | មន្ទីរពេទ្យ៩៨ | ១២-១២-៧៦ | ១៧-៣-៧៧ |
| ១៧៤៦ | គីម យន ហៅ ភាព (ស្រី) | យុទ្ធនារីព-៣១ | កងពល៣១០ | ៧-១-៧៧ | ១៧-៣-៧៧ |
| ១៧៤៧ | មាស រី ហៅ វុធ (ស្រី) | យុទ្ធនារី | កងពល៣១០ | ២៥-១-៧៧ | ១៧-៣-៧៧ |
| ១៧៤៨ | ហែ ហៀម ហៅ គឿន (ស្រី) | អនុក្រុម | ព-៩៨ | ៦-១-៧៧ | ១៧-៣-៧៧ |
| ១៧៤៩ | ឃុន នី ហៅ ណាង (ស្រី) | យុទ្ធនារីពេទ្យ | កងពល៣១០ | ១-១-៧៧ | ១៧-៣-៧៧ |
| ១៧៥០ | ជា អាង ហៅ រ៉េន (ស្រី) | យុទ្ធនារីពេទ្យ | ព-៩៨ | ៦-១-៧៧ | ១៧-៣-៧៧ |

| | | | | | |
|---|---|---|---|---|---|
| ១៧៥១ | នីម យត ហៅ ខូវ (ស្រី) | យុទ្ធនារីពេទ្យ | ព-៩៨ | ៦-១-៧៧ | ១៧-៣-៧៧ |
| ១៧៥២ | កែ អ៊ន ហៅ នឿន (ស្រី) | យុទ្ធនារី | កងពល៣១០ | ៣១-១២-៧៦ | ១៧-៣-៧៧ |
| ១៧៥៣ | ប៊ុច គៀមស៊ី ហៅ ស៊ីម (ស្រី) | យុទ្ធនារី | មន្ទីរពេទ្យ៩៨ | ៦-១-៧៧ | ១៧-៣-៧៧ |
| ១៧៥៤ | ស្រី នួន ហៅ នេត (ស្រី) | យុទ្ធនារី | មន្ទីរពេទ្យ៩៨ | ១៩-២-៧៧ | ១៧-៣-៧៧ |
| ១៧៥៥ | សេង នឿន ហៅ វ៉ាន់ (ស្រី) | យុទ្ធនារី | មន្ទីរពេទ្យ៩៨ | ១៩-២-៧៧ | ១៧-៣-៧៧ |
| ១៧៥៦ | មាស ភន ហៅ សំ (ស្រី) | យុទ្ធនារី | មន្ទីរពេទ្យ៩៨ | ១៩-២-៧៧ | ១៧-៣-៧៧ |
| ១៧៥៧ | ង៉ែត សុខន (ស្រី) | យុទ្ធនារី | ស-២១យ | ៩-៣-៧៧ | ១៧-៣-៧៧ |
| ១៧៥៨ | រដ្ឋ យឹន (ស្រី) | យុទ្ធនារី | ស-២១យ | ៩-៣-៧៧ | ១៧-៣-៧៧ |
| ១៧៥៩ | ពិន ចេង ហៅ ស៊ីម (ស្រី) | យុទ្ធនារី | កងពល៧០៣ | ៩-៣-៧៧ | ១៧-៣-៧៧ |
| ១៧៦០ | គង់ សៅ (ស្រី) | យុទ្ធនារី | ស-២១យ | ៩-៣-៧៧ | ១៧-៣-៧៧ |
| ១៧៦១ | ថេន ដាន ហៅ ដៃ (ស្រី) | យុទ្ធនារី | ស-២១យ | ១៤-៣-៧៧ | ១៧-៣-៧៧ |
| ១៧៦២ | ឃឹម រុន ហៅ វ៉ាត (ស្រី) | យុទ្ធនារី | ស-២១យ | ១៤-៣-៧៧ | ១៧-៣-៧៧ |
| ១៧៦៣ | ពៅ ក្ដឹប ហៅ ហូ (ស្រី) | យុទ្ធនារី | កងពល៣១០ | ?-៣-៧៧ | ១៧-៣-៧៧ |
| ១៧៦៤ | ជា ឡាំងហៀង (ស្រី) | ប្រពន្ធ កែវ ជាត | កងពល៣១០ | ៧-២-៧៧ | ១៧-៣-៧៧ |
| ១៧៦៥ | ហឿង ម៉ឺន ហៅ ថាន (ស្រី) | យុទ្ធនារី | កងពល៣១០ | ១៤-៣-៧៧ | ១៧-៣-៧៧ |
| ១៧៦៦ | សូ ដាត ហៅ សំបាត់ (ស្រី) | យុទ្ធនារី | កងពល៣១០ | ២៥-១-៧៧ | ១៧-៣-៧៧ |
| ១៧៦៧ | ដួង សារុន ហៅ ហាន (ស្រី) | យុទ្ធនារីពេទ្យ | ព-៩៨ | ៦-១-៧៧ | ១៧-៣-៧៧ |
| ១៧៦៨ | ស៊ឹម ស៊ីនឿន ហៅ នា (ស្រី) | យុទ្ធនារីពេទ្យ | ព-៩៨ | ៦-១-៧៧ | ១៧-៣-៧៧ |
| ១៧៦៩ | ដុំ ហៀម ហៅ ស្រន (ស្រី) | យុទ្ធនារី | កងពល៣១០ | ២៨-២-៧៧ | ១៧-៣-៧៧ |
| ១៧៧០ | ចាន់ សឿង ហៅ សាត (ស្រី) | យុទ្ធនារីពេទ្យ | ព-៩៨ | ៦-២-៧៧ | ១៧-៣-៧៧ |
| ១៧៧១ | ហុំ ឃី ហៅ យ៉េម (ស្រី) | យុទ្ធនារីពេទ្យ | ព-៩៨ | ៦-២-៧៧ | ១៧-៣-៧៧ |
| ១៧៧២ | ប៉ុល យ៉េត ហៅ មឿន (ស្រី) | យុទ្ធនារីពេទ្យ | ព-៩៨ | ៦-២-៧៧ | ១៧-៣-៧៧ |
| ១៧៧៣ | រដ្ឋ យឹន (ស្រី) | យុទ្ធនារី | ស-២១យ | ?-៣-៧៧ | ១៧-៣-៧៧ |
| ១៧៧៤ | ហែម លុយ ហៅ ឡាយ (ស្រី) | យុទ្ធនារី | កងពល៣១០ | ២៨-២-៧៧ | ១៧-៣-៧៧ |
| ១៧៧៥ | ខាត់ សំអុល ហៅ ស្រាំង (ស្រី) | យុទ្ធនារី | កងពល៣១០ | ២៨-២-៧៧ | ១៧-៣-៧៧ |
| ១៧៧៦ | ដុំ ហៀម ហៅ ស្រ៊ាន (ស្រី) | យុទ្ធនារី | កងពល៣១០ | ២៨-២-៧៧ | ១៧-៣-៧៧ |
| ១៧៧៧ | ចេង ស៊ុនលី ហៅ ភ័ស្ដុ (ស្រី) | យុទ្ធនារី | កងពល៣១០ | ២៨-២-៧៧ | ១៧-៣-៧៧ |
| ១៧៧៨ | ប៊ុន រី (ស្រី) | យុទ្ធនារី | កងពល៣១០ | ៦-១-៧៧ | ១៧-៣-៧៧ |
| ១៧៧៩ | ជុន ហុង ហៅ ហេង (ស្រី) | យុទ្ធនារីពេទ្យ | ព-៩៨ | ៦-១-៧៧ | ១៧-៣-៧៧ |
| ១៧៨០ | អួន ង៉ាន ហៅ ខេង (ស្រី) | យុទ្ធនារីពេទ្យ | ព-៩៨ | ៦-១-៧៧ | ១៧-៣-៧៧ |
| ១៧៨១ | ហង់ សុង ហៅ កឿន | ប្រធានកងហា | កងពល៣១០ | ?-១២-៧៦ | ១៨-៣-៧៧ |

**(នៅមានត)**

# សហគមន៍ចាមអ៊ីម៉ាំសាន់ៈ ជីវភាពបែបបុរាណ

ប្រជាជនកម្ពុជាភាគច្រើនដឹងថាជនជាតិចាមជាជនមូស្លីម សេសសល់ពីរាជាណាចក្រចម្ប៉ា ដែលធ្លាប់បានគ្រប់គ្រងទឹកដីមួយចំនួនដែលភាគច្រើនជាប្រទេសវៀតណាមបច្ចុប្បន្ននេះនៅចន្លោះពីសតវត្សរ៍ទី២និងទី១៧នៃគ្រិស្តសករាជ ប៉ុន្តែអ្វីដែលមនុស្សភាគច្រើនមិនដឹងនោះគឺថា សហគមន៍ចាមកម្ពុជាបានចែកចេញជាពីរក្រុម ។ ដូចគ្នានឹងសហគមន៍ព្រះពុទ្ធសាសនានៅក្នុងប្រទេសកម្ពុជាដែលចែកចេញជាពីរនិកាយគឺ ព្រះពុទ្ធសាសនាមហានិកាយ និងធម្មយុត្តិកនិកាយ ជនជាតិចាមក៏មានពីរប្រភេទដែរគឺៈ អ្នកដែលប្រតិបត្តិតាមអ៊ីស្លាមបច្ចុប្បន្ន (អ៊ីស្លាមសម័យទំនើប) និងអ្នកដែលប្រតិបត្តិតាមអ៊ីស្លាមចម្ប៉ាសម័យបុរាណ ។

ជនជាតិចាមកម្ពុជាស្ទើរតែទាំងអស់ប្រតិបត្តិតាមអ៊ីស្លាមសម័យទំនើប ហើយអ្នកដឹកនាំក្រុមនេះគឺឧកញ៉ា សុះ ក៏រី ដែលត្រូវបានព្រះបាទ នរោត្តម សីហនុ តែងតាំងជាប្រធាននៃក្រុមប្រឹក្សាជាន់ខ្ពស់សម្រាប់កិច្ចការសាសនាអ៊ីស្លាមនៅកម្ពុជា ។ យើងឃើញជនមូស្លីមសម័យបច្ចុប្បន្នរស់នៅពាសពេញផ្ទៃប្រទេសកម្ពុជា ហើយច្រើនបំផុតគឺនៅក្នុងខេត្តកំពង់ចាម ។ ប្រជាជនក្រុមនេះគឺមានចំនួនប្រមាណ៥ម៉ឺននាក់ (នេះបើយោងទៅតាមក្រសួងវប្បធម៌និងសាសនានិងតាមការស្រាវជ្រាវរបស់ឧកញ៉ា សុះ ក៏រី) ។


ឧកញ៉ា ឃ្លូ កែទាំ

ក្រុមជនជាតិចាមដ៏តូចមួយដែលហាក់បីដូចជាត្រូវបានបំភ្លេចហើយ នោះគឺសហគមន៍អ៊ីម៉ាំសាន់ដែលដឹកនាំដោយឧកញ៉ា ឃ្លូ កែទាំ ។ អ្នកដែលគោរពតាមក្រុមនេះនៅតែប្រតិបត្តិតាមរបៀបចម្ប៉ាបុរាណនូវផ្នែកជាច្រើន ហើយក្រុមនេះមានតាំងទីលំនៅនៅក្នុងភូមិចំនួន៣៥ នៃខេត្តកំពង់ឆ្នាំង បាត់ដំបង ពោធិសាត់ និងខេត្តកណ្តាល ។

### ***ប្រពៃណីជនជាតិចាម***

នៅពេលដែលរាជាណាចក្រចម្ប៉ាដួលរលំ រាជាណាចក្រមួយនេះត្រូវបានស្នងតំណែងដោយកុលសម្ព័ន្ធជនជាតិអារ៉ាប់ និងម៉ាឡេស៊ី ហើយភាគច្រើននៃជនជាតិចាមបានប្តូរទៅកាន់សាសនាអ៊ីស្លាមសម័យទំនើបវិញ ។ ប៉ុន្តែជនជាតិចាមដែលដឹកនាំដោយលោកឧកញ៉ា សុះ ក៏រី នៅតែថែរក្សាសាសនានិងប្រពៃណីដែលបន្សល់ទុកពីអារ៉ាប់និងម៉ាឡេស៊ីដដែល ។ ក្រុមនេះបានប្តូរតួអក្សរពីចាមទៅជាតួអក្សរអារ៉ាប់ដែលត្រូវបានប្រើប្រាស់ស្ទើរតែនៅគ្រប់ភូមិចាមទាំងអស់នៅកម្ពុជាសព្វថ្ងៃនេះ ។

ទោះបីជាយ៉ាងណាក៏ដោយ ភូមិទាំង៣៥របស់ អ៊ីម៉ាំសាន់នៅតែថែរក្សាសាសនានិងប្រពៃណីដែលបន្សល់ទុកពីរាជាណាចក្រចម្ប៉ាបុរាណដដែល ។ ជនជាតិចាមអ៊ីម៉ាំសាន់ខុសពីជនមូស្លីមចាមសព្វថ្ងៃនេះដោយសារតែក្រុមនេះបានទទួលយកឥទ្ធិពលខ្លះៗពីសាសនាហិណ្ឌូនិងព្រះពុទ្ធ ហើយបានបញ្ចូលផ្នែកខ្លះៗនៃសាសនាទាំងនេះទៅក្នុងពិធីបុណ្យផ្សេងៗរបស់ខ្លួន ។ ជាក់ស្តែងផ្នែកដ៏សំខាន់បំផុតនៃពិធីរៀបអាពាហពិពាហ៍របស់ជនជាតិចាមអ៊ីម៉ាំសាន់គឺ ឡាគា ដែលស្រដៀងគ្នាបំផុតទៅនឹងពិធីខាន់ស្លាដាពិធីសំខាន់បំផុតនៃការរៀបអាពាហ៍ពិពាហ៍តាមបែបព្រះពុទ្ធសាសនា ។

ចំនួននៃពិធីបុណ្យក្នុងឆ្នាំនីមួយៗរបស់ជនជាតិចាមអ៊ីម៉ាំសាន់គឺមានច្រើនគួរឲ្យកត់សម្គាល់ ។ នេះគឺដោយសារតែជនជាតិចាមអ៊ីម៉ាំសាន់ប្រារព្ធទាំងពិធីបុណ្យរបស់ចម្ប៉ាសម័យបុរាណទាំងពិធីបុណ្យរបស់ចាមនាសម័យទំនើប ។ ជនមូស្លីមចាមសព្វថ្ងៃនេះមិនអនុវត្តពិធីបុណ្យរបស់ចម្ប៉ានាសម័យដើមទេ ដោយសារតែឥទ្ធិពលរបស់អ៊ីស្លាមទំនើបម៉ាឡេស៊ីនិងអារ៉ាប់ ។

ការប្រើប្រាស់ភាសារបស់អ៊ីម៉ាំសាន់ក៏ប្លែកពីជនជាតិចាមដទៃៗទៀតដែរ ។ ជាឧទាហរណ៍ នៅតែសូត្រកំណាព្យរបស់ចម្ប៉ាសម័យបុរាណដដែល (កំណាព្យទាំងនេះត្រូវបានសរសេរឡើង

ដោយប្រើប្រាស់តួអក្សរចាមនាសម័យដើម នៅមុនពេលដែលអក្សរទាំងនេះត្រូវបានបញ្ចូលភាសាខ្មែរខ្លះៗ) ។ ផ្ទុយទៅវិញ ជនមូស្លីមចាមនាសម័យទំនើបនេះបានបោះបង់ចោលទាំងស្រុងនូវការសូត្រកំណាព្យរបៀបនេះ ។ ជាងនេះទៅទៀត ជនជាតិចាមអ៊ីម៉ាំសាន់នៅតែប្រើប្រាស់ការបញ្ចេញសំឡេងបែបចាស់ដដែលក្នុងការអានគម្ពីរគូរ៉ាន់ ។ ភាសាចាមសព្វថ្ងៃនេះបានប្រើប្រាស់តួអក្សររបស់អារ៉ាប់ ដោយសារតែឥទ្ធិពលរបស់អារ៉ាប់និងម៉ាឡេស៊ីបន្ទាប់ពីការដួលរលំនៃរាជាណាចក្រចម្ប៉ា ដោយឡែកជនជាតិចាមអ៊ីម៉ាំសាន់នៅតែប្រើប្រាស់តួរអក្សរដើមរបស់ភាសាចាម ។ អក្សររបស់ភាសាចាមបុរាណនេះនៅតែត្រូវបានយកទៅបង្រៀននៅក្នុងភូមិរបស់អ៊ីម៉ាំសាន់ដដែល ប៉ុន្តែលែងប្រើប្រាស់អក្សរបុរាណនេះសម្រាប់សរសេរទៀតហើយ ។ ដោយឡែកកំណាព្យនិងអត្ថបទរបស់ចាមនាសម័យបុរាណទាំងអស់ប្រើប្រាស់តួអក្សរសម័យបុរាណដើម្បីសរសេរ ហើយឯកសារប្រភេទនេះមួយចំនួនធំត្រូវបានថែរក្សានៅក្នុងភូមិរបស់ខុកញ៉ា ឃ្លួ កែទាំ ។

លក្ខណៈខុសគ្នាធំបំផុតរបស់សហគមន៍ចាមទាំងពីរនេះប្រហែលជាចំនួននៃការថ្វាយបង្គំព្រះ ។ ជនជាតិចាមអ៊ីម៉ាំសាន់ថ្វាយបង្គំព្រះតែមួយដងប៉ុណ្ណោះក្នុងមួយសប្តាហ៍ នៅឯវិហារអ៊ីស្លាមក្នុងភូមិ ចំណែកឯជនមូស្លីមសម័យទំនើប ថ្វាយបង្គំព្រះប្រាំដងក្នុងមួយថ្ងៃ ។ ដោយសារតែកត្តានេះហើយបានជាជនមូស្លីមសម័យទំនើបនេះមានទស្សនៈថា ជនជាតិចាមអ៊ីម៉ាំសាន់មិនមែនជនមូស្លីមពិតប្រាកដទេ ។ ជនជាតិចាមអ៊ីម៉ាំសាន់បានប្រកែកថា ខ្លួនក៏ថ្វាយបង្គំព្រះបានច្រើនដងដែរ ប៉ុន្តែគ្រាន់តែថ្វាយបង្គំនៅក្នុងចិត្តប៉ុណ្ណោះ ។ ចំណុចខុសគ្នាគួរឲ្យកត់សម្គាល់មួយទៀតរវាងសហគមន៍ចាមទាំងពីរនេះគឺថាវិហារសាសនារបស់ជនជាតិចាមអ៊ីម៉ាំសាន់មិនមានប៉មទេ (កំពូលដែលមានរាងក្រឡូម) សូម្បីតែការតុបតែងខាងក្នុងព្រះវិហារក៏ស្រដៀងនឹងការតុបតែងវត្តរបស់សាសនាព្រះពុទ្ធដែរ ។

## ជីវភាពនៅក្នុងរបបខ្មែរក្រហម

នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ សហគមន៍ចាមកម្ពុជាបានទទួលរងនូវការធ្វើបាបយ៉ាងខ្លាំង ។ ព្រះវិហារអ៊ីស្លាមប្រហែល១៣០ត្រូវបំផ្លាញ (យោងតាមប្រភពរបស់ជនជាតិចាម) ព្រះវិហារជាច្រើនទៀតបានទទួលការប្រមាថ(ឧទាហរណ៍ៈ ដូចជាប្រែក្លាយព្រះវិហារឲ្យទៅជាគុកជាដើម) ជនមូស្លីមមិនត្រូវបានអនុញ្ញាតឲ្យគោរពបូជាព្រះឡើយ ។ អ្នកខ្លះបាននិយាយថាការធ្វើទុក្ខបុកម្នេញជនជាតិចាមនៅប្រទេសកម្ពុជាគឺជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ព្រោះជាការធ្វើទុក្ខបុកម្នេញលើជនជាតិភាគតិច ។ បញ្ហានេះគឺជាបញ្ហាដ៏ចម្រូងចម្រាស់មួយដែលមានអត្ថបទជាច្រើនបានចុះផ្សាយអំពីបញ្ហានេះ ។ សៀវភៅ អ៊ីគូបះ របស់ អ៊ីសា ឧស្មាន ដែលបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជាក៏បាននិយាយអំពីការធ្វើទុក្ខបុកម្នេញលើជនជាតិចាមនៅកម្ពុជាក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែរ ។ ឥឡូវនេះ ឧស្មាន កំពុងតែសរសេរសៀវភៅមួយទៀតស្តីអំពីការបះបោរនៅក្នុងភូមិចាមចំនួនពីរក្នុងសម័យខ្មែរក្រហម ។

អ៊ីម៉ាំសាន់ ក៏បានទទួលរងនូវការធ្វើបាបយ៉ាងធ្ងន់ធ្ងរដែរ ។ ជនជាតិចាមជាច្រើនត្រូវបានជម្លៀសចេញពីភូមិរបស់ខ្លួន និងមិនត្រូវបានអនុញ្ញាតឲ្យប្រតិបត្តិសាសនារបស់ខ្លួនឡើយ ។ ខុកញ៉ា ឃ្លួ កែទាំ បានរំឭកអំពីការថ្វាយបង្គំព្រះយ៉ាងសម្ងាត់របស់គាត់រៀងរាល់យប់ថ្ងៃសុក្រនៅក្នុងមុងដែលទាហានខ្មែរក្រហមមិនអាចមើលឃើញ ។ គាត់នៅចាំថា ខ្មែរក្រហមបានចូលមកក្នុងភូមិរបស់គាត់នៅឆ្នាំ១៩៧៣ ។ ចាប់តាំងពីពេលនោះរហូតមកដល់ឆ្នាំដែលរបបខ្មែរក្រហមដួលរលំភូមិរបស់គាត់និងតំបន់ទាំងឡាយនៅជុំវិញនោះមិនដែលមានសុវត្ថិភាពសោះឡើយ ។ ជនជាតិចាមជាច្រើនបានភៀសខ្លួនទៅនៅប្រាំងចំរេះ (គីឡូម៉ែត្រលេខ៧, លេខ៨ និង លេខ៩) នៅក្បែរទីក្រុងភ្នំពេញ ។ ខុកញ៉ា ឃ្លួ កែទាំ បានភៀសខ្លួនទៅគីឡូម៉ែត្រលេខ៨នៅដើមឆ្នាំ១៩៧៤ ហើយបន្ទាប់មកគាត់បានផ្លាស់ទៅទួលគោក និងព្រះវិហារខ្វបៃ នៅភ្នំពេញ ។ នៅពេលខ្មែរក្រហមជម្លៀសប្រជាជនឲ្យចេញពីទីក្រុងភ្នំពេញនៅខែមេសា ឆ្នាំ១៩៧៥ គាត់បានចំណាយពេលអស់មួយខែដើម្បីត្រឡប់ទៅភូមិរបស់គាត់វិញ ប៉ុន្តែខ្មែរក្រហមបានជម្លៀសគាត់ទៅខេត្តកំពង់ចាម ។ ដោយបោះបង់ចោលនូវទ្រព្យសម្បត្តិទាំងអស់ ខុកញ៉ា ឃ្លួ កែទាំ និងក្រុមគ្រួសាររបស់គាត់បានភៀសខ្លួនម្តងទៀត ហើយបានវិលត្រឡប់ទៅភូមិរបស់គាត់

វិញ ។ មុនពេលដែលក្រុមគ្រួសាររបស់គាត់ធ្វើដំណើរទៅដល់ផ្ទះ ម្តាយក្មេកនិងកូនស្រីរបស់គាត់បានបាត់បង់ជីវិតដោយសារជំងឺនិងខ្វះខាតម្ហូបអាហារ ។ បន្តិចក្រោយមក ខ្មែរក្រហមបានចាត់តាំងគាត់ឲ្យធ្វើស្រែនិងកៀបទឹកត្នោត ហើយបន្ទាប់មកទៀតគាត់ត្រូវបានផ្លាស់ឲ្យទៅនៅក្នុងកងវេញខ្សែ ។ កូនប្រុសម្នាក់របស់គាត់បានធ្លាក់ខ្លួនឈឺ ហើយអ្នកភូមិនិយាយថាកូនរបស់គាត់ត្រូវយកទៅកប់ទាំងរស់ ។

ខុកញ៉ាឃ្លួ កែតាំ បានផ្លាស់ទៅនៅអណ្តូងស្នាយ នៅពេលដែលចាមជាច្រើនត្រូវអង្គការជម្លៀសចេញពីស្រុកកំណើត ហើយគាត់ត្រូវខ្មែរក្រហមចោទប្រកាន់ថាជាហាគីម(អ្នកដឹកនាំភូមិចាម) និងចោទថានៅតែបន្តប្រតិបត្តិសាសនារបស់គាត់ ។

ខុកញ៉ា ឃ្លួ កែតាំ បានរួចផុតពីការស្លាប់ចំនួនពីរដង ។ លើកទីមួយគាត់បានពន្យល់ខ្មែរក្រហមថាគាត់មិនដែលស៊ីសាច់គោទេ (ហើយខ្មែរក្រហមបានចាត់ទុកទង្វើរបស់គាត់នេះថាជាសកម្មភាពដែលមានការសង្ស័យ) ហើយមួយលើកទៀតគឺដោយសារការរំដោះរបស់កងទ័ពវៀតណាមនៅឆ្នាំ១៩៧៩ ។ ខុកញ៉ា ឃ្លួ កែតាំ មានសេចក្តីត្រេកអរជាខ្លាំងដោយនៅរស់រានមានជីវិតរហូតមកទល់សព្វថ្ងៃនេះ ។ គាត់ដឹងថាមិនមែនមានតែជនជាតិចាមទេដែលត្រូវបានខ្មែរក្រហមធ្វើទុក្ខបុកម្នេញក្រុមសាសនាដទៃទៀតក៏ត្រូវខ្មែរក្រហមធ្វើបាបដែរ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ខុកញ៉ា ឃ្លួ កែតាំ បានគាំទ្រជាខ្លាំងចំពោះតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមដែលនឹងបង្កើតក្នុងពេលឆាប់ៗនេះ ។

## ជនជាតិចាមអ៊ីម៉ាំសាន់សព្វថ្ងៃនេះ

ក្នុងនាមជាមេដឹកនាំខ្ពស់បំផុតនៃសហគមន៍អ៊ីស្លាមអ៊ីម៉ាំសាន់ ខុកញ៉ា ឃ្លួ កែតាំ ត្រូវបានអញ្ជើញឲ្យចូលរួមក្នុងពិធីបុណ្យផ្សេងៗនៅក្នុងព្រះបរមរាជវាំងជាញឹកញាប់ ។ នៅក្នុងឆ្នាំនេះគាត់បានចូលរួមនៅក្នុងពិធីឡើងគ្រងរាជ្យសម្បត្តិរបស់ព្រះបាទនរោត្តម សីហមុនី និងពិធីចម្រើនព្រះជន្មាយុរបស់ព្រះបាទនរោត្តម សីហនុ ។ ខុកញ៉ា សុះ កំរី ក៏បានចូលរួមក្នុងពិធីទាំងអស់នេះដែរ ។ ខុកញ៉ាទាំងពីរនេះមានចំណេះដឹងយ៉ាងជ្រៅជ្រះក្នុងវិស័យសាសនាអ៊ីស្លាម បានរួមគ្នាទទួលខុសត្រូវចំពោះសហគមន៍ចាម ។ អ្នកទាំងពីរមានទំនាក់ទំនងនឹងគ្នាយ៉ាងជិតស្និទ្ធ ហើយបានព្រមព្រៀងគ្នាថា ខុកញ៉ា សុះ កំរី នឹងឆ្លើយនូវរាល់សំណួរទាំងអស់ (ទោះបីជាសួរដោយជនមូស្លីមជនបរទេស ឬក៏ព្រះមហាក្សត្រ) អំពីជនមូស្លីមសម័យទំនើបនេះហើយខុកញ៉ា ឃ្លួ កែតាំ នឹងឆ្លើយនូវរាល់សំណួរទាំងឡាយដែលទាក់ទងនឹងប្រវត្តិសាស្ត្រ ឬប្រពៃណីរបស់ចម្ប៉ា ។



អក្សរចម្ប៉ាសម័យបុរាណ ដែលខុកញ៉ា ឃ្លួ កែតាំ បង្រៀននៅផ្ទះរបស់គាត់នៅភូមិស្រែព្រៃ ឃុំអូរឫស្សី ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ។

ជនជាតិចាមអ៊ីម៉ាំសាន់បានទទួលនូវការគាំទ្រពីសំណាក់ព្រះរាជវង្សានុវង្សក្នុងការថែរក្សាប្រវត្តិសាស្ត្ររបស់ជនជាតិចាម ។ ដោយឡែកជនជាតិចាមនៅក្រោមការដឹកនាំរបស់ខុកញ៉ា សុះ កំរី មិនត្រឹមតែទទួលបាននូវការគាំទ្រពីព្រះរាជវង្សានុវង្សប៉ុណ្ណោះទេ ថែមទាំងទទួលបាននូវការឧបត្ថម្ភជាមូលនិធិពីសំណាក់មូស្លីមអារ៉ាប់និងម៉ាឡេស៊ីទៀតផង ។

ជនជាតិចាមអ៊ីម៉ាំសាន់វិញកំពុងតែប្រឈមមុខនឹងការ

លំបាកជាខ្លាំង ដោយសារតែសមាជិករបស់ខ្លួនជាច្រើនបានប្រែក្រឡប់ទៅចូលក្រុមមូស្លីមទំនើប ហើយប្រវត្តិសាស្ត្ររបស់ក្រុមអ៊ីម៉ាំសាន់ហាក់បីដូចជាកំពុងតែជួបគ្រោះថ្នាក់ ។ ដោយសារតែប្រទេសផ្សេងៗជាច្រើននៃពិភពលោកពុំទទួលស្គាល់ថាជនជាតិចាមអ៊ីម៉ាំសាន់ជាជនមូស្លីមពិតប្រាកដ ហេតុដូច្នេះសហគមន៍នេះកំពុងតែជួបប្រទះការខ្វះខាតផ្នែកមូលនិធិនិងកំពុងតែមានការស្រុតចុះយ៉ាងខ្លាំង ។ ជាការចាំបាច់ណាស់ក្នុងការជួយថែរក្សាសហគមន៍ចាមមួយនេះឲ្យនៅរស់រានមានជីវិត ព្រោះសហគមន៍នេះជាសហគមន៍ចាមតែមួយគត់ដែលនៅតែប្រតិបត្តិប្រពៃណីរបស់ចម្ប៉ា និងថែរក្សាប្រវត្តិសាស្ត្ររបស់ចម្ប៉ា ។ យើងមានសង្ឃឹមយ៉ាងមុតមាំថា ថ្ងៃណាមួយសហគមន៍នេះនឹងមានការលូតលាស់ឡើងវិញជាមិនខាន ។

**អ៊ីសាក់ ថេប័រ**

# ពេជ្រ កល្យាណៈ អតីតអ្នកទោសគុកសង់


ពេជ្រ កល្យាណ

*ក្នុងឋានៈជាជំទប់ទី១ឃុំទៀន ខេត្តកណ្តាល ពេជ្រ កល្យាណ មើលទៅរឹងប៉ឹងនិងម៉ឺងម៉ាត់ ក៏ប៉ុន្តែតាមពិតនៅពីក្រោយភាពរឹងប៉ឹងនោះគឺការឈឺចាប់និងតក់ស្លុតដែលបន្សល់ទុកពីរបបខ្មែរក្រហម ដែលបានក្លាយជាដំបៅនៅក្នុងចិត្តរបស់គាត់ ។ ខ្ញុំបានទៅជួបសំណេះសំណាលនិងធ្វើសម្ភាសន៍គាត់អស់រយៈពេលជាង២ម៉ោង ។ ដោយគ្មានការលាក់លៀម កល្យាណ បានរ៉ាយរ៉ាប់ប្រាប់ខ្ញុំអំពីដំណើរជីវិតរបស់គាត់ ។*

កល្យាណ មានស្រុកកំណើតនៅភូមិឈើទាល ឃុំកំពង់លួយ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។ នៅឆ្នាំ១៩៧៣ កល្យាណ បានមករស់នៅទីក្រុងភ្នំពេញនិងបានបន្តការសិក្សានៅក្រុងតាខ្មៅ ។ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កល្យាណ ត្រូវខ្មែរក្រហមជម្លៀសចេញពីទីក្រុងភ្នំពេញជាមួយនឹងប្រជាជនដទៃទៀត ហើយបានធ្វើដំណើរទៅស្រុកកំណើតវិញ ។ មកដល់ស្រុកកំណើត កល្យាណ ត្រូវអង្គការបញ្ជូនទៅធ្វើការក្នុងកងចល័តនារី ។

នៅឆ្នាំ១៩៧៧ អង្គការបានបញ្ជូន កល្យាណ និងនារី២១ នាក់ទៀត ទៅគុកសង់ ដោយប្រាប់ថាឲ្យទៅធ្វើបន្លែនៅសហករណ៍មួយទៀត ។ កល្យាណ រំឭកថា *"ខ្ញុំខំយកកាំបិតយកខោអាវអីទៅ គេប្រាប់ថាមិនបាច់យកកាំបិតយកខោអាវទៅទេ កន្លែងសហករណ៍ហ្នឹងមានគ្រប់ហើយ ។ តើទៅធ្វើបន្លែយ៉ាងម៉េចសូម្បីតែខោអាវក៏មិនបាច់យកទៅដែរនោះ?"* គាត់បន្ថែមទៀតថា *"មូលហេតុដែលគេចាប់ខ្ញុំយកទៅសង់គឺគេស្រាវជ្រាវតាមខ្សែតែម្តង"* ។ គួរបញ្ជាក់ថា បងប្រុសពីរនាក់របស់ កល្យាណ ក៏ត្រូវខ្មែរក្រហមយកទៅសម្លាប់នៅគុកសង់នៅក្នុងឆ្នាំ១៩៧៦ ដោយសារគាត់ធ្លាប់ធ្វើជាគ្រូបង្រៀន ។ កល្យាណ បានឮដំណឹងអំពីការស្លាប់របស់បងប្រុសទាំងពីរនេះនៅពេលដែលខ្លួនគាត់ផ្ទាល់បានចូលទៅដល់គុកសង់ និងបានឮអ្នកដែលជាប់នៅទីនោះនិយាយប្រាប់ ។

នៅក្នុងគុកសង់ កល្យាណ ជួបហេតុការណ៍ជាច្រើនដែលគាត់នឹកស្មានមិនដល់ ។ គាត់រៀបរាប់ថា *"កាលទៅគុកសង់ដំបូងខ្ញុំមានអារម្មណ៍ដូចជាអស់មានព្រលឹង ខ្ញុំដឹងតែខ្ញុំងាប់បាត់ហើយ ព្រោះខ្ញុំមិនដែលឃើញសភាពបែបហ្នឹង"* ។ អ្នកទោសនៅគុកសង់មានរាងកាយស្គមស្គាំង ដៃជើងវែងៗ ហើយដកករហង់មើលទៅហាក់បីដូចជាខ្មោច ។ បន្ទប់ឃុំឃាំងទៀតសោតក៏កខ្វក់ ពាងដុកលាមកនិងទឹកនោមចោលក្លិនអសោចផ្អេះផ្អាបយ៉ាងពិបាកទ្រាំ ។ កល្យាណ រៀបរាប់បន្តទៀតថា ថ្ងៃដំបូង គាត់មិនមានចាននិងស្លាបព្រាដើម្បីទទួលរបបបបរាវៗមួយកានោះទេ ហេតុនេះគាត់ត្រូវទ្រាំអត់អាហារមួយថ្ងៃ ទម្រាំតែចុងភៅចែកចាននិងស្លាបព្រាឲ្យគាត់ ។ នៅពេលយប់ កល្យាណ មិនមានកន្លែង

សម្រាកក្នុងផ្លូវដូចអ្នកទោសឯទៀតទេ ព្រោះក្នុងបន្ទប់គុកនោះមានអ្នកទោសច្រើនពេកដេកតម្រៀបជួរអស់កន្លែងទៅហើយ ដូច្នេះគាត់ត្រូវដេកនៅតាមប្រឡោះជើងអ្នកផ្សេង ។ ប្រហែលមួយខែក្រោយមកទើបគាត់រកបានប្រឡោះទំនេរដើម្បីដេកក្នុងជួរដោយសារមានអ្នកទោសខ្លះស្លាប់ហើយត្រូវយកចេញ ។

រស់នៅក្នុងគុក កល្យាណ ត្រូវទ្រាំជាមួយនឹងការហេវហត់ដោយសារតែរបបទទួលទានមិនគ្រប់គ្រាន់ ត្រូវទ្រាំទាំងក្លិនលាមក ទាំងក្លិនមនុស្សនិងសត្វល្អិតដែលមាននៅពាសពេញបន្ទប់ ។ កល្យាណ បញ្ជាក់ថា «ចៃឡើងពេញចង្កេះខោពេញខ្លួនចៃមនុស្សណា៎» ។ ជារៀងរាល់ថ្ងៃ កល្យាណ ត្រូវឆ្មាំបញ្ចេញពីក្នុងគុកឲ្យទៅធ្វើការងារផ្សេងៗដូចជា បាចទឹកដាក់ស្រែ កាប់ឫស្សី ឬស្ទូងស្រូវជាដើម ។

កល្យាណ បានរៀបរាប់អំពីសភាពគុកថា មានអគារធំៗជាច្រើននៅក្នុងបរិវេណគុក ។ អគារដែលគាត់ជាប់ឃុំមានអ្នកទោសរាប់រយនាក់ ។ អ្នកទោសស្រាលៗត្រូវខ្មែរក្រហមដាក់ឲ្យនៅរួមគ្នា អ្នកទោសស្រីមួយបន្ទប់និងអ្នកទោសប្រុសមួយបន្ទប់ ។ អ្នកទោសស្រីមិនត្រូវបានដាក់ច្រវាក់ជើងឬដៃដូចអ្នកទោសប្រុសទេ ។ អ្នកទោសប្រុសត្រូវឆ្មាំដាក់ខ្នោះជើងជាប់គ្នាពីរនាក់ៗ ។ នៅពេលដើរទៅណាឬធ្វើការងារអ្វីមួយគឺត្រូវទៅឬធ្វើទាំងពីរនាក់ ។ ក្រៅពីអ្នកទោសដែលនៅក្នុងបន្ទប់រួមនៅមានអ្នកទោសផ្សេងទៀតដែលជាប់ដោយឡែកក្នុងបន្ទប់តូចៗទំហំមួយម៉ែត្រការ៉េ ដែលត្រូវដាក់ច្រវាក់ជើងដៃឲ្យឈរនៅក្នុងបន្ទប់តូចនោះរហូតដល់ស្លាប់ ។ អ្នកទាំងនោះគឺសុទ្ធតែអ្នកជាប់ទោសធ្ងន់ ។

នៅខែមករា ឆ្នាំ១៩៧៩ ពេលដែលកងទ័ពវៀតណាមវាយលុកចូលមកដល់ទីក្រុងភ្នំពេញ កល្យាណ មិនបាននៅក្នុងអគារគុកទេ គឺគាត់កំពុងតែច្រូតស្រូវនៅកោះកណ្តឹង ហើយក៏មិនបានដឹងថាសភាពការណ៍ស្រុកទេសបានផ្លាស់ប្តូរដែរ រហូតទាល់តែប្រធានសហករណ៍កណ្តឹងប្រាប់ទើបគាត់ដឹង ហើយវិលត្រឡប់មកស្រុកកំណើតវិញ ។ គាត់បានរៀបការនៅឆ្នាំ១៩៧៩ ហើយបច្ចុប្បន្ននេះមានកូនប្រុស២នាក់ ស្រី៣នាក់ ។

ការស្លាប់របស់ឪពុកម្តាយនិងបងប្រុស២នាក់របស់ កល្យាណ និងបទពិសោធន៍ឈឺចាប់ដែលគាត់បានជួបផ្ទាល់ បានបណ្តាលឲ្យគាត់ក្លាយជាមនុស្សដែលមានផ្លូវចិត្តមិនប្រក្រតី ។ គាត់យល់សប្តិអាក្រក់ជារឿយៗ ។ ជាងនេះទៅទៀត គាត់ឆាប់ភ័យតក់ស្លុតភ្លេចភ្លាំងច្រើន និងមានអារម្មណ៍ដូចត្រូវបោះបង់ចោល ។ បន្ទាប់ពីបានជជែកជាមួយខ្ញុំអំពីរឿងរ៉ាវកន្លងមកគាត់ហាក់ដូចជាសប្បាយចិត្តបន្តិចនិងមានអារម្មណ៍ថាមានអ្នកយកចិត្តទុកដាក់ចំពោះគាត់ដែរ ។


កំនរឆ្អឹងជនរងគ្រោះនៅក្នុងគុកសង់ក្រោយឆ្នាំ១៩៧៩

តាមរយៈការធ្វើសម្ភាសន៍និងការវិភាគស្ថានភាពផ្លូវចិត្តរបស់ កល្យាណ ក្រុម“ជួយជនរងគ្រោះដោយអំពើទារុណកម្មពីរបបខ្មែរក្រហម”របស់មជ្ឈមណ្ឌលឯកសារកម្ពុជាសន្និដ្ឋានថា គាត់គួរតែទទួលបានសេវាពិគ្រោះនិងព្យាបាលផ្លូវចិត្តពីអ្នកជំនាញផ្នែកចិត្តសាស្ត្រដើម្បីឲ្យសុខភាពផ្លូវចិត្តរបស់គាត់បានប្រសើរឡើងវិញ ។

**ស៊ុំ សាឌីណា**

អ្នកទោសនៅមន្ទីរស-២១



# អ្នកទោសគុកក្រាំងតាចាន់: សយ សែន

គុកក្រាំងតាចាន់មានទីតាំងលើទួលមួយក្នុងភូមិក្រាំងតាចាន់ ឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ ។ គុកនេះគឺជាផ្នែកមួយនៃការកាន់កាប់និងដឹកនាំរបស់សមមិត្ត ឈិត ជឿន ហៅ ម៉ុក ដែលជាលេខាភូមិភាគនិរតី ។ តាមការស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ប្រជាជនចំនួន១៣ពាន់៤៥នាក់ត្រូវឃុំឃាំង ធ្វើទារុណកម្ម និងសម្លាប់ចោលនៅក្នុងគុកនេះ ។


សយ សែន

សយ សែន ជាជនរងគ្រោះម្នាក់ដែលធ្លាប់ជាប់ឃុំឃាំងនៅគុកក្រាំងតាចាន់តាំងពីឆ្នាំ១៩៧៤ រហូតដល់ការរលំរលាយនៃរបបខ្មែរក្រហមក្នុងឆ្នាំ១៩៧៩ ។ សែន ត្រូវបានខ្មែរក្រហមចាប់ឃុំឃាំងដោយសារតែមានឪពុកជាចៅហ្វាយស្រុកក្នុងរបបលន់ណុល ។

សែន ត្រូវឈ្លបខ្មែរក្រហមដាក់ខ្នោះដៃនិងជើងទាំងសងខាង ។ ៣ខែក្រោយមក ឈ្លបបានដោះខ្នោះឲ្យ សែន ចេញទៅឃ្វាលក្របីនៅពេលថ្ងៃ ហើយចូលក្នុងគុកនិងដាក់ខ្នោះវិញនៅពេលយប់ ។ យូរៗទៅឈ្លបទុកចិត្ត សែន ក៏អនុញ្ញាតឲ្យ សែន ទៅដេកនៅឯចង្ក្រានបាយជាមួយអ្នកទោសម្នាក់ទៀតឈ្មោះ តាចិន ។

នៅឆ្នាំ១៩៧៥ ខ្មែរក្រហមបានសម្លាប់អ្នកទោសនៅក្នុងគុកនៅកាន់តែច្រើន ហើយក៏យកអ្នកទោសថ្មីចូលកាន់តែច្រើនដែរ ។ សែន ត្រូវបានឈ្លបអនុញ្ញាតឲ្យនៅក្រៅគុកមួយរយៈដើម្បីជីករណ្តៅសម្រាប់កប់សពអ្នកទោស ។ សែន បាននិយាយថា *“នៅឆ្នាំ១៩៧៥ វា[ខ្មែរក្រហម] វៃសម្លាប់កាន់តែច្រើន វាទុកចិត្តឲ្យខ្ញុំនៅកាប់រណ្តៅកាប់អីសម្រាប់កប់[សាកសព]ឲ្យវា អីចឹងទៅកាប់រណ្តៅមានធំមានតូច មានទទឹង២ម៉ែត្របណ្តោយ៤ម៉ែត្រ ទទឹង៤ម៉ែត្របណ្តោយ៥ម៉ែត្រក៏មាន វាវៃម្តងអីចឹងទៅដាក់នៅបាតជ្រៅដល់ពេលវាសម្លាប់ហើយអីចឹង វាលុបដីមួយសាដល់វៃក្រោយមកវាលុបមួយសាទៀត”* ។

អតីតកម្មាភិបាលខ្មែរក្រហមម្នាក់នៅគុកក្រាំងតាចាន់ ឈ្មោះ សាំង បាននិយាយថា *“នៅពាក់កណ្តាលឆ្នាំ១៩៧៥ អ្នកទោសត្រូវនាំចូលមកសម្បើមណាស់ យប់ក៏ដូចថ្ងៃថ្ងៃក៏ដូចយប់ អត់បានដេកទេ”* ។

សែន បានឃើញពេជ្ឈឃាតនៅគុកក្រាំងតាចាន់សម្លាប់មនុស្សដោយផ្ទាល់នឹងភ្នែក ។ មុននឹងសម្លាប់អ្នកទោសខ្មែរក្រហមបានចាក់មេក្រូឲ្យឮសំឡេងសន្ធប់ពេញគុកដើម្បីកុំឲ្យសម្រែករបស់អ្នកទោសឮដល់ប្រជាជន បន្ទាប់មកពេជ្ឈឃាតចាប់ផ្តើមយកអ្នកទោសម្តង២ឬ៣នាក់ចេញពីគុកទៅសម្លាប់ ។ សែន បាននិយាយថា ពេលយកអ្នកទោសទៅសម្លាប់ ពេជ្ឈឃាតបានបោកបញ្ឆោតថាឲ្យវិលត្រឡប់ទៅសហករណ៍វិញ ។ ពាក្យថា “វិលត្រឡប់ទៅសហករណ៍វិញ” ធ្វើអ្នកទោសរីករាយយ៉ាងខ្លាំង អ្នកខ្លះនាំគ្នាទះដៃលាន់រំពងពេញគុក ប៉ុន្តែតាមការពិតអ្នកទោសទាំងនោះត្រូវយកទៅសម្លាប់ទាំងអស់ ។ ខ្មែរក្រហមចងស្លាបសេកនិងចងមុខអ្នកទោសនាំទៅដល់កន្លែងសម្លាប់ ហើយឲ្យអ្នកទោសអង្គុយ ។ បន្ទាប់មក ពេជ្ឈឃាតប្រើត្បូងចបវាយកញ្ចឹងកអ្នកទោស ។ ពេលដែលអ្នកទោសដួលផ្កាប់មុខលើដី ពេជ្ឈឃាតបានធាក់ប្រមៀលអ្នកទោសឲ្យផ្ងារ ហើយយកដាវវែងមួយកាត់ផ្តាច់បំពង់កថែមទៀតរួចទើបអូសទម្លាក់រណ្តៅ ។ សែន បាននិយាយថា *“ដូនកាលវា [ពេជ្ឈឃាត] អស់កម្លាំង វាហៅខ្ញុំហើយនិង តាចិន ឲ្យទៅអូសខ្មោចដាក់រណ្តៅហើយលុបដី”* ។ តាមសម្តីរបស់ សែន សូម្បីតែអ្នកទោសដែលបានចូលមកទីនេះមានកំហុសបន្តិចបន្តួចដូចជា លួចដូង លួចដំឡូងក្នុងសហករណ៍ លួចដឹកទឹកត្នោត ធ្វើឲ្យបាក់ស្លាបព្រា បាក់បង្គី ។ល ។ ក៏ត្រូវសម្លាប់ទាំងអស់ ។

សែន រួចជីវិតពីការសម្លាប់របស់ឈ្លបគុកក្រាំងតាចាន់ដោយសារគាត់ចេះរបៀបធ្វើទឹកត្នោតជូរ ។ តាអាន់ មេគុកក្រាំងតាចាន់ បានប្រើឲ្យ សែន ឡើងធ្វើទឹកត្នោតជូរមិនថាយប់ឬថ្ងៃទេ ។ សែន បានបញ្ជាក់ថា ពេលណាដែល តាអាន់ មកពីសម្លាប់


គំនរឆ្អឹងជនរងគ្រោះនៅក្នុងគុកក្រាំងតាចាន់

មនុស្សអស់កម្លាំង គាត់បានប្រើ សែន ឲ្យទៅឡើងយកទឹកត្នោត ទោះបីជាពាក់កណ្ដាលយប់ក៏ដោយ ។ ពេលខ្លះ សែន កំពុងតែនៅលើចុងត្នោត គាត់បានឃើញពេជ្ឈឃាតខ្មែរក្រហមកំពុងតែអារ-កកុមារតូចៗ ប៉ុន្តែពេជ្ឈឃាតទាំងនោះមិនបានដឹងថា សែន នៅលើចុងត្នោតទេ ។ សែន និយាយថា «បើក្មេងៗតូចៗ វាអត់មានវ៉ៃទេ វាអារ-កតែម្ដង អារ-កហើយវះពោះយកប្រមាត់ទៅដាក់ស្រាផឹកទៀត» ។

ឪពុករបស់ សែន ក៏ត្រូវខ្មែរក្រហមសម្លាប់នៅគុកក្រាំងតាចាន់ដែរ ។ សែន នៅចាំថា មុនពេលយកឪពុករបស់គាត់ទៅសម្លាប់ ពេជ្ឈឃាតបានប្រើឲ្យ សែន ទៅរោងគោមួយនៅខាងលិចគុកដើម្បីទៅកើបអាចម៍គោ តែតាមការពិតពេលនោះ ឈ្លបគ្រាន់តែយកឱកាសនោះដើម្បីយកឪពុករបស់គាត់ទៅសម្លាប់តែប៉ុណ្ណោះ ។ សែន ត្រឡប់មកពីកើបអាចម៍គោវិញ ពេលដែលពេជ្ឈឃាតបានសម្លាប់ឪពុកគាត់និងអូសសាកសពទម្លាក់រណ្ដៅរួចទៅហើយ ។ សែន បានដោះយកសម្លៀកបំពាក់ពីសពឪពុកគាត់មកបោកគក់ដើម្បីប្រើខ្លួនឯង ។ សែន និយាយថា «វា[ពេជ្ឈឃាត] ប្រើខ្ញុំឲ្យទៅកើបអាចម៍គោ តែវាយកឪពុកខ្ញុំចេញទៅសម្លាប់» ។ កាលនោះ សែន មិនអាចទប់អារម្មណ៍ខ្លួនឯងបានក៏សួរទៅ សាំង ថា «បងសាំងដូចខ្ញុំអីគេអាចសម្លាប់ទេបង?» សាំង ឆ្លើយថា «ហ្អែងនៅឲ្យស្ងៀម គេឲ្យរស់ហើយ ហ្អែងរស់ឲ្យស្ងៀម បើគេឲ្យងាប់ងាប់បាត់ទៅហើយហ្អែង» ។

ក្រៅពីការយកទៅសម្លាប់ អ្នកទោសនៅក្នុងគុកក្រាំងតាចាន់ស្លាប់ពី៥ ទៅ ៦នាក់ជារៀងរាល់ថ្ងៃដោយសារខ្វះអាហារនិងទឹកនិងទារុណកម្មសួរចម្លើយ ។ មិនតែប៉ុណ្ណោះ បរិយាកាសនៅក្នុងគុកក្រខ្វក់ជាខ្លាំង ។ មានសង្កើចជាច្រើន ចៃកើតចេញពីសាច់មនុស្សដែលមិនបានងូតទឹកជាច្រើនថ្ងៃ ។ ឈ្លបមិនអនុញ្ញាតឲ្យអ្នកទោសដេករើខ្លួនទេ ទោះបីជាមានសង្កើចខាំក៏ដោយ ។ សែន រំឭកថា «ដេកមិនឲ្យរើយ៉ាងម៉េច បើសង្កើចដូចគេក្រាល ញីតែមួយដៃៗមិនដឹង


បូជនីយដ្ឋាននៅភូមិក្រាំងតាចាន់ ខេត្តតាកែវ

ជាផាប់សង្កើចប៉ុន្មានម៉ឺនទេ ។ និយាយពីចៃ ចៃនោះមិនមែនចៃក្បាលទេ ចៃសាច់មនុស្សតែម្តង សាច់ម្នាក់ៗសង្កៀរអស់ហើយនរណាក៏ដូចនរណាដែរ មិនថាគេមិនថាខ្ញុំទេ ។ អ្នកទោសមិនតិចទេដែលមានជំងឺនិងស្លាប់ដោយសាររស់នៅជាមួយចៃនិងសង្កើច» ។

អ្នកទោសខ្លះលួចរត់នៅពេលដែលឆ្មាំគុកដោះលែងឲ្យធ្វើការនៅខាងក្រៅ ប៉ុន្តែឆ្មាំគុកដេញបាញ់សម្លាប់ចោល ។ ពេលបាញ់សម្លាប់រួចហើយ ឆ្មាំគុកប្រើ សែន ឲ្យសែងសាកសពយកទៅបោះចោល ។ មានពេលមួយពេជ្ឈឃាតម្នាក់ឈ្មោះឌុច បានចាប់រំលោភក្មេងស្រីម្នាក់ រួចសម្លាប់ចោលទាំងខ្លួនអាក្រាតហើយបញ្ជាឲ្យ សែន អូសសាកសពយកទៅចោល ។

ជារៀងរាល់យប់ សែន បានឃើញខ្មែរក្រហមបណ្តើរអ្នកទោសទាំងខ្សែៗចូលក្នុងគុកក្រាំងតាចាន់ ។ ក្នុងមួយខ្សែៗមានអ្នកទោសប្រហែលពី២០ទៅ៥០នាក់ ។ សែន បន្ថែមថា ពេលខ្លះ ជួរអ្នកទោសមានប្រវែងរហូតដល់១០០ម៉ែត្រឯណោះ ។ កងការពារដែលមានកាំភ្លើងគ្រប់ដៃ បានដើរពីមុខពីក្រោយនិងអមសងខាងជួរអ្នកទោស ។

នៅក្នុងគុក សែន មានសិទ្ធិនិងដើរហើរច្រើនជាងអ្នកទោសដទៃ ដោយសារពេលនោះ សែន នៅក្មេងជាងគេផង និងចេះធ្វើទឹកត្នោតជូរឲ្យ តាអាន់ ផង ប៉ុន្តែគាត់នៅតែហូបបបររាវៗដូចជាអ្នកទោសដទៃទៀតដែរ ។ សែន ដើរទៅគ្រប់កន្លែងទាំងអស់ដូចជាកន្លែងសម្លាប់ កន្លែងសួរចម្លើយ បន្ទប់គុកងងឹតជាដើម ។ កិច្ចការរបស់ សែន ពេលនោះគឺ មើលក្របី ជីករណ្តៅសម្រាប់កប់អ្នកទោស ធ្វើទឹកត្នោតជូរ សែងទឹកនោមនិងលាមកអ្នកទោសទៅចាក់ចោលនៅពេលព្រឹក ។ គាត់បានរួចពីគុកក្រាំងតាចាន់នៅពេលដែលរបបខ្មែរក្រហមដួលរលំនៅខែមករា ឆ្នាំ១៩៧៩ ។

សព្វថ្ងៃ សែន មានអាយុ៤៣ឆ្នាំហើយ ។ គាត់រស់នៅស្រុកត្រាំកក់ ខេត្តតាកែវ ។ អតីតពេជ្ឈឃាតប៉ុន្មាននាក់នៅគុកក្រាំងតាចាន់ក៏នៅមានជីវិតនិងរស់នៅយ៉ាងសុខដុមរមនាក្នុងចំណោមអ្នកភូមិទាំងឡាយដែលជាសាច់ញាតិរបស់ជនរងគ្រោះ ។ សែន មិនចង់ជួបអតីតពេជ្ឈឃាតទាំងអស់នោះទេ ព្រោះរាល់ពេលដែលគាត់ឃើញអ្នកទាំងនោះ គាត់នឹកឃើញដល់រឿងរ៉ាវនៅក្នុងរបបខ្មែរក្រហម នឹកឃើញដល់ការស្លាប់របស់ឪពុកគាត់ នឹកឃើញដល់ទុក្ខលំបាកវេទនាដែលគាត់បានជួបប្រទះស្ទើរតែគ្មានសល់ជីវិតរស់ ។

សែន មិនត្រឹមតែចង់ឲ្យតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមតែប៉ុណ្ណោះទេ គាត់ថែមទាំងចង់ឲ្យកាត់ទោសជនដៃដល់ថ្នាក់ក្រោមផង ។ ជាងនេះទៅទៀតគាត់ចង់ឲ្យខ្មែរក្រហមឆ្លើយនឹងសំណួររបស់គាត់ថាហេតុអ្វីបានជាសម្លាប់មនុស្សរាប់សែនរាប់លាននាក់ដូច្នេះ?

**ញាណ សុជាតិ**

# សេចក្តីជូនដំណឹងស្តីអំពីការបើកឱ្យប្រើប្រាស់ ការិយាល័យពត៌មានសាធារណៈ របស់មជ្ឈមណ្ឌលឯកសារកម្ពុជា

ការិយាល័យពត៌មានសាធារណៈរបស់មជ្ឈមណ្ឌលឯកសារកម្ពុជានឹងចាប់បើកទ្វារបម្រើសាធារណជនពីថ្ងៃនេះតទៅ ។ ការិយាល័យពត៌មានសាធារណៈគឺជាទីតាំងសម្រាប់អានឯកសារដែលទាក់ទងនឹងរបបខ្មែរក្រហម ទស្សនាខ្សែភាពយន្តឯកសារខ្មែរក្រហម និងចូលរួមកម្មវិធីពិភាក្សាជាមួយអ្នកច្បាប់និងអ្នកសិក្សាស្រាវជ្រាវអំពីប្រធានបទខ្មែរក្រហមយុត្តិធម៌និងការផ្សះផ្សាបង្រួបបង្រួមជាតិ និងប្រធានបទដទៃទៀត ។ ទិសដៅសំខាន់ពីររបស់ការិយាល័យពត៌មានសាធារណៈគឺ ១) ផ្តល់ពត៌មាននិងអប់រំប្រជាជនខ្មែរអំពីរបបខ្មែរក្រហម ២) ផ្សព្វផ្សាយពត៌មានអំពីដំណើរការអង្គជំនុំជម្រះក្តីអតីតមេដឹកនាំខ្មែរក្រហមជូនសាធារណជនឲ្យបានទូលំទូលាយ ។

ការិយាល័យពត៌មានសាធារណៈរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាមានទីតាំងនៅផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ។ ពត៌មានបន្ថែមស្តីអំពីការិយាល័យពត៌មានសាធារណៈ សូមទាក់ទង **សុភ្វា អ៊ីវ៉ាន** ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។

សូមអរគុណ ។

# តុលាការអន្តរជាតិលាតត្រដាងអំពីការកាត់ទោសដំបូងចំនួនបីនៅក្នុង "តុលាការពិសេសសម្រាប់ការរំលោភសិទ្ធិមនុស្សនៅទីម័រខាងកើត"

***(តចប់)***

***ខ-៣) ការការពារ***

ប្រព័ន្ធច្បាប់របស់ប្រទេសឥណ្ឌូនេស៊ីជាប្រព័ន្ធច្បាប់ស៊ីវិល ដែលចៅក្រមមានសកម្មភាពក្លៀវក្លា និងមិនគ្រាន់តែជាអាជ្ញាកណ្តាលសម្រាប់រកការពិតប៉ុណ្ណោះទេ ។ ទោះជាយ៉ាងណាក៏ដោយ រដ្ឋអាជ្ញាត្រូវតែបង្ហាញភស្តុតាងនៅក្នុងការចោទប្រកាន់ជនជាប់ចោទ ។ គុណភាពនៃការការពារនៅក្នុងសំណុំរឿងក្តីទាំងបីនេះមានភាពអន់ខ្សោយយ៉ាងខ្លាំង ។ រដ្ឋអាជ្ញាមិនបានបញ្ជាក់ពីបំណងបង្ហាញភស្តុតាង និងមិនបានដេញដោលសាក្សីទាំងឡាយដែលធ្វើឲ្យខូចសំណុំរឿងក្តី សូម្បីតែអ្វីដែលបាននិយាយរួចមកហើយមិនស្របគ្នាជាមួយនឹងកសិណដែលសាក្សីបានផ្តល់ពីពេលមុន និងដែលបានក្លាយជាចំណែកមួយនៅក្នុងសំណុំឯកសាររួចហើយក៏ដោយ ។

ឧទាហរណ៍ មានប៉ូលិសម្នាក់នៅសួយបានអះអាងនៅក្នុងតុលាការថា គាត់មិនបានស្គាល់កងជីវពលឡាក់សូពីមុនមកទេ ក្រោយពីមានការសម្លាប់រង្គាលនៅឯព្រះវិហារទើបគាត់ស្គាល់ក្រុមនេះ ។ មេប៉ូលិសនៅទីម័រខាងកើត (ធីមប៊ុល ស៊ីឡែន) បានអះអាងថា គាត់បានណែនាំឲ្យប៉ូលិសឃ្លាំមើលកងជីវពលមូលដ្ឋាន ហើយបានបន្ថែមទៀតថា មានព័ត៌មានជាច្រើនអំពីបញ្ហាដែលឡាក់សូបានបង្កឡើងនៅសួយនៅក្នុងរយៈពេលមុនការធ្វើប្រជាមតិ ។ រដ្ឋអាជ្ញាមិនបានចោទសួរ ធីមប៊ុល ស៊ីឡែន អំពីការផ្លាស់ប្តូរសក្ខីកម្ម និងអំពីការអះអាងជាថ្មីថាមិនបានស្គាល់ពួកកងជីវពលសោះ ។ រដ្ឋអាជ្ញាក៏មិនបានបញ្ជូនមនុស្សទៅស៊ើបសង្កេតអំពីកងជីវពលឡាក់សូនិងមេដឹកនាំក្នុងអំឡុងមុនពេលធ្វើប្រជាមតិ ដើម្បីដេញដោលចំពោះការអះអាងរបស់មេប៉ូលិសមូលដ្ឋាននៅសួយដែលនិយាយថាគាត់មិនបានដឹងថាតើនៅពេលនោះអ្នកទាំងនោះជានរណា ។ សាក្សីនេះជាប្រភពភស្តុតាងតែមួយគត់សម្រាប់ការចោទប្រកាន់ដែលថាអភិបាលស្តីទីបានបង្កើតនិងពង្រីកកងជីវពលឡាក់សូនៅសួយ (ច្បាប់របស់ប្រទេសឥណ្ឌូនេស៊ីតម្រូវឲ្យមានភស្តុតាងប្រភេទនេះចំនួនពីរ) ។

នៅក្នុងករណីទាំងបី ការអះអាងជារឿយៗដែលគ្មានអ្នកណាដេញដោលគឺថា មិនអាចបែងចែកគ្នាឲ្យដាច់រវាងប្រជាជនទីម័រខាងកើត ។ មេប៉ូលិសនៅសួយជាមនុស្សម្នាក់ដែលអះអាងពីភាពដាច់លាក់នៃកំណត់ហេតុតាំងពីដើមដំបូងនៃការផ្តល់កសិណផ្ទាល់មាត់ ។ នៅក្នុងកិច្ចសម្ភាសន៍លើកដំបូង មេប៉ូលិសរូបនេះមិនមានបញ្ហាក្នុងការបែងចែកឲ្យដាច់គ្នារវាងក្រុមគាំទ្រសមាហរណកម្មនិងក្រុមប្រឆាំងសមាហរណកម្មឡើយ ។ ឧទាហរណ៍ គាត់បាននិយាយថា "ខ្ញុំបានប្រញាប់ប្រញាល់ចុះទៅព្រះវិហារនៅពេលមានឮសំឡេងគ្រាប់កាំភ្លើង ហើយខ្ញុំបានឈប់ពីចម្ងាយដោយសារខ្ញុំឃើញហ្វូងមនុស្សប្រមូលផ្តុំគ្នា ។ ក្រុមគាំទ្រស្វ័យភាពបានចូលទៅក្នុងព្រះវិហារហើយស្រែកដែលខ្ញុំមិនអាចយល់បាន ។ ...ឃើញបែបនោះ ខ្ញុំបានបញ្ជាឲ្យបុគ្គលិករបស់ខ្ញុំការពារប្រជាជន និងនាំប្រជាជនទៅរកកន្លែងជ្រកកោននៅ MAKODIM ឬនៅ *POLRES* ។ ដូច្នេះក្រុមអ្នកគាំទ្រស្វ័យភាពមិនមានឱកាសចាប់បង្ខំស្ត្រីទេ ។" ទោះបីជាយ៉ាងណាក៏ដោយ នៅពេលដែលគាត់បានផ្តល់កសិណនៅក្នុងរឿងក្តីមេបញ្ជាការរបស់គាត់ឈ្មោះ ធីមប៊ុល ស៊ីឡែន គាត់បែរជានិយាយថាមិនអាចកំណត់អត្តសញ្ញាណក្រុមនីមួយៗបាន ។ គាត់គ្រាន់តែនិយាយថាមានពីរក្រុមនៅសួយ ។ ចៅក្រមចាប់បាននូវចំណុចមិនស្របគ្នានេះ ប៉ុន្តែមិនបានដេញដោល ។ រដ្ឋអាជ្ញាបានសួរសាក្សីថាតើគាត់អាចកំណត់អត្តសញ្ញាណប្រជាជននៅខាងក្រៅព្រះវិហារបានឬអត់ សាក្សីឆ្លើយថាកំណត់មិនបាន ដោយសារតែពេលពេលនោះមានប្រជាជនច្រើនសន្ធឹកសន្ធាប់ពេក ។ រដ្ឋអាជ្ញាមិនបានដេញ

ដោលសាក្សីអំពីភាពមិនស្របគ្នានៅត្រង់ចំណុចនេះទេ។ សាក្សីបានប្រាប់ក្រុមអ្នកស៊ើបអង្កេតថា «ខ្ញុំមិនអាចវាយតម្លៃបានថាតើអ្នកទាំងនោះជាក្រុមគាំទ្រសមាហរណកម្មឬក្រុមគាំទ្រស្វ័យភាពទេ»។ តាមពិតមានរូបថតដ៏ច្រើនសន្ធឹកសន្ធាប់ដែលបានមកពីប្រព័ន្ធឃោសនានិងអ្នកអង្កេតការបោះឆ្នោតអន្តរជាតិនៅប៉ុន្មានខែមុនពេលឈានទៅដល់អំពើបំផ្លិចបំផ្លាញ។ រូបថតទាំងនោះបង្ហាញថា ក្រុមនីមួយៗមានអត្តសញ្ញាណច្បាស់លាស់ដែលអាចបែងចែកដាច់ពីប្រជាជនធម្មតាបានយ៉ាងងាយស្រួល ឧទាហរណ៍ក្រុមមួយមានពាក់សញ្ញាសម្គាល់ក្រហមសនិងពាក់អាវយឺតដៃខ្លីមានផ្លាកឈ្មោះកងជីវពលនៅលើនោះ។ ជាមួយនឹងរូបថតបែបនោះ វាជាការងាយស្រួលណាស់សម្រាប់រដ្ឋអាជ្ញាដ៏វៃឆ្លាត។ ការអះអាងមួយផ្សេងទៀតគឺថា មិនមានអ្នកណាបំពាក់អាវុធឲ្យក្រុមអ្នកគាំទ្រសមាហរណកម្មទេ។ អ្វីដែលអ្នកទាំងនោះមានគឺកាំភ្លើងផលិតក្នុងស្រុក។ នៅគ្រប់ដំណាក់កាល រដ្ឋអាជ្ញាមិនបានដេញដោលទេ ទោះជាមានបញ្ជីអាវុធដែលរឹបអូសបានពីកងជីវពលនៅទីម័រខាងលិចនៅចុងឆ្នាំ២០០០ ឬមានការតវ៉ារបស់សហគមន៍អន្តរជាតិអំពីការប្រើប្រាស់អាវុធនៅក្នុងពេលត្រៀមរៀបចំការធ្វើប្រជាមតិក៏ដោយ។

តាមពិត សំណួរហាក់ដូចជាធ្វើឡើងដើម្បីទាញយកភស្តុតាងបញ្ជាក់អំពីភាពគ្មានកំហុសរបស់ជនជាប់ចោទ។ ឧទាហរណ៍មួយគឺរឿងក្តីសម្លាប់រង្គាលនៅឯព្រះវិហារស្វួយ។ សាក្សីលុដូហ្វីគូស អ៊ុលូម៉ាណែក គឺជាសមាជិកក្រុមធីអិនអាយ និងជាអ្នកក្រោមបង្គាប់របស់ជនជាប់ចោទ អាដម៉ាត យ៉ាមស៊ុឌីន។ ដោយមិនសួរសំណួរចំហអំពីបទបញ្ជា រដ្ឋអាជ្ញាបែរជាសួរថាតើជនជាប់ចោទមានបានបញ្ជាឲ្យការពារឬជួយអ្នករបួសឬស្លាប់ឬទេ។ សាក្សីប្រាកដជាឆ្លើយនូវចម្លើយដែលអាចព្យាករណ៍ទុកបានថា ពិតជាមានបញ្ជាមកពី យ៉ាមស៊ុឌីន ឲ្យជួយមនុស្សដែលជម្លៀសទៅកាន់ *KODIM* ទីបញ្ជាការយោធាស្រុក) ផ្តល់ដល់អ្នកទាំងនោះនូវការព្យាបាល និងឧបត្ថម្ភម្ហូបអាហារនិងសម្ភារៈផ្ទះបាយ។ អ្វីដែលគួរឲ្យចាប់អារម្មណ៍នោះគឺថារដ្ឋអាជ្ញាបានប្រព្រឹត្តខុសពីតួនាទី គឺសួរសំណួរដែលមិនពាក់ព័ន្ធនិងមិនចំចំណុច ពោលគឺមានចេតនាចៀសចេញពីបញ្ហាសំខាន់។ មានការផ្តោតអារម្មណ៍ជាពិសេសទៅលើក្រុមសន្តិសុខមូលដ្ឋានប៉ាមវ៉ាកាសាដែលធ្លាប់បានប្រឆាំងនឹងកងជីវពលដែលខេភីភីហាំបានកំណត់ថាត្រូវបានបង្កើតនិងគាំពារយ៉ាងពិសេសដោយអង្គភាពយោធា។ ទង្វើនេះបានងាកចេញពីអ្វីដែលគួរតែត្រួតពិនិត្យឲ្យបានល្អិតល្អន់ ដូចជាសំណួរថាតើកងជីវពលទាំងនេះជាអ្វីមកពីប្រភពណា តើនរណាខ្លះជាសមាជិករបស់កងជីវពល តើអ្វីជាកម្មវត្ថុរបស់កងជីវពល តើនរណាហ៊ឹកហ៊ឺន បំពាក់អាវុធនិងផ្តល់មូលនិធិដល់កងជីវពលទាំងនេះ តើកងជីវពលទាំងនេះនៅក្នុងរចនាសម្ព័ន្ធណា និងទទួលបញ្ជាពីនរណា។ល។ រដ្ឋអាជ្ញាបាននិយាយម្តងហើយម្តងទៀតសំដៅទៅលើកុបកម្មនិងជម្លោះរវាង«ភាគីទាំងពីរ» ជាជាងសំដៅទៅលើការវាយប្រហារប្រឆាំងជនស៊ីវិលដែលស្វែងរកការជ្រកកោននៅក្នុងព្រះវិហារ។ រដ្ឋអាជ្ញាបានសួរសំណួរដូចជា «តើអ្នកដឹងថានៅទីម័រខាងកើតមានភាគីជម្លោះចំនួនពីរ គឺក្រុមគាំទ្រសមាហរណកម្មនិងក្រុមគាំទ្រឯករាជ្យភាពឬទេ?»

ជាធម្មតា រដ្ឋអាជ្ញាសួរតែសំណួរនាំមុខប្រៀបដូចជាបបួលសាក្សីឲ្យយល់ស្របជាមួយខ្លួន។ គួរឲ្យអស់សំណើចណាស់ សំណួរទាំងអស់មិនផ្តោតការយកចិត្តទុកដាក់បង្ហាញទោសកំហុសរបស់ជនជាប់ចោទទេ បែរជាពិពណ៌នាអ្វីៗផ្សេងពីការប្រព្រឹត្តដែលស័ក្តិសមនឹងស្តីបន្ទោសទៅវិញ។ សាក្សីត្រូវបានបណ្តោយឲ្យដំឡើងបុកយ៉ាងយូរគ្មានអ្នកណាបញ្ឈប់។ គ្មានភស្តុតាងណាមួយត្រូវបានលើកឡើងដើម្បីបង្ហាញថាសាក្សីកំពុងតែនិយាយកុហកទេ។ ជាការពិតណាស់ អ្វីដែលគួរឲ្យអស់សំណើចនោះគឺថាទង្វើនេះពាក់ព័ន្ធទៅនឹងករណីដែលសាក្សីខាងដើមចោទផ្តល់កសិណការពារចុងចោទ។

ស្វែងរកភស្តុតាងដើម្បីបង្ហាញនៅក្នុងការចោទប្រកាន់ទំនងមិនមែនជាគោលដៅពិតប្រាកដទេ។ ឧទាហរណ៍ នៅក្នុងរឿងក្តី ធីមប៊ុល ស៊ីឡែន រដ្ឋអាជ្ញាបានសួរ អឺរីកូ គូតេរ៉េស ថាតើគាត់ពិតជាបាននិយាយនៅឯកិច្ចប្រជុំកាលពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៩៩ នៅមុខលំនៅឋានរបស់លោកអភិបាលដូចដែលដីកាបានចោទប្រកាន់ដែរឬទេ? តើ អាប៊ីលីអូ ស័ររ៉េមានបានអំពាវនាវឲ្យសម្លាប់មេដឹកនាំក្រុមប្រឹក្សាតស៊ូរំដោះជាតិ

នៅទីម័រ និងអំពាវនាវឲ្យសម្លាប់មេដឹកនាំគាំទ្រឯករាជ្យភាពដែរឬទេ? មេធាវីខាងចុងចោទបានជំទាស់ទៅនឹងសំណួរទាំងនេះដោយឈរលើមូលដ្ឋានថា គូតេរ៉េស បង្ហាញខ្លួននៅក្នុងរឿងក្តីនេះក្នុងនាមជាសាក្សី មិនមែនជាជនជាប់ចោទទេ ក៏ប៉ុន្តែបើតុលាការបានបញ្ជាឲ្យបន្តសំណួរ ។ គូតេរ៉េស បានផ្តល់ចម្លើយស្រពេចស្រពិល ដូចជាគាត់មិនអាចនិយាយឡើងវិញឲ្យបានច្បាស់អំពីអ្វីដែលគាត់បាននិយាយរួចហើយ ក៏ប៉ុន្តែអ្វីដែលគាត់បានដឹងនោះគឺថា ម៉ានូអែល ការ៉ាសកាឡូ ជាជនក្បត់ ។ ចំពោះអ្វីផ្សេងទៀតគាត់មិនបានដឹងទាំងអស់ ។ គាត់បានប្រាប់ចៅក្រមជំនុំជម្រះថា "សម្រាប់ខ្ញុំ វាសាហាវខ្លាំងណាស់ការដែលចេញបញ្ជាឲ្យមានការសម្លាប់បែបនេះ" ។ ចៅក្រមសួរទៀតថា "ដូច្នេះលោកមិនបាននិយាយអំពីការសម្លាប់ទេមែនទេ?" ។ ចម្លើយតបវិញគឺ "ប្រហែលជា...អីយ៉ា!" ។ ខ្សែភាពយន្តជាច្រើនដែលបង្ហាញយ៉ាងច្បាស់អំពីអ្វីដែលសាក្សីបាននិយាយ មិនត្រូវបានដាក់បញ្ចូលជាភស្តុតាងទេ ។

នៅក្នុងករណីសម្លាប់រង្គាលនៅព្រះវិហារស្វួយ ភស្តុតាងដែលលេចចេញពីចម្លើយរបស់ជនជាប់ចោទ ហឺម៉ាន សេដ្យូណូ គឺថា ប្រធានក្រុមឡាក់សូឈ្មោះ អូលីវើ ម៉ូរុក ធ្លាប់ធ្វើជាប្រធានភូមិ ។ អភិបាលស្តីទី ហឺម៉ាន ទទួលបានបណ្តឹងប្រឆាំងនឹងគាត់ និងបណ្តេញគាត់ចេញពីការងារ ប៉ុន្តែឈ្មោះរបស់គាត់នៅតែមាននៅក្នុងបញ្ជីប្រាក់ខែរបស់រដ្ឋបាលស្រុកក្នុងនាមជាមន្ត្រីរដ្ឋការ សូម្បីតែនៅក្នុងវិស័យទូទៅក៏នៅតែមានឈ្មោះរបស់គាត់ដែរ ។ ម៉ាទីណុស បេរេ ជាកងជីវពលនាំមុខម្នាក់ទៀត និងជាអ្នកដែលបានកប់សាកសពជនរងគ្រោះនៅទីម័រខាងលិច ក៏ជាប្រធានភូមិនៅកូវ៉ាលីម៉ាដែរ ។ ក្នុងនាមជាមន្ត្រីរដ្ឋការបុរសទាំងពីរនេះនៅក្រោមបង្គាប់របស់អភិបាលស្តីទី ហឺម៉ាន ។ រដ្ឋអាជ្ញាមិនបានតាមរកខ្សែបណ្តាញដ៏មានសារសំខាន់នេះទេ ។ រដ្ឋអាជ្ញាមិនសួរអភិបាលស្តីទី ហឺម៉ាន អំពីការចោទប្រកាន់ថាគាត់បានបង្កើតពួកកងជីវពលនៅស្វួយផងទេ ។

នៅក្នុងករណីសម្លាប់រង្គាលនៅព្រះវិហារស្វួយ នាយប៉ូលិសម្នាក់មកពីទីម័រខាងលិចបានផ្តល់កសិណអំពីសម្តីរបស់ប្រជាជននៅស្វួយដែលបានប្រាប់គាត់ថា កាលពីដើមឆ្នាំ១៩៩៩ ក្រុមឡាក់សូនៅទីបញ្ជាការយោធាស្រុក *KODIM* ជានិច្ចកាល ។ កាន់តែច្បាស់ទៅទៀតគឺពេលដែលគាត់បានធ្វើដំណើរទៅស្វួយ គាត់បានប្រទះឃើញក្រុមឡាក់សូនៅទីនោះ ។ គ្មានការបង្ហាញភស្តុតាងនេះដើម្បីបង្ហាញពីទំនាក់ទំនងរវាងកងជីវពលនិងក្រុមយោធាជាមួយនឹងជនជាប់ចោទដែលជាមេបញ្ជាការ ឬដើម្បីដេញដោលសាក្សីជាច្រើនផ្សេងទៀតដែលបាននិយាយថាខ្លួនមិនបានពុំអំពីក្រុមនេះទេ ។

មានប្រយោគតិចតួចណាស់ដែលមានទម្រង់ជាសំណួរឧទាហរណ៍ នៅក្នុងករណីសម្លាប់រង្គាលនៅព្រះវិហារស្វួយ រដ្ឋអាជ្ញាយល់ថាចាំបាច់ក្នុងការចោទសួរសាក្សីគ្រប់ៗគ្នាអំពីអ្វីដែលសាក្សីទាំងអស់បានដឹង ។ រដ្ឋអាជ្ញាបានចំណាយពេលវេលាយ៉ាងច្រើនទៅលើបញ្ហាទាំងអស់នេះនិងបញ្ហាមិនសូវសំខាន់ផ្សេងទៀត ជាជាងទៅលើការជាប់ពាក់ព័ន្ធរវាងក្បាលម៉ាស៊ីនសន្តិសុខនិងក្បាលម៉ាស៊ីនស៊ីវិល និងការសម្លាប់រង្គាល ។ ឧទាហរណ៍សវនាការក្នុងរឿងក្តីសម្លាប់រង្គាលនៅព្រះវិហារស្វួយនៅថ្ងៃទី៧ ខែឧសភា ឆ្នាំ២០០២ ។ សាក្សីជានាយប៉ូលីសបីនាក់មកពីទីម័រខាងលិចដែលបានឃើញផ្ទាល់ភ្នែកនូវការកប់សាកសពជនរងគ្រោះនៃការសម្លាប់នៅព្រះវិហារស្វួយ ។ ទោះបីជាសាក្សីទាំងបីនាក់នេះត្រូវបានចោទសួរខ្លះៗអំពីអ្វីដែលខ្លួនបានឃើញហើយដែលទាក់ទងទៅនឹងឧបទ្ទវហេតុនៅព្រះវិហារស្វួយក៏ដោយ ក៏ការយកចិត្តទុកដាក់ដ៏លើសលប់នោះគឺទៅលើអ្វីដែលសាក្សីទាំងបីបានដឹងអំពីការធ្វើប្រជាមតិ, អំពីមូលហេតុនៃការជម្លៀសប្រជាជនចេញពីទីម័រខាងកើត, តើសាក្សីបានពុំដឹងអីអាយ ឬប៉ូលិស ឬអាជ្ញាធរស៊ីវិល បង្ខំឲ្យប្រជាជនជម្លៀសដែរឬទេ, ប្រសិនបើបានពុំអំពីអ្វីដែលបានកើតឡើងនៅស្វួយ តើសាក្សីមានដឹងថាមនុស្សប៉ុន្មាននាក់បានស្លាប់ដែរឬទេ, អំពីប្រភេទអាវុធដែលក្រុមកប់សាកសពកាន់មកពីស្វួយ, អំពីបញ្ហាដែលក្រុមប៉ូលិសនៅទីម័រខាងលិចបានទទួល, អំពីដំណោះស្រាយរបស់ក្រុមប៉ូលិសចំពោះជនភៀសខ្លួនក្នុងស្រុក ។ល។និង ។ល។

## ៤) ការផ្លាស់ប្តូរកសិណ

ចំណុចដ៏គួរឲ្យចាប់អារម្មណ៍នៅក្នុងដំណើរការជំនុំជម្រះក្តីនោះគឺចំនួនសាក្សីដែលបានផ្លាស់ប្តូរកសិណដែលធ្លាប់ផ្តល់ឲ្យ

*ការិយាល័យអគ្គមេធាវីពីពេលមុន ។ ការផ្លាស់ប្តូរនេះកើតឡើងជាពិសេសនៅក្នុងករណីសម្លាប់រង្គាលនៅព្រះវិហារសួយ ។ ការកែប្រែនេះជាទូទៅរាប់បញ្ចូលទាំងៈ*

◆ *ការផ្លាស់ប្តូរលើការពិពណ៌នាអំពីឧបទ្ទវហេតុ រាប់ចាប់តាំងពីការវាយប្រហារដោយភាគីម្ខាងទៅលើភាគីម្ខាងទៀត រហូតដល់ជម្លោះរវាងប្រជាជនទីម័រខាងកើតគ្នាឯង ។*

◆ *ការបដិសេធថាគ្មានការចូលរួមរបស់ក្រុមធីអិនអាយឬក្រុមប៉ូលិស ។*

◆ *ការនិយាយយ៉ាងទូចថាស្នូរកាំភ្លើងបាញ់ចេញពីបរិវេណព្រះវិហារ (ទាំងនៅសួយនិងលីគ្វីកា) និងថាមានការបង្កហេតុមកពីអ្នកដែលនៅខាងក្នុង (លំនៅឋានរបស់ ម៉ានូអែល ការ៉ាសកាឡូ) បណ្តាលឲ្យអ្នកនៅខាងក្រៅបើកការវាយប្រហារទៅលើអ្នកនៅខាងក្នុង ។*

◆ *ការបដិសេធថាក្រុមធីអិនអាយឬក្រុមប៉ូលិសគ្មានទំនាក់ទំនងជាមួយកងជីវពល ។ និង*

◆ *ការបដិសេធថាមិនបានដឹងពីវត្តមាននៃកងជីវពល ឬមិនបានដឹងអំពីអត្តសញ្ញាណរបស់មេដឹកនាំ ។*

*ពីមួយពេលទៅមួយពេល ចៅក្រមបានសួរសំណួរមិនស្របគ្នា ប៉ុន្តែមិនបានសង្កេតឲ្យបានដិតដល់លើភាពញឹកញាប់និងភាពមិនស្របគ្នាយ៉ាងចម្លែក ដែលបង្ហាញឲ្យឃើញពីការប៉ុនប៉ងគេចចេញពីគន្លងយុត្តិធម៌ ។ ការអះអាងរបស់សាក្សីដែលខុសគ្នាពីមួយលើកទៅមួយលើក គឺជាអ្វីដែលគួរតែពិចារណា ។ ទោះជាយ៉ាងណាក៏គួរតែកត់សម្គាល់ថា សាក្សីជាច្រើនបានអះអាងថាបានអានកសិណរបស់ខ្លួននិងបានចុះហត្ថលេខាទៀតផង ។ នៅក្នុងករណីជាច្រើន នៅពេលចាប់ផ្តើមផ្តល់កសិណផ្ទាល់មាត់ សាក្សីមិនបានជំទាស់ទៅនឹងកសិណដែលអះអាងពីមុនមកទេ ប៉ុន្តែការជំទាស់កើតមានឡើងបន្ទាប់ពីលេចចេញនូវភាពមិនស្របគ្នា ។ ជួនកាលសាក្សីប្តូរពីការប្រើពាក្យ "ការវាយប្រហារ" ទៅជាពាក្យ "ជម្លោះ" វិញ ។*

*សាក្សី ចេហេកៀល បេរេក បានដកការអះអាងដែលចង្អុលបង្ហាញយ៉ាងច្បាស់អំពីតួនាទីរបស់ក្រុមធីអិនអាយនៅក្នុងអំពើសម្លាប់រង្គាលនៅព្រះវិហារសួយ ។ សាក្សីរូបនេះបានប្តូរការពិពណ៌នាពីការវាយប្រហារទៅជាជម្លោះវិញ ។ គាត់ក៏បាននិយាយអំពីទំនាក់ទំនងរវាងទីបញ្ជាការយោធាឃុំនិងឡាក់សូ ហើយនិយាយថា ក្រុមប៉ូលិសមិនអាចធ្វើអ្វីឡាក់សូបានទាល់តែសោះ ពីព្រោះក្រុមនេះទទួលបញ្ជានិងការពារដោយទីបញ្ជាការយោធាស្រុក ។ រដ្ឋអាជ្ញាមិនបានចាប់អារម្មណ៍ចំពោះការអះអាងនេះទេ ក៏ប៉ុន្តែមានចៅក្រមម្នាក់បានសួរដេញដោល ។*

*សាក្សីបានបដិសេធពាក្យសម្តីទាំងអស់នៅក្នុងតុលាការដោយនិយាយថា "តាមពិតវាមិនមែនដូច្នោះទេ ។ នៅពេលនោះខ្ញុំឃើញថាក្រុមប៉ូលិសមិនបានស៊ើបអង្កេតទេដោយសារតែមានមនុស្សច្រើនពេកខណៈពេលដែលយើងមានតែសមាជិកបន្តិចបន្តួច ។ ដូច្នេះប៉ូលិសមិនមានលទ្ធភាពស៊ើបអង្កេតទេ" ។ ចៅក្រមបានទទូចថា នេះជាការអះអាងមួយដែលបង្ហាញថាមានការប្រឈមមុខដាក់គ្នារវាងក្រុមប៉ូលិសនិងក្រុមទាហានមកពីទីបញ្ជាការយោធាស្រុក ។ "ត្រង់នេះនិយាយថា ប៉ូលិសត្រូវតែប្រយុទ្ធតទល់នឹងប្រជាជនដែលរួមកម្លាំងជាមួយក្រុមធីអិនអាយ ។ លោកបានពន្យល់ដូច្នេះនៅពេលត្រូវចោទសួរ ហើយលោកអ្នកបានចុះហត្ថលេខាទៀត ។ ដូច្នេះតើវាពិតដែរឬអត់?" សាក្សីឆ្លើយថា "តាមពិតមិនបូកបញ្ចូលក្រុមធីអិនអាយទេ ។ ខ្ញុំចង់ប្រៀបធៀបកងកម្លាំងធីអិនអាយជាមួយនឹងហ្វូងមនុស្សដែលកំពុងវាយប្រយុទ្ធគ្នានៅពេលនោះ ។ អារឿងបញ្ចូលរួមកម្លាំងគ្នានោះប្រហែលជាខ្ញុំមានការភ័ន្តច្រឡំទេ" ។*

*ការផ្តល់កសិណរបស់ ដូលូស បាសាបឺ បានបង្ហាញថា គាត់ស្ថិតនៅក្រោមសម្ពាធមិនសមរម្យ ។ សាក្សីរូបនេះជានាយប៉ូលិសមកពីមេតាម៉ូក ជាទីកន្លែងកប់សាកសពជនរងគ្រោះចំនួន២៧ដែលដឹកមកពីព្រះវិហារសួយ ។ នៅក្នុងកិច្ចសម្ភាសន៍ជាមួយការិយាល័យអគ្គមេធាវី បាសាបឺ បាននិយាយថា ស៊ូហ្គិតូ មេបញ្ជាការរបស់ក្រុមឡាក់សូ ជាអ្នកបង្គាប់បញ្ជាឲ្យមនុស្សរបស់ឡាក់សូកប់សាកសពទាំងនោះ ។ នៅក្នុងតុលាការ បាសាបឺ បានកែប្រែសម្តីរបស់គាត់ថា ស៊ូគីតូ គ្រាន់តែឈរក្បែរនោះ ប៉ុន្តែមិនបានធ្វើអ្វីទាំងអស់ ។ សាក្សី បាននិយាយថា គ្មានសម្ពាធណាមួយទេក្នុងអំឡុងពេលធ្វើកិច្ចសម្ភាសន៍ ប៉ុន្តែគ្មាននរណាម្នាក់សួរថាតើគាត់រងសម្ពាធណាមួយឬអត់នោះទេ ។ មេធាវី*

ចុងចោទបានព្យាយាមសួរបញ្ជាក់ថាតើសម្តីមួយណាត្រឹមត្រូវ ។ បន្ទាប់ពីនៅស្ងៀមមួយសន្ទុះមក សាក្សីនិយាយថា គាត់មិនអាចឆ្លើយបានទៀតទេ ។ នៅចុងបញ្ចប់ អង្គចៅក្រមបានសួរថាតើគាត់មានអ្វីចង់និយាយ ហើយមានអារម្មណ៍ដូចជាមិនស្រួលមែនទេ ។ សាក្សីបង្ហាញការស្ទាក់ស្ទើរ ហើយនៅទីបំផុតឆ្លើយថាគាត់មានអារម្មណ៍ភ័យខ្លាចក្នុងការមកធ្វើសាក្សី នៅទីនេះ ហើយបន្ថែមថា គាត់មិនបានធ្វើអ្វីខុសទេ ហើយក៏គ្មានជាប់ពាក់ព័ន្ធនឹងអ្វីដែលបានកើតឡើងដែរ ។ អង្គចៅក្រមបានចំណាយពេលវេលាយ៉ាងច្រើនដើម្បីធានាចំពោះសាក្សីថា ការផ្តល់កសិណរបស់គាត់មានតម្លៃ និងបានប្រាប់គាត់ថាអំពីប្រយោជន៍នៃកសិណរបស់គាត់ចំពោះប្រទេសឥណ្ឌូនេស៊ី ។ ចៅក្រមមិនបានសួរសាក្សីថាតើមាននរណាម្នាក់គាបសង្កត់ឲ្យគាត់ផ្លាស់ប្តូរកសិណដែរឬអត់ ហើយក៏មិនបានសួរថាហេតុអ្វីបានជាគាត់ស្ថិតក្រោមការគំរាមកំហែងដែរ ។

មានភាពមិនស្របគ្នាមួយចំនួនរវាងអ្វីដែលសាក្សីដើមចោទ សូនី អ៊ីសកាន់ដា បានប្រាប់តុលាការនៅក្នុងករណីសម្លាប់រង្គាលនៅព្រះវិហារស្វួយ និងបទសម្ភាសន៍របស់គាត់ជាមួយការិយាល័យអគ្គមេធាវី ។ គាត់បានដកយកកំណត់ហេតុសម្ភាសន៍របស់គាត់វិញដោយសំអាងថាគាត់ត្រូវគំរាមដកចេញពីតំណែងប្រសិនបើគាត់មិនចុះហត្ថលេខាលើកំណត់ហេតុនោះទេ ។ ទាំងរដ្ឋអាជ្ញាទាំងមេធាវីចុងចោទមិនបានដេញដោលលើបញ្ហានេះទេ ហើយតុលាការក៏មិនបានបញ្ជាឲ្យស៊ើបអង្កេតករណីបំភិតបំភ័យសាក្សីដែរ ។

នៅក្នុងរឿងក្តីសម្លាប់រង្គាលនៅព្រះវិហារស្វួយ ជនជាប់ចោទ កាតុត ស៊ុប៊ីយ៉ាកតូរ៉ូ ជាអតីតមេប៉ូលិសនៅស្វួយ បាននិយាយថា គាត់ពេញចិត្តចំពោះភាពជាក់លាក់នៃកំណត់ហេតុស៊ើបអង្កេតដែលធ្វើឡើងដោយការិយាល័យអគ្គមេធាវី ។ ប៉ុន្តែគាត់បានផ្តល់កសិណខុសពីកំណត់ហេតុស៊ើបអង្កេតជាច្រើនចំណុច ។ កាលពីខាងដើម គាត់អះអាងថាបានឃើញមេដឹកនាំយោធាដែលមានបំពាក់អាវុធផងនៅព្រះវិហារស្វួយ ប៉ុន្តែនៅក្នុងតុលាការគាត់បដិសេធសម្តីនេះចោលវិញដោយលើកហេតុផលថា «នៅពេលរដ្ឋអាជ្ញាកោះហៅខ្ញុំ ខ្ញុំមានការភ័យខ្លាច ។ ខ្ញុំត្រូវចោទប្រកាន់ពីបទប្រព្រឹត្តខុសនៅពេលដែលកំពុងតែការពារប្រទេសរបស់ខ្ញុំ» ។ គ្មានអ្នកណាម្នាក់សួរគាត់ទាល់តែសោះអំពីអ្វីដែលគាត់ចង់និយាយសម្រាប់ពាក្យ «ការពារប្រទេសរបស់ខ្ញុំ» ។ ចៅក្រមបានដេញដោលលើភាពមិនស្របគ្នាផ្សេងៗដូចជា សម្តីដែលគាត់និយាយពីពេលមុននៅក្នុងកថាខ័ណ្ឌទី៦ថា គាត់អាចមើលស្គាល់ក្រុមគាំទ្រឯករាជ្យភាពនិងក្រុមប្រឆាំងឯករាជ្យភាព ហើយដែលក្រោយមកគាត់បានដកសម្តីនេះវិញ ដោយពន្យល់ថាភាពមិនស្របគ្នាទាំងអស់នេះគឺ«ដោយសារតែខ្ញុំជាជនសង្ស័យ ខ្ញុំបានព្យាយាមសង្គ្រោះជីវិតមនុស្ស អនុវត្តតាមបញ្ជារបស់រដ្ឋ និងក្រោយមកខ្ញុំបានក្លាយជាជនសង្ស័យ ។ ខ្ញុំមិនសប្បាយចិត្ត ។ ខ្ញុំបានពិភាក្សាជាមួយប៉ូលិស ។ ប៉ូលិសបាននិយាយថាវាជាបញ្ជារបស់រដ្ឋាភិបាល ។ ខ្ញុំឆ្លើយតាមតែប៉ូលិសប្រាប់» ។

យ៉ូពី លេកាតុមប៉េស៊ី អតីតមេប៉ូលិសនៅកូវ៉ាលីម៉ាក៏បានដកសម្តីដែលពីមុនហៅហេតុការណ៍នៅព្រះវិហារស្វួយថាជាការវាយប្រហារ ។ នៅក្នុងតុលាការគាត់និយាយថា «តាមការពិតទៅវាមិនមែនជាការវាយប្រហារទេ គឺជាជម្លោះទៅវិញ» ។ គាត់ក៏បានច្រានចោលសម្តីរបស់គាត់ដែលថាគាត់ស្គាល់ថ្នាក់ដឹកនាំរបស់កងជីវពលឡាក់សូ (អ៊ូលីវើ ម៉ូរុក និង ម៉ាទីណុស បេរ៉េ) និងឃើញមេបញ្ជាការឡាក់សូកាន់កាំភ្លើងអឹម-១៦ ។ នៅពេលត្រូវចោទសួរថាតើហេតុអ្វីបានជាមានចំណុចមិនស្របគ្នាច្រើនម្ល៉េះ គាត់ឆ្លើយថា *«ពេលនោះគឺថ្ងៃរសៀលហើយក្តៅទៀតផង ។ ខ្ញុំត្រូវកោះហៅយ៉ាងប្រញាប់ប្រញាល់ឲ្យមកផ្តល់កសិណ ។ ខ្ញុំមិនមានពេលវេលាគ្រប់គ្រាន់ដើម្បីរំឭកឡើងវិញអំពីហេតុការណ៍ទេ ។ ជាការពិតណាស់ វាមិនមែនជាការវាយប្រហារនោះ ។ ពាក្យដែលគួរតែប្រើនោះគឺជម្លោះទៅវិញទេ» ។*

### ក) ការប្រព្រឹត្តរបស់សាក្សីទីម័រខាងកើតឈ្មោះ ដូមីងកាស ដុស សាន់តូស ម៉ូហ្ស៊ីនហូ

ដូមីងកាស ដុស សាន់តូស ម៉ូហ្ស៊ីនហូ ជាសាក្សីដំបូងបង្អស់មកពីទីម័រខាងកើតដើម្បីផ្តល់កសិណ ។ គាត់ជាអ្នករស់រានមានជីវិតពីអំពើសម្លាប់រង្គាលនៅព្រះវិហារស្វួយ ។ សាក្សីរូបនេះអាចនិយាយភាសាបាហាសាក្នុងកម្រិតតិចតួច ។ ដូច្នេះ រដ្ឋបាលបណ្តោះអាសន្នទីម័រខាងកើតបានបញ្ជូនអ្នកបកប្រែម្នាក់មក

ឲ្យគាត់ ដោយមានការព្រមព្រៀងពីការិយាល័យអគ្គមេធាវី ។

រដ្ឋអាជ្ញាបានជូនដំណឹងទៅតុលាការថា ដោយសារសាក្សីរូបនេះនិយាយភាសាបាហាសាឥណ្ឌូនេស៊ីមិនបានល្អ រដ្ឋអាជ្ញាបានរៀបចំអ្នកបកប្រែភាសាម្នាក់របស់អង្គការសហប្រជាជាតិ ។ អង្គចៅក្រមបាននិយាយថា តុលាការព្យាយាមប្រើប្រាស់ភាសាបាហាសាឥណ្ឌូនេស៊ី ក៏ប៉ុន្តែមិនបានបដិសេធការប្រើប្រាស់អ្នកបកប្រែទេប្រសិនសាក្សីមិនចេះភាសាបាហាសា ។ មេធាវីចុងចោទសម្តែងកង្វះការជឿទុកចិត្តទៅលើអ្នកបកប្រែភាសា ។ បន្ទាប់ពីចោទសួរសាក្សីនូវសំណួរដំបូងចំនួន១៧ដែលទាក់ទងទៅនឹងការកំណត់អត្តសញ្ញាណ (ចម្លើយចំពោះសំណួរទាំងនោះគឺតែពាក្យមួយម៉ាត់ៗ) អង្គចៅក្រមបានកំណត់ថាសាក្សីរូបនេះនិយាយភាសាបាហាសាឥណ្ឌូនេស៊ីបានល្អគ្រប់គ្រាន់ហើយមិនចាំបាច់ត្រូវការអ្នកបកប្រែទេ ។ ដូច្នោះ អង្គចៅក្រមបានបដិសេធអ្នកបកប្រែភាសា ។

សាក្សី ដូមីងកាស ត្រូវចោទសួរជាភាសាបាហាសាឥណ្ឌូនេស៊ីអស់រយៈពេលប្រហែលប្រាំម៉ោងដោយគ្មានឈប់សម្រាក សូម្បីតែទឹកមួយកែវក៏មិនបានទទួលទានដែរ ។ ចាប់តាំងពីដើមដំបូងគាត់មានការលំបាកយ៉ាងខ្លាំងក្នុងការយល់ភាសា ។ ក្រោយមកនៅពេលដែលគាត់បានត្រូវសម្ភាសន៍នៅទីម័រខាងកើត សាក្សីរូបនេះបានប្រាប់អ្នកនិពន្ធថា នៅក្នុងតុលាការ គាត់បានស្នើសុំការអនុញ្ញាតពីអង្គចៅក្រមដល់ទៅពីរដងដើម្បីប្រើអ្នកបកប្រែភាសា ក៏ប៉ុន្តែអង្គចៅក្រមបានអះអាងប្រាប់គាត់ទាំងពីរលើកថា ភាសាបាហាសាឥណ្ឌូនេស៊ីរបស់គាត់គឺល្អគ្រប់គ្រាន់ហើយ ។ ដូមីងកាស បានប្រាប់ចៅក្រមថា គាត់មិនអាចនិយាយភាសាបាហាសាឥណ្ឌូនេស៊ីដើម្បីផ្តល់ព័ត៌មានដ៏ពេញលេញស្តីអំពីហេតុការណ៍នោះបានទេ ហើយចៅក្រមបាននិយាយថា មិនអីទេ ។

មាត្រាទី១៧៧ របស់ *KUHAP* តម្រូវឲ្យអង្គចៅក្រមតែងតាំងអ្នកបកប្រែភាសាប្រសិនបើចុងចោទឬសាក្សីមិនយល់ភាសាឥណ្ឌូនេស៊ីទេនោះ ។ តម្រូវការតែមួយគត់គឺថា អ្នកបកប្រែត្រូវតែស្បថសច្ចាថានឹងបកប្រែឲ្យបានត្រឹមត្រូវនូវរាល់អ្វីដែលត្រូវបកប្រែ ។ វាហាក់ដូចជាថាអង្គចៅក្រមយល់ថាមាត្រាទី១៧៧មិនអាចយកមកអនុវត្តបានទេនៅពេលណាដែលសាក្សីអាចនិយាយភាសាឥណ្ឌូនេស៊ីបានខ្លះៗ ។ បើគិតក្នុងន័យអវិជ្ជមានគឺថា ការមិនផ្តល់អ្នកបកប្រែឲ្យសាក្សីនឹងធ្វើឲ្យព័ត៌មានដែលសាក្សីផ្តល់នោះមានភាពមិនច្បាស់លាស់ ដោយសារតែសាក្សីយល់សំណួរមិនច្បាស់ ដោយសារការសម្លុត និងដោយសារការរំខានពីសំណាក់មេធាវីចុងចោទ ។ គួរកត់សម្គាល់ដែរថា នៅក្នុងបរិបទនៃការទទួលខុសត្រូវរបស់ប្រព័ន្ធតុលាការ *KUHAP* ពន្យល់យ៉ាងល្អិតល្អន់ថា អង្គចៅក្រមដែលដឹកនាំការពិនិត្យពិច័យ "ត្រូវធានាឲ្យប្រាកដថាគ្មានអំពើគំរាមកំហែងណាមួយ ឬគ្មានសំណួរណាមួយដែលនាំឲ្យចុងចោទឬសាក្សីគ្មានសេរីភាពក្នុងការផ្តល់ចម្លើយឡើយ" (មាត្រាទី១៥៣) ។ ម្យ៉ាងវិញទៀត នៅពេលណាដែលរបាំងភាសាបង្កឲ្យសាក្សីគ្មានសេរីភាពក្នុងការឆ្លើយ ចៅក្រមមានភារកិច្ចសម្របសម្រួលសភាពការណ៍ ។ តើហេតុអ្វីបានជាអង្គចៅក្រមមិនធ្វើទៅតាមអ្វីដែលបានចែង? ចម្លើយគឺថា អង្គចៅក្រមគិតថាសាក្សីរូបនេះមានលទ្ធភាពយល់និងនិយាយភាសាបាហាសាឥណ្ឌូនេស៊ីបានយ៉ាងល្អ ។ ការប្រព្រឹត្តបែបនេះគឺជាកង្វះការហ្មឹកហ្វឺនជិតដល់ ។ ទោះជាយ៉ាងណាក៏ដោយ វាជាការពិបាកក្នុងការបើពិនិត្យមើលអំពីថាតើកង្វះខាតការយល់ដឹងរបស់សាក្សីមានសភាពធ្ងន់ធ្ងរយ៉ាងណា ។

សាក្សី ដូមីងកាស ជាអ្នកភូមិម្នាក់មកពីភាគមួយដាច់ស្រយាលនៃទីម័រខាងកើត ដែលបានរស់រានមានជីវិតពីអំពើសម្លាប់រង្គាលដ៏ធ្ងន់ធ្ងរបំផុតនៅក្រោយការធ្វើប្រជាមតិនៅទីម័រខាងកើត ។ វាគួរឲ្យចាប់អារម្មណ៍ខ្លាំងណាស់ដែលរដ្ឋអាជ្ញាបណ្តោយឲ្យសាក្សីដ៏សំខាន់ទទួលរងនូវការរំខាននិងបំភិតបំភ័យពីសំណាក់មេធាវីចុងចោទ ដែលបានធ្វើប្រព្រឹត្តហួសពីការសួរសំណួរស៊ើបអង្កេតស្របច្បាប់ ។ ចំណែកតុលាការវិញហាក់ដូចជាយល់ឃើញថាគ្មានអ្វីខុសសោះចំពោះសំណួររបស់មេធាវីចុងចោទ និងអនុញ្ញាតឲ្យបន្តសំណួរដែលមានលក្ខណៈបង្ខំ ចំអក និងសម្លុត ។ ដើម្បីបង្កើនបញ្ហា ជួនកាលចៅក្រមខ្លះបាននិយាយពាក់ព័ន្ធទៅនឹងរឿងរ៉ាវអាម៉ាស់ផ្ទាល់ខ្លួនរបស់សាក្សីថែមទៀត ។

អនុលោមតាមមាត្រាទី១៧៣នៃ *KUHAP* អង្គចៅក្រមស្តាប់កសិណរបស់សាក្សីដោយយកចិត្តទុកដាក់ ដោយគ្មានវត្តមានរបស់ចុងចោទទេ ។ មាត្រាទី៣ផ្នែកទី៥នៃបទបញ្ជា

ការពារសាក្សីថែងថា សាក្សីត្រូវតែលើកសំណើទៅតុលាការសុំការការពារ"នៅក្នុងដំណាក់កាលពិនិត្យពិច័យ" ឬស្នើសុំដោយផ្ទាល់ទៅក្បាលម៉ាស៊ីនសន្តិសុខ។ មុនពេលចាប់ផ្តើមដំណើរការជំនុំជម្រះ សាក្សី ដូមីងកាស បានស្នើសុំតាមរយៈអង្គការសហប្រជាជាតិឬETTA មិនឲ្យមានវត្តមានជនជាប់ចោទក្នុងពេលផ្តល់កសិណ ក៏ប៉ុន្តែសំណើនេះទំនងជាមិនត្រូវបានពាំនាំទៅតុលាការទេ។ ផ្ទុយទៅវិញ ក្នុងពេលដែលកំពុងតែសួរសំណួរ មេធាវីចុងចោទបានស្នើម្តងហើយម្តងទៀត ឲ្យសាក្សីសម្លឹងទៅជនជាប់ចោទដើម្បីកំណត់អត្តសញ្ញាណជនជាប់ចោទទាំងនោះ។ រដ្ឋអាជ្ញាឬតុលាការមិនបានជំទាស់ទេនៅពេលដែល មេធាវីចុងចោទណែនាំឲ្យសាក្សីរូបនេះសម្លឹងមើលកែវភ្នែករបស់ជនជាប់ចោទស៊ុហ្គីតូ។

នៅក្នុងអំឡុងពេលស៊ើបអង្កេត អង្គចៅក្រមបានសាកល្បងលើកម្រិតនៃភាពជឿជាក់របស់សាក្សី ដូមីងកាស។ ចៅក្រមបានសរសេរនៅលើក្រដាសមួយសន្លឹក ហើយបានសុំឲ្យសាក្សីអាន។ បន្ទាប់ពីសាក្សីពន្យល់អំពីវិធីដែលគាត់លាក់ខ្លួននៅក្នុងទូទឹកកកក្នុងអំឡុងពេលមានការវាយប្រហារ ចៅក្រមក៏សង្ស័យចំពោះអត្តសញ្ញាណរបស់គាត់។ ចៅក្រមបានផ្ទៀងផ្ទាត់ហត្ថលេខារបស់សាក្សីនៅក្នុងតុលាការជាមួយនឹងហត្ថលេខានៅលើអត្តសញ្ញាណប័ណ្ណ។ ទង្វើទាំងអស់នេះបង្កក្តីអាម៉ាស់ដល់សាក្សីហើយបង្ហាញថាតុលាការយល់ស្របទៅនឹងការលើកឡើងរបស់មេធាវីចុងចោទដែលថាសាក្សីរូបនេះមិនអាចទុកចិត្តបានទេ។

ជាការពិតដែលថា កង្វះសមត្ថភាពខាងភាសា ការភ័យខ្លាច ឬប្រការផ្សេងៗទៀត បណ្តាលឲ្យសាក្សី ដូមីងកាស ផ្តល់ចម្លើយខុសៗគ្នា និងជារឿយៗមិនឆ្លើយសំណួរ។ ទោះជាយ៉ាងណាក៏ដោយ ដំណើរជំនុំជម្រះនិងសាក្សីបន្តបន្ទាប់ទៀតក៏មិនអាចទុកចិត្តបានដែរ ហើយសាក្សីខ្លះបាននិយាយរឿងរ៉ាវមិនពិតយ៉ាងគឃ្លើន។ ជានិច្ចកាល រឿងរ៉ាវមិនពិតត្រូវបានទុកឲ្យហួសទៅដោយគ្មានការដេញដោល ប៉ុន្តែនៅក្នុងករណីនេះតុលាការយល់ថាស័ក្តិសមក្នុងការបណ្តែតបណ្តោយឲ្យមានការសួរដោយរំលោភនិងរំខាន និងដើម្បីបង្ហាញថាសាក្សីរូបនេះមិនអាចជឿទុកចិត្តបាន។ ដើមចោទមិនបានតវ៉ាទេ ហើយហាក់ដូចជាមានការពេញចិត្តចំពោះរបៀបដែលមេធាវីចុងចោទនិងក្រុមចៅក្រមប្រព្រឹត្តមកលើសាក្សីរបស់ខ្លួន។

### ឃ) សេចក្តីវិនិច្ឆ័យ

ក្រៅពីការផ្តន្ទាទោស អាប៊ីលីអូ ស័រេរ៉េ ដោយដាក់គុករយៈពេលបីឆ្នាំ (តិចជាងរយៈពេលដែលបញ្ញត្តិដោយច្បាប់) ប្រហែលជាអាចមានការកាត់ឲ្យរួចទោសនៅក្នុងក្តីផ្សេងទៀត។ ខាងដើមចោទបានបរាជ័យយ៉ាងច្បាស់ក្រឡែតក្នុងការបង្ហាញភ័ស្តុតាងដាក់បន្ទុក។ ជាខ្លឹមសារវាច្បាស់ណាស់ថា ចៅក្រមបានខិតខំប្រឹងប្រែង បូករួមទាំងការបញ្ចូលចៅក្រមពិសេសដែលមានជំនាញច្បាស់លាស់ខាងច្បាប់អន្តរជាតិ។ ទោះបីជាមនុស្សម្នាក់អាចយកបញ្ហាទៅបកស្រាយតាមច្បាប់ក៏ដោយ ក៏ចំណុចពិសេសបំផុតនោះគឺឥរិយាបថជាវិជ្ជមាននិងការលើកទឹកចិត្តចំពោះការប្រើប្រាស់ច្បាប់អន្តរជាតិនៅក្នុងតុលាការឥណ្ឌូនេស៊ី។ ប្រការនេះអាចជាចំណែកមួយដ៏មានសារសំខាន់ក្នុងការអនុវត្តបទដ្ឋានសិទ្ធិមនុស្សនៅក្នុងករណីជាច្រើននៅក្រោមច្បាប់២៦/២០០០។

សាក្សីទីម័រខាងកើតបីនាក់ហាក់ដូចជាត្រូវបានចាត់ទុកថាជាសាក្សីគួរឲ្យទុកចិត្តបាន ក៏ប៉ុន្តែមានសាក្សីជាច្រើនទៀតដែលជាឥស្សរជនឆ្នើមៗក្នុងជួរទាហាន ប៉ូលិស និងមន្ត្រីរដ្ឋការសុទ្ធតែបានបដិសេធយ៉ាងដាច់អហង្ការចំពោះតួនាទីរបស់ជនជាប់ចោទនៅក្នុងអំពើហិង្សា។ ភ័ស្តុតាងដែលបានបង្ហាញនៅឯអង្គជំនុំជម្រះត្រូវបានដាក់ទម្ងន់ទៅលើការផ្លាស់ប្តូរមួយចំនួនចំពោះអ្វីដែលបានកើតឡើង ហើយភ័ស្តុតាងនេះជាមូលដ្ឋានគ្រឹះដែលតុលាការមានសិទ្ធិសម្រេចខ្វះៗទាក់ទងទៅនឹងភាពល្មៀងភាពវៀចវេរ និងការបោកប្រាស់របស់UNAMET នៅក្នុងអំឡុងពេលនៃការធ្វើប្រជាមតិ និងទាក់ទងទៅនឹងការទទួលខុសត្រូវរបស់UNAMETចំពោះអំពើហិង្សាដែលកើតឡើងបន្ទាប់ពីនោះ។ ភ័ស្តុតាងដែលដើមចោទនិងចុងចោទបានផ្តល់ដល់ចៅក្រមទាំងបីក្រុមគឺថា ជនជាប់ចោទបានប្រឹងប្រែងអស់ពីសមត្ថភាពក្នុងការបំបែកជនទីម័រខាងកើតដែលកំពុងតែឈ្លោះគ្នា ហើយជនជាប់ចោទមិនគួរត្រូវស្តីបន្ទោសឡើយ។ អាស្រ័យហេតុនេះ ចៅក្រមសម្រេចក្តីនៅក្នុងករណីសម្លាប់រង្គាលនៅព្រះវិហារស្វាយថា "គ្មានភ័ស្តុតាងណាមួយបង្ហាញឲ្យឃើញថាកងកម្លាំងសន្តិសុខ

ទាំងក្រុមប៉ូលិសនិងធីអិនអាយ ទាំងក្រុមប៉ូលិសបង្រ្កាបកុបកម្ម ជាប់ពាក់ព័ន្ធនៅក្នុងការវាយប្រហារទៅលើព្រះវិហារនោះទេ» ។ នៅក្នុងករណីខ្លះ ចៅក្រមទាត់ចោលភ័ស្តុតាងដ៏គួរឲ្យអស់សំណើច មួយចំនួន ។ ឧទាហរណ៍ នៅក្នុងករណីសម្លាប់រង្គាលនៅព្រះវិហារ សួយ ចៅក្រមបានបដិសេធភ័ស្តុតាងដែលពិពណ៌នាអំពីជម្លោះ របស់ប្រជាជនទីម័រខាងកើតនៅឯព្រះវិហារ ដោយសំអាងថា វាជារឿងសមហេតុផលក្នុងការសន្និដ្ឋានថាពិតជាមានជនប្រដាប់ អាវុធមួយក្រុមបានចូលទៅក្នុងព្រះវិហារជាទីកន្លែងដែលជន ស៊ីវិលកំពុងជ្រកកោន ហើយបន្តការវាយប្រហារបណ្តាលឲ្យ ប្រជាជនស្លាប់និងរបួស ។ ចៅក្រមយល់ឃើញថា ហេតុផល ក្នុងការផ្លាស់ប្តូរចម្លើយកសិណគឺមិនសមហេតុផលនិងគ្មានមូលដ្ឋាន គ្រប់គ្រាន់ ។ ចៅក្រមបានសន្និដ្ឋានថា សាក្សីទាំងអស់នោះមិន ស្មោះត្រង់ ហើយបានបដិសេធចោលទាំងស្រុងនូវការផ្លាស់ប្តូរ ចម្លើយរបស់ជនជាប់ចោទ កាតុត ស៊ុបឺយ៉ាកតូរ៉ូ ដោយសំអាង ថា គាត់ជាមេប៉ូលិសនៅក្នុងមូលដ្ឋាន និងបានដឹងយ៉ាងច្បាស់ អំពីដំណើរការនៃបទសម្ភាសន៍នោះ ។ ទោះជាយ៉ាងណាក៏ដោយ ចៅក្រមមិនបានដោះស្រាយចំពោះការផ្លាស់ប្តូរចម្លើយកសិណ ដ៏មានសារសំខាន់មួយចំនួនដូចជា ចេហេកៀល បេរេក ដែល បានសុះស៊ែរុងដកសម្តីរបស់គាត់អំពីតួនាទីរបស់ទីបញ្ជាការយោធា ស្រុកក្នុងការការពារក្រុមឡាក់សូ និងទប់ស្កាត់មិនឲ្យប៉ូលិស បំពេញភារកិច្ច ។

មានលក្ខណៈពិសេសមួយចំនួននៅក្នុងការវិនិច្ឆ័យ ។ ការ វិនិច្ឆ័យមួយចំនួនមានមូលដ្ឋានច្បាស់លាស់ យោងទៅតាមហេតុ ផលនិងការជឿទុកចិត្ត រីឯការវិនិច្ឆ័យមួយចំនួនទៀតមិនដូច្នោះ ទេ ។ ឧទាហរណ៍ ភ័ស្តុតាងនៅឯតុលាការមិនបានផ្តល់យុត្តិធម៌ ក្នុងការកាត់ក្តីជនទីម័រខាងកើត អាប៊ីលីអូ ស័រេរ៉េ ទេ ។ ហេតុផល ដែលលើកឡើងក្នុងការដាក់ទោសទណ្ឌមានលក្ខណៈមិនសមហេតុ ផល និងស្រាលជាងអ្វីដែលចែងដោយច្បាប់ ។ ចៅក្រមបាន ពន្យល់ថា «ចៅក្រមមិនមែនជាទាសកររបស់ច្បាប់នោះទេ» ហើយ «ការដាក់ទោសគឺមិនគ្រាន់តែទាមទារឲ្យមានភាពប្រាកដ ប្រជាខាងផ្លូវច្បាប់ប៉ុណ្ណោះទេ ប៉ុន្តែថែមទៀតបំពេញឲ្យបាននូវ ស្មារតីយុត្តិធម៌ផង» ។ ចៅក្រមបង្ហាញថា ប្រធានាធិបតីទីម័រ បច្ចុប្បន្ន សាណាណា ហ្គូសម៉ៅ ដែលបានសរសេរលិខិតគាំទ្រ អាប៊ីលីអូ ស័រេរ៉េ ជាការសបញ្ជាក់ថា «ស្មារតីផ្សះផ្សាមិនអាច ដួលរលំបានដោយសារតែការដាក់ទោសឲ្យបានធ្ងន់ធ្ងរទៅលើជន ជាប់ចោទទេ» និងបានប្រកាស «គាំទ្រចំពោះកិច្ចខិតខំប្រឹងប្រែង ក្នុងការផ្សះផ្សាដែលបន្តទៅមុខដោយគ្មានវប្បធម៌នៃការរួច ទោស» ។ ជាទូទៅ ចៅក្រមស្ទាក់ស្ទើរក្នុងការនិយាយចំៗ ក្នុងការហៅកងជីវពលដែលចូលរួមនៅក្នុងអំពើឃោរឃៅ ក៏ប៉ុន្តែបានប្រើពាក្យដែលមានលក្ខណៈទូទៅជាងដូចជាហៅថា «ក្រុមគាំទ្រស្វ័យភាព» និង «ក្រុមគាំទ្រសមាហរណកម្ម» ។

នៅក្នុងការវិនិច្ឆ័យរឿងក្តី ធីមប៊ុល ស៊ីឡែន តុលាការបាន រាយការណ៍ខុសនូវកសិណមួយចំនួនរបស់ប្រជាជនទីម័រខាងកើត ។ ឧទាហរណ៍ កសិណរបស់ អេមីឡូ បារ៉េតូ មកពីលីគ្វីកា ស្តីពី អំពើសម្លាប់រង្គាលនៅព្រះវិហារមានដូចខាងក្រោម៖

អ្នកវាយប្រហារជាក្រុមជីវពល ហើយក្រុមធីអិនអាយ ដែលស្លៀកពាក់ស៊ីវិលនិងក្រុមប៉ូលិសបង្រ្កាបកុប្បកម្មស្ថិតនៅ ខាងក្រៅ ។ ក្នុងចំណោមអ្នកវាយប្រហារ មានប្រជាជនដែល ពាក់មួកនិងមានកាំភ្លើង ។ ក្រុមប៉ូលិសនិងប៉ូលិសបង្រ្កាបកុប្បកម្ម ស្លៀកពាក់ឯកសណ្ឋាន ហើយនៅខាងក្រៅរបង ប៉ុន្តែបើកការ បាញ់ប្រហារដែរ ។ ក្រុមទាហានស្លៀកសម្លៀកបំពាក់ស៊ីវិលបាន ចូលរួមនៅក្នុងការវាយប្រហារនោះដែរ ហើយអ្នកខ្លះមាន កាំភ្លើង ។ យើងមើលស្គាល់ក្រុមទាហានធីអិនអាយ ដោយសារ តែក្រុមនេះមានអាវុធស្វ័យប្រវត្តិ ចំណែកឯអ្នកផ្សេងទៀត មានតែដាវសាមូរ៉ៃឬដាវវែងៗ ។ ថម ឌីយេហ្គោ បានស្រែក ឡើងថា «ឆាប់ឡើង សម្លាប់ពួកវាឲ្យអស់» ។ សាក្សីបានស្គាល់ ចូស រ៉ាម៉ូស សមាជិកក្រុមធីអិនអាយ ដែលចូលមកក្នុងព្រះវិហារ ដោយគ្របមុខនិងក្រណាត់ពណ៌ខ្មៅ ។

តុលាការបានសម្រួលកសិណនេះទៅជា «ថម ឌីយេហ្គោ បានបញ្ជាឲ្យវាយប្រហារទៅលើបរិវេណព្រះវិហារ ហើយសាក្សី បានឃើញប៉ូលិសចំនួនប្រហែល២០០នាក់» ។ ទង្វើនេះខុស ទាំងស្រុងពីអ្វីដែលសាក្សីបាននិយាយ ហើយបានធ្វើឲ្យលុបការ ចោទប្រកាន់អំពីការចូលរួមរបស់ក្រុមយោធាដែលអ្នកខ្លះមាន អាវុធ ។

ស្រដៀងគ្នានេះដែរ ភស្តុតាងរបស់ ចូអៅ ប៉េរៀរ៉ា ត្រូវបានបញ្ជាក់ដោយក្រុមរបស់ ធីមប៊ុល ស៊ីឡែន ថា «នៅម៉ោងប្រហែល ១៣ះ០០ ថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៩ កងជីវពលប្រដាប់ដោយអាវុធ បានវាយប្រហារទៅលើប្រជាជនដែលបានជម្លៀសនិងស្វែងរកទីជម្រកនៅឯលំនៅឋានរបស់ ប៉ាស្ទ័រ រ៉ាហ្វែល នៅក្នុងបរិវេណព្រះវិហារនៅលីគីកា» ។ សាក្សីស្គាល់អត្តសញ្ញាណក្រុមធីអិនអាយយ៉ាងច្បាស់ ។ កសិណរបស់គាត់គឺថា គាត់ស្គាល់ ថម ឌីយេហ្គោ ជាសមាជិកទីបញ្ជាការយោធាស្រុក១៦៣៦ និងទាហានម្នាក់ឈ្មោះ ចូស រ៉ាម៉ូស ដែលបានចូលទៅក្នុងព្រះវិហារដោយគ្របមុខនឹងក្រណាត់ខ្មៅ ។ គាត់បានឃើញផ្ទាល់ភ្នែក ចូស រ៉ាម៉ូស បាញ់មនុស្សពីប្រាំទៅប្រាំពីរនាក់ ហើយប្រជាជនទាំងនោះបានដួលស្រុបទៅដី ។ អ្វីដែលតុលាការបានធ្វើចំពោះកសិណរបស់សាក្សីម្នាក់នេះ គឺលុបចោលចំណុចដែលនិយាយអំពីការចូលរួមរបស់ក្រុមធីអិនអាយ ។

ដូចគ្នាដែរក្នុងរឿងក្តីរបស់ ធីមប៊ុល ស៊ីឡែន តុលាការមិនបានកត់ត្រាផ្នែកសំខាន់នៃសេចក្តីអះអាងរបស់ ម៉ារីយ៉ា ហ្វេរៀរ៉ា ស័ររ៉េ ។ ដូចសាក្សីឯទៀតដែរ កសិណរបស់គាត់ត្រូវបានអានដើម្បីកត់ត្រាក្នុងកំណត់ហេតុរបស់តុលាការ ព្រោះគាត់បដិសេធមិនផ្តល់ភស្តុតាងនៅក្នុងទីក្រុងហ្សាកាតាដោយសារតែព្រួយបារម្ភផ្នែកសន្តិសុខ ។ កាន់តែធ្ងន់ធ្ងរទៀតគឺតុលាការមិនបានកត់ត្រាភស្តុតាងដែល ហ្វេរៀរ៉ា ស័ររ៉េ បានផ្តល់អំពីការវាយប្រហារទៅលើលំនៅឋានរបស់អាចារ្យបេឡូៈ *«នៅពេលមកដល់ខាងមុខលំនៅឋាន ខ្ញុំបានឃើញកងជីវពលអៃតារ៉ាក់ ក្រុមធីអិនអាយ និងប៉ូលិស បាញ់សំដៅជនភៀសខ្លួនដែលកំពុងស្ថិតនៅខាងក្នុងនិងជុំវិញលំនៅឋានរបស់អាចារ្យបេឡូ ហើយដុតលំនៅឋាននោះដោយប្រើសាំង»* ។ សាក្សីនេះជាជនរងគ្រោះតែម្នាក់គត់ដែលមានវត្តមាននៅឯលំនៅឋានអាចារ្យបេឡូ បានឃើញការវាយប្រហារដោយផ្ទាល់ភ្នែក ហើយដែលត្រូវបានសម្ភាសន៍ ។ ការខកខានកត់ត្រាផ្នែកនេះមានន័យថា គ្មានភស្តុតាងណាមួយមកពីជនរងគ្រោះនៃអំពើវាយប្រហារទៅលើលំនៅឋានរបស់អាចារ្យបេឡូដើម្បីចោទប្រកាន់ ធីមប៊ុល ស៊ីឡែន ឡើយ ។ រឿងដែលគួរឲ្យអារម្មណ៍មួយទៀតគឺ ការខកខានមិនបានកត់ត្រាការពន្យល់របស់ ហ្វេរៀរ៉ា ស័ររ៉េ អំពីការភៀសខ្លួនរបស់ប្រជាជនទៅទីម័រខាងលិច ដោយសារតែ «ប្រជាជនភ័យខ្លាចមិនហ៊ានស្នាក់នៅក្នុងទីក្រុងឌីលី ក្រៅពីនេះភាគខ្លះនៃទីក្រុងឌីលីត្រូវបានដុតបំផ្លាញដោយកងជីវពលដែលឧបត្ថម្ភដោយក្រុមធីអិនអាយនិងប៉ូលិស ។ ជាងនេះទៀតក៏មានការគំរាមកំហែងរបស់ក្រុមជីវពល BMP ថានឹងដុតទីបញ្ជាការយោធាស្រុកបណ្តាលឲ្យប្រជាជនភៀសខ្លួនទៅ អាតាំបួ និង គុប៉ាង» ។

ការផ្តន្ទាទោស អាប៊ីលីអូ ស័ររ៉េ ហាក់ដូចជាមានយុត្តិធម៌បើធៀបនឹងអភិបាលស្តីទីនៅកូវ៉ាលីម៉ាដែលត្រូវបានកាត់ឲ្យរួចទោស ។ គ្មានជនរងគ្រោះណាមួយមកពីសួយដើម្បីផ្តល់កសិណនៅក្នុងអង្គជំនុំជម្រះនេះទេ ហើយក៏គ្មានជនរងគ្រោះណាម្នាក់ត្រូវបានធ្វើសម្ភាសន៍នៅក្នុងអំឡុងពេលនៃការស៊ើបអង្កេតទៅលើ អាប៊ីលីអូ ស័ររ៉េ ដែរ ។ ភស្តុតាងទាំងអស់ដែលបានផ្តល់នៅក្នុងអង្គជំនុំជម្រះមិនបានបង្ហាញកំហុសរបស់អាជ្ញាធរទាំងស៊ីវិលយោធា ឬប៉ូលិសឡើយ ។ ក៏ប៉ុន្តែ ចៅក្រមបានរកឃើញថា ÷

*ដោយឈរលើហេតុផលដ៏រឹងមាំ វាមិនទំនងថាអភិបាលស្តីទីកូវ៉ាលីម៉ា ហឺម៉ាន សេដ្យូណ្ណូ មិនបានដឹងអំពីការជួបជុំរបស់មនុស្សរាប់ពាន់នាក់ដែលហៀបតែនឹងវាយប្រហារទៅលើក្រុមអ្នកគាំទ្រឯករាជ្យភាពដែលបានស្វះស្វែងរកទីជម្រកនៅឯព្រះវិហារ ។ ដូចគ្នាដែរ ដោយមានមេបញ្ជាការយោធាឃុំសួយ និងមេប៉ូលិសនៅសួយ និងក្បាលម៉ាស៊ីនសន្តិសុខដទៃទៀត អ្នកទាំងអស់នេះគួរតែបានដឹងអំពីសភាពការណ៍ដែលហៀបនឹងកើតឡើង ។*

តុលាការបានសន្និដ្ឋានថា អភិបាលស្តីទី ហឺម៉ាន សេដ្យូណ្ណូ ជាមេបញ្ជាការយោធាឃុំសួយ មេប៉ូលិសនៅសួយ និងកងកម្លាំងសន្តិសុខ បានផ្តល់ឱកាសឲ្យក្រុមគាំទ្រសមាហរណកម្មវាយប្រហារទៅលើក្រុមគាំទ្រឯករាជ្យដែលបានស្វះស្វែងរកការជ្រកកោននៅក្នុងព្រះវិហារសួយ ។ មនុស្ស២ពាន់នាក់ឬច្រើនជាងនេះបានជាប់នៅក្នុងព្រះវិហារដោយគ្មានម្ហូបអាហារនិងទឹកនិងស្ថិតនៅក្នុងស្ថានភាពទន់ខ្សោយ ។ ចាប់ពីដើមដំបូងមកកងកម្លាំងសន្តិសុខមិនបានបណ្តេញចេញឲ្យអស់ពីព្រះវិហារនូវក្រុមដែលនឹងក្លាយទៅជាអ្នកវាយប្រហារ ហើយមិនបានខិតខំ



អ្នកទោសនៅមន្ទីរស-២១

ប្រើងប្រែងការពារអ្នកដែលកំពុងជ្រកកោននៅក្នុងព្រះវិហារទេ។ តុលាការយល់ឃើញថា អភិបាលស្តីទីនៅកូវ៉ាលីម៉ា ឈ្មោះ ហ៊ុម៉ាន សេដ្យូណូ ត្រូវតែទទួលខុសត្រូវតាមច្បាប់ បើទោះជាគាត់មិនបានចូលរួមដោយផ្ទាល់នៅក្នុងការវាយប្រហារក៏ដោយ ក៏ប៉ុន្តែការដែលមិនធ្វើអ្វីដែលគាត់គួរតែធ្វើនោះ គាត់មិនអាចគេចផុតពីការទទួលខុសត្រូវចំពោះអំពើហិង្សាដែលកើតឡើងនៅព្រះវិហារសួយបានទេ។ ក្រុមធីអិន-អាយ ក្រុមប៉ូលិស មេបញ្ជាការយោធាឃុំសួយ មេប៉ូលិសនៅសួយនិងអភិបាលស្តីទី ទើបតែបានទៅដល់កន្លែងកើតហេតុបន្ទាប់ពីការវាយប្រហារបានបញ្ចប់ ។ លើសពីនេះទៀត អភិបាលស្តីទី ហ៊ុម៉ា សេដ្យូណូ មិនបានបញ្ជាឲ្យបញ្ចុះសាកសពទាំងអស់ឲ្យបានសមរម្យទេ។ សាកសពទាំងនោះត្រូវបានទុកចោលរាយប៉ាយគ្រប់កន្លែងហើយនៅថ្ងៃបន្ទាប់ ស៊ុហ្គិតូ មេបញ្ជាការយោធានៅសួយនិងសាក្សីឈ្មោះ ប្រាណូតូ នៅឆ្នេរមេតាម៉ូក បានប្រមូលយកទៅបញ្ចុះ។ អាស្រ័យហេតុនេះហើយ តុលាការបានរកឃើញថា "ការចោទប្រកាន់ដំបូងគឺជនជាប់ចោទបានចូលរួមនិងគាំទ្រសកម្មភាពវាយប្រហារនៅព្រះវិហារសួយ" ។ នេះជាការដាក់កម្រិតឲ្យទទួលខុសត្រូវក្នុងបទដ្ឋានដ៏តឹងរ៉ឹងក្រៅពីការទទួលខុសត្រូវលើការបញ្ជា ហើយតុលាការមិនបានពន្យល់អំពីថាតើហេតុអ្វីបានជាលោកអភិបាលត្រូវតែទទួលខុសត្រូវចំពោះបទឧក្រិដ្ឋទាំងពួងរបស់អភិបាលស្តីទី ហឺម៉ាន។ ក្នុងនាមជាអ្នកបង្គាប់បញ្ជាម្នាក់គឺមិនចាំបាច់ខ្លួនឯងស្ថិតនៅក្នុងអំពើឧក្រិដ្ឋនោះផ្ទាល់ទេ។ ចៅក្រមខកខានមិនដោះស្រាយបញ្ហាសំខាន់ស្តីអំពីថាតើសកម្មភាពរបស់ហឺម៉ាន សេដ្យូណូ ស្របឬផ្ទុយទៅនឹងបទបញ្ជារបស់លោកអភិបាលនិងស្តីអំពីថាតើអ្វីដែលលោកអភិបាលអាចធ្វើបាន ប្រសិនបើ ហឺម៉ាន បានប្រព្រឹត្តផ្ទុយពីបទបញ្ជា។ តុលាការក៏បានដាក់កំហុសលោកអភិបាលពីបទបរាជ័យដោយផ្ទាល់ក្នុងការបំបែកការជួបប្រជុំគ្នានាថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៩៩ នៅខាងមុខការិយាល័យរបស់គាត់ បើទោះជាគាត់គ្រាន់តែត្រូវចោទប្រកាន់ពីបទទទួលខុសត្រូវលើការបញ្ជានិងពីបទខកខានមិនបានត្រួតពិនិត្យមើលអភិបាលស្តីទីនៅកូវ៉ាលីម៉ា។ ទោះជាយ៉ាងនេះក្តី ជនជាប់ចោទមិនត្រូវបានចោទប្រកាន់ពីបទទទួលខុសត្រូវចំពោះសកម្មភាពរបស់អភិបាលស្តីទីរូបនេះទេ ក៏ប៉ុន្តែទាក់ទងទៅនឹងសកម្មភាពផ្សេងទៀតរបស់ អឺរីកូ គូតេរ៉េស។ តុលាការរកឃើញថាគ្មានទំនាក់ទំនងផ្លូវការណាមួយរវាងលោកអភិបាលនិងមេបញ្ជាការ

កងជីវពល អ៊ីរីកូ គូតេរ៉េស ទេ ។ ការប្រព្រឹត្តរបស់អភិបាលស៊ីវិលនៅកូវ៉ាលីម៉ាបានគេចផុតពីការពិនិត្យពិច័យរបស់តុលាការ ។

អ្នកសង្កេតការណ៍បានវាយតម្លៃថា ការផ្តន្ទាទោស អាប៊ីលីអូ ស័រស៉េ មិនត្រឹមត្រូវ បើឈរលើមូលដ្ឋានភ័ស្តុតាងដែលបានដាក់ជូនអង្គជំនុំជម្រះ ។ ចំណែកជាច្រើននៃការរកឃើញពិសេសនោះគឺ មានការវាយប្រហារពាលដាលប្រឆាំងប្រជាជនស៊ីវិលនៅទីម័រខាងកើត ។ ខបទុវហេតុបានបង្ហាញឲ្យឃើញថាមានមនុស្សស្លាប់យ៉ាងច្រើន ។ ការវាយប្រហារនេះជាការវាយប្រហារបែបប្រព័ន្ធ រៀបចំផែនការទុកជាមុនយ៉ាងម៉ត់ចត់ គឺជាមនោគមវិជ្ជាមួយ ដែលក្នុងន័យនេះគឺជាការបំផ្លិចបំផ្លាញប្រជាជនស៊ីវិល សកម្មភាពមនុស្សធម៌ ទ្រព្យសម្បត្តិសាធារណៈនិងឯកជន ឬការធ្វើឲ្យសហគមន៍ចុះខ្សោយ ។

តុលាការបានរកឃើញថា ការវាយប្រហារទៅលើព្រះវិហារលីគ្វីកាមានទម្រង់ដូចគ្នាទៅនឹងការវាយប្រហារនៅកូវ៉ាលីម៉ា និងឌីលី ពោលគឺគ្មានការទប់ស្កាត់ ហើយកងកម្លាំងសន្តិសុខនិងអាជ្ញាធរមូលដ្ឋានបានគាំទ្រ និងលម្អៀងក្នុងការដោះស្រាយជម្លោះ ។ ក្នុងនាមជាប្រមុខដឹកនាំខេត្តនិងនាយករដ្ឋបាល ជនជាប់ចោទទទួលខុសត្រូវយ៉ាងធំធេងចំពោះការបាត់បង់អាយុជីវិតមនុស្ស ដោយសារគាត់មិនបានបញ្ឈប់អំពើហិង្សានិងរួមចំណែកទៅក្នុងអំពើហិង្សាតាមរយៈសកម្មភាពរបស់ប៉ាមវ៉ាកាសា ។

## ៨) ការជំនុំជម្រះក្តីត្រូវបានលាតត្រដាង

ដំណើរការជំនុំជម្រះក្តីត្រូវតែបំពេញទៅតាមបទដ្ឋានឲ្យបានត្រឹមត្រូវប្រសិនបើចង់ឲ្យដំណើរការកាត់ក្តីនេះទទួលបាននូវការទទួលស្គាល់ថាត្រឹមត្រូវតាមច្បាប់និងបំពេញកាតព្វកិច្ចរបស់រដ្ឋបានត្រឹមត្រូវក្នុងការស៊ើបអង្កេត ការចោទប្រកាន់ និងការដាក់ទណ្ឌកម្មចំពោះបទល្មើសឧក្រិដ្ឋកម្មអន្តរជាតិ ។ ការសង្កេតមើលលើដំណើរការរបស់សាលាជំនុំជម្រះក្តីបណ្តោះអាសន្នមួយនេះមិនបានបង្ហាញឲ្យឃើញពីភាពមិនប្រក្រតីទាក់ទងនឹងសិទ្ធិរបស់ជនជាប់ចោទចំពោះការកាត់សេចក្តីដោយយុត្តិធម៌និងត្រឹមត្រូវតាមច្បាប់នោះទេ ។ ជនជាប់ចោទទាំងអស់ ជាពិសេសជនជាប់ចោទដែលជាសមាជិករបស់ក្រុមធីអិនអាយបានទទួលការការពារពីក្រុមមេធាវីដែលមានសកម្មភាពយ៉ាងក្លៀវក្លាក្នុងការការពារផលប្រយោជន៍របស់កូនក្តីរបស់ខ្លួន ។ គ្មានសញ្ញាណាណាមួយបង្ហាញថាតុលាការនេះមានភាពលម្អៀងចំពោះជនជាប់ចោទទេ ។

ទោះជាយ៉ាងណាក៏ដោយ ការសង្កេតមើលដំណើរការជំនុំជម្រះនិងការវាយតម្លៃទៅលើច្បាប់និងឯកសារដែលយកមកអនុវត្តនៅក្នុងរឿងក្តីទាំងបី បានរកឃើញគំរូដ៏គួរឲ្យព្រួយបារម្ភ ។ អ្វីដែលនៅតែជាបញ្ហានោះគឺបរាជ័យរបស់ប្រទេសឥណ្ឌូនេស៊ីក្នុងការបំពេញកាតព្វកិច្ចអន្តរជាតិដើម្បីអនុវត្តដំណើការទទួលខុសត្រូវស្របច្បាប់សម្រាប់ការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ ។ ការស្វែងរកយុត្តិធម៌សម្រាប់ទីម័រខាងកើតបានបង្កើតនូវទស្សនីយភាពមួយពាក់ព័ន្ធទៅនឹងរដ្ឋអាជ្ញាដែលអសមត្ថភាពនិងមិនយកចិត្តទុកដាក់ការខ្វះខ្វាយឱកាសដើម្បីទទួលបាននូវការពិតអំពីអ្វីដែលពិតជាបានកើតឡើងនៅទីម័រខាងកើត និងការរំលោភលើប្រព័ន្ធយុត្តិធម៌ដើម្បីបង្ហាញឲ្យឃើញនូវចក្ខុវិស័យតែមួយគត់ ពោលគឺការកែប្រែសភាពការណ៍នៅទីម័រខាងកើតរបស់ក្រុមអ្នកមានអំណាចនៅឥណ្ឌូនេស៊ី ។ សភាពការណ៍នេះផ្ទុយគ្នាទៅនឹងសេចក្តីសន្និដ្ឋានរបស់ក្រុមស៊ើបអង្កេតជាន់ខ្ពស់ផ្សេងៗទៀតដែលមានការទទួលស្គាល់ ។ ដំណើការនេះមិនបានរកឃើញការពិតឬយុត្តិធម៌ឡើយ ។ ការរកឃើញទាំងនេះត្រូវបានធ្វើឡើងដើម្បីទទួលស្គាល់ការពិតដ៏ពេញលេញស្តីអំពីថា នេះជាសំណុំរឿងក្តីដ៏ស្មុគស្មាញបំផុតដែលពាក់ព័ន្ធទៅនឹងខបទុវហេតុច្រើន ហើយជនជាប់ចោទមានតួនាទីផ្សេងៗគ្នា រាប់ចាប់តាំងពីយោធារហូតដល់អាជ្ញាធរប៉ូលិសនិងស៊ីវិល ។ ការចោទប្រកាន់លើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតម្រូវឲ្យមានការយល់ដឹងអំពីគំនូសបត់បែនដ៏សែនស្មុគស្មាញរបស់គោលនយោបាយរដ្ឋ និងការជាប់ពាក់ព័ន្ធរបស់រដ្ឋមន្ត្រីក្នុងការប្រព្រឹត្តបទឧក្រិដ្ឋដោយផ្ទាល់ឬមិនផ្ទាល់តាមរយៈទម្រង់នៃការប្រព្រឹត្តខុសប្លែកគ្នា ដូចជា ការចេញបញ្ជា ការជួយឧបត្ថមគាំទ្រ និងការសមគំនិត ។ ទាំងនេះជារឿងមួយដែលស្មុគ្រស្មាញយ៉ាងខ្លាំង ហើយវាច្បាស់ណាស់ថា កន្ទុះខាតជំនាញនិងការហ៊ឹកហ៊ឺនពិតប្រាកដប៉ះពាល់ធ្ងន់ធ្ងរដល់អាជីព ។ ទោះជាយ៉ាងណាក៏ដោយ អ្វីដែលបានកើតឡើងនៅទីក្រុងហ្សាកាតាបានទៅហួសពីបទដ្ឋានទាំងនេះទៀត ។ របាយការណ៍ដ៏ច្រើនលើសលប់បង្ហាញថា ដំណើការនេះមិនល្អ ។

ការរឹតត្បិតលើយុត្តាធិការដែលដាក់ចេញដោយក្រិត្យរបស់ប្រធានាធិបតី វ៉ាហ៊ីដ និងបន្ទាប់មកប្រធានាធិបតី មេហ្គាវ៉ាទី បានកំណត់ព្រំដែននៃលទ្ធភាពរបស់ការិយាល័យអគ្គមេធាវីក្នុងការដោះស្រាយអ្វីដែលបានកើតឡើងនៅទីម័រខាងកើត ។ ក៏ប៉ុន្តែជាជាងប្រើប្រាស់ឲ្យអស់ពីលទ្ធភាពនូវប្រភពធនធានភស្តុតាងដែលមានស្រាប់ទាក់ទងទៅនឹងខបទុវហេតុនៅក្នុងខែមេសានិងខែកញ្ញា ឆ្នាំ១៩៩៩ នៅក្នុងទីក្រុងឌីលី លីគីកា និងសួយ ការិយាល័យអគ្គមេធាវីបានបំផ្លាញចោលនូវឱកាសដ៏ស្តួចស្តើងក្នុងការរកយុត្តិធម៌តាមរយៈអ្វីដែលរកឃើញដោយប្រុងប្រយ័ត្ន ។ កំហុសបច្ចេកទេសដ៏គួរឲ្យចាប់អារម្មណ៍មួយចំនួនត្រូវបានពិនិត្យពិច័យក្នុងអំឡុងពេលធ្វើសេចក្តីរាយការណ៍នេះ ។ សំណុំរឿងក្តីនេះត្រូវបានចាត់ចូលជាសំណុំរឿងក្តីឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ក៏ប៉ុន្តែភស្តុតាងដែលរកឃើញដោយស្ថាប័នស៊ើបអង្កេតក៏គួរជឿជាក់បំផុតចំនួនបី (គឺខេភីភីហាំ គណៈកម្មាធិការស៊ើបអង្កេតឯករាជ្យ និងអ្នករាយការណ៍ពិសេស) ពិតជាមិនមែនដើម្បីបង្ហាញនៅក្នុងការចោទប្រកាន់ទេ ។ តាមពិត ដើមចោទគ្មានលទ្ធភាពបង្ហាញភស្តុតាងនៅក្នុងការចោទប្រកាន់ជាមូលដ្ឋានមួយចំនួន ។ ស្រដៀងគ្នានេះដែរ ក្នុងសំណុំរឿងក្តីទាំងបីនេះដើមចោទគ្មានលទ្ធភាពបង្ហាញថា ក្រុមប៉ូលិស ក្រុមធីអិនអាយ ឬអាជ្ញាធរស៊ីវិល បានប្រព្រឹត្តបទឧក្រិដ្ឋកម្ម នេះមិនគិតដល់អំពើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផង ។

បន្ទាប់ពីមានការប្រព្រឹត្តរបស់ដើមចោទនៅក្នុងករណីទាំងបីនេះ (រាប់ចាប់តាំងពីដីកាចោទប្រកាន់ទន់ខ្សោយ ការជ្រើសរើសសាក្សីដែលមានការភ័យខ្លាច កង្វះខាតភស្តុតាងឯកសារនិងសម្ភារផ្សេងៗ ការប្រព្រឹត្តខុសប្រក្រតីក្នុងពេលជំនុំជម្រះ ការចោទសួរសាក្សីគ្មានប្រសិទ្ធភាព អសមត្ថភាពក្នុងការប្រើប្រាស់ចម្លើយកសិណរបស់ជនរងគ្រោះទាំងបីនាក់មកពីទីម័រខាងកើត រហូតដល់ការបដិសេធជម្រើសដ៏មានប្រសិទ្ធភាព) សេចក្តីសន្និដ្ឋានចំពោះការកាត់ក្តីទាំងបីនេះគឺ រដ្ឋអាជ្ញាខ្វះឆន្ទៈដើម្បីធានាឲ្យមានការកាត់ក្តីដោយយុត្តិធម៌ ។ ការអះអាងដែលថាសំណុំឯកសាររបស់ដើមចោទត្រូវបំផ្លាញដោយសារបរាជ័យរបស់ *UNTAET* ក្នុងការឧបត្ថមគាំទ្រសាក្សីទីម័រខាងកើត មិនអាចចាត់ទុកថាជារឿងធំដុំបានឡើយបើពិនិត្យឲ្យបានគ្រប់ជ្រុងជ្រោយទៅលើដំណើរការកាត់សេចក្តី ។ មានចំណុចជាច្រើនបង្ហាញថាភស្តុតាងនិងសាក្សីមួយចំនួនត្រូវបានរៀបចំដោយប្រុងប្រយ័ត្នក្នុងគោលបំណងកែប្រែអ្វីដែលបានកើតឡើងនៅទីម័រខាងកើត និងក្នុងគោលបំណងបិទបាំងចំណុចលេចធ្លោមួយចំនួន ដូចជាតួនាទីរបស់កងកម្លាំងពិសេស ឬភ្នាក់ងារសម្ងាត់ ឬសញ្ញាបង្ហាញពីការរៀបចំផែនការ ជាដើម ។ មានចំណុចជាច្រើនដែលបង្ហាញថា ទង្វើរបស់រដ្ឋអាជ្ញាបានជួយសម្រាលទោសឲ្យជនជាប់ចោទយ៉ាងច្រើន (អាប៊ីលីអូ ស័ររ៉េ តាមពិតត្រូវជាប់គុករយៈពេល១០ឆ្នាំនិង៦ខែបែរជាត្រូវតុលាការកាត់ទោសឲ្យជាប់គុកតែ៣ឆ្នាំ, ធីមប៊ុល ស៊ីឡែន តាមពិតត្រូវជាប់គុក១០ឆ្នាំ៦ខែ បែរជាត្រូវកាត់ឲ្យរួចទោស, ជនជាប់ចោទនៅក្នុងរឿងក្តីសម្លាប់រង្គាលនៅព្រះវិហារសួយតាមពិតត្រូវជាប់គុកពី១០ឆ្នាំទៅ១០ឆ្នាំ៦ខែ បែរជាត្រូវតុលាការកាត់ឲ្យរួចទោស) ។ អនុលោមទៅតាមច្បាប់ ២៦/២០០០ ដាក់គុករយៈពេល១០ឆ្នាំគឺជាការដាក់ទោសកម្រិតទាបបំផុត ។ នៅក្នុងរឿងក្តីរបស់ អាដាម ដាមីរី មន្ត្រីជាន់ខ្ពស់របស់ធីអិនអាយ (ខ្ញុំមិនបានលើកយកមកវិភាគស៊ីជម្រៅនៅក្នុងអត្ថបទនេះទេ) ជំនួយរបស់រដ្ឋអាជ្ញាចំពោះជនជាប់ចោទបានស្តែងចេញយ៉ាងច្បាស់ ។ នៅពេលដែលតុលាការចេញសាលក្រមកាត់ទោស អាដាម ដាមីរី ឲ្យជាប់គុករយៈពេល៣ឆ្នាំ ខាងដើមចោទបានប្តឹងឧទ្ធរណ៍ឲ្យលើកលែងការផ្តន្ទាទោសនេះ ។

សំខាន់ជាងនេះទៅទៀតគឺសំណុំឯកសារដែលចងក្រងដោយខេភីភីហាំ ដែលបាននាំទៅដល់ការរកឃើញដ៏រឹងមាំអំពីការប្រព្រឹត្តបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅទីម័រខាងកើត ។ ការពិតនិងភស្តុតាងបានបង្ហាញដល់ក្រុមអ្នកស៊ើបអង្កេតថាក្បាលម៉ាស៊ីនស៊ីវិលនិងយោធា រួមទាំងប៉ូលិសផង បានគាំទ្រនិងបង្កលក្ខណៈឲ្យកើតមានឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ ក្រៅពីកិច្ចសម្ភាសន៍ដ៏លម្អិតជាមួយសាក្សី ខេភីភីហាំបានចងក្រងឯកសារសម្ងាត់ដែលបានមកពីធីអិនអាយ ខណៈដែលខេភីភីហាំដឹងអំពីតម្រូវការក្នុងការធ្វើសម្បទានដោយសារតែភាពងាយទទួលរងគ្រោះថ្នាក់របស់ប្រទេសឥណ្ឌូនេស៊ីនៅក្រោយរបបស៊ូហាតូ ។ ខេភីភីហាំបានដាក់ឯកសារសំខាន់ជាច្រើនជូនទៅការិយាល័យ

អគ្គមេធាវី រួមទាំងការរកឃើញដ៏គួរឲ្យចាប់អារម្មណ៍នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០០០ ។ ក្នុងចំណោមឯកសារសំខាន់ៗទាំងនោះ ឯកសារតិចតួចណាស់ដែលបានទៅដល់តុលាការ ហើយឯកសារដទៃទៀតដូចជា ផែនការប្រតិបត្តិការហាណឺឡារ៉ូសេទី១ និងទី២ ទិន្នន័យអាវុធដែលប្រមូលបានពីកងជីវពលក្នុងអំឡុងយុទ្ធនាការប្រគល់អាវុធនៅទីម័រខាងលិច និងការគាស់សាកសពជនរងគ្រោះនៅព្រះវិហារសួយចំនួន២៧យកពីទីម័រខាងលិច មិនត្រូវបានយកមកប្រើប្រាស់ទេ ។

មានប្រភពធនធានភស្តុតាងផ្សេងទៀតដែលអាចរកបាននៅក្នុងប្រទេសឥណ្ឌូនេស៊ីនិងទីម័រខាងកើត ក៏ប៉ុន្តែគ្មានភស្តុតាងណាមួយត្រូវបានរដ្ឋអាជ្ញារបស់ការិយាល័យអគ្គមេធាវីយកមកប្រើប្រាស់ឡើយ ។ សូម្បីតែខ្សែវីដេអូអំពីការជួបជុំគ្នារបស់ក្រុមគាំទ្រស្វ័យភាពនៅខាងក្រៅលំនៅឋានរបស់លោកអភិបាលនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៩៩ ពេលដែលមេដឹកនាំជីវពលឈ្មោះ អឺរីកូ គូតេរ៉េស ធ្វើសេចក្តីថ្លែងការណ៍ដុតបញ្ឆេះនិងញុះញង់ឲ្យមានអំពើហិង្សា ក៏មិនត្រូវបានដាក់ជូនជាភស្តុតាងដែរ ។ ខ្សែវីដេអូនេះមានប្រយោជន៍នៅក្នុងចោទប្រកាន់ចំនួនពីរ ។ សេចក្តីរាយការណ៍មកពីអគ្គការសហប្រជាជាតិ អគ្គការក្រៅរដ្ឋាភិបាល ឬប្រព័ន្ធឃោសនា មិនត្រូវបានយកមកប្រើប្រាស់ទេ ។ ឯកសារពាក់ព័ន្ធផ្សេងៗទៀត ឧទាហរណ៍ បទបញ្ជាលូមីងតាង មិនត្រូវបានបង្ហាញនៅក្នុងតុលាការទេ ។ គ្មានការប្រើប្រាស់រូបថតទាល់តែសោះ ។ សូម្បីតែរូបថតដែលបញ្ជាក់អំពីភាពខុសគ្នារវាងកងជីវពលគាំទ្រឥណ្ឌូនេស៊ីនិងសមាជិកសង្គមធម្មតា ក៏មិនបានប្រើដែរ ។

សំអាងលើភស្តុតាងដែលបានដាក់ជូនតុលាការនៅក្នុងការកាត់សេចក្តីទាំងបីនេះ គ្មានហេតុផលណាមួយទាល់តែសោះក្នុងការទាញសេចក្តីសន្និដ្ឋានដូចខាងក្រោមៈ

◆ មានការវាយប្រហាររាលដាលឬជាប្រព័ន្ធទៅលើប្រជាជនស៊ីវិល

◆ អាជ្ញាធរឥណ្ឌូនេស៊ីបានចូលរួមនៅក្នុងការវាយប្រហារនេះ

◆ អាជ្ញាធរឥណ្ឌូនេស៊ីបានអនុញ្ញាតឲ្យមានការវាយប្រហារបែបនេះ

◆ អាជ្ញាធរឥណ្ឌូនេស៊ីបានជួយឧបត្ថម្ភគាំទ្រដល់ការវាយប្រហារនេះ

◆ អាជ្ញាធរឥណ្ឌូនេស៊ីបានបិទបាំងការវាយប្រហារនេះ

◆ អាជ្ញាធរឥណ្ឌូនេស៊ីមិនអើពើចំពោះកាតព្វកិច្ចរបស់ខ្លួន

◆ មានគោលនយោបាយឬផែនការដើម្បីអនុវត្តការវាយប្រហារនេះ

◆ អាជ្ញាធរឥណ្ឌូនេស៊ីមានតួនាទីក្នុងការបង្កើត អភិវឌ្ឍន៍ ផ្តល់មូលនិធិ ហ្វឹកហ្វឺន បញ្ជា និងដឹកនាំកងជីវពលប្រដាប់អាវុធ

◆ អ្នកក្រោមបង្គាប់បានប្រព្រឹត្តបទឧក្រិដ្ឋដែលមេបញ្ជាការស៊ីវិល ប៉ូលិស ឬយោធា ត្រូវតែទទួលខុសត្រូវ ។

ដូច្នេះភស្តុតាងដាក់បន្ទុកមិនគ្រប់គ្រាន់សម្រាប់ចោទប្រកាន់នៅក្នុងសំណុំរឿងក្តីទាំងបី នេះមិនទាន់គិតដល់កំហុសឆ្គងផ្សេងៗទៀតនៅក្នុងដំណើរការនេះផង ។

ដើម្បីឲ្យអស់មន្ទិលសង្ស័យចំពោះរឿងក្តីមួយថាតើបុគ្គលម្នាក់មានឬគ្មានទោស ដំណើរការកាត់ក្តីពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅទីម័រខាងកើតគួរតែអនុវត្តតាមច្បាប់ រកឲ្យឃើញការពិតនៅពីក្រោយអំពើឃោរឃៅដែលបានកើតឡើង ។ ដំណើរការនេះគួរតែពិនិត្យពិច័យភស្តុតាងទាំងអស់ថាតើគ្រប់គ្រាន់ដើម្បីចោទប្រកាន់ដែរឬទេ ។ តាមផ្លូវច្បាប់ ដំណើរការទទួលខុសត្រូវក្រោយអំពើហិង្សាគួរតែត្រូវបានយកមកប្រើប្រាស់ដើម្បីក្តាប់ឲ្យបាននូវអ្នកទាំងឡាយដែលនៅពីខាងក្រោយគោលនយោបាយឬសកម្មភាពឧក្រិដ្ឋ ព្រមទាំងជនដែលប្រព្រឹត្តផ្ទាល់ ។ ធ្វើដូចនេះ ដំណើរការយុត្តិធម៌តាមផ្លូវច្បាប់សម្រាប់ទីម័រខាងកើតនឹងត្រូវបានត្រួតពិនិត្យយ៉ាងលម្អិតអំពីតួនាទីរបស់ឥណ្ឌូនេស៊ីនៅទីម័រខាងកើត ភាពសកម្មឬអសកម្មរបស់មន្ត្រីស៊ីវិល ប៉ូលិស ឬយោធា ហើយបានធ្វើគ្រាប់សាឡើងវិញនូវប្រតិបត្តិការនោះដោយប្រើប្រាស់ភាពមិនលម្អៀងនៃអាជីពរបស់ខ្លួន ។ ដំណើរការនេះនឹងកំណត់បានច្បាស់អំពីអ្វីដែលស្ថាប័នទាំងអស់បានធ្វើនៅទីម័រខាងកើត និងកំណត់បានអំពីទំនាក់ទំនងរបស់ស្ថាប័នទាំងនេះជាមួយនឹងសហគមន៍មូលដ្ឋាន ។ គួរតែផ្តោតការចាប់អារម្មណ៍ជាពិសេសទៅលើការបង្កើត ការរៀបចំរចនាសម្ព័ន្ធ និងគោលបំណងរបស់ប្រជាជនទីម័រខាងកើតដែលគាំទ្រ

ក្រុងហ្សាកាតា មិនថាអ្នកទាំងនោះជាកងជីវពល, ប៉ូលីស, ហានស៊ីប, វ៉ានរ៉ា ឬ កាមរ៉ា ទេ ។ ដំណើរការនេះនឹងពិនិត្យមើលថា តើកាលពីខែកញ្ញា ឆ្នាំ១៩៩៩ ប្រជាជនទីម័រខាងកើតត្រូវសម្លាប់យ៉ាងដូចម្តេចបើមានវត្តមានធីអិនអាយនិងប៉ូលិសដ៏ច្រើនសន្ធឹកសន្ធាប់បែបនោះ ។ ទោះជាមានភស្តុតាងបែបនេះនៅក្នុងសេចក្តីរាយការណ៍រួចហើយក៏ដោយ ក៏វាមិនត្រូវបានដាក់ជូនតុលាការទេ ហើយក៏គ្មានការផ្តួចផ្តើមគំនិតដើម្បីដាក់បញ្ចូលភស្តុតាងនេះដែរ ។ ចៅក្រមទាំងបីក្រុមមិនបានខ្វះខ្វែងក្នុងតួនាទីជាអ្នកស្វែងរកការពិត ហើយក៏គ្មានរកឃើញអ្វីស៊ីជម្រៅក្រៅតែអំពីភស្តុតាងសើៗលំៗដែលជាជំនួសឲ្យការរកមិនឃើញអ្វីទាល់តែសោះ ។

តុលាការពិសេសបានផ្តល់ដល់អ្នកមានអំណាចឥណ្ឌូនេស៊ី និងប្រជាជនទីម័រខាងកើតដែលគាំទ្រស្វ័យភាព នូវសិទ្ធិគ្មានដែនកំណត់ក្នុងការប្រើប្រាស់គ្រប់យន្តការដើម្បីផ្សព្វផ្សាយដំណឹងអំពីសោកនាដកម្មនៅទីម័រខាងកើតទៅឲ្យសហគមន៍ជាតិនិងអន្តរជាតិ ។ ឥឡូវនេះ សោកនាដកម្មនេះត្រូវបានទទួលស្គាល់តាមផ្លូវច្បាប់ ។ មានចំណុចដូចគ្នាតិចតួចបំផុតរវាងសោកនាដកម្មនេះនិងប្រភពឯកសារឯករាជ្យដ៏ច្រើនសម្បូរបែបនិងភស្តុតាងដែលមាននៅគ្រប់ទីកន្លែង ។ ប្រជាជនទីម័រខាងកើតដែលគាំទ្រស្វ័យភាព បានស្ថិតនៅក្នុងស្ថានភាពឈ្នះ-ឈ្នះ គឺថា ការជំនុំជម្រះក្តីបានធ្វើឡើងតាមការទាមទាររបស់សហគមន៍អន្តរជាតិ ដោយបានផ្តល់ឱកាសដ៏ពិសេសដើម្បីផ្សព្វផ្សាយអំពីខ្សែបណ្តាញរបស់មន្ត្រីធីអិនអាយ ប៉ូលិស និងក្រុមគាំទ្រស្វ័យភាព គ្មានការដេញដោល ហើយនៅទីបញ្ចប់ ចៅក្រមឥណ្ឌូនេស៊ីបានដោះលែងមន្ត្រីឥណ្ឌូនេស៊ីឲ្យរួចពីការទទួលខុសត្រូវចំពោះអ្វីដែលកើតឡើងនៅទីម័រខាងកើត (អ្នកដែលជាប់ទោសគឺប្រជាជនទីម័រខាងកើត) ។ ការជឿជាក់និងគម្រោងការទាំងអស់នេះបានបង្ហាញនូវគំនិតដែលគួរឲ្យកត់សម្គាល់មួយដែរថា អ្វីដែលសហគមន៍អន្តរជាតិត្រូវការជានិច្ចនោះគឺជាដំណើរការយុត្តិធម៌ព្រហ្មទណ្ឌដ៏ត្រឹមត្រូវមួយ ហើយប្រសិនបើអាចរៀបចំបានតាមតម្រូវការនេះ សាលាជំនុំជម្រះក្តីអន្តរជាតិដែលគួរឲ្យខ្លាចមួយនេះនឹងមិនលេចចេញជារូបរាងទេ ។

បើពិនិត្យមើលកំហុសឆ្គងដ៏ធ្ងន់ធ្ងរនៅក្នុងដំណើរការដែលចាត់ទុកថាមិនស៊ីគ្នាជាមួយបទដ្ឋានអន្តរជាតិ សាលក្រមដែលបានសម្រេចនៅក្នុងរឿងក្តីទាំងអស់នេះគ្មានហេតុផលជាសារវន្តទាល់តែសោះ ហើយសាលក្រមកាត់សេចក្តីទាំងបីករណីមានកំហុសឆ្គងគួរឲ្យគ្រោះថ្នាក់ ។ ផលវិបាកនៃសាលក្រមនេះគឺមានលក្ខណៈយូរអង្វែង ជាពិសេសចំពោះមនុស្សទាំង៦នាក់ដែលត្រូវបានកាត់ឲ្យរួចទោស ។ ជនជាប់ចោទត្រូវបាន“បង្ហាញ”ថាគ្មានទោសពៃរ៍ ហើយការចោទប្រកាន់នេះមិនត្រឹមត្រូវ ។ ការកែប្រែរបស់ធីអិនអាយ ប៉ូលិស ក្រុមគាំទ្រស្វ័យភាព ចំពោះអ្វីដែលបានកើតឡើងនៅទីម័រខាងកើត ត្រូវបានយកមកធ្វើសាឡើងវិញនិងបង្ហាញនៅក្នុងតុលាការ អាស្រ័យហេតុនេះ កេរ្តិ៍ឈ្មោះរបស់ធីអិនអាយនិងប៉ូលិសទីម័រខាងកើតត្រូវបានស្តារឡើងវិញយ៉ាងហោចណាស់ក៏ក្នុងស្រុកដែរ ។ បន្ទាប់មកមានបញ្ហាមួយទៀតគឺថា ជាគោលការណ៍ អ្នកដែលត្រូវកាត់ឲ្យរួចទោសអាចទាមទារផលប្រយោជន៍អំពីសិទ្ធិមនុស្សជាមូលដ្ឋានដើម្បីបង្ការការចោទប្រកាន់ម្តងទៀតក្នុងពេលអនាគត ឬការធ្វើបត្យាប័នណាមួយក្នុងការឡើងតុលាការនៅឯបរទេស ឧទាហរណ៍នៅទីម័រខាងកើត ។ ក៏ប៉ុន្តែ ដូចមានចែងនៅក្នុងលក្ខន្តិកៈរបស់តុលាការឧក្រិដ្ឋអន្តរជាតិ ***ne bis in idem*** អាចយកមកអនុវត្តបានតែនៅកន្លែងណាដែលដំណើការតុលាការធ្វើឡើងស្របទៅតាមបទដ្ឋានអន្តរជាតិ ។ ក្នុងករណី អាប៊ីលីអូ ស័ររ៉េ, ធីមប៊ុល ស៊ីឡែន និងករណីសម្លាប់រង្គាលនៅព្រះវិហារសួយ មិនបានធ្វើឡើងក្នុងរបៀបមួយដែលស្របគ្នាទៅនឹងគោលបំណងក្នុងការនាំយកអ្នកដែលទទួលខុសត្រូវចំពោះការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរនៅទីម័រខាងកើតឡើងតុលាការទេ ។ ក្រៅពីមិនបានផ្តោតទៅលើអំពើឃោរឃៅដែលនាំទៅដល់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងមិនដាក់ឲ្យជនដៃដល់ទទួលខុសត្រូវ ទង្វើនេះបែរជាត្រូវបានប្រើជាឱកាសដើម្បីបិទបាំងការទទួលខុសត្រូវរបស់ឥណ្ឌូនេស៊ីនៅទីម័រខាងកើត និងដើម្បីដោះលែងអ្នកដែលប្រកាន់គំនិតជាតិនិយមនិងសមាហរណកម្មនិយម ឲ្យរួចទោសទៅវិញ ។

**ស៊ូហ្សាណា លីនតុន**

**អត្ថបទរបស់សារពត៌មាន** *Leiden Journal of International Law* **លេខ១៧ ឆ្នាំ២០០៤**

# សង្គមស៊ីវិលកម្ពុជាអំពាវនាវឱ្យសហគមន៍អន្តរជាតិ ផ្តល់ជំនួយថវិកាដល់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម

យើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំអង្គការសិទ្ធិមនុស្សចំនួន១៨ដែលជាសមាជិកគណៈកម្មាធិការសិទ្ធិមនុស្សនៅកម្ពុជា និងសមាជិកផ្សេងទៀតនៃសង្គមស៊ីវិលកម្ពុជា ដែលបានចុះហត្ថលេខានៅទីនេះ សូមសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសហគមន៍អន្តរជាតិដែលកំពុងតែជួយកសាងនីតិរដ្ឋនៅកម្ពុជា ។ ទន្ទឹមនឹងនេះ យើងខ្ញុំក៏សំណូមពរឲ្យសហគមន៍អន្តរជាតិបន្តការជួយឧបត្ថម្ភថវិកាដល់មូលនិធិស្ម័គ្រចិត្តរបស់អង្គការសហប្រជាជាតិសម្រាប់ដំណើរការសាលាក្តីខ្មែរក្រហម ។

បន្ទាប់ពីរង់ចាំអស់រយៈពេល៣០ឆ្នាំ នៅទីបំផុតប្រជាជនកម្ពុជាប្រហែលជាមានឱកាសបានឃើញយុត្តិធម៌ខ្លះចំពោះឧក្រិដ្ឋកម្មដែលកើតឡើងនៅក្នុងប្រទេសក្នុងអំឡុងរបបខ្មែរក្រហម ។ នៅថ្ងៃទី៤ ខែតុលា ឆ្នាំ២០០៤ រដ្ឋសភាជាតិបានអនុម័តកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិ ដើម្បីនាំយកមេដឹកនាំខ្មែរក្រហមទៅកាត់ទោសនៅក្នុងតុលាការចម្រុះមួយ ហើយច្បាប់វិសោធនកម្មច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាក៏ត្រូវបានរដ្ឋសភាអនុម័តនៅថ្ងៃទី៥ ខែតុលា ឆ្នាំ២០០៤ ព្រឹទ្ធសភាអនុម័តនៅថ្ងៃទី៨ ខែតុលា ឆ្នាំ២០០៤ ។ ទោះជាយ៉ាងណាក្តី តុលាការនេះប្រហែលជារង់ចាំរហូតដល់ពេលមានជំនួយថវិកាគ្រប់គ្រាន់ពីសហគមន៍អន្តរជាតិទើបចាប់ផ្តើមដំណើរការ ។

យើងខ្ញុំទាំងអស់គ្នាដែលកំពុងតែធ្វើការងារអំពីវិបត្តិនៅក្នុងប្រទេសកម្ពុជាសព្វថ្ងៃ ដឹងថាកម្ពុជាត្រូវចំណាយច្រើនប៉ុនណាក្នុងការស្តារឡើងវិញនូវប្រព័ន្ធយុត្តិធម៌ ស្ថាបនាជាថ្មីនូវនីតិរដ្ឋ និងការគោរពសិទ្ធិនិងសេរីភាពរបស់ប្រជាជនកម្ពុជាគ្រប់រូប ។ ទោះជាយ៉ាងនេះក៏ដោយ យើងខ្ញុំមានជំនឿយ៉ាងមុតមាំថា ការខកខានក្នុងការបង្ហាញការពិតអំពីរបបមួយដែលប្រជាជនកម្ពុជាប្រមាណជាងមួយភាគបីបានស្លាប់ នឹងបន្តធ្វើឲ្យសង្គមខ្មែរជាប់គាំងនិងបន្ទុចបន្ទាក់ការរីកចម្រើនរបស់កម្ពុជាទាំងពេលបច្ចុប្បន្ន និងទៅអនាគត ។

យើងខ្ញុំឃើញថា តុលាការខ្មែរក្រហមគឺជាវិធីសាស្ត្រមួយក្នុងការព្យាបាលរបួសនិងស្វែងយល់អំពីការពិតមួយចំនួននៅក្នុងអតីតកាល ។ យើងខ្ញុំសង្ឃឹមថា តុលាការនេះនឹង៖

◆នាំយកឧក្រិដ្ឋជននៃរបបខ្មែរក្រហមទៅកាត់ទោសប្រកបដោយតម្លាភាព ចំហ និង ពេញលេញ ។

◆ បង្កើតឲ្យមានការកត់ត្រាប្រវត្តិសាស្ត្ររបបខ្មែរក្រហមដែលពិតនិងពេញលេញជាងមុនតាមរយៈការស៊ើបអង្កេតផ្លូវច្បាប់ ។

◆ពង្រឹងគុណភាពច្បាប់ស៊ីវិលតាមរយៈការធានាបទដ្ឋានអន្តរជាតិរបស់តុលាការនេះ ។

យើងខ្ញុំមានបំណងសង្កេតមើលដោយប្រុងប្រយ័ត្ននូវដំណើរការរបស់តុលាការនេះ ពីព្រោះនេះជាបញ្ហាប្រវត្តិសាស្ត្រនិងជាបញ្ហាអនាគតរបស់យើង ។ ក្នុងនាមជាសង្គមស៊ីវិលយើងខ្ញុំសំណូមពរឲ្យតុលាការនេះមានតម្លាភាពនិងប្រកបដោយយុត្តិធម៌ ។ យើងខ្ញុំក៏សំណូមពរទាំងចៅក្រមជាតិក៏ដូចជាចៅក្រមអន្តរជាតិដែលនឹងត្រូវតែងតាំងឲ្យធ្វើការក្នុងតុលាការនេះ គឺជាអ្នកដែលមានចំណេះដឹងខ្ពង់ខ្ពស់និងមិនស្ថិតក្រោមឥទ្ធិពលនយោបាយ ។ យើងខ្ញុំសង្ឃឹមថា សហគមន៍អន្តរជាតិដែលតែងតែយកចិត្តទុកដាក់ចំពោះបញ្ហាកម្ពុជា ក៏ចាប់អារម្មណ៍ចំពោះបញ្ហានេះដែរ ។ ផ្អែកលើបទពិសោធន៍ជាមូលដ្ឋានរបស់យើងខ្ញុំ ជាមួយនឹងតុលាការកម្ពុជា យើងខ្ញុំនៅតែមានមន្ទិលសង្ស័យ ក៏ប៉ុន្តែយើងខ្ញុំជឿជាក់ថាមានជម្រើសតិចតួចក្រៅពីទុកឲ្យតុលាការនេះបង្ហាញដោយខ្លួនឯង ។ បើពិនិត្យមើលអាយុរបស់មេដឹកនាំខ្មែរក្រហមនិងទំហំនៃបទល្មើសដែលអ្នកទាំងនោះបានប្រព្រឹត្ត យើងគួរតែឆក់យកឱកាសនេះនាំឧក្រិដ្ឋជនទាំងនោះទៅតុលាការ បើមិនដូច្នោះទេ

យើងនឹងគ្មានឱកាសជារៀងរហូត ។

ទោះជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះវិសាមញ្ញនេះនឹងទទួលបានជោគជ័យប្រសិនបើមានថវិកាគ្រប់គ្រាន់សម្រាប់ចំណាយក្នុងការស៊ើបអង្កេត ជួលបុគ្គលិកដែលមានសមត្ថភាព និងផ្តល់ការការពារតាមផ្លូវច្បាប់និងផ្នែកសុខភាពដល់ចុងចោទ ជនរងគ្រោះនិងសាក្សី ។ ការផ្តល់ជំនួយទៅឲ្យមូលនិធិស្ម័គ្រចិត្តក៏ដូចជាការតាមដានសង្កេតមើលដំណើរការរបស់តុលាការ មានសារសំខាន់ក្នុងការធ្វើឲ្យតុលាការនេះមានតម្លាភាព ឯករាជ្យ និងគោរពបទដ្ឋានអន្តរជាតិ តាមដែលអាចធ្វើបាន ។ ហេតុដូច្នេះហើយយើងខ្ញុំសំណូមពរដល់បណ្តាប្រទេសម្ចាស់ជំនួយសូមមេត្តាផ្តល់ជំនួយដល់មូលនិធិស្ម័គ្រចិត្តរបស់អង្គការសហប្រជាជាតិសម្រាប់ចំណាយលើតុលាការនេះ ។

យើងខ្ញុំសំណូមពរសហគមន៍អន្តរជាតិសូមមេត្តាផ្តល់ការគាំទ្រនេះចំពោះប្រទេសកម្ពុជាដូចដែលធ្លាប់បានធ្វើរួចមកហើយចំពោះតុលាការអន្តរជាតិនៅអឺរ៉ុបនិងអាហ្វ្រិកដែលមានទំហំធំធេងនិងចំណាយថវិកាយ៉ាងច្រើនសន្ធឹកសន្ធាប់ ។ យើងខ្ញុំសូមកោតសរសើរចំពោះប្រទេសមួយចំនួនដែលបានជួយក្នុងការបង្កើតតុលាការនេះ ។ យើងខ្ញុំនិងអ្នកសង្កេតការណ៍ជាច្រើននាក់ទៀតបារម្ភចំពោះភាពទន់ខ្សោយនិងគុណវិបត្តិរបស់តុលាការកម្ពុជា ហើយយើងបានបង្ហាញកង្វល់នេះតាមរយៈឯកសារ និងតាមរយៈការថ្លែងជាសាធារណៈច្រើនដងរាប់មិនអស់រួចមកហើយ ។ ទោះជាយ៉ាងណាក៏ដោយ យើងខ្ញុំជឿជាក់ថា វាគួរឲ្យសោកស្តាយខ្លាំងណាស់ប្រសិនបើតុលាការខ្មែរក្រហមមិនអាចដំណើរការនៅពេលនេះបានដោយសារតែមូលហេតុខ្វះថវិកា ។

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការឧបត្ថម្ភគាំទ្ររបស់សហគមន៍អន្តរជាតិក្នុងការពង្រឹងសង្គមស៊ីវិលនិងនីតិរដ្ឋនៅកម្ពុជា ។ ដោយមានជំនួយរបស់សហគមន៍អន្តរជាតិយើងខ្ញុំសង្ឃឹមថានឹងបើកទំព័រថ្មីនៃយុត្តិធម៌និងសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា ។

# ពៀរអាចរំងាប់បានដោយការមិនចងពៀរ

អត្ថបទការផ្សះផ្សានៅកម្ពុជាដែលសរសេរដោយអ្នកស្រី ស៊ូហ្សាណា លីនតុន ជាប្រធានរឿងមួយដ៏ធំធេងណាស់សម្រាប់ស្តារនិងកសាងកម្ពុជាឲ្យមានសុវត្ថិភាព ។ ខ្ញុំសូមគោរពចំពោះអ្នកស្រី ស៊ូហ្សាណា លីនតុន ដែលបានធ្វើវិភាគជុំវិញអត្ថបទនេះតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យ នីតិវិធីយុត្តិធម៌ ធម្មាធិបតេយ្យ រួមផ្សំនឹងទ្រឹស្តីព្រះពុទ្ធ "ពៀរអាចរំងាប់បានដោយការមិនចងពៀរ" ដោយតម្រូវដោះស្រាយតាមរយៈតុលាការជាតិនិងអន្តរជាតិជូនជនរួមជាតិនូវសេចក្តីថ្លៃថ្នូរដែលប្រជារាស្ត្រទូទៅប្រាថ្នាចង់បានដែលកន្លងមកកម្រមានវរជនណាយកមធ្យោបាយនេះមកប្រើប្រាស់ក្នុងការអប់រំ ផ្សះផ្សា និងការកសាងសង្គមខ្មែរ ។ ជាអកុសល មេដឹកនាំនយោបាយខ្មែរមិនដែលយកវិធីបែបនេះមកអប់រំក្នុងជួរនយោបាយទេ ។ ជាទូទៅអ្នកនយោបាយខ្មែរតែងតែអះអាងថាខ្លួនជាអ្នកស្នេហាជាតិ ដើរអំពាវនាវប្រមូលកម្លាំងឲ្យគាំទ្រខ្លួនដើម្បីការពារទឹកដីនិងជាតិសាសន៍ បំពាក់បំប៉នកំហឹងហិង្សាសងសឹកដោយកម្លាំងបាយ ។ នៅទីបញ្ចប់ លទ្ធផលដែលបានមកគឺៈ ១) បានត្រឹមតែបម្រើប្រយោជន៍បុគ្គលដែលលោភលន់អំណាចនិងបំប៉នតណ្ហាពោរពេញដោយលោភៈទោសៈ ។ ២) ប្រទេសជាតិទទួលបានតែការបាត់បង់កាន់តែធ្ងន់ថែមទៀត ។ ប្រជារាស្ត្របាក់បែក គ្មានសន្តិសុខ ប្រកាន់យកទ្រឹស្តីខុសគ្នាហើយបង្ក្រាបគ្នាទៅវិញទៅមកដោយប្រើកម្លាំងហិង្សា ជាកត្តានាំឲ្យហ៊ានសម្លាប់កម្ទេចពូជសាសន៍ឯង គ្រួសារឯង បំផ្លាញទ្រព្យសម្បត្តិជាតិ ប្រទេសជាតិ ដែលពិបាកនឹងជឿបាន ។ ទោះបីនៅសម័យនេះមានជនដៃដល់ដែលធ្លាប់បានប្រព្រឹត្តអំពើឃោរឃៅលើពូជសាសន៍ឯងមួយចំនួនបានសរសេរអត្ថបទរបស់ខ្លួនដោយសារភាពទាំងវិប្បដិសារីតាមរយៈសៀវភៅស្វែងរកការពិត យ៉ាងណាក៏ដោយ ក៏នៅតែមានមនុស្សមួយចំនួននិងមេដឹកនាំខ្លះ

នៅតែមិនព្រមសារភាពអំពើយង់ឃ្នងដែលខ្លួនបានអនុវត្តមមក លើប្រទេសជាតិដែរ ហើយបន្តឃោសនាថា អំពើឃាដកម្មដ៏ធំនោះគឺជាយួនទេដែលជាអ្នកប្រព្រឹត្ត "វាចូលមកសម្លាប់ ហើយធ្វើជាចូលមកជួយជានយោបាយចង់បានទឹកដី" ។

ព្រះពុទ្ធបានសម្តែងថា "មនុស្សគ្រប់រូបត្រូវតែប្រឈមមុខទទួលកម្មផលដែលខ្លួនបានប្រព្រឹត្ត" ។ ការស្វែងរកយុត្តិធម៌ជូនជនរងគ្រោះតាមរយៈតុលាការជាតិនិងអន្តរជាតិបានផ្តល់នូវក្តីអំណរឥតខបមាដល់ប្រជារាស្ត្រទន់ខ្សោយដែលអាចរំសាប់អារម្មណ៍ឈឺចាប់របស់ខ្លួន និងបន្តជីវិតរស់នៅឲ្យបានសុខសាន្តទៅអនាគត ។ សុភាសិតបារាំងមួយបានចែងថា "គំនិតរបស់អ្នកខ្លាំងតែងតែត្រូវជានិច្ច" (La raison du plus fort est toujours la meilleure) ទន្ទឹមគ្នានឹងអ្នកដែលខំធ្វើការស្វែងរកយុត្តិធម៌ជូនជនរួមជាតិ អ្នកនយោបាយមួយចំនួនក៏ខំឃោសនា បំពាក់បំប៉ន គោលជំហរប្រកាន់យកគំនិតបដិសេធថា មិនមែនខ្មែរក្រហមទេដែលប្រព្រឹត្តឧក្រិដ្ឋកម្មនេះជាល្បិចរបស់យួនទេ ចូររួមគ្នាឡើងដើម្បីការពារទឹកដី ។ ដូច្នេះគួរតែប្រយ័ត្នការឃោសនានៃអ្នកនយោបាយខ្លះដែលអះអាងថាខ្លួនស្នេហាជាតិ ស្អាតស្អំ រិះគន់អំពើពុករលួយជាលេសមួយក្នុងល្បិចកលឲ្យអ្នកផងគាំទ្រខ្លួនដើម្បីឆានៅក្នុងន័យដុតឲ្យខ្លោចរោចឲ្យឆៅ មិនឲ្យលទ្ធិប្រជាធិបតេយ្យសិទ្ធិមនុស្សលូតលាស់បាន ។ ឧទាហរណ៍ កាលជំនាន់មុនឆ្នាំ១៩៧០ លោកខៀវ សំផន បានឃោសនាទូទាំងប្រទេសថា ខ្លួនជាអ្នកស្នេហាជាតិជាបុគ្គលស្អាតស្អំ ស្មោះត្រង់នឹងជាតិ មិនលក់ខ្លួនឲ្យបរទេស តែដល់ខ្លួនគាត់កាន់អំណាចវិញ គាត់ដេញប្រជាជនឲ្យចុះចេញពីផ្ទះតែខ្លួនទទេ ហើយយកទ្រព្យសម្បត្តិរបស់ជាតិនិងប្រជាជនតាមអំពើចិត្ត ។ ទាំងអស់គ្នាសុទ្ធតែអះអាងថាជាអ្នកស្នេហាជាតិ គាំទពីប្រជារាស្ត្រតូចតាចរហូតដល់មេដឹកនាំកំពូល ។ ពេលចូលប្រឡូកក្នុងជួរនយោបាយ ម្នាក់ៗពុំមានការស្មោះត្រង់ជាតិនិងប្រជារាស្ត្រទេ គិតតែធ្វើយ៉ាងណាតម្រូវចិត្តមហាអំណាចបរទេស មហាអំណាចនេះមហាអំណាចនោះ ហើយសុំឲ្យមហាអំណាចទាំងនោះជួយតែការភ្លើងយកមកសម្លាប់គ្នាទៅវិញទៅមកដើម្បីការពារខ្លួនក្នុងអត្តចរិតមហិច្ឆតាលោភលន់អំណាចផ្ទាល់ខ្លួនតែប៉ុណ្ណោះ ។ ដូច្នេះមុននឹងសម្រេចចិត្តគាំទ្រមេដឹកនាំនយោបាយណាមួយ ចូរធ្វើការពិចារណាឲ្យបានល្អិតល្អន់ពីគុណសម្បត្តិនិងគុណវិបត្តិនៃបុគ្គលនោះ មិនមែនគ្រាន់តែអះអាងថាខ្លួនស្នេហាជាតិស្អាតស្អំជាការគ្រប់គ្រាន់នោះទេ ។ ត្រូវស្វែងរកការពិតមួយថាតើបុគ្គលនោះមានសមត្ថភាពកសាងជាតិប៉ុណ្ណេះទេ និងដោយរបៀបណា?

បងប្អូនរួមជាតិជាទីស្នេហា ចូរចាប់អារម្មណ៍ក្នុងសម័យបច្ចុប្បន្ននេះ ប្រទេសជាតិយើងមានភ័ព្វវាសនាទទួលបាននូវមាគ៌ាលទ្ធិប្រជាធិបតេយ្យ ជារបបមួយដែលផ្តល់សិទ្ធិឲ្យប្រជារាស្ត្រជាធំ ដែលកន្លងមកមិនធ្លាប់បានយកមកអនុវត្តនៅប្រទេសយើងទេ ។ ប្រជារាស្ត្រគ្រប់រូបគួរតែនាំគ្នាសិក្សាអំពីលទ្ធិប្រជាធិបតេយ្យនេះឲ្យបានចេះដឹងជ្រៅជ្រះដើម្បីយកទៅអនុវត្តឲ្យបានសមស្របទៅនឹងបំណងកសាងប្រទេសជាតិ ឈានទៅកាន់ការអភិវឌ្ឍជឿនលឿន កុំឲ្យចាញ់ប្រទេសជាតិខាង ។ ជាកម្លាំងពង្រឹងស្មារតីការពារប្រទេសជាតិ និងទឹកដី ។

**ហ៊ុំ ឃីម**

# ស្តាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតឲ្យមានកម្មវិធីអានអត្ថបទទស្សនាវដ្តីស្វែងរកការពិតដែលចាក់ផ្សាយរៀងរាល់ថ្ងៃពុធនិងព្រហស្បតិ៍ វេលាម៉ោង៣ៈ៣០-៣ៈ៤៥នាទី តាមរយៈវិទ្យុ FM១០២ MHz របស់មណ្ឌលពត៌មានស្ត្រីកម្ពុជា ។

មជ្ឈមណ្ឌលក៏បានបង្កើតកម្មវិធីដូចគ្នានេះផ្សាយតាមស្ថានីយ៍វិទ្យុ FM៩៣.២៥MHz ខេត្តកំពតជារៀងរាល់ថ្ងៃ នៅម៉ោង៧-៧ៈ៣០នាទីព្រឹក និងម៉ោង៧-៧ៈ៣០នាទីល្ងាចនិងស្ថានីយ៍វិទ្យុ FM៩៩MHz ខេត្តព្រះវិហារ នៅម៉ោង៧-៧ៈ៣០នាទីព្រឹក និងម៉ោង៦ៈ៣០-៧នាទីល្ងាច ។

នៅក្នុងពេលដ៏ខ្លីខាងមុខនេះ មជ្ឈមណ្ឌលឯកសារកម្ពុជានឹងផ្សាយកម្មវិធីដូចគ្នានេះនៅគ្រប់បណ្តាស្ថានីយ៍វិទ្យុខេត្តនៃព្រះរាជាណាចក្រកម្ពុជា ។

យើងខ្ញុំសង្ឃឹមថា កម្មវិធីនេះនឹងចូលរួមចំណែកក្នុងការផ្តល់ឱកាសឲ្យប្រជាជនកម្ពុជាស្វែងយល់អំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហម និងទប់ស្កាត់ការកើតមានឡើងវិញនៃរបបនេះ ។

**លី សុផល និង ស្វ ហ្វារីណា**

## *ពីប្រទេសកាណាដា:*

# រឿងរ៉ាវរបស់ជនរងគ្រោះនៃរបបខ្មែរក្រហម

*(អត្ថបទខាងក្រោមនេះគឺជាការចម្លងចេញពីកាសែតថតសំឡេងមួយដែលមជ្ឈមណ្ឌលឯកសារកម្ពុជាទទួលបានពីប្រជាជនខ្មែរមួយក្រុមរស់នៅប្រទេសកាណាដា ។)*

**អ្នកស្រី ផង់ស៊ី នួៈ** ថ្ងៃនេះជាថ្ងៃទី៣១ ខែតុលា ឆ្នាំ២០០៤ ។ ទីនេះគឺជាប្រទេសកាណាដា ខេត្តប្រ៊ីតទីសកូឡុមប៊ីយ៉ា ទីក្រុងវែនខូវើ ។ ខ្ញុំមានចិត្តសប្បាយនឹងនិយាយរឿងរ៉ាវជម្រាបជូនដល់បងប្អូនយើងអំពីការរស់នៅក្នុងរយៈពេល៤ឆ្នាំជាមួយរបបកុម្មុយនិស្តយើងថា "របបប៉ុលពត" ។

នៅក្នុងឆ្នាំ១៩៧៥ គឺនៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ជាថ្ងៃដែលពួក ប៉ុល ពត បានវាតត្បាតចូលដល់ទីក្រុងភ្នំពេញ ភ្លាមនោះខ្ញុំភ័យផងអរផង ជាពិសេសភ័យច្រើនជាងអរ ។ ខ្ញុំបានឃើញពួកមិត្តយើងជាច្រើនចូលមកដល់ទីក្រុង កាន់កាំភ្លើងគ្រប់ដៃ មានទាំងរថក្រោះបើកពេញនៅលើវិថីទីក្រុងភ្នំពេញ ប្រទេសកម្ពុជា ។ ផ្ទះខ្ញុំនៅត្រង់កន្លែង១៨មីនា នៅកាច់ជ្រុងវិទ្យាល័យយុគន្ធរ ។ ពេលនោះខ្ញុំឃើញមិត្តយើងក្មេងៗកាន់កាំភ្លើងមកភ្ជង់ហើយប្រាប់ថាឲ្យថយចេញទៅ ពីព្រោះអាមេរិកាំងនឹងយកកប៉ាល់ហោះមកទម្លាក់គ្រាប់បែកលើយើង ឲ្យចេញសិនឲ្យចេញតែពីរ-បីថ្ងៃទេ មិត្តឯង ម៉ែឯង មិនបាច់យកអីទៅទេ ។ ខ្ញុំភ្ញាក់ដែរ ព្រោះខ្ញុំអត់ដែលឮសូរភាសាគាត់ គាត់ហៅខ្ញុំម៉ែ ខ្ញុំត្រូវហៅគាត់ថាមិត្តវិញ ចង់មិត្តតូចមិត្តធំអីសុទ្ធតែមិត្តទាំងអស់ ។ ពេលនោះខ្ញុំនិយាយជាមួយស្វាមីខ្ញុំថា យើងគួរតែនាំគ្នាភៀសខ្លួនទៅរកកន្លែងណាស្ងាត់សិនទៅ ព្រោះអីស្រុកយើងឥឡូវអត់ស្រួល ។ បងប្អូនដែលបានមកឲ្យប្តីខ្ញុំឲ្យជួយពិនិត្យរោគហ្នឹងគេតែងតែនិយាយថា លោកស្រីអញ្ជើញចេញទៅព្រោះគេអារ-កយើងនឹងធាងត្នោត ខ្ញុំថាខ្ញុំមិនជឿទេ មនុស្សឯណាក៏ធ្វើដល់ថ្នាក់ហ្នឹង គាត់ថាធ្វើមែន កូនក្មេងគេលើកជើងពីរឡើងគេបោកនឹងសសរ ឬមួយបោកនឹងដើមឈើក៏ស្លាប់ទៅ គេគ្រវាត់ចោលទៅ ខ្ញុំមិនជឿគេទៀត ។ ប្រហែល៣ថ្ងៃក្រោយគេឲ្យយើងចេញទាំងអស់ ។ គេចូលមកដល់កន្លែងខ្ញុំហ្នឹងនៅម៉ោង៧ព្រឹក ដល់ម៉ោង១១ថ្ងៃស្រាប់តែមិត្តយើងចូលមកថា ឥឡូវម៉ែចេញទាំងអស់ ម៉ែឯងចេញទៅគ្មានយកអីទៅជាមួយទេ ។ ខ្ញុំក៏ប្រមែប្រមូលអង្ករដែលនៅសល់ជាងកន្លះការុងទៅដាក់ក្នុងឡានហ្នឹងទៅ ម្តាយចាស់មួយផង ហើយខ្ញុំនិងកូនខ្ញុំអាយុ៣-៤ខែ ក៏រុញឡានចុះទៅក្រោម តាមផ្លូវព្រះមុនីវង្ស ។ គេចេះតែថាឲ្យទៅអង្គការលើ គ្រាន់តែចេញទៅបានបន្តិច ពួកមិត្តយើងគាត់ស្នើ គេថា"ស្នើ" ខ្ញុំមិនដែលនិយាយទេ ពាក្យ "ស្នើ" ពាក្យសន្តមគាត់ថាសុំស្នើនាឡិកា សុំស្នើរ៉ាដ្យូ ស្អីៗដែលមានប៉ុន្មានហ្នឹងគាត់សុំស្នើទាំងអស់ ក៏ជូនទៅគាត់អស់ទៅ ពីព្រោះថាអ្នកខ្លះមាត់រឹងមិនព្រមឲ្យគាត់បាញ់ ខ្ញុំឃើញគាត់បាញ់ស្លាប់ភ្លាម ។ គេរុញយើងឲ្យដើរទៅមុខអត់មានថយក្រោយឯណា ម្ល៉ោះហើយបងប្អូនម៉ែឪក៏ដោយ តែបែកគ្នាតែបន្តិចបាត់គ្នាបាត់រកអត់ឃើញទេ ។ ខ្ញុំចុះពីឡាន គេអត់ឲ្យយើងជិះឡានទេ គេឲ្យយើងរុញឡានពីព្រោះកាលណាយើងជិះឡាន គេថាយើង មូលធននិយម អ្នកមានជិះជាន់អ្នកក្រ ។ ខ្ញុំទៅតាមផ្លូវឃើញប្អូនមួយហ្នឹងក្មេងដែរគាត់ឈឺពោះ ព្រោះគេដេញមនុស្សចេញពីពេទ្យចិន ។ ពេទ្យចិននៅទល់មុខផ្ទះខ្ញុំ ពេលចេញដំណើរហ្នឹង អត់មានគិតអ្នកណាទេ នាងហ្នឹងឈឺពោះ គាត់កើតកូននៅកណ្តាលថ្នល់ ដូចសត្វដូចធាតុអីចឹង អត់មានមនុស្សធម៌ទេ ។ បើកឡានហ្នឹងទៀត ខ្មែរក្រហមហ្នឹង បើថាឃើញនៅមុខ យើងអត់ចៀសគាត់បើកកិនហើយតែកិនហើយហីទៅ ទៅកៀនថ្នល់ទៅ ហើយអ្នកណាដើរទៅមុខទៀតចេះតែដើរទៅជាអំពើមួយព្រៃផ្សៃចំពោះខ្ញុំ ។ ខ្ញុំមិនដឹងអ្នកឯទៀតគិតយ៉ាងម៉េចទេ ចំពោះខ្ញុំជាអំពើមួយព្រៃផ្សៃ គ្មានមនុស្សធម៌ក្នុងខ្លួនទាល់តែសោះ អត់មានអាណិតមនុស្សចាស់អ្នកដែលគ្នាសម្រាលកូនសម្រាលចៅអី ក៏អត់មានអីទាំងអស់ ។ អ្នកឈឺនៅក្នុងផ្ទះពេទ្យហ្នឹងក៏អត់ មានដកសេរ៉ូមចេញទេ រុញ

ចេញក្រៅអស់រលីង បើថាមិនចេញគឺថាបាញ់ផ្តួលៗ ស្លាប់អស់អត់មានសល់ទេ ។ នៅតាមផ្លូវមនុស្សម្នាទាំងឡាយប្របូកប្របល់គ្នាណាស់ មិនដឹងអ្នកណាទៅរកអ្នកណាទេ ។

ដប់ថ្ងៃក្រោយមកបានខ្ញុំទៅដល់ទីកន្លែងមួយឆ្ងាយពីភ្នំពេញប្រហែលជា៣០គីឡូម៉ែត្រ គេហៅថា«វត្តកណ្តាល» ។ ខ្ញុំសួរបងប្អូនថា នៅឯណាអង្គការលើនោះ? គេថាទៅមុខទៀតទៅ ខ្ញុំថាទៅមុខឯណា ខ្ញុំទៅមុខអស់៣០គីឡូម៉ែត្រ អត់ឃើញអង្គការលើនៅកន្លែងណាទេ ខ្ញុំចង់ទៅដល់គាត់ ។ គាត់ថាឥឡូវហ្នឹងមិត្តឯងនៅកន្លែងហ្នឹងហើយ មើលក្រោមផ្ទះអ្នកណាទំនេរសុំគេចូលនៅទៅ កន្លែងហ្នឹងហើយអង្គការលើ ។ នៅពេលនោះគ្រួសារខ្ញុំទាំងអស់នាំគ្នាឈប់សម្រាកនៅផ្ទះមួយ ។ គេនៅខាងក្រោម ខ្ញុំនៅខាងលើទាំងអស់បីគ្រួសារ គ្រួសារខ្ញុំមួយ គ្រួសារមិត្តភក្តិខ្ញុំមួយ និងគ្រួសារមួយទៀតប៉ុន្តែខ្ញុំអត់ដែលស្គាល់ទេ ។ ទៅដល់ភ្លាម គេក៏ប្រាប់ឲ្យទៅចុះឈ្មោះដើម្បីចែកអង្ករ ខ្ញុំក៏អរដែរ ព្រោះអីយើងអត់មានអង្ករអីទេ យើងញុំានៅតាមផ្លូវអស់ហើយ ។ បន្ទាប់មកគេប្រាប់ថា ឲ្យយើងទៅធ្វើស្រែទៅធ្វើចម្ការ ។ ព្រលឹមឡើងម៉ោង៦គេឲ្យយើងចេញ ដល់ល្ងាចឡើងម៉ោង៥-៦ឯណោះបានគេឲ្យឡើងមកវិញ ។ គេចែកបាយចែកអង្ករអីក៏មិនសូវអីប៉ុន្មានទេ នៅគ្រាន់ដែរទេ ។ ខ្ញុំស្នាក់នៅទីកន្លែងនោះបាន៣ខែគេយកកប៉ាល់មកដឹកពួកខ្ញុំទាំងអស់គ្នាទៅកាន់ខេត្តពោធិសាត់កាត់តាមមុខវាំង ។ កូនខ្ញុំទាំងអស់គ្នាចេះតែថា យើងទៅផ្ទះវិញទៅដល់មុខវាំងហើយម៉េចក៏មិនឃើញកប៉ាល់ចូល? ទៅហួសធ្វើអី? ខ្ញុំមិនហ៊ានសួរគេ ព្រោះគេស្លៀកពាក់ខោអាវខ្មៅទាំងអស់កាំភ្លើងវែងៗណាស់ កាំភ្លើងអត់គ្រាប់ក៏ខ្លាចដែរ ។ ទៅដល់ពោធិសាត់គេដេញឲ្យឡើងគោកដូចគោដូច ក្របីអីចឹង អ្នកខ្លះទៅជួបផ្ទះអ្នកស្រុក ទៅឃើញអង្ករ ឃើញប្រហុក ផ្អក អំបិលនាំគ្នាយក ព្រោះដឹងថាគ្មានអ្នកណាផ្តល់ឲ្យយើងទេ ។ ខ្ញុំសម្រាកបានមួយយប់ដល់ព្រលឹមឡើងធ្វើដំណើរទៅតាមរទេះភ្លើងមកខាងបាត់ដំបង ។ រទេះភ្លើងដាក់អីវ៉ាន់និងមនុស្ស មានទាំងមនុស្សឈឺ មានមនុស្សចាស់និងកូនក្មេងតូចៗ មកដល់កន្លែងមួយគេហៅថាភ្នំធិបដេ គេប្រាប់ឲ្យអ្នកនៅក្នុងរទេះភ្លើងទាំងប៉ុន្មានចុះ ។ ខ្ញុំសួរថា នៅកន្លែងណាទៅមិត្ត បើអត់មានអីផង ឃើញតែវាលទទេហ្នឹង គេប្រាប់ថាកុំមាត់ច្រើន ខ្ញុំក៏ឈប់សួរទៅ ។ ម៉ែកូនយកក្រណាត់កៅស៊ូបាំងធ្វើជាទីជម្រកទឹកភ្លៀង ធ្វើកូនខ្ទមនៅកន្លែងហ្នឹង ។ ខ្ញុំនៅកន្លែងហ្នឹងបាន២ឆ្នាំកន្លះ ការវេទនានោះគឺថារកមិនបានទេ ជាពិសេសប្រជាជនខ្មែរ-ចិនដែលគាត់មិនធ្លាប់ពិបាកសោះនោះគឺថាមួយគ្រួសារមាន៨-១០នាក់ សែងគ្នាយកទៅកប់រាល់ថ្ងៃ អាមួយឯរាប់ទៅអាមួយនៅរស់សែងយកទៅ២នាក់ ស្អែកឡើងទៅសែងទៀត សែងតគ្នារហូតស្លាប់ទាល់តែស្ងាត់ភូមិអស់ ។ គេនិយាយប្រាប់យើងទៀតថា ឲ្យមិត្តយើងខំធ្វើការហត្ថកម្មទៅនឹងបានចម្រុងចម្រើនបន្តិចទៀតយើងមិនបាច់ចាំរកគោមកទឹមទេ គឺសុទ្ធតែអាត្រាក់ទ័រ ។ ខ្ញុំដេកសង្ឃឹម ប៉ុន្តែសង្ឃឹមនៅក្នុងអស់សង្ឃឹម ។ ការស្លាប់ដោយសារអត់បាយផង រោគផងដល់អ៊ីចឹងទៅស្លាប់បន្តគ្នាអស់ ។ មិត្តភក្តិរបស់ខ្ញុំដែលជាអ្នកធ្វើការដូចគ្នា ស្លាប់អស់អត់មានសល់ទេ ។ ខ្ញុំបានជួបមិត្តភក្តិប្តីខ្ញុំម្នាក់គាត់ធ្វើគ្រូពេទ្យនៅបាត់ដំបង គាត់ប្រាប់ខ្ញុំថា គាត់យកខ្មោចកូនរបស់គាត់ទៅកប់នៅក្រោមគ្រែដើម្បីទុករបបកូនហូបបន្ថែម ។ បានន័យថាធ្វើបាបមនុស្សហ្នឹងគ្មានមនុស្សធម៌បន្តិចសោះ ។

នៅពេលមួយនោះ លោកម្នាក់ដែលដើរតួកុនខ្មែរយើងឈ្មោះ ង៉ោ វេជ្ជបណ្ឌិត ហាំង ង៉ោ គាត់បានដើរតួក្នុងរឿង *Killing Field* ថ្ងៃមួយគាត់ទៅរកប្តីខ្ញុំ ព្រោះប្តីរបស់ខ្ញុំធ្វើពេទ្យដូចគ្នា ប៉ុន្តែយើងលាក់ប្រវត្តិរូប បើគេដឹងគេយកទៅសម្លាប់ចោលហើយ ។ គេចង់យកគ្រួសារខ្ញុំទៅវ៉ៃចោល៣ដងហើយ ប៉ុន្តែទេវតាលោកអាណិតអាសូរ គេចេះតែខុសពេលខុសវេលា គេមិនបានយកទៅ ។ នៅមុនដែលលោក ង៉ោ មកសួរ ប្តីខ្ញុំនៅខ្ទម គាត់សួរខ្ញុំថា អ្នកបងៗ បងប្រុសនៅឯណា? ធម្មតាគ្រួសារ (ប្តីប្រពន្ធ) គេអត់ហៅបងហៅអូនទេ តែហ៊ានហៅបាត់ខ្លួនឥឡូវហើយ ទាល់តែហៅមិត្តបង មិត្តអូន ឬមិត្តម៉ែ ស្អីៗក៏មិត្តទាំងអស់ ។ គាត់សុំឲ្យគ្រួសារខ្ញុំជួយប្រពន្ធគាត់ផង ព្រោះប្រពន្ធគាត់ត្រូវកើតកូន ។ ប្តីខ្ញុំគាត់ឆ្លើយទៅវិញថា ជួយម៉េចបាន បើយើងប្រាប់គេថាយើងអត់ធ្វើពេទ្យផង ហើយម្យ៉ាងទៀតខ្ញុំមានតែម្រាមដៃ១០ ធ្វើអីកើត ។ អាទិត្យមុនហ្នឹងគ្រួសារខ្ញុំបានជួយខ្មែរម្នាក់ដែរ ថាលួចលាក់ក៏បាន ថាមិនលួចលាក់ក៏បាន ពីព្រោះមានបញ្ហាឲ្យគាត់ទៅជួយនាងហ្នឹង នាងហ្នឹងក៏សម្រាលកូនដែលស្លាប់នៅក្នុងពោះ

រួចទៅហើយ ។ គេក៏ដាក់ផ្សាយទៅគ្រប់ទាំងអស់ ប្រាប់ទៅគណៈស្រុកថា អាឡូវហ្នឹងនៅភូមិធិបដេមានតាម៉ប មិនមែនយាយម៉បទេ បើអ៊ីចឹងទេចាត់ការឲ្យឆាប់ៗ ។ ២-៣ថ្ងៃក្រោយមកប្រពន្ធគាត់ក៏ស្លាប់ ។ ខ្ញុំហ្នឹងដល់ទៅមែនទែនមិនដឹងជាថ្ងៃសៅរ៍ថ្ងៃអាទិត្យទេ អត់មានប្រក្រតីទិនមើលដឹងរនោចដឹងខ្នើតដោយសារតែលោកខែហ្នឹងឯង គ្មានដឹងថ្ងៃដឹងខែអីទេ ស្តាប់តែវិទ្យុគេហ្នឹងគេឲ្យខំតែធ្វើការ ។ ខ្ញុំរត់មកទៅកន្លែងមួយផ្សេងទៀត ពីព្រោះបើមិនលួចរត់ទេ តាម៉បហ្នឹងត្រូវយកទៅសម្លាប់ទាំងអស់ ។ នៅកន្លែងថ្មីមេក្រុម មេកងគាត់មានធម៌សប្បុរស គាត់អ្នកមូលដ្ឋានចាស់គាត់ឲ្យបាយសម្លដែលនៅសេសសល់មកក្រុមគ្រួសារខ្ញុំ ក៏បានហូបចុកគ្រប់គ្រាន់អ៊ីចឹងទៅ ។ ដល់ថ្ងៃមួយក៏ស្រាប់តែឮសូរកាំភ្លើងក្តុងក្តាំងៗ គេថាយួនចូលមករំដោះខ្មែរខ្ញុំដូចជាឆ្ងល់ដែលថាយួនមករំដោះខ្មែរម៉េចទៅវិញដូចជាមិនយល់ដែរ ប៉ុន្តែនៅកន្លែងនោះមិនអាចស៊ើបដឹងការពិតយ៉ាងម៉េចទេ គឺស្រេចតែគេថាខាងណាយើងទៅខាងហ្នឹង ខ្ញុំបានរត់ចេញពីទីតំបន់ថ្មីមកដល់ក្រុងបាត់ដំបង ។ នៅពេលខ្ញុំដើរកាត់វាលស្រែឆ្លងស្ពានមកជួបជាតិមកបាត់ដំបង យួនដែលមកជួយហ្នឹង ពួកស័ក្តិ៣ ស័ក្តិ៤ហ្នឹង ជិះឡានហ្សុីប បានសួរយើងរកខ្មែរក្រហម វាសួរជាភាសាយួន ខ្ញុំចេះយួនដែរ ព្រោះខ្ញុំមានពួកម៉ាកយួន និយាយយួនជាមួយវាយូរៗចេះភាសាយួន ។ ខ្ញុំប្រាប់វាជាភាសាយួនថា ខ្មែរក្រហមរត់ទៅខាងមុខអស់ហើយ បើអ្នកឯងចង់ដេញទៅដេញខាងមុខទៅពួកខ្ញុំអត់ដឹងអីទេ ។ ខ្ញុំឃើញមនុស្សស្លាប់និងរបួស ស្លាប់នៅកណ្តាលថ្នល់ហ្នឹង អ្នកខ្លះទៀតយកគ្នាទៅអង្កន់ៗដូចយើងអង្កន់ត្រីត្បូកប៉ុណ្ណឹងហើយអត់ទាន់ស្លាប់ទៀត ។ ខ្ញុំឃើញអ៊ីចឹង ក៏ការឆ្លងកាត់មកឆ្ងាយៗមកទៀត ឃើញមីនផ្ទុះតាមផ្លូវខ្ញុំមិនហ៊ានដើរចេញពីថ្នល់ទេ ។ ខ្ញុំគ្រាន់តែចង់ជម្រាបប៉ុណ្ណឹង ។

ខ្ញុំសូមបើកវង់ក្រចកនិយាយពីអារម្មណ៍របស់ខ្ញុំបន្តិចកាលដែលខ្ញុំរស់នៅឆ្នាំទីពីរក្នុងរយៈពេល៨ឆ្នាំ ខ្ញុំអត់ចង់រស់ទៀតទេ ។



រស់យ៉ាងម៉េចបើវេទនាយ៉ាងហ្នឹង? ព្រលឹមឡើងដើរបេះផ្លែដង្កោយកទៅបន្សាបដើម្បីហូបសន្តត់ពោះវាឃ្លាន ណាមួយកូនខ្ចីទៀត វេទនាពេក ថានឹងចង់កខ្វាចវាតឹងក ឥឡូវថាយកការបិតមកចាក់វាដូចជាឈឺពេក ។ ខ្ញុំចេះតែបន្ទោសគ្រួសារ(ប្តី) ខ្ញុំថា ប្រាប់មិនជឿ ហ្នឹងហើយមនុស្សធម៌អ្នកឯងនោះ មនុស្សធម៌ខ្លាំងពេក ឥឡូវគេធ្វើមនុស្សធម៌ដាក់យើងវិញអ៊ីចឹង ។ ទីបញ្ចប់ខ្ញុំថាខ្ជិល មិនសម្លាប់ខ្លួនឯងទេ ចេះតែទ្រាំនៅវេទនាធ្វើការ១៣ម៉ោង១២ម៉ោងជាមួយទឹកបបរហ្នឹងហុតបន្តិចបន្តួចហ្នឹងទៅ ។ ប៉ុន្តែខ្ញុំសូមលើកគុណសម្បត្តិខ្លះដែរ អ្នកធ្វើរបបកុម្មុយនិស្តប៉ុលពតហ្នឹង ខ្ញុំឃើញកន្លែងនេះមួយ ពីមុនខ្ញុំមិនដែលស្គាល់ដើមស្រូវទេ ឥឡូវខ្ញុំស្គាល់ ខ្ញុំចេះធ្វើស្រែ ខ្ញុំចេះកិនស្រូវ បុកស្រូវ ដល់មែនទែនទៅអត់មានអីកិនបុកស្រូវក៏មានអង្ករញ៉ាំដែរ គ្រាន់បើដែរ ។ គេហៅថាលត់ដំយើង ។ ពួកអស់នេះ(ខ្មែរក្រហម) ធ្វើមកលើយើងទាំងអស់គ្នាគឺមានតែពាក្យ៣ម៉ាត់ទេ គឺការប្រណែនឈ្នានីសនិងការសងសឹក ។ អ្នកដែលធ្វើជាខ្មែរក្រហមជំនាន់ហ្នឹង គឺអ្នកធ្វើការផ្ទាល់ជាមួយប្រជាជន សុទ្ធតែអត់ចេះអក្សរ គាត់សួរខ្ញុំថាខ្ញុំចេះអក្សរទេ ខ្ញុំថាអត់ទេ ។ គាត់ហុចក្រដាសមកឲ្យខ្ញុំបញ្ច្រាស ខ្ញុំហុចឲ្យគាត់បញ្ច្រាសវិញ អាហ្នឹងល្អមួយដែរ បើគាត់ដឹងថាខ្ញុំធ្វើគ្រូហ្នឹង ប្រហែលជាវៃខ្ញុំចោលបាត់ទៅហើយ ។ អ្នកខាងលើ មេៗធំខ្មែរក្រហមបានសុទ្ធតែអ្នកចេះ ។ ពាក្យសម្តីដែលគាត់និយាយជាមួយប្រជាជនយើងសុទ្ធតែពាក្យសីលធម៌ទាំងអស់ ហើយខ្មែរយើងដែលមិនបានរៀនអក្សរដល់ទៅដាក់ពាក្យសីលធម៌មកគាត់ចាំអត់ភ្លេចទេ ពាក្យខ្លះខ្ញុំអត់ដែលប្រើ អត់ទាំងចេះផង ។ មេខ្មែរក្រហមខ្លះនៅរស់ អ្នកខ្លះស្លាប់ហើយ អ្នកខ្លះជាគ្រូរបស់ខ្ញុំ ប៉ុន្តែខ្ញុំមិននិយាយចេញឈ្មោះទេ ។ ខ្ញុំរស់នៅ៤ឆ្នាំនៅជាមួយគេ ហើយបានខ្ញុំគេចរត់មកនៅប្រទេសទី៣ហ្នឹង គេស្រោចស្រង់ឲ្យខ្ញុំបានរស់ ។

ខ្ញុំអត់ភ្លេចទេការឈឺចាប់ ព្រោះខ្ញុំនៅរស់ ប៉ុន្តែមិត្តភក្តិបងប្អូនខ្ញុំស្លាប់អស់ហើយ ខ្ញុំចង់រកយុត្តិធម៌ មិនមែនថាស្លាប់បាត់ហើយបំភ្លេចចោលទៅអត់បានទេ សូម្បីតែខាងធម៌ព្រះក៏មានថាដែរ “នរណាធ្វើគេ អ្នកនោះបានបាប ហើយយូរប៉ុណ្ណាប់គង់តែបាបទេ” ។ បើយើងធ្វើបាបម្ល៉ឹងៗ ហើយថាអត់អីទៀតម៉េចបាន ។ ខ្ញុំក៏ចង់រកយុត្តិធម៌ដែរ ។ ខ្ញុំសូមអរគុណអ្នកដែលមានបំណងចង់រកយុត្តិធម៌ឲ្យដល់បងប្អូនដែលបានស្លាប់បាត់ទៅហើយនោះ ខ្លះបាត់ប្តី ខ្លះបាត់ប្រពន្ធ ខ្លះបាត់កូន យើងអត់ភ្លេចទេ សូមរកយុត្តិធម៌ ។ សូមអរគុណ ។

ឥឡូវនេះខ្ញុំសូមសួរសំណួរទៅលើរឿងមនុស្សឃាត តើនៅក្នុងអំឡុងពេលគិតចាប់ថ្ងៃទី១៧ មេសា ១៩៧៥ រហូតដល់ថ្ងៃ៦ មករា ឆ្នាំ១៩៧៩ នេះ តើមានលោកពូអ្នកមីងណាធ្លាប់បានឃើញជនណាម្នាក់ដែលសម្លាប់មនុស្សដែរឬទេ? បើឃើញនៅកន្លែងណា ហើយដោយរបៀបណាខ្លះ?

**លោក“ក”**: បាទ! ក្នុងឆ្នាំ១៩៧៦ ខ្ញុំបាទបានឃើញបនពេជ្ឈឃាតដែលសម្លាប់ប្រជាជននៅភ្នំធិបដេ បឹងតាមក់ ។ អ្នកសម្លាប់នោះឈ្មោះ អាប៉ក់ ។ វាចងទាំងខ្សែៗយកមិត្តយើងប្រជាជន១៧មេសាទៅសម្លាប់ចោលប្រហែលម៉ោង៣ វាយកទាំងខ្សែៗទៅសម្លាប់ ប៉ុន្តែមិនដឹងវាយកទៅសម្លាប់នៅឯណាទេ ខ្ញុំបាទឃើញគេចងខ្សែយកទៅខាងផ្លូវកាស់ក្រឡ ។ ច្រើនណាស់



រាប់មិនអស់ទេ មិនមែនរយទេ ប្រហែលទាំងពាន់ ។ ចាប់រាល់ថ្ងៃឲ្យតែម៉ោង៣ លើកភ្ជួរស្រែយកទៅហើយ ។ជួនកាលគេបាញ់ជួនណាគេយកទៅវ៉ៃនឹងត្បូងចប ។ នៅគាស់ក្រឡូជួនបា គេហៅស្រែមួយរយសុទ្ធតែខ្មោចហើយ ។

**លោក«ខ»:** រឿងសម្លាប់មនុស្ស ថ្ងៃដំបូងបង្អស់ដែលខ្ញុំត្រូវជម្លៀសពីភ្នំពេញទៅដល់ចុងស្ពានមុនីវង្ស មិត្តយើងដេញឲ្យស៊ីក្លូទៅមុខ រួចដល់គ្រាន់តែគ្នាងាកបន្តិចបាញ់ពីក្រោយដាំងធ្លាក់ពីលើស៊ីក្លូ ។ មួយទៀតនៅចុងស្ពានមុនីវង្សហ្នឹងដែរ មិត្តយើងបើកឡានបញ្ច្រាសផ្លូវ រួចស្រីម្នាក់ដើរមិនដឹងឆ្វេងមិនដឹងស្តាំក៏បុកគ្នាដួលមិនដឹងរស់មិនដឹងស្លាប់ទេ ខ្ញុំក៏ដើរទៅមុខទៀតព្រោះគេឲ្យដើរទៅមុខត្រូវតែទៅមុខ ។សុំចប់ប៉ុណ្ណឹងបាទ ។

**អ្នកស្រី ផង់ស៊ី ទូះ** សូមអរគុណ ។

**អ្នកស្រី«គ»:** ចំពោះរឿងកាប់សម្លាប់នេះ នាងខ្ញុំក៏ធ្លាប់ជាសាក្សីដែរ មិនបានឃើញគេសម្លាប់ផ្ទាល់ទេ ប៉ុន្តែធ្លាប់ឃើញគ្រួសារមួយដែលគេយកឪពុកម្តាយនិងកូនចៅទៅសម្លាប់ស្រាប់តែពេលព្រឹកឡើងកូន២នាក់រត់មកវិញ វាគ្រាន់មានរបួសជើងធូន់ ពួកខ្ញុំនៅធ្វើស្រែស្រាប់តែឃើញមកឈាមរហាច ។ ដឹងតែពីយប់ថា គេយកគ្រួសារទៅសម្លាប់ ប៉ុន្តែដល់ឃើញកូនហ្នឹងត្រឡប់មកវិញ ម្នាក់ៗអត់ហ៊ានទៅជិតទេ ព្រោះខ្លាចការស្លាប់ ។ ដល់ពេលប្រហែលត្រឹមថ្ងៃត្រង់ ពួកខ្ញុំឡើងពីស្ទូងហូបបាយឃើញមេ ប៉ុន្មាននាក់នាំក្មេង២នាក់ហ្នឹងទៅចូលក្នុងព្រៃបាត់ យើងសន្និដ្ឋានថាយកក្មេងហ្នឹងទៅសម្លាប់ដែរ ។ រឿងអស់នេះខ្ញុំមិនបានឃើញផ្ទាល់ភ្នែក ប៉ុន្តែឃើញក្មេងហ្នឹងត្រឡប់មកវិញសម្លាប់មិនស្លាប់ ហើយគ្នាក្មេងគ្នាមិនដឹងទៅណាមានតែត្រឡប់ចូលស្រុកវិញ ហើយក៏យកទៅបង្ហើយទៅ ។

**លោក«ខ»:** ដល់ពេលជម្លៀសខ្ញុំទៅដល់ភ្នំធិបដេ ប៉ុន្តែមិនទាន់ទៅដល់ជើងភ្នំពេកទេ ត្រឹមបឹងកន្ទួត តាមផ្លូវរទេះភ្លើងខេត្តបាត់ដំបង មានមួយថ្ងៃមិត្តយើងសួរថាអ្នកណាចង់រត់ទៅស្រុកសៀម បើចង់រត់ទៅគេនឹងដឹករទេះគោយកទៅ ។ គ្រួសារខ្ញុំតែចេះពិចារណាថាវាមិនសម គ្រួសារខ្ញុំថា អូ⁺!អានេះបោកហើយ រួចក៏សម្រេចចិត្តថាមិនទៅទេ ប៉ុន្តែគ្រួសារចិនមួយគាត់ជាអ្នកមាននៅភ្នំពេញពីដើម គាត់សុខចិត្តទៅដើម្បីរត់ទៅស្រុកសៀម ។ ដល់ថ្ងៃល្ងាចព្រលប់ៗ គេយករទេះគោមកដឹក បានចម្ងាយប្រហែលមួយគីឡូម៉ែត្រពីខ្ទមនៅបឹងកន្ទួតភ្នំធិបដេហ្នឹងក៏ស្រាប់តែបាញ់ដាំងៗក៏ស្លាប់អស់ទៅ គេក៏ប្រមូលយកមាសយកពេជ្រពីចង្កេះអស់ទៅ ។ ខ្ញុំបានដឹងដោយសារខ្មែរយើងម្នាក់គាត់មិនស្លាប់ គាត់ត្រូវគ្រាប់បញ្ចៀងថ្ងាសនិងបាក់មេដៃ ។ ពេលគេបាញ់គាត់ធ្វើជាស្លាប់ ព្រឹកឡើងគាត់រត់មកខ្ទមនៅបឹងកន្ទួតនោះវិញ ។ គាត់រៀបរាប់ថាគេធ្វើបាបយ៉ាងម៉េចដូចខ្ញុំជម្រាបអម្បាញ់មិញអ៊ីចឹង ។ នៅសល់គាត់មួយហ្នឹងបានដឹងថាគេដឹកយើងនេះមិនមែនទៅស្រុកសៀមទេ គឺយកទៅសម្លាប់តែម្តង ។ ចប់តែប៉ុណ្ណឹង ។

**អ្នកស្រី«គ»:** សុំម្តងទៀត ខ្ញុំនិយាយអម្បាញ់មិញមិនបានបញ្ជាក់ពីទីកន្លែងដែលខ្ញុំរស់នៅសម័យប៉ុលពត គឺនៅភូមិស្ពឺចម្ការលើ ខេត្តកំពង់ចាម ។ មិត្តភក្តិខ្ញុំដែលធ្វើស្រែជាមួយគ្នាហ្នឹងឈ្មោះ ចាន់ទី ប្តីធ្វើទាហានដែរ គេយកទៅសម្លាប់តាំងពីគ្នាចេញមកម្ល៉េះ ហើយធ្លាប់ដើរទៅធ្វើការជាមួយគ្នា២-៣ឆ្នាំហើយ ។ រៀងរាល់រដូវធ្វើស្រែដកស្ទូងហ្នឹង គឺគេសម្លាប់មនុស្ស គ្រប់គ្នាតែងតែភ័យខ្លាច ។ នៅឆ្នាំ១៩៧៨ ពួកម៉ាកខ្ញុំដូចដឹងខ្លួនថាគេនឹងមកបោសសម្អាតដល់ខ្លួនហើយ ។ មានមេកងឈ្មោះ តេង ដែលយើងធ្លាប់លេងកំប្លែងសើចសប្បាយជាមួយគ្នា ។ នៅថ្ងៃមួយខ្ញុំឃើញមុខគាត់ឡើងសស្លាំងហើយទៅជាគ្រុន តាមពិតគេឲ្យគាត់សម្លាប់ នាងចាន់ទី ដោយផ្ទាល់ ម៉្លោះហើយគាត់តក់ស្លុតពេកទៅជាគ្រុន ។ តាំងពីថ្ងៃនោះមកក៏បាត់មិត្តភក្តិខ្ញុំហ្នឹងទៅ ។ ការណ៍នេះខ្ញុំមិនបានឃើញផ្ទាល់ទេប៉ុន្តែដឹង ។ ជួនកាលសូម្បីនៅក្នុងវង់អ្នកធ្វើការជាមួយគ្នា ធ្លាប់ស្រឡាញ់រាប់អានគ្នាក៏លើកដៃសម្លាប់គ្នាឯងដោយមិនអាចតវ៉ាបាន ។ ដូច្នេះឃើញថាសម័យនោះគឺយង់ឃ្នងសាហាវខ្លាំងណាស់ ។

**អ្នកស្រី ផង់ស៊ី ទូះ** នៅក្នុងអំឡុងពេលដដែលនេះគឺក្នុងរយៈពេលសម័យប៉ុលពត ពីឆ្នាំ១៩៧៥-៧៩នេះ តើលោកពូអ្នកមីងបុបងប្អូនណាម្នាក់ដែលបានឃើញជនណាម្នាក់ធ្វើទុក្ខបុកម្នេញលើមនុស្សដោយសារមូលហេតុសាសនាដែរឬទេ? សូមជួយរៀបរាប់ឲ្យបានក្បោះក្បាយ ។

**លោក«ខ»:** នៅពេលគេជម្លៀសខ្ញុំដល់ភ្នំធិបដេ ខេត្តបាត់ដំបងហ្នឹង នៅជិតភ្នំធិបដេមានវិហារមួយយ៉ាងស្អាត ប៉ុន្តែ

ពេលហ្នឹងផ្ទះធំឬក៏វិហារល្អៗទាំងប៉ុន្មាន គេធ្វើឲ្យតូចៗស្មើៗគ្នា ។ មិត្តយើងបានប្រើខ្ញុំឲ្យទៅរុះរើវិហារហ្នឹង ។ ខ្ញុំមានសេចក្តីសោកស្តាយ ប៉ុន្តែមិនហ៊ាននិយាយទេ និយាយទៅខ្លាចបាត់ខ្លួន ម៉្លោះហើយចេះតែទ្រាំធ្វើទៅ ។

**អ្នកស្រី ផង់ស៊ី ឆ្នូ:** ឥឡូវនេះយើងនិយាយពីអំពើប្រល័យពូជសាសន៍ ការបង្ការមិនឲ្យមានកំណើតទារក ។ តើមានបងប្អូនណាដឹងអ្វីខ្លះអំពីរឿងនេះដែរឬទេ?

**លោក«ខ»:** រឿងប្រល័យពូជសាសន៍ បើតាមធម្មជាតិកាលណាយើងគ្មានអ្វីទទួលទានបរិបូរណ៍ ខ្វះមុខ ខ្វះក្រោយ រូបកាយស្គម គ្មានជីវជាតិ គ្មានជាតិស្ករ គ្មានជាតិវីតាមីន គ្មានជាតិខ្លាញ់នៅក្នុងខ្លួន ស្ត្រីម្នាក់ៗរស់នៅដោយគ្មានរដូវ រួចដល់គ្មានរដូវហើយតើបង្កបង្កើតកូនម៉េចនឹងកើត? ហ្នឹងហើយជារឿងមួយដែលគេនិយាយថាប្រល័យពូជសាសន៍ ។

**អ្នកស្រី ផង់ស៊ី ឆ្នូ:** រឿងមួយទៀតក្នុងរយៈពេលនោះ តើលោកពូអ្នកមីងដែលបានឃើញអ្នកណាម្នាក់ត្រូវបានបង្ខំឲ្យធ្វើពលកម្ម ឬនៅកន្លែងដែលខ្លួនមិនពេញចិត្តដែរឬទេ?

**លោក«ខ»:** សំណួរនេះតាមការយល់ឃើញរបស់ខ្ញុំ នៅពេលនោះគឺថា មិត្តយើងតែងតែនិយាយថា ឆ្នាំទី១យើងត្រូវប្រើមនុស្សយកទៅទាញនង្គ័លរនាស់ដើម្បីធ្វើស្រែចម្ការ ។ ដល់ឆ្នាំទី២យើងមានគ្រឿងម៉ាស៊ីនជំនួសគោក្របីទាញនង្គ័ល ប៉ុន្តែតាមខ្ញុំសង្កេតមើលទៅឆ្នាំទី១មនុស្សនៅមានសាច់ទេ គោក៏នៅតែមានសាច់ដែរ ដល់ឆ្នាំទី២គោរឹតតែស្គមឡើងរទេះ ក៏កាន់តែរខេករខាកអាហ្នឹងហើយដែលខ្ញុំថាឆ្នាំទី២គេនិយាយថាយើងប្រើសុទ្ធតែគ្រឿងយន្ត តើអាគ្រឿងយន្តបានពីណាមក បើចេះតែអន់ទៅៗ ។

**អ្នកស្រី«គ»:** នាងខ្ញុំសូមបន្ថែមបន្តិច នៅក្នុងអំឡុង២-៣ឆ្នាំស្រុកចម្ការលើនៅស្ទឹង ខេត្តកំពង់ចាម ខ្ញុំនៅក្នុងក្រុមមីងៗ ។ នៅពេលផុតពីដកស្ទូង គេប្រមូលមីងៗឲ្យទៅអូសឈើហ៊ុបដើម្បីយកមកធ្វើរោងបាយរួម យើងអូសដូចជាសត្វគោក្របីអ៊ីចឹងឈើហ៊ុបមួយកាន់២នាក់អូស ។ រហូតដល់មាននារីខ្លះដែលមានគភ៌ក៏ត្រូវរលូតដោយសារអូសឈើហ៊ុបនេះដែរ ។ ដូច្នេះឃើញថានៅក្នុងសម័យប៉ុលពតនេះអ្វីក៏កើតមានឡើងគ្រប់ពេលវេលាហើយហេតុការណ៍យ៉ាងម៉េចក៏អាចកើតបានដែរ ។

**អ្នកស្រី«ឃ»:** នៅក្នុងឆ្នាំ១៩៧៥ ដែលពួកខ្មែរក្រហមជម្លៀសប្រជាជនចេញពីទីក្រុងបាត់ដំបងថ្មីៗ ហើយចំពេលរដូវធ្វើស្រែ ប្អូនខ្ញុំដែលធ្លាប់តែនៅផ្សារ ដល់ជម្លៀសចេញមកមានតែខ្លួន អត់មានរបស់ទ្រព្យ អត់មានគោអីនឹងគេ ដល់ពេលធ្វើស្រែគឺត្រូវទឹមខ្លួនឯងធ្វើជាគោតែម្តង ។ វេទនាខ្លាំងណាស់ ។ ទ្រាំនៅមិនបាន ប្រហែលជា១វស្សា ដល់ស្ទូងហើយពិបាកខ្លាំងពេកមានបងប្អូននៅខាងស្ទឹងទាក់ទងយកមកនៅជាមួយ ។

**លោក«ង»:** ខ្ញុំនិយាយពីប្រវត្តិរបស់ខ្ញុំពីជំនាន់៧៥-៧៨ គឺខ្ញុំបាទមានភ័ព្វវាសនាបានមកនៅទីក្រុងភ្នំពេញ ។ គេឲ្យខ្ញុំធ្វើជាកម្មករនៅចាក់អង្រែក្រោម ប៉ុន្តែមកដេកនៅផ្ទះនៅក្បាលថ្នល់ ។ មុនដំបូងចូលទៅដល់គេឲ្យស៊ីនំប៉័ងមួយប្រហែលជាប៉ុនកដៃកូនក្មេងស៊ីមួយពេល និងល្ងាចមួយទៀត ។ អ៊ីចឹងបាន២ក្នុងមួយថ្ងៃហូបជាមួយសម្លចេកអំបូងនិងគល់ព្រលិត អត់មានសាច់មានស្អីទេ ប៉ុន្តែមិនមែនចំពោះតែខ្ញុំម្នាក់ទេ គឺជំនាន់ហ្នឹងក្នុងម៉ារោងចក្រខ្ញុំវាមានទៅដល់៥០០នាក់ ។ រោងចក្រធ្វើម៉ាស៊ីនបូមទឹកនិងរោងចក្រម៉ាស៊ីនអារឈើ ។ រួចហើយដល់ពេលហូបអត់ឆ្អែត ម្នាក់ៗដេកមិនលក់ ដូច្នេះរកវិធីលួច ។ លួចហ្នឹងគ្មានលួចស្អីទេ លួចមេនំប៉័ងសុទ្ធ មេទឹកស៊ីអ៊ីវចេញពីស៊ីទែន នាំគ្នាចោះបង្អួរដាក់ប៊ីដុង ។ យកមកកន្លែងលាក់លួចមិនឲ្យគ្នាឯងដឹង ព្រោះមានអ្នកយាម ។ ពេលចូលគេងចាក់ដាក់កានាំគ្នាហុត ដល់ពេញពោះទើបនាំគ្នាទៅដេកវិញ ។ ប៉ុន្តែក្រោយមកដឹងយ៉ាងម៉េចទេ មេទឹកស៊ីអ៊ីវវាធ្វើទុក្ខទៅជារាក ហូរមកដូចឈាមអ៊ីចឹង ។ ក្រោយពីហូរមកឈាមអស់ជាតិនំប៉័ងហ្នឹងវាទៅជាសរសៃទាញដៃទាញជើង ។ ដល់អ៊ីចឹងទៅអាពួកម៉ាក៣នាក់នៅក្នុងបន្ទប់ជួយទាញដៃ ទាញជើង កោសខ្យល់ប្របាច់គក់ទើបបានគ្រាន់បន្តិច ។ ថ្ងៃក្រោយមកទៀត ខ្ញុំឃ្លានខ្លាំងពេកទៅហូបមេនំប៉័ង ដល់ស៊ីរួចវាហើមពោះ ។ ពោះម្នាក់ៗតឹងឡើងចង់បែក ភើដង ដោមដង អត់ឈប់ទេ ចង់ងាប់ ។ ក្រោយមកទៀត ពួកទូតចិនបានទៅថតពួកខ្ញុំជាកម្មករហ្នឹង គឺថតដើម្បីឲ្យសហករណ៍មើលប្រៀបធៀបគ្នាអ្នកណារីកចម្រើនជាងអ្នកណា ។ ពេលនោះ គេកាត់សក់របៀបទាហានអ៊ីចឹង កម្មករ ខ្ញុំប្រហែល៣០០នាក់ទុកនៅសល់តែកំប៉ោយខ្លីៗទេ ប៉ុន្តែមើលមុខដូចមុខខ្មោច ភ្នែករូង ដេកអត់ឆ្អែតទេ ស៊ីក៏អត់ឆ្អែតដែរ ម្នាក់ៗមុខឡើង

ជ្រុង ហើយភ្នែកឡើងរូងមិនថាតែរូបខ្ញុំទេ ទាំងអស់គ្នានៅដ-៦ ហ្នឹង ។ ផុតពីហ្នឹងគេថាហ៎ខ្មែរនេះក្បត់ ខ្មែរនោះក្បត់គេមកប្រមូល យកទាំងមេក្រុមទាំងមេពួកយកទៅរៀនសូត្រទៅទៀត ប៉ុន្តែ ខ្ញុំមិនបានឃើញគេយកទៅឯណាទេ ។ ក្រោយមកឆ្នាំ១៩៩១ ខ្ញុំបានទៅលេងស្រុកខ្មែរ បងខ្ញុំទាញខ្ញុំឲ្យចូលទៅមើលគុកទួលស្លែង ។ ដល់ឃើញគុកទួលស្លែងខ្ញុំស្រងាកចិត្ត ព្រោះខ្ញុំនៅភ្នំពេញដែរខ្ញុំ អត់ស្គាល់គុកទួលស្លែងយ៉ាងម៉េចទេ ។ ទៅដល់ឃើញគុក ឃើញ កន្ត្រៃនោម កន្ត្រៃអាចម៍ ច្រវាក់ជើង ច្រវាក់ដៃអីនៅពេញហ្នឹង ខ្ញុំរន្ធត់តែម្តង ។ ដល់ពេល៧៩ វៀតណាមជិតចូលមកហើយនេះ គេចោទខ្ញុំថាគិញយួន ។ ខ្ញុំភ័យណាស់ ឮថាគិញយួន ព្រោះយួន និងអាពតអត់ត្រូវគ្នាទេ ។ ដល់គេចោទថាគិញយួនអីចឹង ខ្ញុំដេក ក្តៅខ្លួនប្រហែលជា១អាទិត្យ ដេកកើតទុក្ខ ខ្លាចគេយកទៅវៃ ចោល ។ ធ្វើការមួយយប់ទល់ភ្លឺ គេឲ្យដេកថ្ងៃកាលហ្នឹង ។ ដេក អត់ដែលឆ្អែតទេ គេឲ្យទៅពលកម្មទៀត ដេកបាន៣-៤ម៉ោង ពលកម្មដាំដុះឧបត្ថម្ភខ្លួនឯងទៀត ។ ដល់ឃ្លានពេកឃើញទ័ពមជ្ឈិម ការពារនៅទីក្រុងភ្នំពេញ ដាច់ចិត្តទៅសុំគេថា បងខ្ញុំឃ្លានណាស់ ខ្ញុំសុំដូងមួយផ្លាយបងឲ្យទេ ។ គេឲ្យមួយផ្លាយមកគ្នាបីបួននាក់ផឹក ទឹក ស៊ីសាច់ទាំងអស់ហ្នឹងដូចជាមានកម្លាំងគ្រាន់បើដែរ ។ ថ្លែង អំណរគុណគេ ។ គេក៏អត់ដែរ មជ្ឈិមនៅក្បែរហ្នឹង គេជាទ័ព ខ្ញុំជា កម្មករ ប៉ុន្តែគេស៊ីបាយយ៉ាប់ជាងខ្ញុំទៅទៀត សុទ្ធតែថ្នឹង ខ្ញុំដួស ៣វែក ។ ដល់គេថាខ្ញុំជាគិញយួន ខ្ញុំដេករន្ធត់តាំងពីពេលហ្នឹងមក រហូតដល់យួនចូលមកខ្ញុំរួចខ្លួនទៅ ខ្ញុំអរសម្បើមណាស់ពេលហ្នឹង ។ មានតែប៉ុណ្ណឹងទេ ។

**អ្នកស្រី“ង”:** ក្នុងឆ្នាំ១៩៧៥គឺចាប់ផ្តើមគេជម្លៀសចេញ ពីទីក្រុងហ្នឹង ខ្ញុំបាននៅក្នុងខេត្តបាត់ដំបង ។ ពេលនោះខ្ញុំកូនខ្ចីផង ហើយប្តីខ្ញុំហ្នឹងគាត់ជាទាហាន ដើមកំណើតជាគ្រូ ពេលសម័យ កើតសង្គ្រាម គាត់ស្ម័គ្រចិត្តធ្វើជាទាហាន ។ ពេលជិតចុងបញ្ចប់ ហ្នឹងគាត់ត្រូវចូលជាទាហានអាក់ទីហ្វ គាត់ត្រូវទៅរៀនច្បាប់នៅ សេអ៊ីកំពង់ឆ្នាំង ។ ពេលនោះឆ្នាំ១៩៧៥ ហើយទៅរៀនសេអ៊ី នៅកំពង់ឆ្នាំងហ្នឹងបានប្រហែលជា២ខែក៏សង្គ្រាមចប់ទៅក៏ បែករហូត មិនដឹងថាគាត់ហ្នឹងទៅខាងណាៗខ្ញុំអត់ដឹងរហូតទល់ សព្វថ្ងៃ ។ ខ្ញុំត្រូវគេជម្លៀសចេញពីខេត្តបាត់ដំបង ពកូនខ្ចីហ្នឹង គឺថាអារម្មណ៍ក្នុងពេលនោះនិយាយមិនបានទេ គឺថារៀបរាប់ មិនបានទេ ។ វាទុក្ខព្រួយ វាណែនទ៊ា គឺថាក្តុកក្តួល ភ័យៗ ម្យ៉ាង គិតពីខ្លួនឯង ម្យ៉ាងគិតពីប្តី និយាយមិនចេញ យំក៏មិនហ៊ានយំ យំឲ្យគេឃើញមានបញ្ហាទៀត ក្នុងទ្រូងចង់បែកហើយខ្ញុំហ្នឹង ។ កូនខ្ចីទៀត មិនដឹងថាចេញទៅណាអីខាងណាមិនដឹងរៀបចំអី ចេញដំណើរទាំងទុក្ខទាំងព្រួយខ្វល់ខ្វាយ គេឲ្យយើងចេញហ្នឹងគឺ ចេញមកជាមួយប្អូនបង្កើត និងប្អូនស្រី ដូចថាយួរម៉ួរចៗ ខ្ញុំហ្នឹងបី តែកូន ។ ខ្ញុំមានកូន៣នាក់ កូនច្បង២ហើយនិងកូនខ្ចីមួយចេញពី បាត់ដំបងមកភ្នំសំពៅមកនៅស្ទឹង ។ ខ្ញុំបានមកនៅស្ទឹងប្រកបរបរ ធ្វើស្រែចម្ការតាមអង្គការរហូតរៀងមក ។ ទើបតែពេលខ្ញុំបានមក នៅកាណាដា ហើយខ្ញុំត្រឡប់ទៅស្រុកខ្មែរវិញ ទៅជួបបងប្អូនខ្ញុំ នៅស្រុកខ្មែរបានដឹងថា បងប្អូនខ្ញុំបានបាត់បង់ជីវិតអស់ជាច្រើន នាក់ ។ ប្អូនជីដូនមួយ ប្អូនប្រុសបានប្រឡងជាប់ខាងកសិកម្មហើយ មិនទាន់ចូលរៀនច្បាប់ទេ ក្នុងឆ្នាំ៧៥ហ្នឹងគេបានជម្លៀសចេញ ទៅធ្វើស្រែនៅស្រុកកំណើតវិញ ។ វាចេះគូរប្លង់ ធ្វើផ្លូវប្រឡាយ អីហ្នឹងគឺនៅលើវាទាំងអស់ តាំងពីឆ្លាក់អក្សរធ្វើបដាធំៗពេល មិទ្ទិង ។ គេប្រាប់ថា អ្នកណាធ្វើអីគេឲ្យធ្វើហ្នឹង ហើយគ្នាល្ងង់និយាយ ទៅគ្នាស្មោះត្រង់ គ្នានៅក្មេង ម៉្លោះហើយធ្វើតាមគេប្រើ ។ ដល់ អីចឹងទៅវាធ្វើអីក៏ស្អាត ល្បិចគេបោកប្រាស់យកទៅសម្លាប់គេសួរ ថាប្អូនឯងរៀនដល់ថ្នាក់ណា? វាថារៀន ដល់ថ្នាក់ទីបញ្ចប់ ។ ដល់ អីចឹងគេក៏យកវាទៅបាត់រហូតទៅ ។ មានផ្សេងៗទៀតដែលធ្វើការ សុទ្ធតែជាបងប្អូន ធ្វើការខាងកសិកម្ម ខាងពេទ្យ ចូលធ្វើជាទាហាន បាត់អស់ ។ មានម្នាក់ទៀតនៅបួសសុខៗទារសឹក ដល់បានទៅធ្វើ ទាហានក៏ស្លាប់នៅគាស់ក្រឡ អត់បានយកខ្មោចទេ ។ មានទៀត ខ្លះហ្នឹងធ្វើពេទ្យគ្រាន់តែគ្នាមកនៅភ្នំពេញ ពេលសង្គ្រាមហ្នឹងនៅ ស្រុកស្រែគ្នានៅមិនបានណា ក៏រត់មកនៅភ្នំពេញ ។ ដល់ចប់ សង្គ្រាមគេវិលទៅស្រុកវិញ សង្ឃឹមថាចប់សង្គ្រាមអាចទៅរកស៊ី ធម្មតាវិញ ។ ប៉ុន្តែអកុសលមិនដឹងពីកលល្បិចរបស់គេ គេថាយើង ខ្សែខ្មាំងខាងក្នុងជាវណ្ណៈរាជការ ឬមានបងប្អូនធ្វើនេះធ្វើនោះ អីចឹងគេមិនទុកយើងទេ គេសម្លាប់អស់ ។ ខ្ញុំបានរស់មកហ្នឹងខ្ញុំ ហាក់ដូចជាខ្ញុំដឹងខ្លួនតាំងពីឆ្នាំ៧០មក ឪពុកខ្ញុំគាត់ប្រាប់ថាកុម្មុយ និស្តដូររបប ។ ឪពុកខ្ញុំជាអ្នកស្រែទេ ប៉ុន្តែគាត់ដឹង គាត់ប្រាប់ថា

កូន! គេប្ដូររបបហើយ គាត់ប្រាប់ខ្ញុំអ៊ីចឹង ។ ប្អូនខ្ញុំវាថាឪឯងកុំនិយាយប្រយ័ត្នគេយកទៅសម្លាប់ចោល អ៊ីចឹងមានតែហែ្អងទៅប្រាប់គេ ។ គាត់និយាយអ៊ីចឹង ខ្ញុំដឹងខ្លួនរហូតចេះតែគេចមករហូត គេចមកតាំងពីខេត្តតាកែវរត់រហូតមកដល់ភ្នំពេញដល់បាត់ដំបង បានជម្លៀសមកខាងស្ទឹង ។ បងប្អូនសាច់ជិតស្លាប់ មានប្ដីខ្ញុំ បងប្រុសម្នាក់ធ្វើកសិកម្ម ប្អូនប្រុសម្នាក់ទៀតធ្វើពេទ្យ ប្អូនប្រុសម្នាក់ធ្វើទាហាន និងជីដូនមួយខ្ញុំប្រុសរៀនដែលគេយកទៅឲ្យធ្វើបដាធ្វើអី ។ បងថ្លៃខ្ញុំមួយទៀតធ្វើខាងសុរិយោដី គេមិនសម្លាប់ទេប៉ុន្តែស្លាប់ដោយអត់បាយ គឺស្លាប់ទាំងគ្រួសារ នៅសល់កូនកំព្រា ៨នាក់នៅសព្វថ្ងៃកូនហ្នឹង ។

**អ្នកស្រី ផង់ស៊ី ធូះ** បន្ទាប់ទៅនេះមានសំណួរមួយដែលសួរទៅបងប្អូនយើងទាំងអស់គ្នាថា តើមានធ្លាប់ឃើញបុគ្គលណាម្នាក់រាប់ទាំងរូបមីងដែលត្រូវបានគេចាប់រំលោភដែរឬទេ?

**អ្នកស្រី«ឆ»:** ខ្ញុំសូមជូនយោបល់កន្លែងហ្នឹងបន្តិច ខ្ញុំនិយាយការពិត ខ្ញុំមិនមែននិយាយវៀចវេរអីទេ ។ កន្លែងដែលខ្ញុំនៅហ្នឹងរឿងសីលធម៌ជាពិសេសរឿងសីលធម៌ស្រីនិងប្រុសស្រឡាញ់គ្នាដោយអត់មានអង្គការលើទុកដាក់ឲ្យអត់បានទេ ។ សូម្បីតែខាងយោធាហ្នឹងក៏ដូចអត់ហ៊ានដែរ ។ ក្រែងទៅទាហានឯណាខ្ញុំ មិនឃើញមិនដឹងទេ ប៉ុន្តែបើតាមខ្ញុំដឹងព្ធ រឿងសីលធម៌ រឿងរំលោភឬទៅស្រឡាញ់គេផ្ដេសផ្ដាសអត់បានទេ ។ ប៉ុន្តែអ៊ីចេះមួយដែរ អង្គការហ្នឹងធ្វើល្អព្រោះអ្នកដែលប្រព្រឹត្តហ្នឹងគឺទាហានរបស់អង្គការ ។ គេធ្វើការល្អ ហើយប្រជាជនក៏ខ្លាច ព្រោះអីតែអ្នកណាខុសសីលធម៌គេសម្លាប់ចោល ។ ច្បាប់របស់គេអត់មានថ្នាក់ទី១ទី២ទេ មានតែសម្លាប់ចោល ដល់អ៊ីចឹងមនុស្សចេះខ្លាច គឺម្យ៉ាងដែរ ។ ដល់តែត្រង់កន្លែងមួយទៀតនោះអង្គការគ្មានសួរយោបល់ដូចសម័យយើងឥឡូវនេះខ្ញុំមករស់នៅក្នុងប្រទេសទី៣នេះក៏ដោយ នៅស្រុកខ្មែរយើងក៏ដោយ យើងមិនអាចចាប់ប្រុសនិងស្រីយកមកការបានទេ ទាល់តែសួរសិន ។ បើទុកជាយើងមានកូនស្រីក៏ត្រូវសួរចិត្តវាដែរ បើយើងចង់ឲ្យទៅកូនប្រុសរបស់អ្នកមួយ ទាល់តែកូនស្រីយើងយល់ព្រមដែរ ខ្លាចរៀបការហើយវាអត់នៅជាមួយគ្នា ។ ប៉ុន្តែសម័យនោះគ្មានទេ គេរៀបការឲ្យម្នាក់មួយគូៗអ៊ីចឹងមក ៣០គូម្ដងទៅ នាំគ្នាអង្គុយទៅលើកម្រាលបាវ សុទ្ធតែប្ដេជ្ញានឹងយក១ទល់១មិនអាចយកអ្នកណាទៀតទេទោះណាជាមិនចង់ស្រលាញ់ក៏ដោយ ។ រហូតកងយោធាខ្មែរក្រហមបាក់ដៃបាក់ជើងអីហ្នឹងក៏ទៅរកប្រពន្ធកូនឲ្យគ្នាទៅអ្នកមានជើងមានដៃហ្នឹងក៏ត្រូវតែរៀបការជាមួយ ដោយអត់មានសួរចិត្តថា សុខចិត្តឬមិនសុខចិត្តអីទេ ។ត្រង់ហ្នឹងមួយខ្ញុំអត់យល់ព្រមថាធ្វើត្រូវទេ ។ សូមអរគុណ ។

**អ្នកស្រី«គ»:** នាងខ្ញុំសូមរៀបរាប់ពីរឿងហេតុដែលកើតឡើងនៅភូមិស្រុកនាងខ្ញុំ គឺខាងស្ពឺចម្ការលើ ។ នៅក្នុងឆ្នាំ១៩៧៨ហ្នឹងមានយកមនុស្សទៅសម្លាប់ជាហូរហែរហូតមក ។ មានម្ដងនោះយកក្មេងស្រី២នាក់ នាងជាប្រជាជនថ្មី ពីដើមឪពុកធ្លាប់ធ្វើជាទាហានស័ក្តិ៤ ស័ក្តិ៥អ៊ីចឹងដែរ ហើយ២នាក់ហ្នឹងស្អាតៗណាស់ ។ នាងប្អូនធ្វើការនៅចម្ការកប្បាសទេ ប៉ុន្តែគេទៅឌុបយកមកដើម្បីសម្លាប់ ។ ហេតុការណ៍ទាំងអស់នេះមិនបានឃើញដោយផ្ទាល់ភ្នែកទេ ព្ធតែតៗគ្នាមក ។ បើយើងបានឃើញ យើងក៏មិនបានរស់មកដល់សព្វថ្ងៃនេះដែរ ។ ព្ធគេថាមុននឹងសម្លាប់នាងយោធាទាំងអស់នោះនាំគ្នាចាប់រំលោភ ដូច្នេះឃើញថារឿងសីលធម៌ហ្នឹងបានដាក់ឲ្យតែប្រជាជនទេ ប៉ុន្តែយោធាខាងប៉ុលពតខ្លួនឯងជាអ្នកជិះជាន់លើច្បាប់ខ្លួនឯង ធ្វើអំពើបាបជនស្លូតត្រង់ដូចជាមិត្តនារីទាំងពីរហ្នឹង ។

**លោក«ជ»:** ពេលខ្មែរក្រហមចូលមកដល់ទីក្រុងបាត់ដំបងខ្ញុំបាទនៅតាមស្រុក ខ្ញុំជារដ្ឋការមួយរូបពីជំនាន់មុន ខ្ញុំធ្វើការផ្នែករដ្ឋបាល ។ ពេលដែលខ្មែរក្រហមចូលពេញនៅទីផ្សារនៅក្នុងស្រុកអភិវឌ្ឍន៍សហគមន៍ខ្ញុំរស់នៅ មានការប្រមូលមេទាហានធំៗតាំងពីស័ក្តិ២ស័ក្តិ១ អាស៊ូដង់ ខាងផ្នែកពេទ្យ ទាហានអីហ្នឹង ហើយក្នុងការប្រកាសហ្នឹងម្នាក់ៗ ត្រូវត្រិះរិះពិចារណាថាតើខ្លួនយើងត្រូវទៅជួបគេឬអត់ ។ ចំណែកខ្លួនខ្ញុំសម្រេចថាមិនទៅប្រជុំទេ ពីព្រោះថាទៅប្រជុំហ្នឹងមិនដឹងថាទៅខាងមុខវាយ៉ាងម៉េច ។ ថាទៅទទួលសម្ដេចៗហ្នឹងវាមិនដឹងថាទៅទទួលហ្នឹងវាយ៉ាងម៉េច ម្ល៉ោះហើយនៅតែលើផ្ទះ អត់ហ៊ានចុះទៅណាទេ ព្រោះយើងដឹងថាអនាគតរបស់ខ្មែរយើងនៅខាងមុខប្រាកដជាប្រែប្រួលឬប្រេះឆា ។ ដល់ពេលគេហៅទៅហ្នឹងមានមិត្តភក្តិខ្ញុំស័ក្តិ២ខ្លះ ស័ក្តិ៣ដូចលោក ឆៀវ ឆាម ដូចលោក សារី គេទៅៗស្រាប់តែគេថា

ត្រូវទៅទទួលសម្តេច គេយក២ឡានមកដឹកទាហាន តែមិនដឹកទៅបាត់ដំបងទេ គេដឹកតាមផ្លូវជាតិលេខ១០ទៅប៉ៃលិនប្រហែលជាហួសត្រែង។ ដល់ទាហានដែលដឹងខ្លួនដូចខ្ញុំអ៊ីចឹង វាលួចមកបាត់ដំបងហ្នឹង ស្រាប់តែឃើញមនុស្សគរដើងលើគ្នា។ វាសម្លាប់ចោលទាំងអស់ អ្នកដែលយកទៅទទួលសម្តេចហ្នឹង។ គេបាញ់ មិត្តភក្តិខ្ញុំបាទមកពីប៉ៃលិន វាប្រាប់ថាឃើញអ្នកនេះមួយ អ្នកនោះមួយ ខ្ញុំថាម៉េចក៏ដឹង វាថាអញដឹង អញឃើញ អញស្គាល់ ហើយអ្នកនេះៗ ដូចខ្ញុំបានជម្រាបអម្បាញ់មិញ ឆៀវ ឆាម និងលោក សារី អីហ្នឹង។ ដល់ឃើញអ៊ីចឹងវាប្រាប់ពួកយើងអត់ស្រួលទេ។ ដល់ពុអ៊ីចឹងខ្លួនខ្ញុំរឹតតែខ្លាចទៀតណាំ ដូច្នេះអត់ចុះទេនៅតែលើផ្ទះទេរហូតដល់ពេលជម្លៀស។ មេៗអត់ដឹងទេ ស្រាប់តែចូលមកឃើញពេញហ្នឹង វាមិនដឹងពិតប្រាកដថាជានរណាអីនរណាទេ ហើយគ្រាន់តែឈ្មោះប៉ុលពតហ្នឹងក៏មិនទាន់ដឹងដែរ។

ដល់ក្រោយមកគេជម្លៀសយើងខ្ញុំហ្នឹងទៅនៅតាមស្រែនៅភូមិជិតៗហ្នឹងដោយថាអ្នកណាមានស្រែនៅត្រង់ណា នៅត្រង់ហ្នឹងវិញទៅ ខ្ញុំក៏ទៅនៅលើស្រែខ្លួនឯង ព្រោះប្រពន្ធខ្ញុំគាត់ធ្លាប់មានស្រែមានចម្ការ ក៏នៅលើស្រែខ្លួនឯងហ្នឹងរយៈប្រហែលជា៥-៦ខែ។ ដល់ខែច្រូតកាត់រួចស្រាប់តែគេប្រមូលប្រជាជនតាមចុងកាត់មាត់ញកតាមស្រែចម្ការឲ្យចូលមកនៅក្នុងឃុំស្ទឹង។ មួយឃុំស្ទឹងហ្នឹងមានសហករណ៍៥ គ្រាន់តែឃុំស្ទឹង យើងដឹង យើងស្គាល់មនុស្សជាច្រើន យើងសាកសួរគ្នាទៅហេតុអីបាត់អ្នកនោះបាត់អ៊ីចឹង ដល់សួរទៅគេថានៅក្នុងឃុំស្ទឹងនេះគេសម្លាប់មនុស្សអស់៤០នាក់។ ខ្ញុំពិចារណាថាអានេះប្រហែលជាមានគំនុំគុំកួនគ្នាឯងក៏មិនដឹង ព្រោះកាលណោះយើងអត់ដឹងថាក្នុងរបបហ្នឹង គេធ្វើយ៉ាងម៉េចៗក៏យើងមិនបានដឹងពិតប្រាកដដែរ។ ខ្ញុំនៅក្នុងសហករណ៍៥ហ្នឹង។ រឿងស្រែ រឿងចម្ការ យើងចេះតែខំប្រឹងធ្វើដើម្បីការពារអាយុជីវិតរបស់យើង យើងខំធ្វើដើម្បីកុំឲ្យគេសង្ស័យថាយើងពីមុនធ្លាប់ស្រណុកស្រួល ហើយរកស៊ីហ្នឹងក៏ពូកែហេតុអីស្រាប់តែមកអ៊ីចឹង យើងមិនចង់ឲ្យឃើញ។ ដល់ក្រោយមកសូម្បីតែនៅក្នុងភូមិស្ទឹង វត្តដែលភូមិខ្ញុំនៅក្នុងវត្តហ្នឹងប្រហែល១៥០ម៉ែត្រ ប៉ុន្តែខ្ញុំមិនដែលចូលក្នុងវត្តហ្នឹងទេ អត់ដឹងមានលោកប៉ុន្មានអង្គទេ។ ស្រាប់តែដល់ថ្ងៃមួយមានបើកសន្និបាតដោះស្រាយរឿងមនុស្សស្រីមានប្តីនិងមនុស្សប្រុសមានប្រពន្ធ គេហៅខាងសេនាជន។ សេនាជនបានន័យថា មានប្តីប្រពន្ធហើយទៅធ្វើការរួមគ្នា ដល់ពេលហើយខុសសីលធម៌ យើងអត់ដឹងទេ ស្រាប់តែពេលគេហៅមកប្រជុំគេប្រាប់ថាមនុស្សខុសសីលធម៌គេយកមកសម្លាប់ ហើយក៏ប្រកូកប្រកាសឲ្យពួកយើងដឹងខ្លួន។ យើងផ្ទាល់ថាយើងមានគ្រួសារមនុស្សស្រី យើងមិនចង់ទៅប្រជុំទេ មិនចង់ឲ្យទៅកន្លែងហ្នឹងយើងឃាត់ស្វាត់ៗថាមិនបាច់ទៅទេ ទៅតែយើងមួយបានហើយ។ ដល់ខ្ញុំទៅក្នុងវត្តហ្នឹង មន្ទីរគេបើកប្រជុំក្នុងវត្តយកមនុស្ស២នាក់មកដែលខុសសីលធម៌។ ស្រីប្រុសដែលមានប្តី មានប្រពន្ធ វាខុសអ៊ីចឹងណាំជិតគ្នា។ ខ្ញុំឃើញផ្ទាល់នឹងភ្នែក។ ពេលប្រជុំសន្និបាតកាត់ទោសមនុស្សដែលមានកំហុស ដូចថាយើងមានប្រពន្ធ ហើយទៅយកប្រពន្ធគេមានប្តីហើយទៅយកប្តីគេ គេកាត់ទោសនៅក្នុងវត្ត។ ខ្លួនខ្ញុំផ្ទាល់ក៏មានអារម្មណ៍មិនល្អដែរ ព្រោះពីមុនមកទោះបីយើងខុសអ៊ីចឹងក៏មិនដល់ថ្នាក់យកទៅវ៉ៃយកទៅកាប់យកទៅសម្លាប់អ៊ីចឹងទេ ប៉ុន្តែដល់មកសម័យនោះគេធ្វើអ៊ីចឹង។ នៅក្នុងវត្តហ្នឹងមនុស្សទាំង៥សហករណ៍មកប្រជុំវ៉ៃទាំង២នាក់ គេយកដំបងឈើ៤ជ្រុងវ៉ៃទាល់តែស្លាប់ មិនមែនមនុស្សតិចទេ មនុស្សច្រើនណាស់។ ពិសេសសង្កត់ធ្ងន់ទៅលើគ្រួសារខាងស្រីនិងខាងប្រុសទាំងពីរហ្នឹង វ៉ៃប្អូនខ្លួនឯង វ៉ៃបងខ្លួន ថាមិនសមធ្វើអ៊ីចឹង។ ឃើញវ៉ៃមនុស្សហ្នឹង អាមួយកាន់ដំបងឈរមើល វាអ៊ីចឹង យើងមើលអ៊ីចឹងចុះ អាហ្នឹងម៉េចវាក្លាហានម្ល៉េះបងខាងស្រីៗទៅឈរវ៉ៃខាងប្រុស។ ដល់យើងគិតសម្គាល់ថា ហ្វែងធ្វើហ្នឹងក៏វាមិនត្រូវដែរ ពីព្រោះហេតុអីក៏យើងក្លាហានដល់ថ្នាក់ហ្នឹង ប្អូនយើងរួមគំនិតគ្នាហេតុអីយើងទៅយកដំបងជន្ទុចុះជន្ទុឡើង គេមិនទាន់បើកឲ្យវ៉ៃផង វានៅតែជន្ទុចុះជន្ទុឡើងនៅមុខវត្តស្ទឹងណា។

**អ្នកស្រី ផង់ស៊ី ៖** ខ្ញុំសូមជម្រាបសួរបងថា តើបងឃើញកិច្ចការដែលគេធ្វើហ្នឹង គេកោះប្រជុំ គេហៅមនុស្សមកថា មានទោសគេវ៉ៃ នៅទីប្រជុំជនអ៊ីចឹងតើបងមានអារម្មណ៍យ៉ាងម៉េចដែរ? នៅក្នុងចិត្តបងនឹកឃើញយ៉ាងម៉េចដែរ? គេធ្វើហ្នឹងបងពេញចិត្តឬមួយបងមិនពេញចិត្តទេ? សូមបងមានប្រសាសន៍។

**លោក«ជ»៖** ខ្មែរយើងជាអ្នកកាន់ព្រះពុទ្ធសាសនារឿង

អ៊ីចឹងៗដូចថាយើងមានប្ដីមានប្រពន្ធមិនគួរណាយើងធ្វើអ៊ីចឹងទេ ក្នុងការវាយនេះយើងខ្ញុំបានឃើញជាញឹកញយពីជំនាន់មុនៗមកដែរ ប៉ុន្ដែមិនដល់យកជីវិតគេ វ៉ៃស្រស់ៗអ៊ីចឹងទេ ទើបតែក្នុងសម័យប៉ុលពតហ្នឹង បានជាអារម្មណ៍ ខ្ញុំតក់ស្លុត ។ យើងធ្លាប់រស់នៅពីសង្គមមុនមក គ្រាន់តែមានការជំនុំជម្រះឲ្យអ្នកនេះបង់ឲ្យអ្នកនោះបង់អ៊ីចឹងក៏រួចខ្លួនទៅ ។ ប៉ុន្ដែនៅក្នុងសម័យប៉ុលពតនេះសាហាវណាស់អារឿងអ៊ីចឹង ។ បានថាវាមិនដឹងថាគំនិតខ្ញុំផ្ទាល់ខ្ញុំថាក្នុងវត្តអារាមរបស់ព្រះពុទ្ធសាសនាមនុស្សស្លាប់បានគេយកទៅដាក់មិនមែនយកទៅវ៉ៃនៅក្នុងហ្នឹងទេ ។ ក្នុងសម័យហ្នឹងធ្វើអ៊ីចឹងដូចជាមានការផ្ទាញ់ផ្ទាលនឹងរឿងព្រះពុទ្ធសាសនាដែរ ខ្មែរទូទាំងប្រទេសគឺគោរពរក្សាប្រពៃណី ហើយដល់យកមនុស្សមកកាប់សម្លាប់នៅក្នុងវត្តអ៊ីចឹងវាខុសទាំងស្រុង ។ នៅក្នុងវត្តស្ទឹងពេលខ្ញុំទៅប្រជុំអត់មានលោកសង្ឃទេ ។ ខ្ញុំមកនៅស្ទឹងបានប្រហែលមួយឆ្នាំ ខ្ញុំមិនដែលហ៊ានចូលវត្តទេ ដឹងតែចេញពីផ្ទះទៅស្រែ ចេញពីស្រែមកផ្ទះ ។ ដើម្បីការពារអាយុជីវិតមានតែប៉ុណ្ណឹង យើងដឹងតែប៉ុណ្ណឹង ធ្វើម៉េចឲ្យខ្លួនយើងរស់តស៊ូ ។ សម័យប៉ុលពតដូចយើងដឹងហើយ ៣ឆ្នាំ៨ខែការរស់នៅរបស់យើងៗធ្លាប់មានការពិសោធន៍នៅក្នុងជួររដ្ឋការជាពិសេសដូចខ្លួនខ្ញុំផ្ទាល់ធ្វើការ ផ្នែករដ្ឋបាលគឺខ្ញុំដឹងមិនមែនថាខ្ញុំមិនដឹងទេ នយោបាយធ្វើបដិវត្តន៍ហ្នឹងខ្ញុំដឹង បើអ្នកឯងធ្វើបានយូរអាហ្នឹងរស់បានយូរ តែអ្នកឯងធ្វើបាន២-៣ឆ្នាំវាក៏សើរើរហ័សដែរ ។ អាហ្នឹងវាមានតែប៉ុណ្ណឹង ខ្ញុំសូមបញ្ចប់តែប៉ុណ្ណេះ ។

**អ្នកស្រី ផង់ស៊ី ធូ៖** ខ្ញុំសូមអរគុណបងច្រើនៗ ខ្ញុំសូមអរគុណដល់បងស្រីបងប្រុសទាំងអស់បានចំណាយពេលមួយថ្ងៃរសៀលមកបញ្ចេញយោបល់ ។ ខ្ញុំជឿថាការដែលបងប្អូនបញ្ចេញរឿងរ៉ាវប្រវត្តិរបស់ខ្លួននៅក្នុងសម័យនោះមិនអស់ទេ ខ្លួនខ្ញុំក៏មិនអស់ដែរ ។ យើងគ្រាន់តែសង្ខេបតែប៉ុណ្ណោះ ខ្ញុំជឿជាក់ថា យើងទាំងអស់គ្នាក៏គ្មានការឈ្នានីសអីដែរ សុំតែមួយទេ សុំរកយុត្តិធម៌ឲ្យអ្នកដែលបាត់បង់ជីវិតទៅ ។ យើងខ្ញុំទាំងអស់គ្នាមិនមែនជាអ្នកវិនិច្ឆ័យទៅលើអ្នកណាមួយទេ គ្រាន់តែនិយាយអំពីប្រវត្តិរបស់ខ្លួនដែលរស់នៅក្នុងសម័យខ្មែរក្រហម ។ ខ្ញុំសូមអរគុណ ។

**អ្នកស្រី «ង»៖** ឥឡូវខ្ញុំសូមបន្តរឿងមួយទៀតគឺថា បន្ទាប់ពីការច្បាំងចប់ សង្គ្រាមគេមិនទាន់ជម្លៀសប្រជាជនចេញពីទីក្រុងទេ ។ ខ្ញុំនៅបាត់ដំបងនៅឡើយ ។ ពេលចប់ហ្នឹងខ្ញុំខ្វល់ខ្វាយខ្លាំងណាស់ ខ្ញុំចូលមក គេមកត្រួតត្រាហើយ ព្រោះចរាចរណ៍ត្រូវបិទទាំងអស់ ។ មិនថា ផ្លូវទឹក ផ្លូវអាកាស ផ្លូវថ្នល់គ្មានទេ មានតែឡានអង្គការទាំងអស់ ។ ប្ដីខ្ញុំគាត់បានចាកចេញទៅរៀនច្បាប់នៅសេអ៊ីកំពង់ឆ្នាំងរយៈ២ខែ ហើយគាត់ត្រូវរៀន៥ខែត្រូវចប់ ប៉ុន្ដែមិនបានចប់ទេ សង្គ្រាមចប់មុន ដូច្នេះការធ្វើដំណើរហ្នឹងត្រូវដាច់ការឆ្លងឆ្លើយគ្នា សំបុត្រទាក់ទងក៏មិនបានដែរ ។ ខ្ញុំដើរសួរពួកម៉ាកគាត់ដែលធ្វើការដូចគ្នា ក្រែងលោមានទំនាក់ទំនងគ្នា តើគាត់ត្រូវបញ្ជូនទៅខាងណាៗ ។ ខ្ញុំទៅខាងលោកស័ក្តិ៣ម្នាក់នោះ គាត់ត្រូវគេហៅទៅប្រជុំ ។ ប្រពន្ធអត់បានជួបប្ដីទេ ប្ដីហៅប្រជុំបាត់ ប្រពន្ធគាត់ប្រាប់ថាគេហៅទៅប្រជុំរួម គេបញ្ជូនគាត់ទៅធ្វើថ្នល់ ។ មិនអស់ចិត្តក៏ទៅសួរលោកម្នាក់ទៀត គាត់ពីឡុតរៀនបើកកប៉ាល់ហោះ ផ្ទះគាត់និងផ្ទះខ្ញុំនៅទន្ទឹមគ្នា ។ ខ្ញុំទៅសួរគាត់ផ្ទាល់មាត់តែម្ដង ខ្ញុំឡើងទៅដល់ គាត់មកជួបជុំមិត្តភក្តិទាំងអស់នៅផ្ទះហ្នឹង គាត់ថាត្រូវទៅទទួលសម្ដេច ខ្ញុំសួរគាត់ថា លោកៗត្រូវបញ្ជូនទៅខាងណា? គាត់ថាគាត់ទៅទទួលសម្ដេច គាត់ខំពាក់តាំងពីស័ក្តិលើស្មាយកបន្ដោងរូបសម្ដេច ។ គាត់រៀបចំខ្លួនដើម្បីធ្វើដំណើរទៅទទួលសម្ដេច ។ ខ្ញុំសួរគាត់ថា លោកទៅប៉ុន្មាននាក់ គាត់ថាទៅ២០០នាក់ ខ្ញុំថាចុះបានអីទៅ? គាត់ថាកប៉ាល់ហោះមកពីចិន ប៉ុន្ដែខ្ញុំនេះអត់ជឿទេ ព្រោះខ្ញុំមិនដឹងថាកប៉ាល់ហោះមកពីចិនឬយ៉ាងណា បើមើលសភាពជុំវិញខ្លួនអត់មានអីសោះ ។ ស្ថានការណ៍ប្រែប្រួលទាំងអស់ វាខុសពីសង្គមដែលយើងធ្លាប់ទៅទទួលសម្ដេចណ៎ា ខ្ញុំក៏ធ្លាប់ទៅទទួលអ៊ីចឹងដែរ ពេលទទួលសម្ដេចពីមុនគគ្រឹកគគ្រេងណាស់ ។ សូម្បីខ្ញុំជាសិស្សមានការសប្បាយរីករាយដែរ ហើយនេះអត់ទេ ។ ខ្ញុំយំ គាត់និយាយថា បងកុំព្រួយមិនអី គាត់មិនអីទេ ខ្ញុំទៅសួរគាត់ហ្នឹងមិនមែនទៅសួរត្រឹមតែគាត់ទេ តាមពិតខ្ញុំចង់ដឹងពីរឿងគ្រួសារខ្ញុំ តើមានទំនាក់ទំនងដូចគាត់ដែរឬអី ។ ខ្ញុំសន្មតក្នុងចិត្តថា ទំនាក់ទំនងគាត់និងគ្រួសារខ្ញុំប្រហែលជាមិនខុសគ្នាទេ ខ្ញុំស្មានមើលទៅ ខ្ញុំប្រហែលជារបៀបនឹងគ្នាបានជាតាំងពីហ្នឹងមកបាត់រហូតបាត់សូន្យឈឹងតែម្ដង មិនដឹងជាយ៉ាងណាទេ ខ្ញុំមិនដឹងមិនដឹងរហូត ។ សូមចប់ប៉ុណ្ណឹងចុះ ។

# គ្រួសារខ្ញុំ

គ្រួសារខ្ញុំជាគ្រួសារធុនកណ្តាលមួយ ឪពុកខ្ញុំឈ្មោះ ស៊ិន សួន ជាគ្រូបង្រៀននៅវិទ្យាល័យកំពង់ចឹង ។ គាត់រៀនបានសញ្ញាប័ត្រ ស៊ើទីហ្វីកា សម័យអាណានិគមបារាំង ជាមនុស្សដែលមានចរិត ម៉ឺងម៉ាត់ណាស់ចំពោះការសិក្សារបស់កូនៗ ។ មុនពេលក្លាយជាគ្រូបង្រៀន គាត់ធ្លាប់ធ្វើជាទាហានមានឋានៈជាអនុសេនីយ៍ទោ ធ្លាប់បានទៅសិក្សាថ្នាក់នាយទាហានរយៈពេល៣ខែនៅឡុងហាយ ប្រទេសវៀតណាម ។ ក្រោយពីឈប់ពីទាហាន គាត់មកធ្វើជាគ្រូបង្រៀនវិញតាមការស្នើសុំរបស់ម្តាយខ្ញុំ ។ គាត់គឺជាកូនទី២ ក្នុងចំណោមបងប្អូនប្រុសស្រី៣នាក់ គឺប្រុស២នាក់ ស្រីម្នាក់ ជាក្មេងកំព្រាឪពុកមានតែម្តាយចាស់ជរាងងឹតភ្នែកទាំងសងខាង ។ ម្តាយខ្ញុំឈ្មោះ ញ៉ែម លាប ជាស្ត្រីមេផ្ទះដ៏ចំណាន និងជាមាតាដ៏សប្បុរសរបស់ខ្ញុំនិងបងប្អូនខ្ញុំ ។ គាត់គឺជាកូនពៅក្នុងចំណោមបងប្អូនប្រុស ស្រី៤នាក់ (ប្រុស២នាក់ ស្រី២នាក់) ។ ជីដូនខាងម្តាយខ្ញុំឈ្មោះ តាំង ឡាយ មានដើមកំណើតជាជនជាតិថៃ ។ ជីតារបស់ខ្ញុំឈ្មោះ ញ៉ែម ខាត់ ជាអ្នកមានឥទ្ធិពលម្នាក់ក្នុងសម័យអាណានិគមបារាំង ដោយសារបងស្រីគាត់ជាភរិយារបស់រ៉េស៊ីដង់បារាំងប្រចាំខេត្ត ។ តាមការរៀបរាប់របស់ម្តាយខ្ញុំ ជីតាខ្ញុំកាចណាស់ ហើយចេះមន្តអាគមពូកែស័ក្តិសិទ្ធិទៀតផង ។ ឪពុកម្តាយរបស់ខ្ញុំមានចរិតស្លូតបូតនិងចូលចិត្តរាប់អានញាតិណាស់ ។

ឈ្មោះដើមរបស់ខ្ញុំគឺ ស៊ិន លីសីលា ជាឈ្មោះឪពុកខ្ញុំដាក់ឲ្យ ។ ក្រោយមកខ្ញុំបានប្តូរឈ្មោះទៅជា សួន សីលា វិញ ។ ការដែលខ្ញុំយកឈ្មោះរបស់ឪពុកខ្ញុំធ្វើជានាមត្រកូល ពីព្រោះខ្ញុំចង់រំឭកដល់អតីតកាលដ៏ជូរចត់របស់គាត់ដែលត្រូវខ្មែរក្រហមចងយកទៅសម្លាប់ចោល ។ ខ្ញុំកើតនៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៧០ នៅភូមិកំពង់លែង ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ។ ខ្ញុំជាកូនប្រុសពៅក្នុងចំណោមបងប្អូនប្រុស-ស្រីខ្ញុំ៥នាក់ គឺប្រុស៣នាក់ ស្រី២នាក់ ។ ក្នុងចំណោមបងស្រីរបស់ខ្ញុំទាំង២នាក់ មានម្នាក់ជាកូនដែលឪពុកខ្ញុំរើសមកចិញ្ចឹមតាំងពីអាយុ៣ខែ ។ នៅក្នុងឆ្នាំ១៩៧៥ នៅពេលដែលស្ថានការណ៍ស្រុកទេសកំពុងតែវឹកវរ បងស្រីទាំងពីររបស់ខ្ញុំដែលស្នាក់នៅរៀនឯទីក្រុងភ្នំពេញជាមួយឪពុកមាររបស់ខ្ញុំបានបាត់ដំណឹងឈឹងរហូតមកដល់សព្វថ្ងៃនេះ ។ សព្វថ្ងៃនេះខ្ញុំនៅសល់តែបងប្រុសពីរនាក់ដែលកំពុងតែរស់នៅទីក្រុងភ្នំពេញ ។ គាត់ទាំងពីរជាមន្ត្រីនគរបាលជាតិនៃក្រសួងមហាផ្ទៃ ។

## ការសម្រេចចិត្តដ៏តឹងតែងមួយ

ខណៈដែលប្រទេសកម្ពុជាមានសង្គ្រាមរវាងរបបសាធារណរដ្ឋខ្មែរនិងខ្មែរក្រហម គ្រូបង្រៀនទាំងអស់នៅវិទ្យាល័យកំពង់ចឹងត្រូវបានចាត់តាំងឲ្យការពារស្រុកភូមិរបស់ប្រជាជនមិនឲ្យខ្មែរក្រហមចូលមករំខាន ។ ឪពុកខ្ញុំនិងលោកគ្រូមួយចំនួនក៏ត្រូវចាត់តាំងឲ្យយាមយប់នៅសាលារៀន ។ មានយប់មួយនោះ ខ្មែរក្រហមមួយក្រុមលួចចូលមកជិតសាលារៀន ហើយវាយប្រហារទៅលើគ្រូៗដែលកំពុងដេកយាម ។ ក្នុងស្ថានភាពដែលមិនបានដឹងខ្លួនជាមុន គ្រូចំនួន១០នាក់បានស្លាប់ ។ ចំណែកឪពុកខ្ញុំបានរត់គេចខ្លួនឆ្ពោះទៅបន្ទាយទាហានដែលមានចម្ងាយ៣០គីឡូម៉ែត្រពីសាលារៀន ។ ក្រោយពីការវាយប្រហារ ទៅលើសាលារៀន ខ្មែរក្រហមបានដុតផ្ទះប្រជាជនអស់ជាច្រើនរយខ្នងទៀត ។ នេះជាចំណុចចាប់ផ្តើមដែលធ្វើឲ្យឪពុកខ្ញុំឈឺចាប់ ហើយសម្រេចចិត្តចូលធ្វើជាទាហានក្នុងសម័យសាធារណរដ្ឋខ្មែរ ។ ក្រោយពីធ្វើទាហានប្រមាណជាង២ឆ្នាំម្តាយរបស់ខ្ញុំបានសុំឲ្យពុកធ្វើជាគ្រូបង្រៀនវិញ ។ ឪពុកម្តាយខ្ញុំតាំងចិត្តថានឹងមិនត្រឡប់ទៅស្រុកកំណើតវិញឡើយ ។

ចុងឆ្នាំ១៩៧៤ សភាពការណ៍នយោបាយកាន់តែធ្លាក់ចុះទៅៗនោះ ឪពុកខ្ញុំសម្រេចចិត្តផ្លាស់ទៅបង្រៀននៅថ្នូពុកចម្ងាយជាង៩០គីឡូម៉ែត្រពីទីរួមខេត្តបាត់ដំបង ។

យើងធ្វើដំណើរចេញពីភូមិកំពង់ចឹងតាមកាណូតកាត់តាមបឹងទន្លេសាបឆ្ពោះទៅខេត្តពោធិសាត់ រួចយើងបន្តដំណើរពីខេត្ត

ពោធិសាត់តាមរថយន្តរហូតដល់ស្រុកថ្មពួក ។ ឪពុកខ្ញុំត្រូវបានបញ្ជូនឲ្យទៅបង្រៀននៅភូមិថ្មី ឃុំគោករមៀត ។ នៅទីនោះម៉ែធ្វើលតលក់ដើម្បីជួយសម្រាលបន្ទុកគ្រួសារ ។ លុយដែលគាត់សន្សំបានពីការលក់លតបានច្រើនគួរសមដែរ គាត់គ្រោងទិញរថយន្តមួយ ប៉ុន្តែអកុសលលុយបានក្លាយទៅជាក្រដាសនៅពេលដែល ប៉ុល ពត ឡើងកាន់អំណាច ។ យើងរស់នៅទីនេះបានជាង១ឆ្នាំ រហូតដល់ថ្ងៃ១៧មេសា ១៩៧៥ ។

ខ្សែជីវិតរបស់ក្រុមគ្រួសារខ្ញុំគឺពោរពេញដោយភាពខ្លោចផ្សាឈឺចាប់ ក្រោយពេលរបបអាវខ្មៅកាន់កាប់ប្រទេសបានធ្វើឲ្យជីវិតប្រជាជនស្លូតត្រង់ជាង១លាននាក់ស្លាប់ដែលមានរួមទាំងឪពុកនិងបងស្រីពីរនាក់របស់ផង ។ ក្រៅពីនេះខ្ញុំត្រូវបាត់បង់ម្តាយធំ បងប្អូនជីដូនមួយ ឪពុកមា សរុបទាំងអស់មានចំនួន៨នាក់ ។

## ការរស់នៅក្នុងភូមិតាសៀវ

ពេលដែលរបប ប៉ុល ពត ឡើងកាន់អំណាច ប្រជាជនទាំងអស់ត្រូវជម្លៀសចេញពីទីក្រុងនិងទីប្រជុំជនឲ្យទៅរស់នៅតាមជនបទ ។ គ្រួសារខ្ញុំបានត្រូវជម្លៀសចេញពីរួមស្រុកថ្មពួកទៅរស់នៅភូមិជនបទដាច់ស្រយាលមួយឈ្មោះភូមិតាសៀវ ។ ម៉ែកាន់ដៃបណ្តើរខ្ញុំ ចំណែកពុករែកអំរែកដែលមានកន្ទេលខ្នើយ មុងខោអាវ ចានឆ្នាំង អំបិល ប្រហុក ។ បងប្រុសទាំងពីរកាន់និងទូលរបស់របរបន្ទាប់បន្សំ ។ អ្នកមានឡាន រទេះ ម៉ូតូ កង់ គ្រាន់ដឹកជញ្ជូនទ្រព្យសម្បត្តិនិងស្បៀងអាហារ ។ ចុះយើងវិញតើបានអ្វី? មានតែ ទូល លី សែង រែក ដូច្នោះឯង ។ អ្នកភូមិទាំងអស់ចេញព្រមៗគ្នា ព្រោះខ្លាចអង្គការចោទប្រកាន់ថារឹងទទឹងនឹងបទបញ្ជា ។ គ្មាននរណាម្នាក់បានទទួលសិទ្ធិពិសេសឲ្យស្នាក់នៅក្នុងភូមិទេ ។ សូម្បីតែអ្នកជំងឺសម្រាកពេទ្យដើរមិនរួច ក៏ត្រូវបង្ខំឲ្យចាកចេញដែរ ។

ក្រោមកម្តៅថ្ងៃព្រះអាទិត្យក្តៅហែង នៅតាមដងផ្លូវធូលីហុយសំពោងពេលខ្យល់បក់ម្តងៗ កង់ ម៉ូតូ ឡាន រទេះ មនុស្សចម្រុះគ្នានៅលើដងផ្លូវ ។ សំឡេងក្មេងយំលាយឡំនឹងសម្រែកម៉ាន់ទាដែលអ្នកខ្លះចងរែកមកជាមួយបង្ការធ្វើម្ហូប បានក្លាយជាតន្ត្រីខ្លងខែកពុះជ្រែកអារម្មណ៍មួយហ្វូងប្រជាជនជម្លៀសដែលហូរញើសជោកខ្លួន ។

ម៉ោងប្រហែល១២ថ្ងៃត្រង់ គ្រួសារខ្ញុំបានមកដល់ភូមិតាសៀវ ។ នៅទីនោះហើយដែលខ្ញុំបានបង្កើតនូវអនុស្សាវរីយ៍ដ៏ផ្អែមល្ហែមនិងជូរចត់ដល់ក្រុមគ្រួសារខ្ញុំមិនអាចបំភ្លេចបានឡើយ ។ ពុកខ្ញុំត្រូវអង្គការបញ្ជូនឲ្យទៅចាំចម្ការរួម ចំណែកម្តាយខ្ញុំត្រូវបញ្ជូនទៅដកស្ទូងនៅឯវាលស្រែ ក្រោយមកដោយឃើញម៉ែពិការខ្វិនទើបប្រធានភូមិដកគាត់ឲ្យមកដាក់បាយជ្រូកវិញ ។ បងប្រុសធំរបស់ខ្ញុំត្រូវបញ្ជូនទៅធ្វើការនៅកងចល័ត ឯបងប្រុសទី២ត្រូវបញ្ជូនទៅកងចល័តកុមារ ។

គ្រួសារខ្ញុំបានមករស់នៅភូមិនេះដោយគ្មានអ្វីទាំងអស់ សូម្បីដីធ្លី ផ្ទះសម្បែង និងញាតិសន្តានក៏គ្មានដែរ ប៉ុន្តែដោយសារភាពរួសរាយរាក់ទាក់របស់ពុកខ្ញុំ គ្រួសារខ្ញុំបានទទួលការស្រឡាញ់រាប់អានច្រើនពីសំណាក់អ្នកមូលដ្ឋាន ។ ម្តាយខ្ញុំបានរំឭកប្រាប់ខ្ញុំថា ពេលដែលមកដល់ទីនេះភ្លាម សម្លៀកបំពាក់ថ្មីៗដែលយើងយកមកតាមខ្លួន ពុកចែកឲ្យអ្នកមូលដ្ឋានអស់ ។ ដើម្បីជាការតបស្នងដល់ទឹកចិត្តល្អរបស់ពុក អ្នកស្រុកបានប្រគល់ខោអាវពណ៌ខ្មៅថ្មី១កំប្លេ មួកកន្ទឹបមួយ និងស្បែកជើងកង់ឡានមួយគូដល់ពុក ។ ក្រៅពីទឹកចិត្តសប្បុរសរបស់ពុកដែលមានចំពោះអ្នកដទៃ ពុកក៏ស្រឡាញ់ម៉ែខ្លាំងណាស់ដែរ គាត់មិនដែលឲ្យម៉ែធ្វើកិច្ចការណាដែលធ្ងន់ៗទេតាំងពីម៉ែបានជាសះស្បើយពីជំងឺក្វាត់ឆ្អឹងខ្នងរបស់គាត់មក ។ ម៉ែនិយាយប្រាប់ខ្ញុំទាំងទឹកភ្នែករលីងរលោងថា នៅពេលដែលម៉ែដេកស្នាក់នៅព្យាបាលជំងឺនៅពេទ្យរុស្ស៊ីក្រុងភ្នំពេញ ម៉ែបានប្រាប់ពុកឲ្យរើសរកនារីណាម្នាក់ដែលល្អ ព្រោះគាត់លែងស្អាតទៀតហើយ ។ ពេលនោះពុកតបទៅម៉ែដោយទឹកមុខមាំថា «ខ្ញុំនឹងមិនរៀបការជាមួយនារីណាផ្សេងជាដាច់ខាត ទោះជាឯងមិនល្អដូចដើមក៏ពិតមែន តែឯងត្រូវតែរស់ដើម្បីឲ្យកូនៗរបស់យើងហៅម៉ែៗដែរ» ។

កាលណោះខ្ញុំនៅតូច អង្គការមិនបានបញ្ជូនខ្ញុំឲ្យទៅណាឆ្ងាយពីម្តាយទេ តែបញ្ជូនខ្ញុំឲ្យទៅរៀនសូត្រនៅសាលាជិតនោះ ។ ខ្ញុំរៀនក្រោមដើមអម្ពិល គ្មានតុ គ្មានសៀវភៅសរសេរទេ ។ គ្រូបង្រៀនគឺជាមនុស្សរបស់អង្គការ ដែលបញ្ជូនឲ្យមកដុសខាត់ខួរក្បាលកុមារឲ្យស្រឡាញ់និងគោរពអង្គការនិងស្មោះត្រង់ជាមួយអង្គការជានិច្ច ។ សំណាងល្អ គ្រូគឺន ជាគ្រូរបស់យើង

ចិត្តល្អណាស់ មិនដែលធ្វើបាបកុមារម្តងណាទេ ។ ថ្វីបើគាត់ជាមនុស្សរបស់អង្គការយ៉ាងណាក៏ដោយ ក៏ចិត្តគំនិតរបស់ គ្រូគីន មិននៅជាមួយអង្គការឡើយ ។ មេរៀនរបស់យើងគឺ “ក, ខ,គ...” គ្រូឲ្យយើងទន្ទេញចាំមាត់នូវបទចម្រៀងបដិវត្តដ៏រុងរឿងរបស់អង្គការទំនុកចម្រៀងមានខ្លឹមសារដូចខាងក្រោមនេះ÷

*យើងខ្ញុំកុមារ ស្រឡាញ់អង្គការ ឥតមានព្រំដែន ដោយសារអង្គការ យើងខ្ញុំរស់រាន ជីវិតថ្កើងថ្កាន រីករាយអស្ចារ្យ ។ មុនបដិវត្តន៍ កុមារក្រខ្សត់ រងទុក្ខវេទនា រស់ដូចសត្វធាតុ កំព្រាខ្ទេចផ្សា អាក្រាត់មោហា គ្មាននឹកនាដល់ ។ ស្បែកដណ្តប់ឆ្អឹង ស្គាំងស្គមកំព្រឹង ហៅសែនកន្ទល់ យប់ដេកនឹងដី ថ្ងៃឡើងខ្វាយខ្វល់ កាយកាកសំណល់ ដើរសុំទានគេ ។ ឥឡូវយើងខ្ញុំ អង្គការឧត្តម ឧបត្ថម្ភគ្រប់គ្នា បំប៉ន់សុខភាព កម្លាំងខ្លាំងក្លា ឲ្យរស់នៅជា សមូហភាព ។ មានស្លៀកមានពាក់ លែងរងាញាក់ លែងរស់ថោកទាប រស្មីបដិវត្តន៍ រស្មីស្មើភាព សិទ្ធិសេរីភាព ចាំងចែងឆ្អិនឆ្អៅ ។ ឱសឱអង្គការ! យើងខ្ញុំស្នេហា យ៉ាងសែនជ្រាលជ្រៅ យើងខ្ញុំប្តេជ្ញា ដើរតាមផ្លូវត្រូវ ផ្លូវក្រហមឆ្អៅ អង្គការបវរ ។ ខិតខំរៀនសូត្រ ឲ្យចេះដឹងស្ទាត់ លេខនិងអក្សរ ពលកម្មជំនាញ សតិអារម្មណ៍ល្អ ដើម្បីបន្តវេនបដិវត្តន៍ ។*

បើតាមអត្ថន័យនៃបទចម្រៀងនេះគឺពីរោះស្តាប់ណាស់ តែផ្ទុយទៅវិញ គឺជាការខ្ទេចផ្សាក្រៃលែងសម្រាប់កុមារដែលមានវាសនាអាក្រក់នាសម័យនោះ ។ មិត្តរួមថ្នាក់របស់ខ្ញុំសល់តែស្បែកដណ្តប់ឆ្អឹង ដោយសារការហូបចុកមិនគ្រប់គ្រាន់ ។ ក្រៅពីការរៀនសូត្របន្តិចបន្តួច “សឹងតែគ្មាន” បញ្ជូនកុមារឲ្យទៅរើសដីអាចម៍គោលាយជាមួយដើមទន្ទ្រានខែត្រនៅតាមវាលស្រែក្រោមកម្តៅថ្ងៃ ដើម្បីយកទៅដាក់ស្រែបង្កើនទិន្នផលស្រូវមួយហិកតាឲ្យបាន៣តោនតាមផែនការរបស់អង្គការ ។ ខ្ញុំឃើញផ្ទាល់ភ្នែកកុមារជនជាតិចិនម្នាក់គ្រាន់តែខ្យល់បក់ក៏ដួលធ្លាក់ទឹកលង់ហៀបនឹងស្លាប់ទៅហើយ ។

គ្រូគីន ស្រឡាញ់យើងទាំងអស់គ្នាណាស់ ចំណែកយើងក៏ស្រឡាញ់គាត់វិញណាស់ដែរ ។ ថ្ងៃមួយក្រោយពេលសម្រាកពីរៀនសូត្រ គាត់បាននាំយើងចូលទៅក្នុងព្រៃជ្រៅដោយប្រាប់អង្គការថា នាំសិស្សទៅរើសដីអាចម៍គោ ។ គាត់បង្គាប់ឲ្យកុមារដែលមានអាយុច្រើនសែងឆ្នាំងដីមួយធំបន្តួរ ។ ពេលចូលទៅដល់ក្នុងព្រៃ គាត់បង្គាប់ឲ្យយើងរកកន្ទែងសម្រាកបន្តិចសិន រួចបង្កាត់ភ្លើងដើម្បីស្ងោរដំឡូងដែលគាត់បានលាក់ទុក ។ យើងហូបដំឡូងយ៉ាងឆ្អែតទើបនាំគ្នាត្រឡប់មកផ្ទះវិញ ។

ថ្ងៃមួយក្រុមរបស់ខ្ញុំត្រូវបញ្ជូនឲ្យទៅរើសដីអាចម៍គោនៅឆ្ងាយពីភូមិ ហើយត្រូវដេកនៅទីនោះចំនួន២ថ្ងៃ ។ នេះជាពេលវេលាមួយដែលធ្វើឲ្យខ្ញុំមានអារម្មណ៍ចុកចាប់គ្មានភ្លេច ។ កុមារអាយុក្រោម១០ឆ្នាំដែលត្រូវការថ្នាក់ថ្នមពីឪពុកម្តាយ បែរជាត្រូវទទួលការឈឺចាប់និងសម្ពុតគំរាមកំហែងបំបាក់ស្មារតីពីអង្គការ ។ យប់នោះជាយប់ដំបូងបំផុតក្នុងជីវិតរបស់ខ្ញុំ ដែលដេកឆ្ងាយពីម្តាយខ្ញុំ ។ ក្រោមតំណក់ទឹកសន្សើមដ៏ត្រជាក់នារដូវរងាលាយឡំនឹងសំឡេងឆ្កែចចកលូកណ្តាលរាត្រី យើងនាំគ្នាដេកក្រោមចំបើងកណ្តាលវាលស្រែគួរឲ្យកម្សត់វេទនាណាស់ ។

នៅសម័យ ប៉ុល ពត ប្រជាជនត្រូវបែងចែកជាពីរប្រភេទ គឺប្រជាជន១៧មេសា និង ប្រជាជនមូលដ្ឋាន ឬប្រជាជនចាស់ ។ ហើយប្រជាជនដែលមានឥទ្ធិពលខ្លាំងគឺប្រជាជនមូលដ្ឋាននេះឯង ។ អង្គការបំផុសអ្នកមូលដ្ឋានឲ្យស្អប់និងចងគំនុំអ្នក១៧មេសាថា “អ្នក១៧មេសាគឺជាមូលធននិយម សក្តិភូមិ ពួកជិះជាន់កេងប្រវ័ញ្ចអ្នកក្រ ។ ចំណែកអ្នកមូលដ្ឋានគឺជាកម្មករ កសិករ និងវណ្ណៈអធនដែលត្រូវបានចាត់ទុកថាជាកម្លាំងចលករដ៏រឹងមាំ” ។ ប្រជាជន១៧មេសាត្រូវបញ្ជូនឲ្យទៅរស់នៅតាមជនបទដាច់ស្រយាលនិងបង្ខំឲ្យធ្វើការជាទម្ងន់ ។

ប្រជាជននៅភូមិតាសៀវក៏ចាត់ទុកគ្រួសារខ្ញុំជាអ្នក១៧មេសាដែរ ។ ដំបូងឡើយអ្នកមូលដ្ឋានមើលងាយគ្រួសារខ្ញុំណាស់ថាគ្រួសារខ្ញុំមិនព្រមជម្រុះចោលនូវ“កម្មសិទ្ធិក្រាស់” មិនតែប៉ុណ្ណោះ ថែមទាំងដៀលគ្រួសារខ្ញុំថា “ពួកចម្ប៉ា” អត់ផ្ទះសម្បែងនៅនឹងគេប្រៀបបីដូចជាមនុស្សខ្វាត់ព្រាត់ ។ ទោះជាទទួលការមើលងាយយ៉ាងណាក៏ដោយ ក៏គ្រួសារខ្ញុំស៊ូទ្រាំអត់ធ្មត់មិនដែលឲ្យមានបញ្ហាកើតឡើងម្តងណាឡើយ ។ គ្មាននរណាម្នាក់ហ៊ានប្រឆាំងនឹងអង្គការទេ អ្នកដែលប្រឆាំងនឹងអង្គការគឺជាមនុស្សដែលត្រូវ “កម្ទេច” ដោយអនុវត្តតាមទ្រឹស្តីៈ បំបាត់រាជ្យ បង្កើតអង្គការ បំបាត់ពុទ្ធដារ បង្កើតវិភាគទាន បំបាត់អ្នកមាន បង្កើតអ្នកក្រ

បំបាត់ពណ៌ស បង្កើតពណ៌ខ្មៅ ដំឡើងអ្នកខ្មៅ បំបាត់អ្នកចេះ ។

ការសម្លាប់ក្នុងសម័យនោះ “ស្រួលជាងបកចេកទៅទៀត” អង្គការគឺជាអ្នកកំណត់ខ្សែជីវិតរបស់យើង ។ គ្រួសារខ្ញុំរស់នៅក្នុងភូមិតាសៀវប្រកបដោយភាពផ្អែមល្ហែមនិងជូរចត់លាយឡំគ្នា ។ ប៉ុន្តែបើគិតទៅគ្មានបញ្ហាអ្វីធំដុំគួរឲ្យកត់សម្គាល់ក្រៅពីការអត់ឃ្លាននិងធ្វើការបាក់កម្លាំងទេ ។ យូរៗទៅយើងហាក់ដូចជាក្លាយទៅជាអ្នកមូលដ្ឋានដោយមិនដឹងខ្លួន ។ ឪពុកខ្ញុំមានមិត្តភក្តិច្រើនដែលសុទ្ធតែជាអ្នកមូលដ្ឋាន ប៉ុន្តែក៏គ្រួសារអ្នកមូលដ្ឋានខ្លះ មានចិត្តប្រណែនគ្រួសារខ្ញុំដែរ ។ ប្រធានភូមិឈ្មោះ បងគាន រាប់អានគ្រួសារខ្ញុំណាស់ ជាហេតុធ្វើឲ្យយើងក្លាយជាអ្នកដែល “ទទួលបានការអនុគ្រោះ» ច្រើនជាងគ្រួសារអ្នក១៧មេសាដទៃទៀត ។ គ្រួសារខ្ញុំមានកម្មសិទ្ធិកាន់កាប់ផ្ទះសម្បែង ដីធ្លី ចានឆ្នាំងជាដើម ដែលគ្មាននរណាមានសិទ្ធិរបៀបនេះទេ ។ គ្រួសារចិនៗដែលបានជម្លៀសមកពីភ្នំពេញនិងពីខេត្តបាត់ដំបង ត្រូវអង្គការបញ្ជូនឲ្យទៅរស់នៅក្នុងជង្រុកស្រូវចាស់ៗ ពេលភ្លៀងធ្លាក់ម្តងៗគាត់ទាំងអស់នោះមិនដែលបានដេកឡើយ ។

ថ្ងៃមួយយើងបានទទួលដំណឹងថា បងប្រុសទី១របស់ខ្ញុំមានជំងឺជាទម្ងន់ ។ គាត់គ្រុនចាញ់ក្នុងខណៈដែលអង្គការបញ្ជូនគាត់ទៅលើទំនប់អាងត្រពាំងថ្ម ។ គ្រាន់តែទទួលបានដំណឹងនេះភ្លាមពុកម៉ែបានរួសរាន់ចេញទៅទទួលគាត់ ប៉ុន្តែអ្វីដែលគាត់ទាំងពីរនឹកស្មានមិនដល់នោះគឺភាពស្គមកំព្រឹងនៅតែស្បែកដណ្តប់ឆ្អឹងរបស់បងប្រុសខ្ញុំ ។ ពុកម៉ែខ្ញុំទប់ទឹកភ្នែកមិនបានទេនៅពេលដែលឃើញសភាពបងប្រុសខ្ញុំបែបនេះ ។ បងប្រុសខំនិយាយទាំងសំឡេងខ្សាវៗមករកពុកម៉ែថា “កូនមានជំងឺគេទុកឲ្យកូនស្លាប់ដោយមិនមានថ្នាំព្យាបាល កូននឹកផ្ទះ នឹកពុកម៉ែនិងប្អូនៗពេកទើបខំត្រដររវាពីត្រពាំងថ្មត្រឡប់មកផ្ទះវិញ ព្រោះបំណាច់នឹងស្លាប់យ៉ាងហោចណាស់បានជួបមុខពុកម៉ែនិងប្អូនៗជាចុងក្រោយដែរ» ។ បងប្រុសរៀបរាប់បណ្តើរទឹកភ្នែកហូរស្រក់លើផែនថ្ពាល់ដ៏ខ្លួងរបស់គាត់បណ្តើរ ។ សំណាងល្អបងប្រុសបានត្រូវអ្នកបរទេះគោម្នាក់ជួយយកអាសា ។ ពុកម៉ែខំបំពោកថ្នាំខ្មែរ ជាពិសេសបុកស្លឹកស្តៅបំពោក រហូតដល់បងប្រុសបានជាដូចដើមវិញ ។

## ទារុណកម្ម

ក្នុងសម័យ ប៉ុល ពត អង្គការប្រើមនុស្សដូចសត្វធាតុ ។ យកមនុស្សទៅអូសនង្គ័ល ប្រើមនុស្សឲ្យលើកដី ជីកស្រះមិនថាថ្ងៃយប់ ។ ទាំងក្មេងទាំងចាស់ត្រូវតែធ្វើការ អ្នកណាធ្វើការអ្នកនោះមានរបបហូប អ្នកមិនធ្វើការជាមនុស្សដែលជិះជាន់កម្លាំងពលកម្មអ្នកដទៃ ។ បើមាននរណាម្នាក់ឈឺក្រោកពីកន្ទេលមិនរួច អង្គការថា “ឈឺសតិអារម្មណ៍” ។ ការហូបចុកមិនដែលគ្រប់គ្រាន់ទេ មានតែបបររាវកក្លូក ។

គ្រួសារខ្ញុំក៏ដូចប្រជាជនដទៃទៀតក្នុងភូមិដែរ ថ្វីបើយើងទទួលបានការអនុគ្រោះច្រើនក៏ពិតមែន ប៉ុន្តែមិនមានន័យថា ការហូបចុករបស់យើងគ្រប់គ្រាន់នោះទេ ។ យើងហូបគល់ចេក គល់ល្ហុង និងក្តួច លួចដាំបាយលាយជាមួយនឹងអង្ករដើម្បីបង្គ្រប់ការហូបចុករបស់យើង ។ យើងហូបកណ្តូប ចង្រិត បង្កួយ ។ល។ ខ្ញុំនៅចាំបានថា ពេលមួយនោះ ក្រោយពេលសម្រាកពីការងារក្រោមកម្តៅថ្ងៃក្តៅហែង មានបុរសម្នាក់រូបរាងស្គមកំព្រឹងពេលដើរមកដល់ជិតគុម្ពស្តៅមួយដើមដែលមានត្រួយខ្ចីល្អ គាត់ក៏ស្ទុះទៅបូតត្រួយស្តៅយកមកហូប ឃើញដូច្នោះកងឈ្លបដែលនៅជិតនោះបានអូសគាត់យកទៅសម្លាប់ចោលចម្ងាយប្រមាណ៥០ម៉ែត្រពីការដ្ឋាន ។ យើងទាំងអស់គ្នាសង្វេគយ៉ាងខ្លាំងចំពោះព្រឹត្តិការណ៍ដ៏សែនឃោរឃៅនេះ ។

ឪពុកម្តាយខ្ញុំស្រឡាញ់ខ្ញុំណាស់ ព្រោះកាលណោះខ្ញុំនៅតូច ។ គាត់ទាំងពីរតែងតែរំលែកអាហារម្នាក់បន្តិចទុកឲ្យខ្ញុំ ប៉ុន្តែកូនៗរបស់អ្នកមូលដ្ឋាននាំគ្នាលួចស៊ីអាហាររបស់ខ្ញុំអស់នៅពេលគាត់មិននៅ ។ នេះជាព្រហ្មវិហារធម៌ដែលពួកគាត់ទាំងពីរមានចំពោះខ្ញុំ ។

រៀងរាល់យប់យើងមិនដែលបានអង្គុយជជែកគ្នាលេងជាលក្ខណៈជាគ្រួសារទេ ព្រោះមានឈ្លបលបចាំស្តាប់ក្រោមផ្ទះ ។ ប្រសិនបើនិយាយអ្វីមួយដែលប្រឆាំងនឹងអង្គការ យើងនឹងត្រូវយកទៅសម្លាប់ចោល ។ ពេលយប់យើងដេកមិនសូវលក់ទេ ព្រោះអារម្មណ៍របស់យើងនៅជាប់តែនឹងសេចក្តីស្លាប់ ។ ពេលរំឭកដល់រឿងនេះខ្ញុំតែងមានអារម្មណ៍ក្តុកក្តួលជានិច្ច នឹកសង្វេគដល់គ្រួសារគយមួយឈ្មោះ កន ដែលរាប់អានគ្នាយ៉ាងស្និទ្ធនឹងបងប្រុសច្បងរបស់ខ្ញុំ ។ គ្រួសារអ៊ឹកនមានសមាជិក១១នាក់ ប្រុស៥

នាក់ និងស្រី៦នាក់ ។ ថ្ងៃមួយកងឈ្លបមកសួរ អ៊ឹកន ថា "ចង់ត្រឡប់ទៅស្រុកកំណើតវិញទេ?" ។ ដោយក្ដីត្រេកអរ អ៊ឹកន ឆ្លើយភ្លាមថា "ចង់" ។ កងឈ្លបនោះប្រាប់ទៅវិញថា "បើចង់ស្អែករៀបចំខ្លួនដើម្បីធ្វើដំណើរត្រឡប់ទៅស្រុកកំណើតវិញ" ។ ល្ងាចនោះគ្រួសារ អ៊ឹកន សប្បាយចិត្តជាខ្លាំង ព្រោះគាត់គិតថាអង្គការបញ្ជូនគាត់ត្រឡប់ទៅភូមិកំណើតវិញមែន ។ គាត់ដើរជម្រាបលាអ្នកជិតខាងទាំងញញឹម ។ ចូលមកដល់ផ្ទះខ្ញុំ អ៊ឹកន មានទឹកភ្នែករលីងរលោង ស្ទុះទៅឱបឪពុកខ្ញុំហើយនិយាយទាំងអួលដើមកថា "ខ្ញុំលាលោក សួន ឯងត្រឡប់ទៅភូមិកំណើតវិញហើយ" ។ ឪពុកខ្ញុំតបទាំងរំភើបក្នុងចិត្តវិញថា "សូមទៅឲ្យបានសុខចុះ ថ្ងៃណាមួយយើងនឹងជួបគ្នាវិញទេ" ។ ឪពុកម្ដាយខ្ញុំបានជូនពរគាត់ប្រកបតែសេចក្ដីសុខគ្រប់ពេលវេលាក្នុងការធ្វើដំណើរត្រឡប់ទៅស្រុកកំណើតវិញ ។

ចម្លែកមែន ថ្ងៃដែលរទេះគោដឹកគ្រួសារ អ៊ឹកន ចេញពីភូមិអង្គការហាមមិនឲ្យប្រជាជនធ្វើដំណើរទៅណាមកណាជាដាច់ខាត ។

អនិច្ចា! ព្រឹកឡើង អ្វីដែលធ្វើឲ្យខ្ញុំស្លុតចិត្តនោះគឺអ្នកភូមិបានឃើញសាកសព អ៊ឹកន និងក្រុមគ្រួសារនៅចម្ងាយកន្លះគីឡូម៉ែត្រពីភូមិ ។ គ្រួសារ អ៊ឹកន ស្លាប់ដោយត្រូវសំពងនឹងដំបង កូនស្រីតូចបង្អស់របស់អ៊ឹកនស្លាប់នឹងចំពុះទុងកាំភ្លើង ។ សាកសពនៅដេករដូករណែលក្បែរៗគ្នាទាំងដៃជាប់ចំណង ។ យើងទាំងអស់គ្នាបានត្រឹមតែលាក់សេចក្ដីសោកសង្រេងក្នុងអារម្មណ៍ប៉ុណ្ណោះ ។ មរណភាពដ៏សែនឃោរឃៅនេះបានបន្សល់ទុកនូវការឈឺចាប់និងការសោកស្ដាយដល់ បងកុសល ឲ្យរស់នៅត្រមង់ត្រមោចតែម្នាក់ឯង ។

## ម្ដាយខ្ញុំមានជំងឺ

ថ្ងៃមួយនារដូវវស្សាឆ្នាំ១៩៧៧ ម្ដាយខ្ញុំចាប់ផ្ដើមឈឺខ្លាំងធ្ងន់ ។ តាមសភាពជំងឺនិងគ្មានថ្នាំព្យាបាល គ្មាននរណាម្នាក់គិតថាគាត់អាចមានជីវិតរស់មកដល់ពេលនេះទេ ។ គាត់មានជំងឺចុះរាកហូរដូចទឹក ។ រយៈពេលត្រឹមតែមួយអាទិត្យគាត់ស្គមនៅសល់តែស្បែកដណ្ដប់ឆ្អឹង ។ ពុកខ្វល់ខ្វាយជាខ្លាំង ។ តាំងពីដើមមកពុកស្រឡាញ់ម៉ែណាស់ គាត់មិនដែលឲ្យម៉ែធ្វើការធ្ងន់ៗទេ ។ មួយថ្ងៃៗពុកមិនដែលបានសម្រាកទេ ណាមួយត្រូវទៅចាំចម្ការ ណាមួយត្រូវមើលថែជំងឺម៉ែ ។ ដោយសារតែសភាពជំងឺមិនបានធូរស្រាលពុកក៏បញ្ជូនម៉ែទៅសម្រាកនៅមន្ទីរពេទ្យផ្ដាំ ។ ខ្ញុំនៅចាំបានថា ថ្ងៃដែលម៉ែត្រូវបញ្ជូនទៅមន្ទីរពេទ្យ ខ្ញុំឱបកន្ទេលចាស់មួយ បងប្រុសទី២ឱបបង្វេចខោអាវចាស់ៗរបស់ម៉ែ ដើរតាមក្រោយពុកដែលកំពុងតែបីម៉ែសំដៅទៅរទេះគោ ។

អង្គការបានអនុញ្ញាតឲ្យខ្ញុំនិងបងប្រុសទី២នៅមើលថែជំងឺម៉ែ ចំណែកពុកមិនបានអនុញ្ញាតទេ ដោយសារពុកត្រូវទៅធ្វើការ ។ រៀងរាល់សប្ដាហ៍ពុកតែងផ្ញើកំពីសហាល ត្រីសាច់បន្តិចបន្តួចឲ្យយើងទាំងបីនាក់នៅមន្ទីរពេទ្យ ។ ពុកតែងតែសួរនាំពីសភាពជំងឺម៉ែនិងកូនៗជានិច្ច ។

មន្ទីរពេទ្យផ្ដាំគឺជាអតីតវត្តអារាម ។ មន្ទីរពេទ្យផ្ដាំមានអ្នកជំងឺប្រហែល១០០នាក់ ដែលមានរាងកាយស្គមកំព្រឹងៗរង់ចាំតែថ្ងៃស្លាប់ប៉ុណ្ណោះ ព្រោះមន្ទីរពេទ្យគ្មានអ្វីទាំងអស់ គ្មានថ្នាំព្យាបាល គ្មានគ្រូពេទ្យចំណានៗ ។ ថ្នាំដែលមានប្រសិទ្ធភាពនៅពេលនោះគឺថ្នាំអាចម៍ទន្សាយ ចំណែកឯថ្នាំចាក់វិញគឺទឹកដូង ។ ដៃស្ដាំរបស់ខ្ញុំជាភស្តុតាងស្រាប់ ដោយសារចាក់ថ្នាំទឹកដូងបណ្ដាលឲ្យដៃរបស់ខ្ញុំកើតបូស ។

ថ្ងៃមួយនៅពេលសម្រាកពីការងារ បងប្រុសទី១របស់ខ្ញុំឆ្លៀតមកសួរសុខទុក្ខម៉ែដល់មន្ទីរពេទ្យ ។ គាត់ស្រក់ទឹកភ្នែកនៅពេលដែលឃើញម៉ែមានសភាពយ៉ាប់យ៉ឺនបែបនេះ ។ គាត់បានប្ដឹងអង្គការថ្នាក់លើថាបុគ្គលិកមន្ទីរពេទ្យមិនយកចិត្តទុកដាក់និងផ្ដល់ចំណីអាហារមិនគ្រប់គ្រាន់ដល់អ្នកជំងឺ ។ ចាប់តាំងពីបងរបស់ខ្ញុំតវ៉ាមក អ្វីៗមានការផ្លាស់ប្ដូរជាងមុន បបរក្លាយពីរាវកក្លុកទៅជាខាប់វិញម្ដង ។ ចំណែកជំងឺរបស់ម៉ែចេះតែធូរស្រាលបន្តិចម្ដងៗរហូតបានជាសះស្បើយ ។ តើមានអ្វីដែលសប្បាយជាងនេះ?

## ការចាប់ខ្លួនពុក

នៅខែកក្កដា ឆ្នាំ១៩៧៧ វេលាម៉ោង១២ថ្ងៃត្រង់ ឪពុកខ្ញុំនិងអ្នកភូមិ១០នាក់ត្រូវអង្គការចាប់ខ្លួន នៅខណៈពេលគាត់កំពុងដើរសំដៅទៅរោងបាយរួមដើម្បីហូបបាយថ្ងៃត្រង់ ។ គ្មាននរណាម្នាក់ក្នុងគ្រួសារខ្ញុំបានឃើញផ្ទាល់ភ្នែកក្រៅពីខ្ញុំឡើយ ។

ស្នូរជួងបានបន្លឺឡើងជាសញ្ញាប្រាប់ថាដល់ពេលហូបបាយហើយ ។ ស្ថិតនៅក្នុងសម្លៀកបំពាក់រហែករហ៊ែ បងក្រមា

ជាមួយនឹងបារីស្លឹកសង្កែបៀមនឹងមាត់ ពុកធ្វើដំណើរសំដៅទៅរោងពាណិជ្ជកម្មទាំងទឹកមុខក្រៀមក្រំ ។ ខ្ញុំដើរតាមពីក្រោយពុកដៃម្ខាងកាន់ចាន ដៃម្ខាងកាន់ស្លាបព្រាគោះប្រគំលេងជាបទភ្លេងតាមនិស្ស័យក្មេង ។ មកដល់ក្បែរជង្រុកស្រូវប្រហែលជា១០០ម៉ែត្រពីរោងពាណិជ្ជកម្ម ស្រាប់តែយោធាស្លៀកពាក់ខ្មៅចំនួន៤នាក់ ស្ទុះចេញពីក្រោយជង្រុកស្រូវមកក្រៀកឪពុកខ្ញុំចងស្លាបសេក ។ ឃើញហេតុការណ៍នេះ ខ្ញុំស្រែកយំយ៉ាងខ្លាំង ។ យោធាម្នាក់ស្រែកគំរាមមិនឲ្យខ្ញុំយំថា «ប្រយ័ត្នអញចាប់ដូចឪហ្អែងណ៎ា» ។ ឪពុកខ្ញុំឮដូច្នោះងាកមកខ្ញុំហើយនិយាយថា «កុំយំអីកូនទៅផ្ទះវិញចុះ ប្រាប់ម៉ែឯងឲ្យផ្ញើខោខ្លីនិងថ្នាំជក់មួយថង់ឲ្យពុកផង» ។ ខ្ញុំរត់ត្រឡប់ទៅផ្ទះយ៉ាងលឿន ខណៈនោះម៉ែកំពុងតែអង្គុយក្រងស្បូវ ។ ខ្ញុំស្រែកពីចម្ងាយប្រាប់ម៉ែថា «ម៉ែអើយ គេចាប់ពុកហើយ» ឮដូច្នោះ ម៉ែស្រែកយំហ៊ូ ។ ខ្ញុំក៏យំ ម៉ែក៏យំ យើងយំទាំងពីរនាក់ម៉ែកូន ។ បងប្រុសទាំងពីររបស់ខ្ញុំមិនបានដឹងឡើយ ។ បងទី១ជាប់រវល់ធ្វើការនៅកងចលត័ បងទី២ជាប់ធ្វើការនៅកងកុមារឆ្ងាយពីភូមិ ។

ម៉ែរៀបចំអីវ៉ាន់តាមបណ្តាំពុកទាំងទឹកភ្នែក ។ ម៉ែនិងខ្ញុំប្រញាប់ធ្វើដំណើរទៅរោងពាណិជ្ជកម្ម ជាកន្លែងដែលខ្មែរក្រហមឃុំខ្លួនពុកខ្ញុំ ។ យើងទាំងអស់គ្នារង់ចាំខាងក្រៅ ។ ប្រហែលកន្លះម៉ោងក្រោយ ខ្ញុំឃើញឈ្លបលើកថាសម្ហូបចេញពីរោងពាណិជ្ជកម្ម ។ បាយនិងម្ហូបនៅសល់ទាំងអស់គ្មាននរណាហូបឡើយ ។

នៅពេលរសៀល ឈ្លបបណ្តើរអ្នកទោសទាំងអស់ចេញពីរោងពាណិជ្ជកម្ម ។ យើងទាំងអស់គ្នាឈរមើលអ្នកទោសដែលជាប់ចំណងស្លាបសេកយ៉ាងតឹងបន្តគ្នាពីម្នាក់ទៅម្នាក់ ។ ឪពុកខ្ញុំនៅកណ្តាល ។ នៅពេលពុកដើរមកដល់ជិត ម៉ែបានប្រគល់ខោខ្លីនិងថ្នាំជក់ឲ្យពុកទាំងទឹកភ្នែក ។ ពុកនិយាយមករកម៉ែជាចុងក្រោយថា «អាលាប ចូរឯងមើលថែទាំកូនឲ្យបានល្អផងណ៎ា ខ្ញុំគ្មានសង្ឃឹមថានឹងបានជួបមុខឯងនិងកូនៗទៀតទេ ខ្ញុំលាឯងសិនហើយ» ។ ពាក្យចុងក្រោយរបស់ពុកធ្វើឲ្យម៉ែនិងខ្ញុំខ្សឹកខ្សួលក្នុងអារម្មណ៍ក្រៃលែង ។ ពាក្យបណ្តាំចុងក្រោយរបស់ពុកនៅលាន់ឮជានិច្ចក្នុងអារម្មណ៍របស់ខ្ញុំ ។

ពុកនិងអ្នកទោសផ្សេងទៀតដើរឆ្លងកាត់មុខយើងរហូតដល់ផុតកន្ទុយភ្នែក ។ ឈ្លបដែលបណ្តើរអ្នកទោសគឺជាយុវជន៣នាក់អាយុប្រមាណ១៥ឆ្នាំ ស្ពាយកាំភ្លើងអាកា៤៧អូសដី ។

នៅថ្ងៃនោះ វេលាល្ងាចប្រហែលម៉ោង៥ អង្គមិទ្ទីងមួយត្រូវបានរៀបចំឡើងដែលទាក់ទិននឹងការចាប់ខ្លួននេះ ។ សមមិត្តលាន គណៈភូមិភាគ៥ ជាប្រធានអង្គប្រជុំ ។ ស្នូរទះដៃបានបន្លឺឡើងដើម្បីជាកិច្ចស្វាគមន៍ដល់សមមិត្ត លាន ឡើងចាប់អារម្មណ៍ ។ មិត្តលាន ក្រោយឈរឡើងកណ្តាលហ្វូងមនុស្ស ។ យើងអាចឃើញរូបរាង មិត្តលាន យ៉ាងច្បាស់លាស់ ។ មិត្តលាន អាយុប្រមាណ៣០ឆ្នាំ មាឌធំ សក់រួញ ខ្វាក់ភ្នែកខាងឆ្វេង ពាក់មួកកន្តឹបពណ៌ត្រួយចេក ក្នុងសម្លៀកបំពាក់ពណ៌ខ្មៅ បង់កក្រមា ។ ក្រោយពីធ្វើការវកិច្ចចំពោះអង្គប្រជុំរួចមក មិត្តលាន បានលើកយកបញ្ហាដែលពាក់ព័ន្ធនឹងការចាប់ខ្លួននេះថា «អ្នកទាំងអស់នោះជាខ្មាំងបង្កប់ ។ វាក្បត់ជាមួយនឹងអង្គការហ៊ានលួចយកបាយឲ្យខ្មាំងនៅភ្នំកូនខ្វែង ។ បើទុកពួកវាក៏មិនចំណេញ ហើយបើដកពួកវាចេញក៏មិនខាតដែរ» ។ តាមពិតអ្វីដែល មិត្តលាន បានលើកឡើងគឺជាការចោទប្រកាន់ទាំងស្រុង ។ ហេតុផលដែលឪពុកខ្ញុំត្រូវចាប់ខ្លួនគឺព្រោះតែគាត់មានអតីតភាពជាអ្នករាជការតែប៉ុណ្ណោះ ។ ឪពុកខ្ញុំមិនដែលហ៊ានធ្វើអ្វីប្រឆាំងនឹងអង្គការទេ គាត់ធ្វើគ្រប់បែបយ៉ាងដើម្បីបានរស់ជិតប្រពន្ធកូន ។ គួរឲ្យអាសូរពុកណាស់មិនគួរមកស្លាប់យ៉ាងអាណោចអាធ័មរបៀបនេះ ។ ម៉ែរំឭកប្រាប់ខ្ញុំថា ពុកអាយុថ្ងៃណាស់ គាត់ធ្លាប់ឆ្លងកាត់សមរភូមិក្តៅៗជាច្រើនកាលពីគាត់ធ្វើជាទាហាន ។ ក្រៅពីភាពស្មោះត្រង់ដែលពុកមានចំពោះអង្គការ ពុកក៏មានភក្តីភាពចំពោះមាតុភូមិណាស់ដែរ ។ ម៉ែនិយាយថា ក្នុងអំឡុងពេល២ឆ្នាំចុងក្រោយគឺក្នុងចន្លោះឆ្នាំ១៩៧៧-១៩៧៩ អ្នកខ្លះហ៊ានប្រថុយរត់ចូលទឹកដីថៃដើម្បីបាន រួចជីវិត ម៉ែបង្ខំឲ្យពុកទៅដែរ ប៉ុន្តែពុកឆ្លើយមកម៉ែវិញថា «អាលាប ខ្ញុំនឹងមិនទៅណាចោលឯងនិងកូនៗទេ ខ្ញុំស៊ូស្លាប់រស់ជាមួយឯងនៅលើទឹកដីខ្មែរ» ។ មែន! ទីបំផុតអ្វីៗត្រូវបានបញ្ចប់លើទឹកដីខ្មែរ ។

## ជីវភាពគ្រួសារខ្ញុំក្រោយពីពុកស្លាប់

ក្រោយពីឪពុកខ្ញុំត្រូវចាប់ខ្លួន ស្ថានភាពគ្រួសារខ្ញុំកាន់តែលំបាកខ្លាំងឡើង ។ បន្ទុកគ្រួសារទាំងមូលត្រូវធ្លាក់មកលើម៉ែ ។ ម៉ែត្រូវបំពេញការងារធ្ងន់ជំនួសពុកទាំងអស់ ។ ពេលព្រឹកម៉ែ

ក្រោកតាំងពីម៉ោង៤ទៀបភ្លឺទៅវាលស្រែដើម្បីគោះស្រងែ ព្រោះយើងខ្វះអង្ករហូប ម៉ែដើររើសកួរស្រូវកណ្ដាលថ្ងៃក្ដៅ ម៉ែបេះកាន់កន្ធុរដើរខ្វាររកផ្ដែប ក្ដាម តាមភ្លឺស្រែ ម៉ែបេះពុះខុសវែកទឹក...។ល។ ម៉ែបំពេញការងារសព្វសារពើដែលពីមុនម៉ែមិនធ្លាប់ធ្វើទាល់តែសោះ ។ ម៉ែបំពេញតួនាទីជាមេគ្រួសារផងនិងឆ្លៀងឱកាសថ្នាក់ថ្នមខ្ញុំផង ។ ម៉ែអប់រំកូនៗឲ្យធ្វើតែអំពើល្អ កុំបង្ករឿងជាមួយកូនអ្នកមូលដ្ឋាន ។ ម៉ែស្រឡាញ់កូនៗណាស់ ម៉ែខិតខំគ្រប់បែបយ៉ាងដើម្បីចិញ្ចឹមកូនៗ ។ ភាពលំបាកលំបិននិងការតស៊ូក្នុងឆាកជីវិតរបស់ម៉ែមានទំហំធំធេងណាស់មិនអាចនឹងសរសេររៀបរាប់បានឡើយ ។

ខ្ញុំមានអារម្មណ៍បាក់ស្បាតចាប់តាំងពីឪពុករបស់ខ្លួនត្រូវចាប់ខ្លួន ។ ខ្ញុំចេះតែគិតថា ថ្ងៃណាមួយប្រាកដជាអង្គការចាប់ម៉ែម្នាក់ទៀតមិនខាន ។ ខ្ញុំដើរតាមម៉ែជានិច្ច សូម្បីតែមួយជំហានក៏តាមដែរ ព្រោះខ្ញុំខ្លាចបាត់បង់ម៉ែទៀត ។

ឆ្នាំ១៩៧៩ កងទ័ពវៀតណាមបានបណ្ដេញខ្មែរក្រហមឲ្យទៅរស់នៅភាគខាងលិចប្រទេសជាប់ព្រំដែនខ្មែរ-ថៃ ។ ក្រោយថ្ងៃ៧មករា ១៩៧៩ ប្រទេសវៀតណាមបានចាត់តាំងឲ្យមានរបបមួយក្នុងប្រទេសខ្មែរឈ្មោះថា "សាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលដឹកនាំដោយលោក ហេង សំរិន, លោក ជាស៊ីម និងឥស្សរជន ជាច្រើនរូបទៀត ។ ចំណែកនៅតាមព្រំដែនខ្មែរ-ថៃមានចលនាតស៊ូដើម្បីប្រឆាំងទៅនឹងអ្វីដែលហៅថា "ការឈ្លានពានរបស់វៀតណាម"ដែរ ។ ក្រៅពីចលនាខ្មែរក្រហមដែលបានរត់គេចខ្លួនទៅនៅតាមជាយដែនខ្មែរ-ថៃ នៅមានចលនាធំៗចំនួន២ទៀតគឺចលនា"រណសិរ្សរួបរួមជាតិដើម្បីកម្ពុជាមួយឯករាជ្យ សន្តិនិងសហប្រតិបត្តិ ហៅថា ហ៊្វុនស៊ិនប៉ិច" ដឹកនាំដោយសម្ដេចព្រះ នរោត្តម សីហនុ ។ សង្គ្រាមបង្ហូរឈាមខ្មែរគ្នាឯងចេះតែបន្តរវាងរដ្ឋាភិបាលដែលនៅក្នុងស្រុកគាំទ្រដោយវៀតណាមនិងសហភាពសូវៀតនិងចលនាតស៊ូដែលគាំទ្រដោយអង្គការសហប្រជាជាតិនិងសមាគមអាស៊ាន ។

ទោះបីជាកងទ័ពវៀតណាមបានរំដោះទីក្រុងភ្នំពេញនៅថ្ងៃទី៧មករា ១៩៧៩ ក៏ដោយ ក៏ប៉ុន្តែនៅតាមមូលដ្ឋានដាច់ស្រយាលមួយចំនួនឋិតនៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហមនៅឡើយ ដូចជាភូមិតាសៀវជាដើម ។ ខ្មែរក្រហមបានបញ្ជាឲ្យប្រធានភូមិគឺ បងគាន ប្រមូលអ្នកភូមិទាំងអស់ទៅជួបគ្នានៅភូមិទ្រាស ។ យើងទាំងអស់គ្នារៀបចំអីវ៉ាន់ជាស្រេចដើម្បីចាកចេញពីភូមិទាំងយប់ ។ បងគាន ប្រាប់អ្នកភូមិទាំងអស់ថា "បើយើងទៅតាមបញ្ជារបស់ខ្មែរក្រហមយើងទាំងអស់គ្នាប្រាកដជាស្លាប់មិនខាន ដូច្នេះយើងត្រូវរកមធ្យោបាយគេចចេញពីទីនេះ" ។ អ្នកភូមិទាំងអស់យល់ស្របតាមគំនិតរបស់ បងគាន ។

ម៉ោងប្រហែល៦ល្ងាចយើងរៀបចំត្រៀមរទេះគោជាស្រេចនៅលើខ្នងទំនប់អាងតាម៉េង ។ ខ្យល់បក់វ៉ូៗធ្វើឲ្យយើងរងាដល់ឆ្អឹងខ្នង ។ បងគាន បានបញ្ជូនអ្នកយកការណ៍ម្នាក់ឲ្យទៅតាមដានសភាពការណ៍នៅភូមិទ្រាស ។ យើងរង់ចាំលើខ្នងទំនប់អាងតាម៉េងរហូតដល់ម៉ោង៧យប់ អ្នកយកការណ៍របស់យើងបានត្រឡប់មកវិញទាំងត្រហេបត្រហប ហើយប្រាប់ថា ប្រជាជនជម្លៀសចេញពីភូមិទ្រាសហើយ ។ គ្រាប់កាំភ្លើង៣គ្រាប់បាញ់ឡើងទៅលើអាកាសជាសញ្ញាឲ្យអ្នកភូមិតាសៀវចេញដំណើរ ។ នៅពេលនោះគ្រួសារខ្ញុំគ្មានរទេះគោទេ ។ មីងទាយ ដែលនៅក្នុងភូមិជាមួយគ្នា អនុញ្ញាតឲ្យយើងដឹកសម្ភារក្នុងរទេះគោរបស់គាត់ ហើយថែមទាំងឲ្យខ្ញុំជិះជាមួយគាត់ទៀតផង ។ យើងធ្វើដំណើរអស់រយៈពេល៣ថ្ងៃ ៣យប់ ឆ្លងកាត់ភូមិតាត្រៃ ជន្លៀសដៃ ស្វាយស ស្វាយខ្មៅ យាងវៀន បុស្សវូ ទើបបានមកដល់ភូមិសាលាក្រៅដែលឋិតនៅក្រោមការត្រួតរបស់វៀតណាម ។

យើងរស់នៅក្នុងភូមិសាលាក្រៅរយៈពេល២ខែទើបត្រឡប់ទៅរស់នៅភូមិតាសៀវវិញ ។ ទៅដល់ភូមិតាសៀវ អនុស្សាវរីយ៍ចាស់ទាំងប៉ុន្មានបានផុសឡើងវិញក្នុងខួរក្បាលរបស់ខ្ញុំ ។ ខ្ញុំបានព្យាយាមបំភ្លេចអតីតកាលដ៏សែនសោកសៅនេះ ប៉ុន្តែស្រមោលអតីតកាលនៅតែតាមលងអារម្មណ៍របស់ខ្ញុំជានិច្ច ។

ចុងឆ្នាំ១៩៧៩ គ្រួសារយើងបានសម្រេចចិត្តទៅរស់នៅជាយដែនដើម្បីបានរស់នៅជួបជុំជាមួយបងប្រុសទី១ដែលរស់នៅទីនោះច្រើនខែមកហើយ ។ យើងចាកចេញពីភូមិតាសៀវតាមរទេះគោនៅវេលាម៉ោង៤ទៀបភ្លឺដោយគ្មាននរណាម្នាក់ដឹងឡើយ ។

**សួន សីលា**

# ការសន្តោសនាំដល់ការគោរពសិទ្ធិមនុស្ស

នៅវេលាម៉ោង៤និង២៥នាទីទៀបភ្លឺ ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៤ មានចោរម្នាក់បានចូលមកក្នុងផ្ទះរបស់ខ្ញុំ ។ ក្នុងពេលដែលចោរនោះលូនឡើងមករកជណ្តើរ ខ្ញុំក៏កំពុងតែដើរទៅរកជណ្តើរចុះទៅក្រោមដែរ ។ ពេលនោះយើងទាំងពីរនាក់ក៏ជួបទល់មុខគ្នា ។ ពេលដែលខ្ញុំកំពុងតែដេញចាប់ចោរនោះ ខ្ញុំបានកត់សម្គាល់ឃើញថា ចោរនោះជាក្មេងប្រុសម្នាក់មានរូបរាងស្គមស្គាំងនិងមានអាយុប្រហែលពី១២ទៅ១៤ឆ្នាំប៉ុណ្ណោះ ។ ក្មេងប្រុសនោះស្លៀកពាក់ពណ៌ខ្មៅ រុំក្បាលនឹងក្រមាពណ៌សស្អាប់ ។

ក្មេងនោះបានព្យាយាមរត់ទៅខាងក្រោយផ្ទះ ដើម្បីសសៀរតាមជញ្ជាំងដែលមានសំយ៉ាបតូចមួយទៅខាងក្រោយ ។ ខ្ញុំបានចាប់ដៃក្មេងនោះជាប់ ។

រំពេចនោះ ខ្ញុំបាននឹកឃើញដល់រឿងរ៉ាវរបស់ខ្ញុំនៅក្នុងរបបខ្មែរក្រហម ។ កាលនោះខ្ញុំមានអាយុប្រហាក់ប្រហែលនឹងចោរម្នាក់នេះដែរ ។ ខ្ញុំបានទៅលួចបូតស្រូវនៅវាលស្រែដើម្បីយកមកឲ្យបងស្រីរបស់ខ្ញុំដែលកំពុងតែមានផ្ទៃពោះនិងជួបប្រទះការអត់ឃ្លានជាច្រើនខែមកហើយ ។ ក្មេងម្នាក់នេះបានធ្វើឲ្យខ្ញុំនឹកឃើញដល់ការចងចាំដ៏ឈឺចាប់មួយគឺពេលដែលខ្ញុំត្រូវឈ្លបខ្មែរក្រហមចាប់បានហើយវាយនឹងខ្នងពូថៅ ។ ពេលនោះខ្ញុំចង់រស់ខ្លាំងណាស់ ។ ឈ្លបខ្មែរក្រហមទាំងនោះបានឃុំខ្លួនខ្ញុំអស់រយៈពេលជាច្រើនសប្តាហ៍ ហើយបានដាក់ទណ្ឌកម្មខ្ញុំយ៉ាងព្រៃផ្សៃបំផុត ។ អនុស្សាវរីយ៍ដ៏ឈឺចាប់មួយនេះស្ថិតនៅជាមួយខ្ញុំរហូតហើយបានរស់រវើកឡើងវិញពេលខ្ញុំចាប់ដៃក្មេងនោះ ។

ដោយនឹកឃើញអារម្មណ៍បែបនេះ ខ្ញុំក៏លែងដៃវិញបណ្តោយឲ្យក្មេងនោះរត់គេច ។ ប្រសិនបើខ្ញុំរុញតែបន្តិច ក្មេងនោះប្រាកដជាធ្លាក់ពីលើអគារកម្ពស់បីជាន់ស្លាប់ជាមិនខាន ។ ខ្ញុំសប្បាយចិត្តដែលមិនបានធ្វើដូច្នេះ ។

បើទោះបីជាខ្ញុំដោះលែងក្មេងនេះក៏ដោយ ក៏ខ្ញុំចង់បង្រៀនឲ្យក្មេងនោះដឹងថាការលួចគឺជាទង្វើមិនត្រឹមត្រូវ ។ ដូច្នេះហើយខ្ញុំបានស្រែកឲ្យអ្នកជិតខាងរបស់ខ្ញុំៗ ។

ដោយសារការតក់ស្លុត ក្មេងនោះបានលោតទម្លាក់ខ្លួនពីលើអគារ ហើយរត់ទៅរកផ្លូវដែលមានភ្លើងអគ្គិសនីភ្លឺព្រោងព្រាតដែលមានសន្តិសុខម្នាក់យាមភោជនីយដ្ឋានមួយនៅខាងក្រោមផ្ទះខ្ញុំ និងអ្នកហាត់ប្រាណជាច្រើននាក់កំពុងតែឈរជជែកគ្នាលេង ។ សន្តិសុខដែលកាន់ដំបងយ៉ាងធំមួយនៅក្នុងដៃ បានរត់ដេញចាប់ចោរនោះ ។ រំពេចនោះ អ្នកដែលមើលឃើញព្រឹត្តិការណ៍បានស្រែកឡើងថា "ចាប់វាឲ្យជាប់ ប៉ុន្តែកុំវ៉ៃវា" ។ សន្តិសុខចាប់ក្មេងនោះបាន ប៉ុន្តែបន្តិចក្រោយមកក៏ដោះលែងវិញ ។

បន្ទាប់ពីហេតុការណ៍នោះខ្ញុំដេកវិញលែងលក់ ប៉ុន្តែខ្ញុំមានអារម្មណ៍ធូរស្បើយក្នុងចិត្តដោយសារតែអនុស្សាវរីយ៍ឈឺចាប់របស់ខ្ញុំប្រហែលជាបានជួយឲ្យក្មេងប្រុសម្នាក់រួចផុតពីសេចក្តីស្លាប់ ហើយវាក៏បានបង្រៀនខ្ញុំឲ្យចេះអភ័យទោសដល់អ្នកដទៃដែរ ។ ខ្ញុំក៏ចាប់អារម្មណ៍ចំពោះវិធីដែលអ្នកមើលមានប្រតិកម្មចំពោះហេតុការណ៍នោះ ។ ប្រសិនបើប្រជាជនកម្ពុជាទាំងអស់មិនយកច្បាប់មកអនុវត្តដោយខ្លួនឯងទេ ការគោរពសិទ្ធិមនុស្សនឹងមានភាពប្រសើរជាងមុន ។

ខ្ញុំសង្ឃឹមថា បន្ទាប់ពីបានទទួលមេរៀនមួយនេះ ក្មេងម្នាក់នោះនឹងព្យាយាមកែប្រែខ្លួនទៅជាមនុស្សល្អ ហើយខ្ញុំក៏សង្ឃឹមថានឹងមាននរណាម្នាក់ពាំនាំសម្តីរបស់ខ្ញុំទៅប្រាប់ក្មេងនោះជាមិនខាន ។

**ឆាំង យុ**

## លិខិតពីសហរដ្ឋអាមេរិក

### *លោក ឆាំង យុ*

កាលពីមុនឪពុករបស់ខ្ញុំក៏ធ្លាប់មានសភាពដូចជាក្មេងដែលចូលក្នុងផ្ទះរបស់លោកនៅយប់នោះដែរ ។ គាត់គឺជាកូនពៅនៅក្នុងគ្រួសារមួយដែលមានសមាជិកច្រើន ដូច្នេះគាត់ត្រូវតែរកអាហារសម្រាប់ខ្លួនឯង ។ បងប្រុសស្រីរបស់គាត់បានចាកចេញពីផ្ទះទៅរកការងារធ្វើ ។ នៅក្នុងផ្ទះសល់តែជីដូនរបស់ខ្ញុំ ឪពុកខ្ញុំនិងបងប្រុសម្នាក់ដែលមានអាយុលើសគាត់តែបន្តិចប៉ុណ្ណោះ ។

ឪពុកខ្ញុំនិយាយប្រាប់ខ្ញុំជារឿយៗអំពីកុមារភាពរបស់គាត់ គឺពេលវេលាដែលគាត់ខ្វល់ខ្វាយតែអំពីការស្វែងរកម្ហូបអាហារ ។ តាមរយៈអ្វីដែលឪពុកខ្ញុំនិយាយប្រាប់ ខ្ញុំមានការយល់ដឹងខ្លះៗអំពីដំណើរជីវិតរបស់គាត់ ។ តាំងពីខ្ញុំនៅតូច ឪពុកខ្ញុំតែងតែប្រដៅខ្ញុំកុំឲ្យមើលងាយកិច្ចការឲ្យសោះ ធ្វើអ្វីក៏ដោយត្រូវតែយកចិត្តទុកដាក់ ពីព្រោះកាលដែលគាត់នៅអាយុប្រហែលខ្ញុំ គាត់គ្មានឱកាសដូចជាខ្ញុំពេលនេះទេ ។ ជួនកាលគាត់យំនៅពេលនិយាយប្រាប់ខ្ញុំអំពីប្រទេសកម្ពុជា ហើយខ្ញុំមិនអាចជួយអ្វីបានក្រៅពីយំជាមួយគាត់តែប៉ុណ្ណោះ ។ ឪពុកខ្ញុំគឺជាព្រះរបស់ខ្ញុំ ជាបុរសដ៏អស្ចារ្យម្នាក់ដែលបានឆ្លងកាត់ការលំបាកវេទនារាប់មិនអស់ ។ គាត់បានខិតខំប្រឹងប្រែងធ្វើការងាររហូតទទួលបានអ្វីដែលគាត់មានសព្វថ្ងៃនេះ ។

ខ្ញុំយល់ពីអារម្មណ៍របស់លោក ហើយខ្ញុំក៏យល់ពីអ្វីដែលក្មេងប្រុសម្នាក់នោះបានឆ្លងកាត់ដែរ ។ ប្រហែលជាលោកមិនជឿខ្ញុំទេ ប៉ុន្តែខ្ញុំពិតជាយល់ច្បាស់ណាស់ក្នុងរឿងនេះ ។

**ប្រាយអាន់ រត**

## លិខិតពីខេត្តបាត់ដំបង

***លោកនាយក!*** អរគុណណាស់ដែលបានចែករំលែករឿងរ៉ាវផ្ទាល់ខ្លួនរបស់លោក ។ ជាការពិត លោកបានសង្គ្រោះជីវិតក្មេងប្រុសនោះដោយក្តីមេត្តារបស់លោក ។ បើមានក្តីមេត្តា សត្រូវនឹងប្រែក្លាយជាមិត្ត ។ សត្រូវរបស់យើងនឹងលែងស្អប់យើងទៀត ផ្ទុយទៅវិញនឹងផ្តល់ក្តីស្រលាញ់តបមកយើងវិញ ។ ដូចជាក្រុមគ្រួសារខ្មែររាប់លានទៀតដែលបានឆ្លងកាត់របបខ្មែរក្រហមដែរ ខ្ញុំយល់ថា អនុស្សាវរីយ៍ឈឺចាប់នៅក្នុងរបបខ្មែរក្រហមនឹងលេចឡើងតាមរបៀបខុសៗគ្នា ជាពិសេសនៅពេលដែលយើងជួបប្រទះនឹងហេតុការណ៍ដូចដែលលោកបានជួបក្នុងយប់នោះ ។

ខ្ញុំកោតសរសើរលោកដែលបានសម្រេចចិត្តដោះលែង និងអភ័យទោសឲ្យក្មេងប្រុសនោះ ។ ព្រះពុទ្ធជាម្ចាស់បានសម្តែងថា "មេត្តាករុណាគឺជាថាមពលដ៏ខ្លាំងក្លា ។ វាសាយភាយទៅគ្រប់វត្ថុមានជីវិតដោយគ្មានរើសអើង ។ វាសាយភាយទៅដល់មនុស្សជាទីស្រលាញ់របស់យើងទៅដល់អ្នកដទៃ និងទៅដល់សត្រូវរបស់យើង ។ មេត្តាករុណាគឺគ្មានព្រំដែនទេ ។" **សួន សីលា**

## អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាបានព្រមព្រៀងគ្នា លើថវិកាចំនួន៥៦លានដុល្លារសហរដ្ឋអាមេរិកសម្រាប់តុលាការខ្មែរក្រហម

កាលពីថ្ងៃទី១០ខែធ្នូ អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាបានព្រមព្រៀងគ្នាទៅលើថវិកាចំនួន៥៦លានដុល្លារសហរដ្ឋអាមេរិកសម្រាប់តុលាការពិសេសមួយដើម្បីនាំមេដឹកនាំខ្មែរក្រហមដែលបានចោទប្រកាន់ថាបានសម្លាប់ប្រជាជនរាប់លាននាក់នៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៧០ ។

ការពិភាក្សារវាងក្រុមអង្គការសហប្រជាជាតិដែលមានសមាជិកប្រាំមួយនាក់និងរាជរដ្ឋាភិបាលកម្ពុជាបានបញ្ចប់នៅទីក្រុងភ្នំពេញ ដោយបានព្រមព្រៀងលើទីតាំងនិងរចនាសម្ព័ន្ធរបស់អង្គជំនុំជម្រះវិសាមញ្ញនេះ ។ អង្គជំនុំជម្រះវិសាមញ្ញនេះមានពីរថ្នាក់គឺ សាលាដំបូងនិងតុលាការកំពូល ដែលសម្រេចសេចក្តីនៅក្នុងវង្វង់នៃប្រព័ន្ធយុត្តិធម៌កម្ពុជាដែលមានស្រាប់ ។

កាលពីខែឧសភា ឆ្នាំ២០០៣កន្លងទៅ មហាសន្និបាតនៃអង្គការសហប្រជាជាតិបានអនុញ្ញាតឲ្យអង្គការសហប្រជាជាតិជួយប្រទេសកម្ពុជាបង្កើតសាលាជំនុំជម្រះក្តីមួយដើម្បីកាត់ទោសជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះបទល្មើសធ្ងន់ធ្ងរនៅក្រោមច្បាប់កម្ពុជានិងច្បាប់អន្តរជាតិនៅក្នុងអំឡុងថ្ងៃ១៧មេសា ឆ្នាំ១៩៧៥ដល់ថ្ងៃ៦មករា ឆ្នាំ១៩៧៩ ។

លោក កូហ្វី អាណាន់ អគ្គលេខាធិការនៃអង្គការសហប្រជាជាតិ បានមានប្រសាសន៍ថា ការឧបត្ថម្ភហិរញ្ញវត្ថុដោយស្ម័គ្រចិត្តនេះគឺត្រូវធ្វើសម្រាប់រយៈពេលបីឆ្នាំនៃដំណើរការរបស់សាលាជំនុំជម្រះក្តី និងយ៉ាងហោចត្រូវមានថវិកាគ្រប់គ្រាន់សម្រាប់ឆ្នាំដំបូងសិន ទើបសាលាជំនុំជម្រះក្តីអាចចាប់ផ្តើមដំណើរការបាន ។ ក្រុមរបស់អង្គការសហប្រជាជាតិនឹងត្រឡប់ទៅលេខាការដ្ឋានរបស់ខ្លួននៅទីក្រុងញូវយ៉កវិញ ដើម្បីជម្រាបជូនអំពីការពិភាក្សាជុំវិញបញ្ហាថវិកានេះ ។ **ការិយាល័យពត៌មានរបស់អង្គការសហប្រជាជាតិ**

## សេចក្ដីប្រកាសរកបងប្រុសពីរនាក់

នាងខ្ញុំឈ្មោះ ហ៊ុល វី ភេទស្រី អាយុ៤៤ឆ្នាំ សព្វថ្ងៃរស់នៅភូមិថ្មីកោះខ្នុរ ឃុំព្រែករកា ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ។ ឪពុកឈ្មោះ ប្រុក ហ៊ុល (ស្លាប់) ម្ដាយឈ្មោះ វ៉ុង កាន ។

នាងខ្ញុំមានបងប្អូន១១នាក់៖ ១) ហ៊ុល ហ៊ាញ ហៅវៃ (ប្រុស, បាត់ខ្លួន) ២) ហ៊ុល ហ៊ីម (ប្រុស, ស្លាប់) ៣) ហ៊ុល គឿន ៤) ហ៊ុល សុងហេង ៥) ហ៊ុល សាវឿន (ស្រី, ស្លាប់) ៦) ហ៊ុល វី (គឺរូបនាងខ្ញុំ) ៧) ហ៊ុល សុកគាន់ (ស្រី, ស្លាប់) ៨) ហ៊ុល សាវ៉ឺន (ស្រី, ស្លាប់) ៩) ហ៊ុល សំឡូត (ប្រុស, ស្លាប់) ១០) ហ៊ុល សាលួត (ប្រុស) និង ១១) ហ៊ុល សាឡាត (ប្រុស) ។

នាងខ្ញុំសូមស្វែងរកបងប្រុសពីរនាក់ឈ្មោះ ហ៊ុល ហ៊ាញ ហៅ វៃ និង ហ៊ុល សុងហេង ដែលបានបែកគ្នានៅឆ្នាំ១៩៧០ និង១៩៧៣ នៅពេលដែលបងទាំងពីរបានចាកចេញពីស្រុកកំណើតទៅធ្វើជាកងទ័ពបដិវត្តន៍ ។ ប្រសិនបើបងបានទទួលដំណឹង ឬញាតិមិត្តណាបានស្គាល់ឈ្មោះទាំងពីរនេះ សូមមេត្តាផ្ដល់ដំណឹងមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ប្រអប់សំបុត្រលេខ១១១០ភ្នំពេញ ។ សូមអរគុណ ។

## សេចក្ដីប្រកាសរកប្អូនស្រី សាម សារ៉េន

នាងខ្ញុំឈ្មោះ សាម សារ៉ុម ឪពុកឈ្មោះ សុខ ម្ដាយឈ្មោះ ណឹប សព្វថ្ងៃរស់នៅភូមិដំណាក់កន្ទួត ស្រុកដំណាក់កន្ទួត ស្រុកកំពង់ត្រាច ខេត្តកំពត ។ នាងខ្ញុំសូមស្វែងរកប្អូនស្រីម្នាក់ឈ្មោះ សាម សារ៉េន ដែលមុនឆ្នាំ១៩៧៥ ត្រូវបានបញ្ជូនទៅសមរភូមិដើម្បីសែងអ្នករបួស ។ បន្ទាប់មក សារ៉េន ត្រូវបញ្ជូនទៅមន្ទីរនារីស្រែអំបិលក្នុងខេត្តកំពត ។ នៅក្នុងឆ្នាំ១៩៧៧ សារ៉េន ត្រូវបញ្ជូនមកធ្វើការនៅមន្ទីរពេទ្យមួយក្បែរវត្តភ្នំ ។ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ នាងខ្ញុំបានដឹងថា សារ៉េន នៅរស់ហើយដឹកអ្នករបួសទៅតាមរថភ្លើង ។ តាំងពីនោះមកនាងខ្ញុំមិនបានទទួលដំណឹងពីនាងទៀតឡើយ ។

ប្រសិនបើប្អូនបានឃើញដំណឹង ឬញាតិមិត្តណាបានស្គាល់ឈ្មោះខាងលើនេះ សូមមេត្តាផ្ដល់ដំណឹងមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមប្រអប់សំបុត្រលេខ១១១០ភ្នំពេញ ឬតាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។

សូមអរគុណ ។

## សេចក្ដីប្រកាសរកកូនពីរនាក់

ខ្ញុំបាទឈ្មោះ ម៉ែន បូ អាយុ៧៤ឆ្នាំ ជាឪពុក និង អ៊ុយ កាន អាយុ៧៤ឆ្នាំ ជាម្ដាយ សព្វថ្ងៃរស់នៅភូមិឈើទាល ឃុំឈើទាល ស្រុកកៀនស្វាយ ខេត្តកណ្ដាល ។

ខ្ញុំបាទមានកូនទាំងអស់៧នាក់÷ ទី១) ម៉ែន ខេង, ទី២) ម៉ែន ខុម ទី៣) ម៉ែន រុំ ទី៤) ម៉ែន ឆុំ, ទី៥) ម៉ែន ឆុន, ទី៦) ម៉ែន ឈួង និងទី៧) ម៉ែន ឈួយ ។

ខ្ញុំបាទសូមស្វែងរកកូនពីរនាក់ឈ្មោះ ម៉ែន ខេង និង ម៉ែន ខុម ដែលបានបាត់ខ្លួនតាំងពីឆ្នាំ១៩៧៤ ។ នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០០ ខ្ញុំបាទបានឮដំណឹងថាកូនទាំងពីរបានស្វែងរកឈ្មោះខ្ញុំចំនួន៣ដង ប៉ុន្តែមិនបានជួប ។

ប្រសិនបើកូនទាំងពីរបានឮ ឬញាតិមិត្តណាបានស្គាល់ឈ្មោះទាំងពីរខាងលើ សូមមេត្តាជួយផ្ដល់ដំណឹងមកមជ្ឈមណ្ឌលឯកសារកម្ពុជា តាមទូរស័ព្ទលេខ (៨៥៥) ០២៣ ២១១ ៨៧៥ ប្រអប់សំបុត្រលេខ១១១០ភ្នំពេញ ។ សូមអរគុណ ។

## សេចក្ដីប្រកាសរកបងប្រុស ទ្រឿង សារី

ខ្ញុំបាទឈ្មោះ ដែន សុខ សព្វថ្ងៃរស់នៅភូមិបឹងទ្រុង សង្កាត់អូរប្រាសា ស្រុកកំពត ខេត្តកំពត ។ ឪពុកឈ្មោះ ទ្រឿង ដែន ម្ដាយឈ្មោះ ម៉ាង គីមសាយ ។

ខ្ញុំបាទសូមស្វែងរកបងប្រុសម្នាក់ឈ្មោះ ទ្រឿង សារី បានចេញពីផ្ទះទៅបម្រើបដិវត្តន៍(មុនឆ្នាំ១៩៧៥) ហើយបាត់ខ្លួនរហូតមកសព្វថ្ងៃ ។

កាលពីឆ្នាំ១៩៨៨ ឪពុកមារបស់ខ្ញុំឈ្មោះ យ៉ាវ បានប្រាប់ខ្ញុំថាគាត់បានជួប សារី នៅក្នុងប្រទេសថៃ ។ ក្រោយមកឪពុកមារបស់ខ្ញុំក៏ស្លាប់ទៅ ខ្ញុំដាច់ការទាក់ទងតាំងពីនោះមក ។

ប្រសិនបើបងប្រុសបានឃើញសេចក្ដីប្រកាសនេះ ឬញាតិមិត្តណាបានជួបឈ្មោះនេះ សូមផ្ដល់ដំណឹងមកខ្ញុំបាទតាមអាសយដ្ឋានខាងលើ ឬតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជា ទូរស័ព្ទលេខ(៨៥៥) ០២៣ ២១១ ៨៧៥ ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ ។ សូមអរគុណ ។







ដើម្បីឧបត្ថម្ភការបោះពុម្ពនិងចែកចាយដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំនៅទូទាំងព្រះរាជាណាចក្រកម្ពុជា
ទស្សនាវដ្ដីចំនួន១០០០ច្បាប់ជារៀងរាល់លេខនឹងដាក់លក់តែនៅក្នុងរាជធានីភ្នំពេញប៉ុណ្ណោះ ក្នុងមួយច្បាប់តម្លៃ ៧០០០រៀល

មជ្ឈមណ្ឌលឯកសារកម្ពុជាអំពាវនាវដល់រដ្ឋាភិបាល មូលនិធិនានា និងសាធារណជនគ្រប់រូប សូមជួយឧបត្ថម្ភការបោះពុម្ពផ្សាយទស្សនាវដ្ដីនេះទៅតាមលទ្ធភាពដែលអាចធ្វើបាន ។ ព័ត៌មានបន្ថែមចំពោះការបោះពុម្ពផ្សាយទស្សនាវដ្ដីស្វែងរកការពិត សូមមេត្តាទាក់ទងមកកាន់នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។ សូមអរគុណ!

The Documentation Center of Cambodia would like to appeal to governments, foundations and individuals for support of the publication of Searching for the Truth!. For contribution, please contact (855) 23 211 875 or By Email: dccam@online.com.kh. Thank you.

**A magazine of the Documentation Center of Cambodia: *Searching for the truth*. Number 60, December 2004.**
**Funded by Germany, Norway, Sweden, and USA.**